# មគ្គុទ្ទេសក៍នគរ

## ភាគ ១-២

ចម្លងដោយ

ផ្ទះលេខ១៣៦អឺ១ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស.២៤៨៤

មគ្គុទ្ទេសក៍នគរ ភាគ ១-២

ទទួលអំណោយពីលោក ម៉ៅ ឃុនសីវង់ ឯលកម្ពុជាជំនួស
ដើម្បីធ្វើឌីជីថលក្នុង eLibrary of Cambodia
ឧសភា 2015

# មគ្គុទ្ទេសក៍នគរ
## ភាគ ១

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ទំនៀមការផ្ទាល់ខ្លួន . . . . . . . . . . . . . . . . . . . . • សៀវភៅថ្លៃ ០រ. ៦០
ទឹកទន្លេសាប . . . . . . . . . . . . . . . . . . . . — ០, ៦០
ច្បាប់ក្រម . . . . . . . . . . . . . . . . . . . . — ០, ១២
ច្បាប់កេរ្តិ៍កាល . . . . . . . . . . . . . . . . . . . . — ០, ១០
ច្បាប់កូនចៅ . . . . . . . . . . . . . . . . . . . . — ០, ១៥
ច្បាប់ត្រីនេតិ . . . . . . . . . . . . . . . . . . . . — ០, ១៥
ភាសិត . . . . . . . . . . . . . . . . . . . . — ០, ១៥

# រូបផ្តិតពុម្ពផ្សេងៗ

ព្រះពុទ្ធរូបមានអគ្គសាវកអម (រចនាណាវ) . . . . . . . . . . ១ សន្លឹកថ្លៃ . ០ រ. ០៥

" និញាន . . . . . . . . . . . . . . . . . . . . — ០, ០៥

រូបបេសនីយប័ត្រគ្រប់បែប . . . . . . . . . . . . . . . . — ០, ០៥

ព្រះពុទ្ធរូបបាយ័ន . . . . . . . . . . . . . . . . . . . — ០, ០២

" មានព្រះឥន្ទ្រនិងព្រះព្រហ្មឈរអម . . . . . . . . . . — ០, ០៥

ព្រះរូបសម្តេចព្រះមហាសង្ឃរាជ (ទៀង) . . . . . . . . . . . — ០, ០៣

ព្រះរូបព្រះបាទសម្តេច ព្រះស៊ីសុវត្ថិមុនីវង្ស ក្រដាសរឹង . . . . — ០, ១៥

" " ក្រដាសទន់. . . . . — ០, ១១

" ព្រះស៊ីសុវត្ថិ . . . . . . . . . . . — ០, ២០

" ព្រះចៅក្រុងកម្ពុជា & ព្រះអង្គ . . . . — ០, ១០

រូបព្រះពុទ្ធបាទ . . . . . . . . . . . . . . . . . . . . — ០, ០៥

រូបព្រះឥន្ទ្រលាក់គាត់រឿងពុទ្ធប្រវត្តិ . . . . . . . . . . . . . — ០, ០៥

រូបវេស្សន្តរជាតក ១៣ សន្លឹក . . . . . . . . . . . . . . . — ១, ០៦

រូបតំនួរតេមិយជាតក . . . . . . . . . . . . . . . . . ១០ — ០, ២៥

" មហាជនកជាតក . . . . . . . . . . . . . . . . . ១០ — ០, ២៥

" សុវណ្ណសាមជាតក . . . . . . . . . . . . . . . ១០ — ០, ២៥

រូបសម្តេចព្រះវររាជជននី . . . . . . . . . . . . . . . . ១ — ០, ០២

រូបលោកសង្ឃប្ចូបទំងកាបាស់ . . . . . . . . . . . . . . . — ០, ០៥

ប្រក្រតិទិនឆ្នាំ ១៩៤២ (សន្លឹករស្តើង) . . . . . . . . . . . — ០, ១៥

" " (បន្ទះក្រាស់) . . . . . . . . . . . — ០, ៣០

" " (បក) . . . . . . . . . . . . . . . . — ០, ៩០

មគ្គុទ្ទេសក៍ឯករ

# ភាគទី ១

អាចារ្យ ប៉ាង-ខាត់ គ្រូបង្រៀនសំស្ក្រឹត
នៅសាលាបាលីជាន់ខ្ពស់ រៀបរៀង

គណៈរដ្ឋមន្ត្រីនិងសម្តេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

បោះពុម្ពលើកទី ១

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព. ស. ២៤៨៤

# MAGGUDDESAKANAGARA

(Guide d'Angkor)

1ère Partie

## L'HISTORIQUE

par

L'Achar PANG-KHAT Professeur de Sanscrit

a l'École Supérieure de Pali

Cette publication a reçu l'approbation du Conseil des Ministres
et des deux Chefs de Sectes

1ère Édition

PHNOM-PENH
Éditions de l'Institut Bouddhique
1941



ព្រះពុទ្ធរូបបែបខ្មែរ ទ្រង់សមាធិមុទ្រ គេតម្កល់ទុកនៅមន្ទីរ
រក្សាបុរាណវត្ថុ សៀមរាប (ពាទរូបថត ព . ស . ប.)

# ពាក្យប្រារព្ធ

បើគេបានដើរមើលបុរាណដ្ឋាន គ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា គេនឹងបានដឹងពិតប្រាកដថា ប្រទេសកម្ពុជាក្នុងអតីតកាល ជាប្រទេសរុងរឿងយ៉ាងឯក ក្នុងចំណោមប្រទេសទាំងឡាយដែលស្ថិតនៅទិសទីកើតនៃទ្វីបអាស៊ី ។ អ្នកដំណើរជាតិផ្សេងៗដែលធ្វើដំណើរមកមើលនគរ, គេតែងនិយាយថា ប្រទេសកម្ពុជាក្នុងអតីតកាលជាប្រទេសរុងរឿងបំផុត១, បណ្ដាជាតិខ្មែរសម័យនោះ ក៏មានអារ្យធម៌បរិបូណ៌, ដោយមានប្រាង្គប្រាសាទទាំងឡាយដេរដាសពាសពេញប្រទេសខ្មែរជាភស្តុតាង ល្មមជាទីសន្និដ្ឋានបាន ចំពោះអារ្យធម៌នៃបណ្ដាជនជាតិខ្មែរក្នុងកាលនោះស្រាប់, បើយើងមិនត្រិះរិះឲ្យហ្មត់ចត់ទេ, យើងនឹងអាចចុះមតិថា ប្រាង្គប្រាសាទនៅនគរ ជាស្នាដៃនៃទេពនិម្មិតថ្វាយស្ដេចខ្មែរត្រង់ៗ ដូចពាក្យបម្រើយខ្មែរម្នាក់ឆ្លើយតបលោក ហង់រី-ម្ហូត កាលលោកមើលនគរនៅថ្ងៃ ២២-១-១៨៦១ ថា: "ប្រាសាទនគរនេះទេពតានិម្មិត មានពួកយក្សនឹងស្រីទេពអប្សរកញ្ញាជួយដឹកជញ្ជូនថ្មតាមអាកាស តាមសេចក្ដីបង្គាប់នៃវិស្សកម្មទេវបុត្រ" ។ ក្នុងសៀវភៅមគ្គុទ្ទេសក៍ជាភាសាអង់គ្លេស របស់លោក ដិក្កាស្សុង (១) ត្រង់ពន្យល់ពីខ្មែរទំព័រលេខ ៥ មានសេចក្ដីថា: "ជនជាតិខ្មែរក្នុងអតីតកាល មានអារ្យធម៌ខ្ពង់ខ្ពស់ណាស់ ខ្មែរបច្ចុប្បន្ន

---

1 Wondrous Angkor by Deane H. Dickason, page 5 et 6, Sanghai 1937.

នេះជាខ្មែរព្រៃ" ។ សេចក្តីទាំងអស់នេះបញ្ជាក់ថា: "ជាតិខ្មែរយើងមានសេចក្តីចំរើនផុតថ្លាក់, ប្រាង្គប្រាសាទ ជាស្នាដៃដែលបុព្វបុរសរបស់យើងបានកសាង គេភាន់ច្រឡំថាជាទេវតាសាងវិញ ។

លោកស្រី ការប៉ុឡែស អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ដែលមានសេចក្តីកប់អានជាតិខ្មែរស្មោះត្រង់ ប្រាថ្នាចង់ឲ្យជាតិខ្មែរភ្ញាក់កណើតទំព្រឹងប្រែងរៀនសូត្រឲ្យបានចេះដឹង ឲ្យបានចំរើនឡើងមានអារ្យធម៌ដូចសម័យនគរ ទើបសុំឲ្យខ្ញុំរៀបរៀងសៀវភៅមគ្គុទ្ទេសក៍នេះ, ទុកសំកប់ជាតិខ្មែរដឹកដៃយុវជនខ្មែរទៅមើលនគរ ជាទេវស្ថានដែលបុព្វបុរសខ្មែរយើងបានកសាងទុក ជាគ្រឿងរឭកជាភស្តុតាងនៃសេចក្តីព្យាយាម ដើម្បីឲ្យកូនចៅខ្មែរយកជាគំនិតថា: "ដោយសេចក្តីព្យាយាម គេនឹងរួចពីកណ្តាប់ដៃនៃសេចក្តីទុក្ខ" ។

ដូច្នេះ, យុវជនទាំងឡាយ អ្នកត្រូវចាំទៀតពេលទៅមើលនគរកុំខាន "ពេលដើរចេញទៅមើលមិនមែនជាពេលខាតទេ នេះជាពាក្យពិត, ព្រោះទៅមើលនគរ ទុកដូចជាយើងទៅគោរពបូជាបូជនីយស្ថាន ដែលបញ្ចុះអដ្ឋិបុព្វបុរសរបស់យើង ដែលយើងត្រូវគោរពខានមិនបានដោយទឹកចិត្តថ្លាបរិសុទ្ធ, ផលានិសង្សដែលយើងត្រូវបានអំពីការបូជានេះ គឺការចាំរឿងប្រាសាទធំៗជាប់ក្នុងចិត្ត ជាគំរូតាងនៃសេចក្តីព្យាយាម យើងនឹងកើតសេចក្តីព្យាយាមក្លៀវក្លាទំព្រឹងប្រែងរៀនសូត្រ, ធ្វើការផ្សេងៗឲ្យបានសេចក្តីចំរើនដូចសម័យនគរ" ។

ដើម្បីនឹងឲ្យងាយដល់អ្នកដែលត្រូវការមើលនគរ យើងចែកសៀវភៅនេះជា ២ ភាគ ធុនស្តើងល្មមនឹងកាន់ឬនឹងដាក់ក្នុងហោប៉ៅបានស្រួល

ព្រោះការរៀនប្រាសាទមួយៗ ប្រកបដោយសេចក្តីអន្តរាយច្រើនប្រការ ដោយប្រាសាទខ្លះមានជណ្តើរចោត, ប្រាសាទខ្លះមាននៅព្រៃព្រឹក្សលតា-ជាតិដុះដេរដាសពាសពេញ ញាតស្បាតពិបាកចូលមើលណាស់, ភាគទី១ ពីវគ្គទី ១ ដល់វគ្គទី ២, ភាគទី ២ តាំងពីវគ្គទី ៣ ដល់វគ្គទី ៧ ។ ទីបំផុតសូមផ្តាំពាក្យមួយម៉ាត់ថា "កុំមើលឬទទេ ត្រូវសួរឬផង" ។

ប-ខ-

វគ្គទី ១

# គោលពង្សាវតារខ្មែរបុរាណដោយសង្ខេប

ដោយការស្រាវជ្រាវតាមបុរាណដ្ឋាន ដែលមានដេរដាសនៅលើផែនដីប្រទេសខ្មែរសព្វថ្ងៃនេះ គេឃើញច្បាស់ថា ជនជាតិខ្មែរបច្ចុប្បន្ននេះ គឺជាពូជពង្សជាប់លោហិតតពីបុព្វបុរសខ្មែរតាំងពីបុរាណកាលមកឥតសង្ស័យ ។ បើពោលតាមភូមិសាស្ត្រ ជនជាតិខ្មែរមិនមែនអាស្រ័យនៅតែក្នុងប្រទេសខ្មែរសព្វថ្ងៃដែលយើងមើលឃើញនោះទេ, មានអាស្រ័យនៅរហូតដល់ប្រទេសសៀមភាគក្រោមទន្លេមេណាម, ប្រទេសលាវ និងប្រទេសកូសាំងស៊ីនផង ។

បើនិយាយអំពីជនជាតិដែលអាស្រ័យនៅប្រទេសឥណ្ឌូស៊ីនទាំងមូលនុះ លោក ហ. ម៉ារសាល់[1] លោកសរសេរទុកថា: "ជនបុរាណដែលអាស្រ័យនៅប្រទេសឥណ្ឌូស៊ីននេះ គឺជនជាតិឥណ្ឌូណេស៊ៀន (Indonésiens) ។ ពួកជនជាតិនេះរត់ទៅជ្រកនៅក្នុងបព៌ត ទុកទីស្ថានរបស់ខ្លួនឲ្យពួកអ្នកក្រោកកាន់ទឹកដីថ្មី គឺជាតិយួនមកពីប្រទេសចិនចូលមកនៅភាគខាងជើង, ជាតិឥណ្ឌូមកនៅភាគខាងត្បូង; សេចក្តីពិត, ត្រូវយកបុរាណវត្ថុដែលមានពាសពេញធរណីប្រទេសឥណ្ឌូស៊ីនជាគោលដើម

1 H. Marchal, La collection khmère, p. 7.

មុនការក្លាយជាតិចិនជាយួន និងការក្លាយជាតិឥណ្ឌាជាខ្មែរ ថាប៉េយ៉េង ចង់ជឹងអំពីជនជាតិឥណ្ឌូណេសៀននោះ" ។

តាមសេចក្តីកយការអ្នកប្រវត្តិសាស្ត្រចិន[1] គេឲ្យឈ្មោះជនជាតិខ្មែរថា "ហ្វូ-ណាន", អ្នកប្រវត្តិសាស្ត្រចិននោះ បានអធិប្បាយពីសណ្តាប់ធ្នាប់, ការរេះដីង និងព្រះរាជាកាលជាន់នោះផង ដូចសេចក្តីថា: "ក្នុងរវាង ព. ស. ៨៦៣ មានជនជាតិហ្វូណនអាស្រ័យនៅតាមខាងត្បូងព្រៃជាយកោះឥណ្ឌូស៊ីន នៅក្រោមអាណាចក្រស្តេចក្រុងចិន" ។ ក្នុងពង្សាវតារនៃរាជវង្ស ត្សុ ខាងត្បូង, មានសេចក្តីថា: "រវាង ព. ស. ១០៥៥-១០៦៦ មានព្រះរាជិនីនាម លៀវ-យ៉េ (Lieu-ye) សោយរាជ្យនៅប្រទេសហ្វូណន, ហើយមានជនម្នាក់ឈ្មោះ ហ៊ុន-តៀន (Houent ien) មកពីប្រទេសឆ្ងាយ បានសម្ពពមរោរសនឹងព្រះនាង; ជនេនះ, លោក ប៉ូល-ប៉ែល្លីយ៉ោត៍ (Paul-Pelliot) យល់ថា ប្រហែលមកពីប្រទេសឥណ្ឌា ។ លុះដល់មកចុងសតវត្សទី ៩ និងខាងដើមសតវត្សទី ១០ នៃពុទ្ធសករាជ ទើបមានព្រាហ្មណ៍ម្នាក់មកអំពីប្រទេសឥណ្ឌា ឈ្មោះ កៅណ្ឌិន្យ ឬ កោណ្ឌញ្ញ មកសោយរាជ្យនៅប្រទេសហ្វូណន, បានរៀបចំទំនៀមប្រពៃណីប្រទេសហ្វូណន ឲ្យប្រព្រឹត្តទៅ

1. Paul-Pelliot. Le Fou-non-B. E. F. E. O., p. 248-SQQ

តាមលទ្ធិប្រទេសឥណ្ឌាឡើង ។ ចំក្រុងហ្វូណន, (វ្យាធបុរៈ) លោក ក. សឺដែស[1] សរសេរថា តាំងនៅក្នុងខែត្របាភ្នំ ។

ម្យ៉ាងទៀត, សេចក្ដីយកការរបស់ចិន មាននិយាយថា:[2] "ព្រះរាជវង្សដើមកើតមកអំពីសម្ពន្ធមេត្រីរវាងព្រាហ្មណ៍និងនាងនាគី 'ជាបុត្រីនាគរាជ" ។ ពាក្យត្រង់នេះ អ្នកស្រី ករ៉ូល រេមុសាត់[3] (Coral Rémusat) ប្រែសម្រួលជាគួប្រស្នាថា: "ព្រាហ្មណ៍ប្រាកដជាសម្បត្តិស្វាមី (តាវ្យធមិ។) នៅប្រទេសឥណ្ឌា, ឯនាងនាគី គឺជាគោលស្រុកទេសដើមកំណើត" ។

សេចក្ដីយកការនៃអ្នកប្រវត្តិសាស្ត្រចិនខាងលើនេះ ធ្វើឲ្យសេចក្ដីមកត្រូវគ្នានឹងពង្សាវតារខ្មែរយើង ។ ពង្សាវតារខ្មែរយើង, សូម្បីមានសេចក្ដីពិតយ៉ាងនេះ ត្រូវគេលះបង់ចោលយូរលង់ណាស់មកហើយ ឥតមានអ្នកណាមួយកាន់ជាប់ទៀយ; សេចក្ដីក្នុងពង្សាវតារនោះថា[4] "មានក្សត្រិយ៍មួយព្រះអង្គទ្រង់ព្រះនាមព្រះបាទអាទិច្ចវង្ស គ្រងរាជ្យនៅឥន្ទបត្តបុរីសិរីយសោធរនគរ គោកធ្លក, ទ្រង់មានព្រះរាជបុត្រ ៥ ព្រះអង្គ, ព្រះរាជបុត្រកណ្ដាលទ្រង់ព្រះនាមព្រះថោង ។ ចំណោរតមក, ព្រះបាទអាទិច្ច-

1 G. Coedès, La tradition généologique des premiers rois d'Angkor, B. E. F. E. O., XXVIII, p. 124. 2 G. Cœdès, La Légende de la Nāgī, B. E. F. E O., XI, 3-4, p. 391 3 Gilberte de Coral Rémusat, L'Art khmer, p. 10.

៤ ព្រះរាជនិពន្ធព្រះបាទសម្ដេចព្រះស៊ីសុវត្ថិមុនីវង្ស, វាំងល្ងាចព្រះករុណា, ទំព័រ ៧, និង ឬរាប់ព្យាណ ។

វៀរទ្រង់ព្រះពិរោធចំពោះព្រះថោង ហើយទ្រង់ត្រាស់បង្គាប់ឲ្យព្រះអនុជ ហោមហាប់ទាំងព្រះរាជបរិពារស្រីប្រុស, ឲ្យកាត់សក់ដើងកញ្ចើបខ្សាត់ ពោងពាយទាំងអស់ ហើយបណ្តែតតាមសមុទ្រសាគរ មកទើរជាប់នៅ ផ្ទៃសមុទ្រជាផែនដីព្រះបាទអស្សបេយ្យរាជ ៗ ថ្ងៃមួយ, ព្រះថោង ស្ដេច ទ្រង់អស្សតរតាជានេយ្យប្រពាតព្រះនគរ ព្រមទាំងព្រះរាជបរិពារតាម ឆ្នេរសមុទ្រ ទ្រង់ទតព្រះនេត្រឃើញផ្ទះខ្សាច់កបស្ដើល្អ ក្រោមដើមធ្លក មួយធំ ទើបស្ដេចទ្រង់ចូលជ្រកក្រសាលក្នុងទីនោះ, ចួនពេលនោះ, ទឹក សមុទ្រជោរជន់ឡើងហើសលិចទីប្រពាតជាប់ស្ដេចត្រឡប់មិនបាន ក៏ ស្ដេចទ្រង់ប្រថាប់នៅទីនោះរហូតដល់កត្រីកាល ៗ កាលនោះ, ព្រះនាង នាគីជាព្រះរាជបុត្រីនាគរាជ បបួលរាជបរិពារក្មេងខ្ចីជាស្រីទេពអប្សរប-រកញ្ញាឡើងមកក្រសាលលេងលើផ្ទះខ្សាច់តាមប្រក្រតី ត្រង់ដើមធ្លកដែល ព្រះថោងទ្រង់ប្រថាប់នោះ—ៗ ឯព្រះថោងទ្រង់ស្ដេចទតព្រះនេត្រឃើញ នាងនាគនាគី មានរូបឆោមលោមពណ៌ល្អ ក៏មានព្រះទ័យប្រតិព័ទ្ធស្ន្រែ ស្នោះ ហើយសូមជាមេត្រីនឹងព្រះនាងនាគី ៗ ព្រះនាងក៏មានសេចក្ដីស្នេ-ហានឹងព្រះថោង ទើបព្រះនាងបដិញ្ញាកតិកាថ្វាយព្រះថោងថា សូម ស្ដេចទ្រង់ចាំកំណត់ ៧ ទិវាសិន, សឹមស្ដេចទ្រង់រៀបគ្រឿងបណ្ណាការនាំ មកប្រតិស្ឋានទុកទាំក្នុងទីនេះ ដើម្បីនឹងថ្វាយព្រះវររាជបិតា គង់នឹងបាន សំរេចពិតប្រាកដដូចព្រះទ័យប្រាថ្នាពុំខាន; លុះស្រេចហើយ, ព្រះនាង

នាគីក៏ក្រាបលាវិលចុះទៅកាន់ពិភពនាគវិញ ចូលទៅក្រាបទូលព្រះវរៈរាជបិតាមាតា តាមប្រព្រឹត្តិហេតុឲ្យស្ដេចទ្រង់ជ្រាបសព្វគ្រប់ប្រការ ។ ព្រះបាទភុជង្គនាគរាជ, ទ្រង់ព្រះសណ្ដាប់ហើយ ក៏ស្ដេចទ្រង់យល់ព្រមតាមព្រះទ័យព្រះរាជបុត្រី; លុះគ្រប់ ៧ ទិវារាត្រីហើយ, ស្ដេចទ្រង់ដឹកប្រថពីឡើងមកជាមួយអគ្គមហេសី ព្រះរាជវង្សានុវង្ស សកលយោធារាជបរិពារ មកកាន់ទីឋានគោកធ្លក, ស្ដេចទ្រង់មានព្រះទ័យសោមនស្សសាទរចំពោះព្រះថោង ព្រមលើកព្រះរាជបុត្រីថ្វាយជាព្រះរាជទេវី; ស្ដេចទ្រង់សំដែងឫទ្ធានុភាពស្រូបយកគង្គាមហាសមុទ្រ ត្រង់ទីស្ថាននោះទើបនិម្មិតព្រះនគររាជធានីប្រាង្គប្រាសាទស្រេច ហើយស្ដេចទ្រង់រៀបចំពិធីរៀបមង្គលាភិសេកព្រះថោងនឹងព្រះរាជបុត្រី ឲ្យគ្រងរាជ្យនគរគោកធ្លក; ស្ដេចទ្រង់ថ្វាយព្រះនាមព្រះសុវណ៌សាជា ព្រះបាទសម្ដេចព្រះកេវវង្សអស្ចារ្យ, ព្រះរាជបុត្រីជា ព្រះនាងធារារាជវតីបរមបពិត្រ, ព្រះនាមនគរគោកធ្លកជា ក្រុងកម្ពុជា តាមហេតុក្រុងនេះ ដែលកើតអោយឫទ្ធានុភាពព្រះបាទភុជង្គនាគរាជ ។ តាមដំណើររឿងនេះ, ព្រះបាទសម្ដេចព្រះទេវវង្សអស្ចារ្យ.(ព្រះថោង) ជាបឋមក្សត្រិយ៍ខ្មែរនៃព្រះរាជវង្សដើមបំផុត ក្នុងក្រុងកម្ពុជា តាំងពីកាលនោះមក ។ អ្នកប្រាជ្ញរាជបណ្ឌិត រៀបចំក្រសួងសិក្សាធិការឲ្យមានការរៀនភាសាសំស្ក្រឹត, មគធៈ ហើយផ្លាស់ប្ដូរមកជាអក្សរខេមរភាសា" ។

ហេតុដូច្នេះ, ភាសាជនជាតិខ្មែរ, តាមសិលាចារឹកជាគោលតឹកតាង មិនស្លាប់, ពិតជាភាសាខ្មែរយើងនិយាយសព្វថ្ងៃនេះ, បើទុកជាមានថែក ខ្លះតែដោយសម្ដីដែលយារក្លាយតៗគ្នាមក; ភាសាខ្មែរ ទឹងអក្សរ-សាស្ត្រខ្មែរ ដែលមានបែបផែនល្អ ហើយចាស់ជាងគេក្នុងចំណោមជនជាតិ ប្រទេសឥណ្ឌូស៊ិន ក៏បានជាបែបយ៉ាងនៃជនជាតិនៅជិតខាងផង ដូចជា ជាតិសៀមជាដើម ។

តាមសេចក្ដីដែលអាងយកខាងលើនេះ, ខេមរជាតិសព្វថ្ងៃនេះ, ខ្ញុំ ហ៊ានពោលឥតសំចៃថាប្រាកដថា បច្ចុប្បន្នជាជនជាប់ខ្សែលោហិតមកពី បុព្វបុរសខ្មែរបុរាណពិតៗឥតសង្ស័យឡើយ ។

## ព្រះរាជាអង្គខ្លះសម័យនគរ(១)

ព្រះរាជាទាំងឡាយដែលទ្រង់រាជ្យនៅប្រទេសកម្ពុជា ខ្ញុំមិនបាន សរសេរទុកក្នុងទីនេះទេ, ព្រោះសៀវភៅនេះ ខ្ញុំត្រូវការឲ្យតែយុវជន ស្គាល់ព្រះនាមព្រះរាជាដែលទ្រង់រាជ្យនៅនគរ ក្នុងពេលដែលទៅមើល នគរ កាន់សៀវភៅទៅដៃ អាចបើកមើលហើយស្គាល់ថា ប្រាសាទ

១ លំដាប់ព្រះរាជាទាំងឡាយនេះ ខ្ញុំដកស្រង់យកក្នុងសៀវភៅរបស់អ្នកស្រី Gilberte de Coral Rémusat ឈ្មោះ L'Art Khmèr, ត្រង់ពង្សាវតារប្រទេសខ្មែរ, ទំព័រលេខ ៩ តទៅ...; និងសៀវភៅលោក Henri Marchal ឈ្មោះ La collection Khmère, ត្រង់ពង្សាវតារនិងការរចនា, ទំព័រលេខ ៨ តទៅ... ។

នេះព្រះរាជាអង្គនោះទ្រង់គ្រងរាជ្យក្នុងពុទ្ធសករាជប៉ុណ្ណោះៗជាដើម ហេតុនេះ, ខ្ញុំត្រូវនិយាយតែពីព្រះរាជាសម័យនគរ តាមតារាងដែលអ្នកប្រាជ្ញបារាំងសែសបានស្រាវជ្រាវរកឃើញ ហើយរៀបចំជាបញ្ជីមាតិកាតាមលំដាប់រាជ្យតៗគ្នា ក្នុងកាលរៀបចំបុរាណដ្ឋាននៅប្រទេសខ្មែរ ។

ព្រះបាទភវវរ្ម័នទី ១ ទ្រង់រាជ្យក្នុងសតវត្សរ៍ទី ១១ នៃពុទ្ធសករាជ (ព.ស. ១០៨៣), ព្រះបាទមហេន្ទ្រវរ្ម័ន ចិត្រសេន ទ្រង់រាជ្យក្នុងសតវត្សរ៍ទី ១២ នៃពុទ្ធសករាជ (ព.ស. ១០៩៣-១១៤៣), ព្រះបាទឦសានវរ្ម័ន ទ្រង់រាជ្យក្នុងសតវត្សរ៍ទី ១២ នៃពុទ្ធសករាជ (ព.ស. ១១៥៩-១១៧០), ទាំង ៣ ព្រះអង្គនេះ ស្ដេចទ្រង់រាជ្យនៅក្រុងហ្វូណន ហើយបានពង្រីកអាណាចក្រហ្វូណន ឲ្យធំទូលាយឡើង ៗ លុះចំណេរតមក, ព្រះបាទឦសានវរ្ម័ន បានផ្លាស់រាជធានីហ្វូណនមកតាំងក្រុងថ្មីនៅសម្បូរព្រៃគុកឈ្មោះ ឦសានបុរៈ (តាមឈ្មោះក្នុងសិលាចារឹក) ស្ថិតនៅទិសឦសាននៃក្រុងកំពង់ធំ ប្រហែល ៣០ គ.ម. ។ ក្នុងសម័យនោះគេគោរពទេវតាឈ្មោះ ហរិហរៈ ជាទេវតាក្នុងសាសនាព្រាហ្មណ៍, ទេវរូបនេះ មានទ្រង់ទ្រាយព្រះឥសូរៈនិងព្រះវិស្ណុលាយចូលគ្នា, ហើយជាភស្តុតាងនៃការរចនាខ្មែរជាន់ចាស់យ៉ាងសំខាន់ ។

ព្រះបាទជយវរ្ម័នទី ១ ទ្រង់រាជ្យក្នុងសតវត្សរ៍ទី ១៣ នៃពុទ្ធសករាជ

(ព.ស. ១២០៧-១២១០) ក្នុងកាលនេះ, ប្រទេសខ្មែរកើតកក្តីប្រែ បែកចេញជា ២ ផ្នែក គឺប្រទេសកម្ពុជាភាគលើ ទៅខាងជើង, ភាគក្រោម ទៅខាងត្បូង ។ កម្ពុជាភាគលើ តាំងនៅពីត្រឹមភាគកណ្ដាលនៃប្រទេសលាវ(១) ចុះមក, កម្ពុជាភាគក្រោម តាំងនៅតាមទំនាបទន្លេមេគុងទាំងផែនកូសាំងស៊ុនទាំងមូល; ប្រទេសទាំងពីរនេះ ធ្វើសឹកសង្គ្រាមទៅវិញទៅមកក្នុងកាលនោះ ។

ក្នុងសតវត្សរ៍ទី ១៤ នៃពុទ្ធសករាជ, ពង្សាវតារខ្មែរស្ថិតនៅក្នុងអាថ៌កំបាំង; ក្នុងឱកាសដែលប្រទេសទាំងពីរធ្វើសង្គ្រាមគ្នាដូច្នេះ ប្រហែលជាមានការលុកលុយមកពីនគរស្រីវិជ័យផង គឺមកពីប្រទេសសុមាត្រានិងប្រទេសជ្វា ។

លុះដល់មកខាងចុងសតវត្សរ៍ទី ១៤ ទងខាងដើមសតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ, ទើបព្រះបាទជ័យវរ្ម័នទី ២ ស្ដេចទ្រង់រាជ្យឡើងក្នុង ព.ស ១៣៤៣, បានរួបរួមប្រទេសកម្ពុជាភាគលើភាគក្រោមទាំងពីរឲ្យជាផែនដីរួមអាណាចក្រតែមួយ ។ តាមសិលាចារឹក, មានសេចក្ដីថាព្រះរាជាអង្គនេះស្ដេចទ្រង់មកពីប្រទេសជ្វា ឧគរស្រីវិជ័យ, ទ្រង់បានរៀបចំប្រទេសឲ្យមានរដ្ឋបាលសាសនាបាយល្អឡើង, ស្ដេចស្ថិតនៅរាជ-

1 G. Cœdès, A propos du Tchen-la d'eau B. E. F. E. O. XXXVI,1,p 1.

ជាទីប្រជុំកខ្វង(១) ក្រុងដែលគេបានស្គាល់ច្បាស់នោះគឺ ក្រុងហរិ-ហរាល័យ: តាំងនៅជាមួយនឹងក្រុមប្រាសាទរលួស ជាខាងជើងទន្លេសាប, ស្ដេចទ្រង់បានបង្កើតឲ្យមានការគោរពទៅលើ "ស្ដេចទេវ-រាជ" ឡើង គឺស្ដេចទ្រង់លើកខ្លួនព្រះអង្គជាដំណាងទេវតា: ការគោរពនេះ គេយកសិវលិង្គជាគោលហើយគេសន្មតជាស្ថានព្រះឥសូរ ។

អំណើះតពីព្រះបាទជយវរ្ម័នទី ២ ទៅ ព្រះរាជាទាំងឡាយក៏ទ្រង់ផ្សេងព្រះរាជវង្សមកនៅក្រុងហរិហរាល័យនោះដែរ គឺ:

ព្រះបាទជយវរ្ម័នទី៣, ទ្រង់រាជ្យក្នុង ព. ស. ១៣៩៧-១៤២០ ។

ព្រះបាទឥន្ទ្រវរ្ម័នទី ១, ទ្រង់រាជ្យក្នុង ព. ស. ១៤២០-១៤៣២, ស្ដេចទ្រង់បានកសាងប្រាសាទព្រះគោ ។

ព្រះបាទយសោវរ្ម័នទី១, ទ្រង់រាជ្យក្នុងព.ស. ១៤៣២-១៤៤៣, ស្ដេចទ្រង់បានកសាងប្រាសាទលលៃ ។

ប្រាសាទបាគង គេចូលស្ដាយដល់ទៅលើ "ស្ដេចទេវតា" ទុកដូចជា "ភ្នំ" គោលធំនៃព្រះនគរ ។ ព្រះបាទយសោវរ្ម័នទី ១ ស្ដេចទ្រង់លះបង់ក្រុងហរិហរាល័យ: ហើយមកតាំងក្រុងថ្មីនៅនគរឈ្មោះ យសោធរបុរ: នៅខាងជើងសៀមរាប, រាជធានីថ្មីនេះ មានភ្នំបាខែងជាគោលកណ្ដាលនៃព្រះនគរ ។

1 G. Coedès, Les capitales de Jayavarman II, B. E. F. E. O. XXVIII, p. 113.

ក្នុងសតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ (តាំងពី ព. ស. ១៤៦៥ ឬ ១៤៧១ ទៅដល់ ១៤៨៧), ព្រះបាទជយវរ្ម័នទី ៤ ស្ដេចទ្រង់លះបង់ក្រុងនគរទៅប្រតិស្ឋានក្រុងថ្មីទៀតឈ្មោះ ឈូកគរគ្យារ? ជិតកោះកែរ ដោយមិនដឹងជាមានហេតុអ្វី; ក្រុងនេះស្ថិតនៅប្រហែល ១០០ គ. ម. ទិសឦសាននគរ, តែការប្រតិស្ឋានក្រុងឈូកគរគ្យារ មិនយូរប៉ុន្មាន គឺមិនយូរជាង ២៣ ឆ្នាំ ។

ក្នុងសតវត្សរ៍ទី ១៦ នៃពុទ្ធសករាជ (ព. ស. ១៤៨៧-១៥១១), ព្រះបាទរាជេន្ទ្រវរ្ម័ន ស្ដេចឡើងទ្រង់រាជ្យ ហើយត្រឡប់មកគង់នៅនគរវិញ, ស្ដេចបានកសាងប្រាសាទប្រែរូប, ប្រាសាទមេបុណ្យនៅកើតនគរ, ស្ដេចបានធ្វើសឹកសង្គ្រាមនឹងចាមមានជ័យច្រើនដង ។

ក្នុងសតវត្សរ៍ទី ១៦ នៃពុទ្ធសករាជ (ព. ស. ១៥១១-១៥៤៤), ព្រះបាទជយវរ្ម័នទី ៥ ឡើងទ្រង់រាជ្យ, ស្ដេចបានកសាងប្រាសាទតាកែវ(១), ប្រាសាទវិមានអាកាស, ប្រាសាទបន្ទាយស្រី និងព្រះរាជវាំង ។

កន្លះចុងសតវត្សរ៍ទី ១៦ នៃពុទ្ធសករាជ · (ព. ស. ១៥៥៣ ១៥៩២), មានច្បាស់រាជវង្សថ្មីឡើង ព្រះបាទសូរ្យវរ្ម័នទី ១ ស្ដេចឡើងទ្រង់រាជ្យ; ទ្រង់ជាព្រះរាជបុត្រព្រះបាទលីគោរ(២) [ ព្រោយកោះ

១ ប្រាសាទកែវ? ។ 2 Gilberte de Coral Rémusat, L'Art khmèr, p. 12.

មាលេ) ។ ស្ដេចទ្រង់បានពង្រីកអាណាចក្រខ្មែរទៅដល់ក្រុងលពរី ប្រទេសសៀមភាគខាងត្បូង ។ ស្ដេចជាអ្នកកាន់ព្រះពុទ្ធសាសនាមុតមាំ តែស្ដេចកសាងប្រាសាទសាសនាព្រាហ្មណ៍ដែរ សម្រាប់ទុកថ្វាយព្រះឥស្សរនិងព្រះវិស្ណុ ដូចប្រាសាទវត្តឯក នៃក្រុងបាត់ដំបង, ប្រាសាទភ្នំជីសូរ (ភ្នំឥសូរ) និងប្រាសាទវត្តបាសិទ្ធ ។

ចន្លោះសតវត្សរ៍ទី ១៦ និងទី ១៧ នៃពុទ្ធសករាជ (ព.ស. ១៥៩២-១៦០៨), ព្រះបាទឧទយាទិត្យវរ្ម័នទី ២, ស្ដេចឡើងគ្រងរាជ្យ, ស្ដេចបានកសាងប្រាសាទបាពួន ។

ក្នុងសតវត្សរ៍ទី ១៧ នៃពុទ្ធសករាជ (ព. ស. ១៦០៨-១៦៣៣). ព្រះអនុជព្រះបាទឧទយាទិត្យវរ្ម័នទី ២ ព្រះនាមព្រះបាទហស៌វរ្ម័នទី ៣ ឡើងគ្រងរាជ្យ ។ ក្នុងរាជ្យព្រះអង្គ ចាប់ផ្ដើមសឹកសង្គ្រាមនឹងចាមឡើង ។ ក្នុងសម័យដែលព្រះរាជាទាំងឡាយគ្រងរាជ្យ តព្រះរាជវង្សមកពីព្រះបាទឧទយាទិត្យវរ្ម័នទី ២ ក, ប្រទេសកម្ពុជាកើតសឹកសង្គ្រាមនឹងប្រទេសចាម ចលាចលខ្លាំងណាស់ ។

ក្នុងសតវត្សរ៍ទី ១៧ នៃពុទ្ធសករាជ, ព្រះបាទសូរ្យវរ្ម័នទី ២ ស្ដេចឡើងគ្រងរាជ្យ ។ ស្ដេចធ្វើចម្បាំងលុកចូលដែនចាម លើកទ័ពទៅវាយយួនមានជ័យ, ហើយត្រឡប់មកវាយចាមវិញទៀត, ទ័ពខ្មែរចូលលុកក្រុង

វិជ័យជាក្រុងចាម ចាប់ស្ដេចចាមជាឈ្លើយបានក្នុង ព.ស. ១៦៨៨ ។ ការឈ្នះសង្គ្រាមចាមគ្រានេះមិនយូរប៉ុន្មាន, ក្នុង ព.ស. ១៦៩២, ចាមលើកទ័ពមកលុកក្រុងខ្មែរវិញ ។ ក្នុងរាជ្យព្រះអង្គ ស្ដេចបានកសាងប្រាសាទនគរវត្ត, ក្នុងរវាង ព.ស. ១១៩៥ ក្រោយស្ដេចទិវង្គតទៅ, ប្រទេសកម្ពុជាកើតកាន់ប្រែ ។ ក្នុង ព.ស. ១៧១០, ចាមចូលមកលុកក្រុងនគរ ដុតផ្ទះលំនៅខ្ទេចខ្ទីអស់ជាច្រើន ។

ក្នុងសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ (ព.ស. ១៧២៤), ព្រះបាទជ័យវរ្ម័នទី ៧ ស្ដេចឡើងគ្រងរាជសម្បត្តិ ។ ស្រមោលសេចក្ដីសុខក្សេមក្សាន្តហោចមកដល់ក្នុងកាលៈនោះ ។ ស្ដេចចាប់ធ្វើសឹកសង្គ្រាមសងសឹកចាមវិញ ស្ដេចបានព្រះរាជបុត្រព្រះអង្គ គឺព្រះបាទឥន្ទ្រវរ្ម័នទី ២ ជាវីរៈបុរសជាជំនួយ ស្ដេចលើកទ័ពចូលទៅលុកក្រុងចាម ឡោមព័ទ្ធចាប់ស្ដេចចាមជាឈ្លើយបាន ហើយស្ដេចតាំងព្រះរៀមថ្លៃជាស្ដេចទ្រង់រាជ្យនៅនគរចាម ។ តាំងពី ព.ស. ១៧៤៦ ទៅដល់ ១៧៦៣ ប្រទេសចាមធ្លាក់មកជាប្រទេសរាជខ្មែរ ។ ក្នុងរាជ្យព្រះអង្គនេះ, ព្រះរាជអាណាចក្រខ្មែរធំទូលាយណាស់ លាតពេញលើទីទំនាបទន្លេមេគុង, ដល់ក្រុងវៀងចន្ទន៍ (ប្រទេសលាវ) និងក្រុងឡាកកើ (ប្រទេសសៀម) ។

ព្រះបាទជ័យវរ្ម័នទី ៧ នេះ, ព្រះអង្គជាស្ដេចសឹកដ៏លើស ជាស្ដេចអ្នកកសាងប្រាសាទដ៏លើស ជាស្ដេចផ្ទុសមានឈ្មោះល្បី, ស្ដេចបាន

កសាងប្រាសាទព្រះខាន់, ប្រាសាទតាព្រហ្ម, ប្រាសាទបន្ទាយក្តី, ប្រាសាទបាយ័ន, ជីកស្រះ (សិន្ធុ) ព័ទ្ធជុំវិញក្រុង កសាងកំពែងធំសំ-បើមប្រកបដោយបុរៈ (ខ្លោងទ្វារធំ) ចំនួន ៥ សម្រាប់ការពារបច្ចាមិត្រមិនឲ្យលុកក្រុងបាន ។ ផងទៀត ក្រៅពីការកសាងប្រាសាទ ស្តេចទ្រង់បានកសាងមន្ទីរពេទ្យជាច្រើនរយកន្លែង, លោក លុយ-ហ្វីណូត៍[1] សរសេរថា: "សិលាចារឹកព្រះបាទជ័យវរ្ម័នទី ៧ ឆ្ងើយប្រាប់តាំងពីប្រទេសលាវ, រហូតទៅដល់ឆ្នេរសមុទ្រប្រទេសវៀតណាម, និងប្រទេសថៃភាគខាងក្រោម គឺប្រទេសកូសាំងស៊ីនសព្វថ្ងៃនេះ, ខ្លះនិយាយបញ្ជាក់ពីជ័យជំនះរបស់ព្រះអង្គ, ខ្លះទៀត និយាយពីអំពើជាកុសល (គឺការកសាងមន្ទីរពេទ្យ) ដែលទ្រង់កសាង, សិលាចារឹកទាំងអស់នេះ បានពោលបំភ្លឺពង្សាវតារប្រទេសកម្ពុជាក្នុងអតីតកាលឲ្យឃើញច្បាស់ថា ព្រះបាទជ័យវរ្ម័នទី ៧ ជាមហាក្សត្រមួយព្រះអង្គទ្រង់ប្រកបដោយធម៌" ។

ដូចបានពោលមកហើយ. កាលសម័យព្រះបាទជ័យវរ្ម័នទី ២ ស្តេចទ្រង់បានប្រតិស្ឋានសិវលិង្គជា "ទេវរាជ ស្តេចទេពតា" ទុកជាទីគោរពនមស្ការ, លុះដល់មកជាន់ព្រះបាទជ័យវរ្ម័នទី ៧ ស្តេចទ្រង់លើកយកព្រះពុទ្ធរូបជា "ទេវរាជ ស្តេចទេពតា" វិញ គឺព្រះពុទ្ធរូបដែលគេទើបជីកយកពីក្នុងប្រាសាទបាយ័ន កាល ព.ស. ២៤៧៨..., ព្រះពុទ្ធរូបនេះ

1 Louis-Finot, L'inscription sanscrite de Say-fong, B. E. F. E. O., III, p. 22.

ជាទេវរាជ ជំណាន់ព្រះបាទជ័យវរ្ម័ននោះឯង ។ ស្ដេចជាសាសនូបត្ថម្ភក មហាណជ ប្រាង្គប្រាសាទដែលទ្រង់កសាងតាំងប៉ុន្មាន សុទ្ធតែឧទ្ទិសបូជាដល់ព្រះពុទ្ធសាសនាមហាយាន ដូចព្រះពោធិសត្វអវលោកិតេស្វរៈ, ព្រះប្រាជ្ញាបារមិតាជាដើម ។

មួយវិញទៀត, ទ្រង់បានកសាងធម្មសាលា ឧទ្ទិសថ្វាយព្រះពោធិសត្វលោកេស្វរៈ និងទេពតា ជាអ្នកថែរក្សាព្រះរាជធានី តាមផ្លូវធំចម្ងាយពីគ្នា ១៥ក. ម. ឬ ២០ ក. ម. សម្រាប់ជាទីស្នានជ្រកកោនឬជាទីស្នានសម្រ· ការនៃអ្នកដំណើរទាំងឡាយ ឲ្យឆាយទីងដើរពីស្ថានមួយទៅស្ថានមួយ ។ ព្រះរាជាអង្គនេះ, ទ្រង់ជាក្សត្រិយ៍សឹក (អ្នកចំបាំង) ដែលមានជ័យជំនះជាដរាប, ជាអ្នកកសាងប្រាសាទមិនឈប់ឈរ, ជារដ្ឋបុរស មានរដ្ឋបសាស·នោបាយខាងតែសេចក្ដីចំរើន, ទ្រង់បានកសាងប្រទេសខ្មែរឲ្យឡើងកាន់សេចក្ដីចំរើនរុងរោចន៍ ដែលឥតមានព្រះរាជាអង្គណា សម័យនគរស្មើនឹងព្រះអង្គបាន; លុះអំណើះឥតអំពីព្រះអង្គទៅ ទើបប្រទេសខ្មែររៀវរោយផុនផាបចុះមកជាលំដាប់ ។ តាមសេចក្ដីពិនិត្យពិចារណាលោក សឺដែស អ្នកប្រាជ្ញបារាំងសែស ដែលលោកត្រិះរិះគិតអំពីការងារស្ដេចអង្គនេះ, លោកសរសេរទុកថា[១] "ត្រូវគិតដល់បុកណាវត្តជាតិកសាងជាតិខ្មែរ ក្នុងកាលដែលកន្លងទៅហើយ ដែលជាតិខ្មែរបានកសាងប្រាសាទនគរវត្ត

1 H. Marchal, La collection Khmère, p. 25-26-27-28.

បន្ទាយសំរែ, បេងមាលា និងព្រះវិហារខ្មែរ ដោយទឹកញើសចេញពីថ្ងាស ដូចមានការកសាងអស់នេះទុកជាតឹកតាងស្រាប់ ដែលស្ដេចបានកេណ្ឌប្រជាជនទៅយកថ្មនៅភ្នំគូលេន ដឹកនាំដុំថ្មធំៗយកមកបន្តុបធ្វើប្រាសាទ, ឆ្លាក់ជាក្បាច់រលេចក្បាច់ជាគ្រឿងអលង្ការ, ត្រូវនឹកគិតដល់ប្រជាជនដែលទ្រង់កេណ្ឌយកមកប្រើប្រាស់ ឲ្យធ្វើការហាក់ដូចជាអ្នកមានមហន្តទោស ក្នុងការកសាងប្រាសាទទុកជាយសសក្តិព្រះរាជជនក, ព្រះរាជជននី ឬមកុដរាជកុមារ ដែលជាការកសាងឥតមានការហាត់ទុកមុន ទាំងការងារគ្រាន់តែយកកេរ្តិ៍ឈ្មោះ; មិនមែនតែជាងអ្នកកសាងប៉ុណ្ណោះឡើយ, ត្រូវគិតដល់ព្រះរាជបរិពារនៃព្រះរាជជននីនោះផង ដែលបានកេណ្ឌស្លួយសារអាករពីមនុស្ស ៨០៨០,១០០ នាក់ (៨លាន ៨ម៉ឺន) ត្រូវគិតដល់ស្លួយសារអាករដែលស្ដេចអង្គនេះ បានប្រមូលយកមកអំពីប្រជាជនជាធម្មតា គិតជាមាស ៥ ពាន់គីឡូក្រាម, នឹងប្រាក់ជាច្រើនពាន់, គង់ ៦ ម៉ឺន មិនគិតដល់វត្ថុឯទៀតៗដែលសំរាប់ជាទេវបូជានោះឡើយ ។ ដោយហេតុនេះ, ប្រទេសកម្ពុជា, ក្នុងទីបំផុតសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ ជាប្រទេសដ៏រុងរឿងឬ? ត្រង់នេះ, យើងត្រូវនិយាយថា សេចក្ដីរុងរឿងនេះ បានមកដោយឈាមជ័រនៃព្រះរាជាស្ថិតនៅលើច្បាប់ ហើយចង់បានកេរ្តិ៍យសកេរ្តិ៍នាម; យើងពិនិត្យមើលមិនឃើញពិតប្រាកដថា ប្រទេស

ខ្មែរជាប្រទេសមានទ្រព្យសម្បត្តិស្ដុកស្ដម្ភទៀត, តាមដែលយើងមើល ឃើញនឹងភ្នែកយើង. យើងឃើញតែដុំថ្មដែលកសាងតាមព្រះរាជបព្វ- ច័យ, ទើបកសាងយ៉ាងរួសរាន់ រហូតដល់ពួកជាងមិនអាចនឹងក្លិតថ្ម ដែល បន្តុចឲ្យបានសំរេច, មិនមានដុំថ្មគប់គ្រាន់នឹងប្រើប្រាស់ហើយយកថ្ម បាយក្រៀមមកដាក់ជំនួសខ្លះ. រឿងរបាក្យត្រធ្លាក់មិនទាន់ហើយស្រេច, គ្រឿងអលង្ការមិនសមរម្យ ឯព្រះបាទជយវរ្ម័នទី ៧ នេះទ្រង់មិនមែនជា ស្ដេចនៅក្នុងវ័យក្មេងផង ហើយសព្វព្រះរ័យទ័ងចកប្រាសាទដែលទ្រង់ កសាងឲ្យបានហើយស្រេចក្នុងកាលដែលទ្រង់គង់ព្រះជន្មនៅទៀត តាម គ្រាន់ការកសាងប្រាសាទដែលទ្រង់ធ្វើទុក ៗ អំពីនេះ លុះទ្រង់ទិ- វង្គតទៅ តើដូចម្ដេច? តាមសិលាចារឹក យើងបានដឹងថាព្រះរាជាដែល ទ្រង់រាជ្យតាមក ទ្រង់បដិសេធព្រះពុទ្ធសាសនាចោលអស់ ហើយប្រតិ បត្តិតាមសាសនាព្រះនារាយណ៍ ជាសាសនាបុរាណ, គេបានឃើញប្រា- សាទជាច្រើន ដែលមានការបដិវត្តិប្រែប្រួលទៅតាមសាសនាព្រាហ្មណ៍; និយាយដោយពិត, គឺព្រះរាជាអង្គនេះ ទ្រង់កសាងសេចក្ដីវិនាសខុសឲ្យ ប្រទេស ដោយការចាយប្រាក់កាសកតប៉េតិត, តមក, ឥតមានកម្លាំង ទប់ទល់នឹងបច្ចាមិត្រទិសខាងលិចដែលទន់ខ្សោយ ដែលមាននិស្ស័យចង់ ក្ដិនក្ដស់ចាប់រួសរាន់ ៗ លុះដល់មក គ. ស. ១៨៣៩ អ្នកដំណើរចិនម្នាក់

ឈ្មោះ ចៀវតាក្វាង់ មកកាន់ប្រទេសខ្មែរ ក៏បានឃើញប្រទេសខ្មែរត្រូវគេកំទេចខ្ទេចខ្ទីហើយដោយចម្បាំងនឹងជាតិសៀម ។

មានអ្នកប្រាជ្ញខ្លះយល់ថា ការធ្លាក់ចុះនៃប្រទេសខ្មែរ ជាប្រស្នាដែលរាយសេចក្តីមិនបែក ហើយអ្នកប្រាជ្ញនោះបដិសេធថា ប្រាសាទអស់នេះមិនមែនជាស្នាដៃខ្មែរទេឡើយ, រឿងនេះ មិនមែនជាប្រស្នារកយមិនបែកដូច្នោះទេ, ខ្មែរសព្វថ្ងៃនេះ ប្រាកដជាពូជពង្សដែលស្រឡាយសាច់ឈាមខ្មែរពិតប្រាកដដែលកសាងនគរ ដូចការនិយាយដែលមាននៅក្នុងសិលាចារឹក តាំងពីសតវត្សរ៍ទី ១២ ក៏មិនខុសគ្នានឹងខ្មែរសម័យយើងនេះទេឡើយ ប្រែតែបន្តិចបន្តួចប៉ុណ្ណោះ ដោយក្លាយយារតៗគ្នាមក ។

ចុះជាតិណា ដែលត្រូវគេកេណ្ឌយកទៅកសាងប្រាសាទធំសំបើមៗ ដោយសេចក្តីព្យាយាមយ៉ាងមាំមួន ហើយចាយទ្រព្យសម្បត្តិកសាងប្រាសាទច្រើនដល់ម្លេះ? ឆ្លើយថា គឺជាតិខ្មែរដែលបានដល់ថ្នាក់ជាមហាសេដ្ឋីហើយ ក៏ធ្លាក់ចុះដោយការញាំញីអំពីកិត្តិយសរបស់ព្រះរាជាព្រះអង្គឯង ។

ហេតុដូច្នេះ, ដល់មកខាងដើមសតវត្សរ៍ទី ២០ នៃពុទ្ធសករាជ, សម័យរុងរឿងនៃការកសាងចប់ចុះហើយ, ចក្រពត្តិខ្មែរ, ដោយការលុកលុយជាតិសៀម ដែលមកធ្វើឲ្យកំរើកមហាអំណាចស្តេចខ្មែរ, ក៏ដើរទៅកាន់

សេចក្ដីលត់ហូតដល់លះបង់នគរ ។ ក្សត្រិយ៍ខ្មែរដែលលះបង់នគរហើយ, មកប្រតិស្ឋានទីក្រុងនៅស្រីសុន្ធរ មកនៅភ្នំពេញ, នៅលង្វែក, នៅឧដុង្គ, ទីបំផុតមកនៅភ្នំពេញវិញ ដែលជាកដណាទីសព្វថ្ងៃនេះ ។

ប្រាសាទខ្មែរ ដោយការញាំញីនៃបច្ចាមិត្រដែលមានជ័យ ក៏ត្រូវលះបង់ចោល, តាំងពីកាលនោះមក, ក្នុងប្រទេសក្ដៅ អាចបង្កើតឲ្យមានរុក្ខាលតាជាតិដុះលូតលាស់យ៉ាងរហ័ស ព្រៃព្រឹក្សាកអាចដុះជិះជាន់ចាក់ឬសពទ្ធព័ន្ធ រំលើងដុំថ្មលើប្រាសាទខ្ទេចខ្ទីអស់ជាច្រើន ។

លុះដល់ ព.ស.២៤៥០ កាលដែលសៀមប្រគល់ខេត្តបាត់ដំបងនិងសៀមរាបមកប្រទេសបារាំងសែសវិញ ទើបលោក ជ. កុម្មៃ (Jean Commaille) អ្នកថែរក្សានគរជាបឋម ជាក្រុមសាលាបារាំងសែសចុងបូព៌ាប្រទេស មករៀបចាត់ចែងកាប់ឆ្កាព្រៃព្រឹក្សា ហើយជួសជុលប្រាសាទដែលរលំខ្ទះឲ្យបានគង់ទ្រង់ឡើងវិញ, ការរៀបចំនេះក៏ចាប់ធ្វើឡើងឥតឈប់ឈរ អាចការពារមិនឲ្យវិនាសអន្តរាយទៀតបានជាច្រើន ។

ទីបំផុត បានរៀបចំឲ្យមានផ្លូវគមនាគមន៍នៅក្នុងទីនគរតាមរបៀបថ្មីឲ្យបានចំរើនរហ័សជានិច្ច ។

ក្នុង ព.ស. ២៤៧៥ បានតាំងមន្ទីរត្រួតត្រាបុរាណវត្ថុនៅប្រទេសខ្មែរ សម្រាប់ការពារប្រាសាទដែលស្ថិតនៅឆ្ងាយគ្នាពីនគរ អាចឲ្យអ្នកថែរក្សាទៅរៀបចំបានស្រួល ។

# បញ្ជីរាយនាមស្តេចសម័យនគរ[1]

| ព្រះនាមស្តេច | សម័យ | ប្រាសាទ |
|---|---|---|
| ភវវរ្ម័ន ទី ១ | រវាង ព.ស. ១០៩៣ | |
| មហេន្ទ្រវរ្ម័ន | –. ព.ស. ១១៤៣ | |
| ឦសានវរ្ម័នទី ១ | ក្រោយឆ្នាំ ព.ស. ១១៥៩ មុនឆ្នាំ ព.ស. ១១៦៩ | សម្បូរណ៍ព្រៃគុក |
| ភវវរ្ម័ន ទី ២ | – ព.ស. ១១៨២ | |
| ជ័យវរ្ម័ន ទី ១ | – ព.ស. ១២០០ មុនឆ្នាំ ព.ស. ១២០៧ | |
| *សម័យកាន់ប៉ែ, ប្រទេសកម្ពុជា បែកចេញជាពីរផ្នែក: កម្ពុជាភាគលើ (នៅខាងជើង) ភាគក្រោម (នៅខាងត្បូង)* | | |
| ជ័យវរ្ម័ន ទី ២ | ព.ស. ១៣៤៥ – ១៣៩៣ | ប្រាសាទនៅភ្នំគូលេន |
| ជ័យវរ្ម័ន ទី ៣ | ព.ស. ១៣៩៣ – ១៤២០ | |
| ឥន្ទ្រវរ្ម័ន ទី ១ | ព.ស. ១៤២០ – ១៤៣២ | បាគង-ព្រះគោ |
| យសោវរ្ម័នទី ១ | រវាង ព.ស. ១៤៣២ ដល់មក ១៤៥៣ | បាខែង, លលៃ, [illegible] |
| ហស៌វរ្ម័ន ទី ១ | ក្នុងរវាង ព.ស. ១៤៥៣ មុនឆ្នាំ ១៤៦៥ | |
| ឦសានវរ្ម័ន ទី ២ | ព.ស. ១៤៦៨ | |
| ជ័យវរ្ម័ន ទី ៤ | ព.ស. ១៤៧១ – ១៤៨៥ | កោះកែរ |
| ហស៌វរ្ម័ន ទី ២ | ព.ស. ១៤៨៥ – ១៤៨៧ | កោះកែរ |
| រាជេន្ទ្រវរ្ម័ន ទី ២ | ព.ស. ១៤៨៧ – ១៥១០ | កំពែងព្រះរាជវាំង, ប្រែរូប, មេបុណ្យខាងកើត |

-1 H. Marchal. La collection khmère, P. 29, 30.

| ព្រះនាមស្ដេច | សម័យ | ប្រាសាទ |
|---|---|---|
| ជ័យវរ្ម័ន ទី ៥ | ព.ស. ១៥១១ – ១៥៤៤ | បន្ទាយស្រី, តាកែវ |
| ឧទយាទិត្យវរ្ម័នទី ១ | ព.ស. ១៥៤៤ – ១៥៤៥ | |
| ជយវីរវរ្ម័ន | ព.ស. ១៥៤៥ – ១៥៥៣ | |
| សូរ្យវរ្ម័ន ទី ១ | ព.ស. ១៥៤៥ – ១៥៩២ | តាកែវ |
| ឧទយាទិត្យវរ្ម័នទី ២ | ព.ស. ១៥៩២ – ១៦០៩ | បាពួន |
| ហស្សវរ្ម័ន ទី ៣ | ព.ស. ១៦០៩ – ១៦៣៣ | |
| ជ័យវរ្ម័ន ទី ៦ | ព.ស. ១៦២៥ – ១៦៥០ | ពេងមាលា |
| ធរណីន្ទ្រវរ្ម័ន ទី ១ | ព.ស. ១៦៥០ – ១៦៥៦ | |
| សូរ្យវរ្ម័ន ទី ២ | ព.ស. ១៦៥៦ – ១៦៨៨ (?) | អង្គរវត្ត |
| ធរណីន្ទ្រវរ្ម័នទី ២ | រវាង ព.ស. ១៦៩៣ | |
| យសោវរ្ម័ន ទី ២, | រវាង ព.ស. ១៧០៣ | |
| ត្រិភុវនាទិត្យវរ្ម័ន | ព.ស. ១៧០៨ – ១៧២០ | |
| ជ័យវរ្ម័ន ទី ៧ | ព.ស. ១៧២៤ មុនឆ្នាំ ព.ស. ១៧៤៤ | កំពែងនគរធំ, បាយ័ន |
| ឥន្ទ្រវរ្ម័ន ទី ២ | ព.ស. ១៧៤៤ – ១៧៨៦ | កាន់ប្រែសាសនាព្រាហ្មណ៍ឡើងវិញ |
| ជ័យវរ្ម័ន ទី ៨ | ព.ស. ១៧៨៦ – ១៨៣៨ | |
| ស្រីន្ទ្រវរ្ម័ន | ព.ស. ១៨៣៨ – ១៨៥១ | |
| ស្រីន្ទ្រជយវរ្ម័ន | ព.ស. ១៨៥០ – ១៨៧០ | |
| ជ័យវរ្ម័នបរមេស្វរៈ | ព.ស. ១៨៧០ | |

## លទ្ធិសាសនា

ប្រាសាទទាំងឡាយដែលយើងបានមើលឃើញសព្វថ្ងៃនៅទីនេះ, សុទ្ធតែជាប្រាសាទដែលគេកសាងឡើងដើម្បីឧទ្ទិសដល់សាសនា មិនមែនជាប្រាសាទសម្រាប់ស្ថិតនៅនៃព្រះរាជាក្នុងសម័យនោះឡើយ ។ សម័យនគរ, ជាសម័យដែលគេគោរពសាសនាយ៉ាងមាំមួន មិនមែនតែប្រទេសកម្ពុជាឡើយ សូម្បីប្រទេសដទៃក្នុងសកលលោកសម័យជាមួយគ្នា ក៏កាន់សាសនាខ្លាំងណាស់ដែរ, ហេតុនេះ, ក្នុងសម័យនគរ គេអាចពិនិត្យឃើញមានសាសនាធំពីរជាប្រធាន ដោយការបញ្ជាក់ដោយរូបផ្សេងៗ ដែលមានជាប់នៅនឹងប្រាសាទ គឺ ព្រះពុទ្ធសាសនានិងសាសនាព្រាហ្មណ៍ ។

## ព្រះពុទ្ធសាសនា

លទ្ធិព្រះពុទ្ធសាសនា ចំរើនបរិបូណ៌ពេញប្រទេសឥណ្ឌា ហើយផ្សាយចេញទៅក្នុងសកលលោកតាំងពីរនិកាយ គឺ ហីនយាន ១ មហាយាន ១ ។

ពុទ្ធសាសនាសម័យនគរ មិនមែនជាលទ្ធិហីនយានដូចយើងសព្វថ្ងៃនេះទេ លទ្ធិហីនយាននេះផ្សាយមកជាខាងក្រោយគឺទាំងចុងដែលប្រទេសខ្មែរយើងមានសេចក្តីរុងរឿង កាលប្រទេសខ្មែរយើងជួបគ្រាទុរភាព

កាលណា ទើបលទ្ធិហីនយាននេះហូរចូលមកច្រើនពីប្រទេសសៀមហូតដល់ពេញប្រទេសខ្មែរដូចសព្វថ្ងៃនេះ តាំងពីតានចុង ព. ស. ២០៤៣ រៀងមក ។

លទ្ធិមហាយាន — អ្នកកាន់តាមលទ្ធិមហាយាន ក៏ឈ្មោះថា អ្នកកាន់ព្រះពុទ្ធសាសនាដែរ, កាលដើមមានតែឈ្មោះមួយថា ព្រះពុទ្ធសាសនា លុះចំណេរតមក អ្នកកាន់ព្រះពុទ្ធសាសនាក៏បែកខ្ញែកគ្នាចេញទៅជាច្រើននិកាយ, និកាយធំៗគឺ ហីនយាននិងមហាយាននេះ ។

ព្រះពុទ្ធសាសនាលទ្ធិមហាយាន ប្រកាន់លទ្ធិអាចរិយវាទ គឺប្រកាន់តាមគ្រូអាចារ្យរបស់ខ្លួនតៗគ្នា មិនប្រតិបត្តិតាមគោលព្រះត្រៃបិដកដូចហីនយានទេឡើយ ។ តាមសេចក្ដីយល់អ្នកកាន់លទ្ធិមហា-យាន គេបានបង្កើតគម្ពីរដីកាផ្សេងៗអំពីគោលដើមគឺព្រះត្រៃបិដកជាច្រើន ដូចគម្ពីរសទ្ធម្មបុណ្ឌរីក, គម្ពីរលង្កាវតារសូត្រ, គម្ពីរប្រាជ្ញាបារ-មិតាជាដើម ចារឹកជាអក្សរសំស្ក្រឹតទាំងអស់ ដោយគេយល់ថា ព្រះពុទ្ធជាគ្រូទ្រង់អនុញ្ញាតឲ្យអ្នកកាន់ព្រះពុទ្ធសាសនារៀនសូត្រជាអក្សរសំស្ក្រឹត ជាទំនាស់នឹងហីនយានដែលរៀនសូត្រតាមភាសាមគធៈ; គេបានបង្កើតទេវរូបជាច្រើនលើសលុបទាំងគណនាបាន សម្រាប់ជាទីគោរពបូជា ដូចព្រះពុទ្ធរូប, រូបលោកេស្វរៈ រូបប្រាជ្ញាបារមិតាជាដើម ។

ព្រះពុទ្ធសាសនាលទ្ធិមហាយាន មានឫទ្ធានុភាពច្រើនណាស់ ផ្សាយពីប្រទេសឥណ្ឌា ចូលៈទៅកាន់ស្រុកតូចស្រុកធំគ្រប់សកលលោក មានប្រទេសទីបេត៍, ចិន, ជប៉ុន, យួន, ខ្មែរ, ជ្វា ជាដើម ប្រទេសទាំងអស់នេះ មានព្រះពុទ្ធសាសនាលទ្ធិមហាយានឋិតថេរៈរហូតមកដល់សព្វថ្ងៃនេះ ។

លទ្ធិហីនយាន — ព្រះពុទ្ធសាសនាលទ្ធិហីនយាន ប្រកាន់តាមលក្ខណៈថេរវាទ គឺកាន់តាមគោលព្រះត្រៃបិដកជាធំ ដូចប្រទេសខ្មែរយើង, សៀម, លង្កា, ភូមា សព្វថ្ងៃនេះ ។

## សាសនាព្រាហ្មណ៍

ព្រះពុទ្ធសាសនានិងសាសនាព្រាហ្មណ៍ទាំងពីរនេះ កើតនៅប្រទេសឥណ្ឌាជាច្រើនរយសតវត្សរ៍មកហើយ ទើបផ្សាយចូលមកប្រទេសកម្ពុជាយើងនេះ; កាលប្រទេសយើងកំពុងរុងរឿង, សាសនាទាំងពីរនេះក៏មកប្រតិស្ឋាននៅប្រទេសកម្ពុជានេះសម័យជាមួយគ្នា, តាមសិលាចារឹក, លោក សឺដែស លោកសរសេរទុកថា: "ព្រះពុទ្ធសាសនានិងសាសនាព្រាហ្មណ៍មានគេកប់កានស្មើគ្នាទាំងពីរ នៅប្រទេសខ្មែររៀងកបផុតបមក" ។ សព្វថ្ងៃនេះ ប្រទីបសាសនាព្រាហ្មណ៍រលត់បាត់បង់ទៅហើយ, តែចិត្តគំនិតជនជាតិខ្មែរមានសេចក្តីប្រកាន់លទ្ធិសាសនា

ព្រាហ្មណ៍នៅឡើយ លាយបន្ទំជាមួយនឹងព្រះពុទ្ធសាសនា ។ ឯទេវរូបសាសនាព្រាហ្មណ៍តំណាងសម័យនគរមាន៣គឺ ព្រះឥសូរ, ព្រះវិស្ណុនិងព្រះព្រហ្ម: សេចក្ដីយល់សម័យនោះថា ព្រះព្រហ្មជាអ្នកកសាងលោក, ព្រះឥសូរជាអ្នកបំផ្លាញលោក, ព្រះវិស្ណុជាអ្នកថែរក្សា, គេច្រើនរាប់អានព្រះវិស្ណុនិងព្រះឥសូរជាង, ព្រះព្រហ្មាគេមិនសូវរាប់អានទេ ។ ព្រះវិស្ណុទេពតាថែរក្សាត្រៃភព អវតារបានច្រើនភេទ, អវតារជាជ្រូកព្រៃឈ្មោះវរាហៈទៅដណ្ដើមយកផែនដីពីក្នុងសមុទ្រដែលយក្សលួចយកទៅ, អវតារជាសីហៈ ចួនកាលជាអណ្ដើក ឬជានរសីហៈ គឺក្បាលជាសត្វសីហៈខ្លួនជាមនុស្សដៃបួន, អវតារជាវាមនៈ គឺព្រាហ្មណ៍តឿជាម្ចាស់ផែនដី, អវតារជាត្រីវិក្រម ច្បាំងដណ្ដើមយកសកលលោកដោយគ្រាន់តែឈាន ៣ ជំហាន ។ តាមគម្ពីរ, ព្រះវិស្ណុនេះជាទេពតាឈរ មានដៃបួន, កាន់ព្រះខាន់, កាន់ដំបង, កាន់ចក្រនិងខ្យងស័ង្ខ, មានសត្វគ្រុឌជាពាហនៈ; ជួនកាលដេកបណ្ដោយលើពស់ឈ្មោះសេសៈ ឬ អនន្តៈ មានដើមឈូកដុះចេញពីផ្ចិត, នៅលើផ្កាឈូកមានរូបព្រះព្រហ្ម(១) ចួនកាលព្រះវិស្ណុនេះអវតារជាក្រិស្ណ លើកដៃម្ខាងទ្រភ្នំការពារហ្វូងសត្វនិងអ្នកគង្វាល ឬអវតារជាព្រះរាមច្បាំងដណ្ដើមនាងសីតាអំពីរាពណ៍ ក្នុងរឿងរាមកេរ្តិ៍(១) ។

---

១ អ្នកខ្លះយល់ថា រឿងរាមកេរ្តិ៍ (ព្រះវិស្ណុអវតារជាព្រះរាម) ថ្លែងកាលពួកអរិយកៈលើកទ័ពទៅវាយយកកោះលង្កាទ្វីប ។ រឿងមហាភារតៈ (ព្រះវិស្ណុអវតារជា[illegible]) ថ្លែងកាលពួកអរិយកៈលើកទ័ពចូលកាយប្រទេសឥណ្ឌា ។

អគ្គមហេសីព្រះវិស្ណុឈ្មោះស្រី ឬ លក្ស្មី ជាទេពធាបញ្ចពិធកល្យាណី និងទេពការពារទ្រព្យសម្បត្តិ នាងនេះកើតចេញមកពីសមុទ្រទឹកដោះ ដៃកាន់ផ្កា ។

ព្រះឥសូរជាទេពតាខាងបំផ្លាញនិងខាងបង្កើត, អវតារជានដរាជ: ស្ដេចនៃរបាំ ជួយទំនុកបំរុងលោក, ដូចរបាំនតាណ្ឌវៈដែលលេងនៅ សមោសរនៃស្ថានសួគ៌, ចួនកាលគេកសាងព្រះឥសូរនិងវិស្ណុលាយចូលគ្នា គេឲ្យឈ្មោះថា ហរិហរៈ រូបនេះមាននៅសម័យហ្វូណន ។ តាមធម្មតា, គេកសាងព្រះឥសូរតែម្នាក់ឯង ឬជាមួយនឹងយានគឺគោឈ្មោះនន្ទិ, នៅប្រាសាទដែលគេចុះសង្ហាយ គេច្រើនធ្វើរូបសិវលិង្គជំនួស, នៅជញ្ជាំងប្រាសាទ, គេឆ្លាក់រូបព្រះឥសូរស្ថិតនៅកណ្ដាលប្រាសាទ ប្រដាប់ដោយគ្រឿងអលង្ការផ្សេងៗ មានដៃច្រើន ក្បាលច្រើន ជួនកាលជារូបឥសី, គេតាងស្គាល់រូបព្រះឥសូរបាន ដោយមានភ្នែកនៅត្រង់ថ្ងាសនិងត្រីសូល ។ អគ្គមហេសីឈ្មោះសក្តិ, បរ្វតី, ឧមា ឬ ទុគ៌ា, នៅប្រាសាទបាគង មានរូបព្រះឥសូរនៅកណ្ដាល នាងឧមានិងនាងគង្គានៅសង ។

ព្រះព្រហ្ម, តាមធម្មតា, គេកសាងទុកកណ្ដាល ព្រះវិស្ណុនិងព្រះឥសូរនៅអមសងខាង, ព្រះព្រហ្មនេះមានមុខបួន, ដៃបួន, មានសត្វហង្សជាពាហនៈ អគ្គមហេសីឈ្មោះនាងស្វរស្វតី ។

ទេពតាក្នុងសាសនាព្រាហ្មណ៍ តាមដែលគេប្រកាន់ជឿ មានច្រើនយ៉ាងក្នុងសម័យនោះ គឺព្រះឥន្ទ្រជាទេពតាស្ថិតនៅស្ថានសួគ៌ ដែលកាន់វជ្រៈ (រន្ទះ) ជិះលើដំរីឯរាវណ្ណក្បាល៣, ព្រះអាទិត្យ, ព្រះចន្ទ្រ, គណេសជាកូនព្រះឥសូរ មានក្បាលជាដំរី ភ្លុកខក ឧទរធំកំប៉ោង ដៃបួន; សេចក្ដីដំណាលថា កាលព្រះឥសូរមានសេចក្ដីក្រោធ, ក៏កាប់ក្បាលគណេសដាច់ហើយយកក្បាលដំរីមកតភ្ជាប់វិញ ។ល។

# កេរ្តិ៍ឈ្មោះនគរ

កេរ្តិ៍ឈ្មោះនគរស្ថិតនៅក្នុងចិត្តនៃបណ្ដាជនទូទៅ តែតែងស្គាល់ទាំងអស់គ្នា, ព្រោះក្នុងបច្ចុប្បន្នកាលនេះ, កេរ្តិ៍ឈ្មោះនគរផ្សាយទៅកាន់ប្រទេសទាំងអស់ក្នុងលោកសន្និវាស មានទ្វីបអឺរ៉ុប នឹងទ្វីបអាស៊ីជាដើម, ប្រទេសទាំងអស់នេះសុទ្ធតែបានទទួលដំណឹងផ្សេងៗ អំពីរឿងនគរ ដោយសៀវភៅនាំមើលនគរ ដោយទស្សនាវដ្ដីដែលគេផ្សាយចេញទៅស្ទើរតែគ្រប់ភាសា ឬដោយរូបថតដែលគេដំកល់ទុកនៅក្នុងពិពិធភណ្ឌរបស់ជាតិគេ ពុំនោះដោយក្រសួងអ្នកត្រាច់ផ្គត់ចេវើលវីង គេផ្សាយដំណឹងអំពីគមនាគមន៍ទៅកាន់នគរ រួមឲ្យខ្ញុំទៅបានសេចក្ដីថា ពាក្យថា: "មិនស្គាល់នគរស្ទើររកមិនមានក្នុងលោកឡើយ" ។

---

សៀវភៅនគរ— អំពីអ្នកប្រទេសដែលបានមកទស្សនានគរមុនគេ ហើយសរសេរសៀវភៅនិយាយអំពីរឿងនគរ ទុកឲ្យគេមើលមកដល់សព្វថ្ងៃនេះ គឺអ្នកប្រទេសជាតិចិនឈ្មោះចៀវតាក្វាន់ ជារាជទូតស្ដេចក្រុងចិន បញ្ជូនមកមើលស្រុកខ្មែរ ក្នុងពុទ្ធសករាជ ១៨៣៩ កាលនោះ ចៀវតាក្វាន់ហៅប្រទេសខ្មែរយើងថា ចេន-ឡា (កម្ពុជា) ។

លុះដល់មក ព.ស. ២១៤៧, ទើបមានជនជាតិអឺរ៉ុបពីរនាក់មកមើលទៀត គឺលោក ប. រីបាដេណៃរា (P. Ribadeneyra) និងលោក

ប. គាព្រិយ៉ែល ដឺ សង់តោ អង់តោនីយោ (P. Gabriel de Santo Antonio) លោកនិយាយថា: "នៅក្នុងប្រទេសខ្មែរ មានប្រាសាទបុរាណល្អវិសេស ស្ថិតនៅកណ្ដាលព្រៃ ជាស្នាដៃជាតិរ៉ូម៉ាំង ឬស្ដេចអាឡិក្សង់ដ្រឺមហារាជ (Alexandre Le Grand) , ពាក្យនេះគួរឲ្យយើងដឹងថា: 'ជាតិទុរុបគេមិនជឿថា ជាតិខ្មែរចេះកសាងប្រាសាទល្អវិសេសបែបនេះទេ" ។

លុះមកដល់ ព.ស. ២២១៥, មានទូតជាតិបារាំងសែសម្នាក់ឈ្មោះ ប. សឺវ្រឺយ (P. Chevreuil) និយាយថា: "ប្រាសាទនគរនេះល្អដូចប្រាសាទសាំងត៍-ពីយែរ (Saint · Piérre) នៅក្រុងរោមដែរ ។

លុះដល់មកថ្ងៃ ២២ ខែយ៉ាំនវីយេរឆ្នាំ ១៨៦១ (ព. ស. ២៤០៤) មានអ្នកប្រាជ្ញបារាំងសែសម្នាក់ទៀតឈ្មោះ ហ. មូហុត (H. Mouhot), ស្លាប់នៅថ្ងៃ ១០ ខែណូវ៉ែមប្រ៊ីឆ្នាំ ១៨៦១ នៅជិតក្រុងហ្លួងប្រាបាង (ប្រ-ទេសលាវ); លោកនេះ បានអញ្ជើញមកមើលនគរ ហើយលោកបាននិយាយអំពីនគរនេះ ប្រាប់ដល់លោកទាំងមូលឲ្យដឹងច្បាស់លាស់អំពីប្រាសាទនគរ ។ សេចក្ដីយកការនិងរូបគំនូររបស់លោក គេបានបោះពុម្ពផ្សាយចេញទៅក្នុងសកលលោក ហើយនាំឲ្យបណ្ដាជនក្នុងលោកសន្និ-ភាស ដឹងដំណឹងអំពីនគរឡើង ដូចពាក្យដែលលោក ហ. គោឡូបេវ (H. Goloubev) និយាយបញ្ជាក់ថា: "រនាំងឬធាក់ដែលបាំងប្រាសាទនគរ

ត្រូវលោក ហ មូហុត បើកចេញហើយ, ការបើកចេញនៃនាំផ្លូវធាក នេះ លែងបិទទៅវិញហើយ" ។ តាំងពីកាលនោះមក ក៏កាន់តែមាន អ្នកបរទេស ចូលមកមើលនគរជាច្រើនគត ៗ គ្នាជាលំដាប់តជាប់ ហើយ កេរ្តិ៍នគរក៏កាន់តែលេចអណ្តែតទៅកាន់ប្រទេសនានាច្រើនឡើង ៗ

អំពីការរៀបចំនគរ. — កាលពីដើម, មុនដែលមានរាជការប្រតិកត្តូក៍ មកនៅគ្រប់គ្រងប្រទេសកម្ពុជា នគរស្ថិតនៅកណ្តាលទ្រូងព្រៃ, ការ ទៅមើលនគរតាមផ្លូវពីសៀមរាបទៅនគរវត្ត ឬនគរធំ, មានផ្លូវរទេះតូច ៗ ចូលទៅ. បើត្រូវការចូលមើលប្រាសាទក៏ពិបាកណាស់ ព្រោះមានភ័យ ជាច្រើន ភ័យពីសត្វសាហាវយង់ឃ្នង ដូចសត្វខ្លា, ដំរី, សត្វអាសិរពិស, ជាដើម ។ ឯបក្សីបក្សាយាសយំស្នូរសំឡេងគនរំពងអឹងកងពេញទាំង ព្រៃ ប្រាសាទទៅជាគុម្ព មានព្រៃក្បាលតាជាតិដុះជេរដាសពាសពេញ ញាត់ស្បាតមិនងាយចូលទៅបានទេ ត្រង់កន្លែងខ្លះត្រូវតែលូនឬវារទើប ឡើងទៅបាន ដើមឈើឬវល្លិដុះព័ទ្ធចាក់ស្រែះកៀវវ៉ុំព័ទ្ធប្រាសាទ ពិបាក សង្កេតមើលក្បាច់ចនាផ្សេង ៗ ដែលមាននៅក្នុងប្រាសាទ ។

ចំនួន ៣៥ ឆ្នាំមកហើយ, រាជការបានប្រគល់ការរៀបចំនគរមក សាលាបារាំងសែសចុងបូព៌ាប្រទេស (École Française d'Extrême Orient) នៅក្រុងហាណូយ ដើម្បីរៀបចំឲ្យបានល្អឡើងវិញ, តាំងពីកាលនោះមក,

សាលាបារាំងសែសចុងបូព៌ាប្រទេស ក៏បានធ្វើមន្ទីរមួយក្នុងនោះនគរ ដើម្បីរៀបចំគាស់ឆ្ការព្រៃព្រឹក្សាលតាជាតិ និងរៀបឲ្យមានផ្លូវគមនាគមន៍ ទៅកាន់ប្រាសាទមួយៗបានស្រួល, កិច្ចការបានចាត់លោក ជ. កុម្មៃ (J. Commaille) ជាអ្នករក្សាអង្គរមុនគេបង្អស់ ក្នុង គ.ស. ១៩០៨-១៩១៦ (ព.ស. ២៤៥១-២៤៥៩) ។ លោកនេះ បានចាត់ចែងរៀបកាប់ឆ្ការព្រៃ នៅប្រាសាទនគរវត្តនិងបាយ័នរួចស្រេចហើយ ទើបរៀបចំបាពួន, វិមានអាកាស, ទីលានគរទៅ; ជាគ្រោះថ្នាក់លោក មានចោរកំណាចកាប់សម្លាប់ក្នុងខែអាព្រិល ១៩១៦ ទៅ ។ លំដាប់តមក, ក៏មានអ្នកថែរក្សាជាតិបារាំងមកនៅថែរក្សាទៀត, ដូចលោក ហ. ម៉ារសាល់ ឆ្នាំ១៩១៦-១៩៣២; លោក គ. ត្រូវេ ឆ្នាំ ១៩៣២-១៩៣៥; លោកគ្លេស ឆ្នាំ១៩៣៧ ។ កាលពីដើម, គេទៅកាន់ប្រាសាទមួយៗរាប់ថ្ងៃ ព្រោះពិបាកនឹងផ្លូវគមនាគមន៍និងការចូលមើលប្រាសាទ, ឥឡូវនេះ, គេអាចជិះរថយន្តមើលប្រាសាទទាំងអស់ក្នុងមួយថ្ងៃបាន ។ អ្នកមើលក្នុងពេលនេះ, ក៏អាចស្មានបន្តិចស្រមៃមើលនគរកាលជាន់ដែលមានព្រៃព្រឹក្សាមិនឃើញ ឬនឹកខ្វះថា ប្រាសាទទាំងនេះ មានសណ្ឋានដូចនេះតែម្តង តាំងពីដើមរៀងមកឥតមានមោះមៃឡើយ ។

# ការរចនាខ្មែរបែបផ្សេងៗតាមលំដាប់ប្រវត្តិការ[១]

បែបការរចនាសម័យប្រាសាទសម្បូណ៌ រវាង ព.ស. ១១៤៣

លក្ខណប្រាសាទ:

ប្រាង្គធ្វើពីឥដ្ឋ

— ផ្ដែលើខ្លោងទ្វារ ចម្លាក់ក្បាច់ មានក្បាច់ពងក្រពើទីឯរូបមនុស្ស-ភាព; ទំបំផុតសងខាង មានចម្លាក់រូបមករ ក្រមែងជាទីងក្បាច់ក្រប

— សសរតូច ធ្វើពីថ្មក្រឡឹងមូល

រូបចម្លាក់មនុស្សភាព

— រូបស្ត្រីភាពតូចៗ តែគាកសាយ មកុដមូល, សំពត់ស្លៀកមានផ្នត់ខ្លួនជ្រៅ ៗ

— លក្ខណរូបខាងលើនេះកើតច្រើនឡើង

— រូបបុរសភាពធំៗ

បែបប្រាសាទសម័យនោះ:

ប្រាសាទសម្បូណ៌ព្រៃគុក

ប្រាសាទក្នុំធំ

ប្រាសាទជម្សង់ដែក

(១) ការរចនាដោយសង្ខេបនិងរូបចិត្រៈក្នុងសៀវភៅនេះ យកតាមការងាររបស់ជីម្លូសែល ការប៉ុរីឡូស អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ។

បែបការរចនាសម័យប្រាសាទព្រៃក្មេង រវាង ព.ស. ១១៩៣ - ១២៤៣

លក្ខណប្រាសាទដូចសម័យប្រាសាទសម្បូណ៌

- ផ្តែលើខ្លោងទ្វារ លំអដោយក្បាច់វល្លិ

- សសរ មានលំអវិសេសឡើង

- រូបមនុស្សភាពធំ, រូបស្ត្រីភាពត្រគាកមិនសូវសាយ, សំពត់ស្លៀកមានផ្នត់តាមគ្នា - ចុងសំពត់មានផ្នត់ចំនៅខាងមុខ ។

បែបប្រាសាទសម័យនោះ:

ប្រាសាទព្រៃក្មេង

ប្រាសាទស្វាយព្រហ្មណ៍

ប្រាសាទក្តុប្រាសិទ្ធ (ទ្វារខាងកើត)

ប្រាសាទអណ្តែត

បែបការរចនាសម័យប្រាសាទកំពង់ព្រះ រវាង ព.ស. ១៣២៣

- កើតមានសណ្ឋានប្រាសាទបែបចេតិយ មានថ្នាក់

- ផ្តែខ្លោងទ្វារ មានការលំអដោយក្បាច់វល្លិសុទ្ធ

- សសរតូចៗ មានចម្លាក់រំលេចសន្លឹកឈើ

- ការចម្លាក់មនុស្សភាពមិនសូវដូចសុទ្ធ ដូចសម័យប្រាសាទសម្បូណ៌និងព្រៃក្មេងទេ ។

- ចម្លាក់មនុស្សភាពម្នាក់ឯងលំអជញ្ជាំង, ឥទ្ធិពលការរចនាចាម និងជ្វាចូលមកលាយ ។

<u>បែបប្រាសាទសម័យនោះ:</u>

ប្រាសាទកំពង់ព្រះ

ប្រាសាទអកយំ

ប្រាសាទត្រពាំងផុង

ប្រាសាទភ្នំបាសិទ្ធ (ទ្វារខាងលិច)

ប្រាសាទភូមិប្រាសាទ

<u>បែបការរចនាសម័យប្រាសាទគូលែន រវាង ព.ស. ១៣៦៨</u>

- ផ្ដែរលើខ្លោងទ្វារ មានរូបមករ និងរូបមនុស្សភាពនៅក្នុងក្បាច់ពន្រ្កតើបែកបាដោយសន្ទឹកឈើ ឥទ្ធិពលការរចនាចាម ជ្វាចូលលាយ

- សសរត្លូច ៨ ជ្រុង ឬបួនជ្រុងទំរង់-នៅផ្ទៃសសរបែកបក្បាច់សន្ទឹកឈើ

- ហោជាង មានមនុស្សភាពនឹងទេពប្រណម្យតិរ

- កើតមានសត្វសីហៈលុតជង្គង់ ក្បាលធំ និងវែងរៃលក្រញ៉ុល

- ចម្លាក់មនុស្សភាពដូចមនុស្សមែនទែន

- សម្លៀកមនុស្សប្រុស ស្រុងលើភ្លៅស្ដាំ ដូចមានជាយពីរ, ជាយសំពត់ខាងលើ បត់ស្មើនឹងពោះ

បែបប្រាសាទសម័យនោះ :

ប្រាសាទនៃព្រៃប្រាសាទ

ប្រាសាទសម្បូណ៌

ប្រាសាទភ្នំគូលែន
- ដំរីក្រាប
- អូប៉ាង
- ខ្ទីងស្លាប់
- រូបការក្ស
- ថ្មដាប
- គតីរ
- ក្រហម
- អ្នកតា (ខត្តា?)

បែបការរចនាសម័យប្រាសាទព្រះគោ រវាង ព.ស. ១៤១៨

- ព្រះប្រាង្គ ធ្វើពីឥដ្ឋ ស្រោបបាយអ
  ផ្តែលើក្លោងទ្វារ រចនាក្រវល្លិមានលំអស្រស់
- សសរមូល រំលេចក្បាច់
- នៅផ្ទៃជញ្ជាំង មានមនុស្សកាចនៅកណ្តាលស៊ុម
- ពាក់មកុដ នៅមើលឃើញផ្នួងសក់ ឬកម្រងសក់ជាកាំៗ

— សម្លៀកបត់ ជាយលើបត់ជាថ្នក់មូល មានផ្នត់ធំៗ

— ក, ដងខ្លួន, ដៃ ប្រដាប់ដោយគ្រឿងអលង្ការ

— រូបសីហៈអង្គុយ កនិមិនសូវក្រអាញ

— គោនន្ទិមានបូក, ដេក, ជើងពីរខាងមុខបត់

— បង្កាន់ដៃមានរូបនាគកើតឡើង ក្បាលនាគពាក់មកុដ ៗ

<u>បែបប្រាសាទសម័យនោះ:</u>

ប្រាសាទព្រះគោ សង់ ព.ស. ១៤២២

ប្រាសាទបាគង សង់ ព.ស. ១៤២៤

ប្រាសាទលលៃ សង់ ព.ស. ១៤៣៦

<u>បែបការរចនាសម័យប្រាសាទបាខែង</u> សង់ ព.ស. ១៤៤៣

— ព្រះប្រាង្គ ធ្វើពីថ្មប្រផែះ

— សសរ លំអដោយសន្លឹកឈើ

— ហោជាង មានរូបមករខាំមនុស្សភាពប្រកបដោយស្លឹកឈើ

— រូបមនុស្សធំៗ

— ត្របកពេមចិញ្ចើមត្រង់

— ភ្នែក, ពពីមាត់មានស្នាមគូសពារ

— ពុកចង្កា, សក់ បក់ជា ៣ ជ្រុង នៅកំភ្លៀងពីរ នៅចង្កាមួយ ៗ

— សត្វសីហៈ,សក្តសម, ប្រែងមិនដូចសុទ្ធ បែបជាគ្រឿងអលង្ការ

<u>បែបប្រាសាទសម័យនោះ</u>

ប្រាសាទភ្នំបាខែង

ប្រាសាទភ្នំក្រោម

ប្រាសាទភ្នំបូក

ប្រាសាទភ្នំក្រវ៉ាន់ រវាង ព.ស. ១៤៦៤

ប្រាសាទប្រែរូប រវាង ព. ស. ១៤៧៣

<u>បែបការរចនាសម័យប្រាសាទបន្ទាយស្រី រវាង ព.ស. ១៥២៣</u>

- វិជ្ជាការកសាងប្រាសាទ កំពុងចំរើនខ្លាំង
- ហោជាង មានការរចនាក្បាច់ល្អពិចិត្រ និងសក្តៃព្រៃ
- មានក្បាច់ចម្លាក់ជារឿងកើតឡើង
- រូបប្រៀបតូច គ្រឿងស្លៀកពាក់លេចធ្លោឡើង
- មុខមាត់សុភាព
- ពពីមាត់ក្រាស់ ហើយខ្វា
- មានរបៀបតែងសក់បែបថ្មី ឥតមានមកុដ
- សត្វសីហៈអង្គុយ ជង្គង់ខ្ពស់ជើងខាងក្រោយបន្តិច

<u>បែបប្រាសាទសម័យនោះ :</u>

បន្ទាយស្រី រវាង ព.ស. ១៥១០

ប្រាសាទស្រឡៅ

បែបការរចនាសម័យប្រាសាទឃ្លាំង រវាង ព.ស. ១៥៣៣ ១៥៥៣

- វិជ្ជាកសាងប្រាសាទនៅចំរើននៅឡើយ
- ព្រះប្រាង្គធ្វើពីថ្ម
- ប្រាសាទបែបភ្នំកើតមានឡើង ហើយមានរោងវែង (រោងទង) ព័ទ្ធជុំវិញ
- ផ្តែរលើទ្វារ មិនសូវមានលំអ តែនៅកណ្តាលមានក្បាលព្រះកាល
- គោនខ្លី ចុកមិនធំ ជើងមុខងើយបន្តិច
- រូបមនុស្សភាពមានសម្លៀកប្រែកបដោយផ្នត់, ជាយសំពត់មានថ្នក់កន្ទ្រែងហើយត្រង់ៗ
- ខាងក្រោយ សំពត់ឡើងដល់ខ្នង, ខាងមុខបើក, ផតមានថ្នក់, សម្លៀកស្រី ខាងថ្នក់មានសណ្ឋានជាកន្ទុយត្រី ។

បែបប្រាសាទសម័យនោះ:

ប្រាសាទតាកែវ
ប្រាសាទឃ្លាំងខាងជើង
ប្រាសាទភ្នំជីសូ (ស្នូរ)
ប្រាសាទព្រះវិហារ
ប្រាសាទចៅស្រីវិបុល

<u>បែបការរចនាសម័យប្រាសាទបាពួន</u> រវាង ព. ស. ១៥៩៣

— ប្រាសាទបែបភ្នំរីកច្រើនឡើង

— កើតថែវមានគោបុរៈ (ខ្លោងទ្វារ) នឹងប្រាសាទជ្រុងគ្រប់ថ្នាក់

— គ្រឿងហោជាង ជាតួខ្លួននាគ ក្បាលបើកពពារចេញទៅម្ខាងៗ

— រឿងរាជក្សត្រិយ៍ទ្វី ឆ្លាក់នៅប្រអប់តូចជាប់ដោយខ្សែ

— សម្លៀកឡើងដល់ខ្នង ហើយមានមុខបិទពោះ

<u>បែបប្រាសាទសម័យនោះ</u>

ប្រាសាទបាពួន

ប្រាសាទមេបុណ្យខាងលិច

ប្រាសាទវត្តឯក

<u>បែបការរចនាសម័យប្រាសាទនគរវត្ត</u> រវាង ព. ស. ១៦៥០

— វិជ្ជាកសាងប្រា~~សាទ~~ ល្អដល់កំរិត.

— ផ្តែឈើខ្លោងទ្វារ, សសរ, ហោជាង រំលេចក្បាច់យ៉ាងល្អ ថ្មី

ដៃវិសេស

— រូបស្ត្រីកាតនៅជញ្ជាំង ប្រកបដោយរូបសត្វនិងភ្ញីល្វិ

— រឿងរាជក្សត្រិយ៍ពេញផ្ទៃផ្ទាំងមួយៗ

— ទេវរូបធំៗ

— សម្លៀកប្រុសៗថ្វី.

— សម្លៀកស្រីៈស្ពត់មានផ្កា ឥតមានផ្នត់

— ទេវរូបមានពាក់មកុដ

— សក់បួងតាមធម្មតា បែបសុភាព

— ខាងបង្កាន់ដៃមានក្រឹនឡើង·ខ្លួននាគទ្រដោយផ្ទាល់ជាក្បាល

— ខាងបើកពពាក់ ប្រកបដោយគ្រឿងបញ្ចាក់

— សត្វសីហៈឈរត្រកែត, ប្រែងក្លាយជាអលង្ការ

— គោនន្ទិ ស្ទើរគ្មានបូក ជើងមុខម្ខាងលើកបន្តិច ។

បែបប្រាសាទសម័យនោះ

ប្រាសាទ នគរវត្ត

ប្រាសាទ បេងមាលា

ប្រាសាទ បាលិលេយ្យ

ប្រាសាទ ភិមៃ (ព. ស. ១៦៥១)

បែបការរចនាសម័យប្រាសាទបាយ័ន រវាង ព. ស. ១៧០០

— វិជ្ជាកសាងមិនវិសេសទេ មិនសូវៈធ័ត តែល្អិតល្អន់ណាស់

— កើតមានប្រាង្គមានមុខបួន

— ក្បាច់ល្អិសាបសូន្យ, តែកើតមានរឿងរាក្សត្រិយ៍ទាំងរូបមនុស្ស

— បង្ហាក់រាក្សត្រិយ៍ខ្ញុំ

— កើតមានបង្ហាក់ព្រះពុទ្ធសាសនា, ឥទ្ធិពលរបច្នាក់ការតែលាយ

— ក្អែកឈ្មោបប៉ប្រិម

— ពពីមាត់ញញឹម-គ្របក្អែកដាក់មកក្រោម

— សម្លៀកប្រសទ្ធី

— ផ្នឹសក់ទៅរូបកំពូលស្រួច ឬមកុដ ៣ ជ្រុង

— នាគបង្កាន់ដៃ មានគ្រុឌមួយ គេឆ្លាក់ភ្ជាប់នៅក្បាលនាគ

— សត្វសីហៈឈរជើង៤ ប្រែក្លាយជាអលង្ការ

បែបប្រាសាទសម័យនោះ:

ប្រាសាទតាព្រហ្ម

ប្រាសាទបន្ទាយក្តី

ប្រាសាទតាព្រហ្មបាទី

ប្រាសាទវត្តនគរ

ប្រាសាទព្រះខ័ន

ទ្វារនគរធំនិងប្រាសាទជ្រុងនគរធំ

ប្រាសាទបាយ័ន

ប្រាសាទបន្ទាយឆ្មារ

ទីព្រះលាននគរធំ

— ភ្នែកស្ទេបប៉ប្រិម

— ពពីមាត់ញញឹម-ត្របកភ្នែកដាក់មករក្រោម

— សម្លៀកប្រុសខ្លី

— ផ្នួងសក់ទៅរូបកំពូលស្រួច ឬមកុដ៣ជ្រុង

— នាគបង្កាន់ដៃ មានគ្រុឌមួយ គេឆ្លាក់ភ្ជាប់នៅក្បាលនាគ

— សត្វសីហៈឈរជើង៤ ប្រែក្លាយជាអលង្ការ

<u>បែបប្រាសាទសម័យនោះ:</u>

ប្រាសាទតាព្រហ្ម

ប្រាសាទបន្ទាយក្តី

ប្រាសាទតាព្រហ្មបាទី

ប្រាសាទវត្តនគរ

ប្រាសាទព្រះខ័ន

ទ្វារនគរធំនិងប្រាសាទជ្រុងនគរធំ

ប្រាសាទបាយ័ន

ប្រាសាទបន្ទាយឆ្មារ

ទីព្រះលាននគរធំ

វគ្គទី ២

# កំពង់ធំ

ការទៅទស្សនានគរ ៖ នេះទៅបានគ្រប់ផ្លូវ តាមផ្លូវដែលយើងស្រួល បើចេញពីភ្នំពេញ មានរថយន្តចេញទៅរាល់ព្រឹក ឬជិះរថយន្ត បុគ្គលមានៗផងក៏ល្អ ១ សប្តាហ៍ ៖ ចម្ងាយផ្លូវពីភ្នំពេញទៅនគរចំនួន ៣២០ គីឡូម៉ែត្រ ។ តាមផ្លូវចេញពីភ្នំពេញទៅ ចន្លោះគីឡូម៉ែត្រ លេខ ១៣៨ និង ១៣៩ មានប្រាសាទបុរាណមួយកន្លែងឈ្មោះវត្តកុក ប្រាសាទ ។ ប្រាសាទនេះ ស្ថិតនៅខាងក្រោយវិហារ គេកសាងពីឥដ្ឋ និងក្រាលថ្ម, នៅស៊ុមមានក្បាច់ចេនាជាន់មុននគរ មានស្លឹកភ្ញីល្អធំៗ ផ្សេងៗ តាមពិនិត្យមើល គេកសាងមុននគរ គេឧទ្ទិសថ្វាយព្រះឥសូរ, ឥឡូវនេះ គេកសាងវិហារថ្មីនៅខាងមុខ ប្រហែលគេរុះរើប្រាសាទបុរាណ ពោលខ្លះ អ្នកផងមិនគួរធ្វើដូច្នេះឡើយ ។

នៅប្រហែល ១៥ គីឡូម៉ែត្រ ផុតពីកំពង់ធំ នៅលើកំពូលភ្នំសន្ទុកមាន ព្រះពុទ្ធរូបនិងក្បាច់ជាច្រើន ។ ពីកំពង់ធំ, នៅគីឡូម៉ែត្រលេខ ២៥៤, នៅផ្លូវកំពង់ក្តី មានស្ពានថ្មបុរាណមួយ មានបង្កាន់ដៃនាគឈ្មោះស្ពាន ព្រះម្ពុស[១], នៅ ៦០ គីឡូម៉ែត្រទៀត, គេនឹងដល់ទៅផ្សារសៀមរាប ។

---

១ បុក្ខិស ?

ពេលត្រឡប់, បើចង់ដើរជុំវិញទន្លេសាបក៏បាន, ត្រូវចេញទៅសិរីសោភ័ណ, មានផ្លូវទៅដល់អរញ្ញប្រទេស ឬទៅបាត់ដំបង, ពោធិ៍សាត់, កំពង់ឆ្នាំង, ភ្នំពេញ, ឬពុំនោះ ថយមកក្រោយវិញតាមកំពង់ធំ, ដល់មក កំពង់ថ្មមានផ្លូវបែកទៅកំពង់ចាម រហូតទៅព្រៃនគរ ។

## ការទស្សនានគរ

ការទស្សនានគរគេចែកចេញជាពីរផ្នែក គឺ វង់តូច ១ វង់ធំ ១ ។

ការមើលវង់តូច ត្រូវចេញពីសៀមរាបទៅដល់ខាងត្បូងនគរវត្ត បត់ទៅខាងកើត, ទៅមើលប្រាសាទក្រវ៉ាញ, ស្រះស្រង់, បន្ទាយក្ដី, តាព្រហ្ម តាកែវ, ស្ពានថ្ម, ចៅសាយ, ធម្មនន្ទ, នគរធំ, បាយ័ន, បក្សីចាំក្រុង, បាពួន ខឹងនគរវត្ត ។

ការមើលវង់ធំ ត្រូវចាប់មើលពីបាពួន, នគរធំ, បាយ័ន, ចៅសាយ, ធម្មនន្ទ, ស្ពានថ្ម, តាកែវ, តាព្រហ្ម, បន្ទាយក្ដី, ស្រះស្រង់, ក្រវ៉ាញ, ប្រែរូប, មេបុណ្យ, តាសោម, ក្រោលគោ, នាគព័ន្ធ, ព្រះខ័ន, ក្រោលដំរី ខ័ងនគរវត្ត ។

ការមើលបញ្ចប់មកចាត់ជា ២ ផ្នែក គឺៈ

១. បន្ទាយស្រី, បន្ទាយសំរែ ។ ២. ប្រាសាទលលៃ, ព្រះគោ, រង, ភ្នំក្រោម, អាទ្វារ, ព្រះឥន្ទកោសី, បារាយណ៍ខាងលិច ។

## ចំងាយប្រាសាទមួយ ៗ រាប់ពីមុខនាគចេញទៅ

ប្រាសាទបាខែង .............. ១ ក.ម. ៥០០

បក្សីចាំក្រុង (៨០ម៉ែត្រពីផ្លូវថ្នល់) .... – ១ ក.ម. ៦០០

## ក្រុងនគរធំ

ខ្លោងទ្វារខាងត្បូង .............. ១ ក.ម. ៩០០

បាយ័ន .................. ៣ ក.ម. ៣០០

បាពួន (២៥០ម៉ែត្រពីផ្លូវថ្នល) .. ៣ ក.ម. ៩០០

វិមានអាកាស (៣០០ ម៉ែត្រពីផ្លូវថ្នល់) . ៤ ក.ម. ១៥០

ទីលានស្តេចគំលង់ .............. ៤ ក.ម. ៣១០

ទេពប្រណម្យ (១៦០ ម៉ែត្រពីផ្លូវថ្នល់) .. ៤ ក.ម. ៤៤០

ព្រះបាលិលេយ្យ (៣៦០ ម៉ែត្រពីផ្លូវថ្នល់). ៤ ក.ម. ៤៤០

ឃ្លាំងខាងជើង (៨០ ម៉ែត្រពីផ្លូវថ្នល់)... ៤ ក.ម. ៣០០

ព្រះពិធូ .................. ៤ ក.ម. ៤០០

ឃុំនិគមក្សន (៨០ ម៉ែត្រពីផ្លូវថ្នល់) .... ៤ ក.ម. ០០

មង្គលជិះ (២៤០ ម៉ែត្រពីផ្លូវថ្នល់) ....... ៥ ក.ម. ០០

ទ្វារជ័យ .................... ៥ ក.ម. ៥០០

ខ្លោងទ្វារខាងជើង .............. ៥ ក.ម. ២០០

## វង់តូប

អក្សរ "ក" សំគាល់ថាចេញពីខាងត្បូងប្រាសាទនគរវត្ត

អក្សរ "ខ" សំគាល់ថាចេញទៅខាងជើងតាមនគរធំ

ទៅសាយ (៥០ ម៉ែត្រពីផ្លូវថ្នល់) .. ក. ១០ ក.ម. ៩០០

ខ. – ៦ ក.ម.

គមាឧទ្ធ (១០០ ម៉ែត្រពីផ្លូវថ្នល់) .. ក. ១០ ក.ម. ៩០០

ខ. ៦ ក.ម.

តាកែវ (៩០ ម៉ែត្រ) ......... ក. ១០ ក.ម. ០៥០

ខ. ៧ ក.ម. ២០០

តាព្រហ្ម ខ្លោងទ្វារខាងលិច .... ក. ៨ ក.ម. ៩០០

ខ. ៨ ក.ម.

បន្ទាយក្តី ខ្លោងទ្វារខាងលិច .... ក. ៧ ក.ម. ៧០០

ខ. ៩ ក.ម. ៦៥០

បន្ទាយក្តី ខ្លោងទ្វារខាងកើត និងស្រះស្រង់ ក. ៦ ក.ម. ៨០០

ខ. ១០ក.ម. ៤០០

ប្រាសាទក្រវាញ (៩០ ម៉ែត្រពីផ្លូវថ្នល់) . ក. ៨ ក.ម. ៣០០

ខ. ១១ក.ម. ៦០០

## វង់ធំ

គិតពីមុខនាគរចេញទៅតាមទ្វារធំតាមខ្លោងទ្វារខាងជើង

ព្រះខ័ន ខ្លោងទ្វារខាងជើង(២០០ម៉ែត្រពីផ្លូវថ្នល់)៦ ក.ម. ៦០០

ព្រះខ័ន ខ្លោងទ្វារខាងកើត(២០០ម៉ែត្រពីផ្លូវថ្នល់)៧ ក.ម. ៦០០

នាគព័ន្ធ ..................... ១០ ក.ម. ២០០

ក្រោលគោ ...... (១២០ម៉ែត្រពីផ្លូវថ្នល់) ១០ ក.ម. ៣០

តាសោម ....... (៤០ ម៉ែត្រពីផ្លូវថ្នល់) ១២ ក.ម. ២០០

មេបុណ្យ ....... (៤០ ម៉ែត្រពីផ្លូវថ្នល់) ១៤ ក.ម. ៦០០

ប្រែរូប ........ (៣០ ម៉ែត្រពីផ្លូវថ្នល់) ១៨ ក.ម. ៩០០

ស្រះស្រង់និងខ្លោងទ្វារខាងកើតបន្ទាយក្តី ១៨ ក.ម. ២០០

## ពេលមើលប្រាសាទ

សម្រាប់អ្នកមើលដែលមានការប្រញាប់នោះ, មានពេលមើលតែ ១ ថ្ងៃ ត្រូវមើលប្រាសាទពីកន្លែង គឺពេលព្រឹកមើលនគរវត្តនិងបាយ័ន ។

ដល់ពេលល្ងាចសឹមជិះរថយន្តមើលតាមរង្វង់ធំ ចេញតាមខ្លោងទ្វារខាងជើងវិលមកដល់រង្វង់តូចមើលស្រះស្រង់ បន្ទាយក្តី តាព្រហ្ម (ឬមើលតាព្រហ្មហើយ) តមកតាកែវ ចូលមកតាមខ្លោងទ្វារជ័យ មើលតែប៉ុណ្ណោះក៏ហាក់ដូចជាបានមើលដោយសព្វគ្រប់ ព្រោះប្រាសាទនៅនគរមានសណ្ឋានទ្រង់ទ្រាយតែ ៣ បែបនេះជាគោលធំ ។

បើមានពេលមើលពីរថ្ងៃ ត្រូវចែកពេលមើលដូច្នេះ គឺ ថ្ងៃទី១, ពេលព្រឹកមើលបាយ័ន, ពេលល្ងាចមើលរង្វង់តូច ។ ថ្ងៃទី ២, ពេលព្រឹក, មើលរង្វង់ធំ, ព្រះខាន់, នាគព័ន្ធ, តាសោម, មេបុណ្យ, ប្រែរូប, ពេលល្ងាច, មើលនគរវត្ត ម៉ោង ៥ មើលបាខែង ។

សម្រាប់អ្នកមើល មិនមានការប្រញាប់ប្រញាល់ទេ ខ្ញុំសូមរំឭកកុំឲ្យមើលប្រាសាទច្រើនពេកក្នុងមួយថ្ងៃ, ដើម្បីសំចៃកម្លាំងមើលតទៅទៀត, ហើយត្រូវដើរមើលតាមចិត្តចុះ តែមើលបានព្រឹកៗពីព្រលឹមរាប់ពីម៉ោង ៦ ទៅដល់ម៉ោង៩ ព្រឹក ប្រាសាទណាដែលខ្ពស់ ត្រូវមើលក្នុងពេលត្រជាក់ស្រួលដូចបាខែង, តាកែវ, បាពួនជាដើម. ឯប្រាសាទដែលទាបៗគួរមើលថ្ងៃក៏បាន ដូចតាព្រហ្ម, បន្ទាយក្តីជាដើម ព្រោះប្រាសាទនេះមានព្រៃព្រឹក្សាធំខ្ពស់ មានមែកត្រសុំត្រសាយជួយឲ្យម្លប់ត្រជាក់គ្រាន់បើ, ហើយពេលល្ងាចម៉ោង ៥ ឬ ៦ គួរជិះរថយន្តតាមរង្វង់តូច

ឬតាមវង់ធំ ជាទីកំសាន្ត ក្នុងផ្លូវវែងឆ្ងុន ជាផ្លូវដើរផ្លូលផ្កាហោលក្លិនក្រអូបឈ្ងុយឈ្ងប់ល្ហើងល្ហើយពេញព្រៃព្រឹក្សា គួរឲ្យជាទីស្នេហាណាស់. ណាមួយសូរសំឡេងសត្វព្រៃកណ្តឹងទំនងបក្សីបក្សាយាសយំរំពងអឺងកង មុខគួរឲ្យស្រណោះគាទៀះអាល័យ ៗ

ដែលបង្ហាញដូច្នេះ សម្រាប់បណ្តាជនតាមធម្មតាទូទៅ, សម្រាប់អ្នកប្រាជ្ញ, អ្នកគវី, អ្នកវិសូករ, ត្រូវមើលតាមចិត្ត ទៅមើលត្រង់កន្លែងណាក៏បាន ដើម្បីពិនិត្យមើលក្បាច់របនា, សណ្ឋានទ្រង់ទ្រាយ ឬរឿងពង្សាវតាររឿងរ៉ាវដែលខ្លួនត្រូវការ ៗ

# បញ្ជីព្រះនាមស្ដេច, ទេវតា, ឈ្មោះប្រាសាទនិងទីស្ថាន និងពាក្យផ្សេងៗ(១)

## ព្រះនាមស្ដេច


អាទិត្យវង្ស ព្រះវររាជបុត្រព្រះបាទទេវវង្សអស្ចារ្យ, ៣
ឥន្ទ្រវរ្ម័ន ទី ១, . . . . . . . . . . ៩
ឦសានវរ្ម័ន, . . . . . . . . . . ៧
ឧទយាទិត្យវរ្ម័ន ទី ២, . . . . . . . ១១
កៅណ្ឌិន្យ . . . . . . . . . . . . ២
ជយវរ្ម័ន ទី ១, . . . . . . . . . . ៧
ជយវរ្ម័ន ទី ២, . . . . . . . . . . ៨
ជយវរ្ម័ន ទី ៣, . . . . . . . . . . ៩
ជយវរ្ម័ន ទី ៤, . . . . . . . . . . ១០
ជយវរ្ម័ន ទី ៨, . . . . . . . . . . ១០
ជយវរ្ម័ន ទី ៧ . . . . . . . . . . ១២
ទេវវង្សអស្ចារ្យ ព្រះបោរាណ, បឋមក្សត្រិយ៍ខ្មែរ, ៥
ណាកភាដវតី, នាងនាគ អគ្គមហេសីព្រះបាទទេវវង្សអស្ចារ្យ. . . . . . . . . ៥
ភវវរ្ម័ន ទី ១, . . . . . . . . . . ៧
មហេន្ទ្រវរ្ម័ន ចិត្រសេន, . . . . . . ៧
យសោវរ្ម័ន ទី ១, . . . . . . . . . ៩
រាជេន្ទ្រវរ្ម័ន, . . . . . . . . . . ១០
លីគោរ នាមក្សត្រិយ៍ប្រទេសមាលេស៊ី, ព្រះវររាជបិតាព្រះបាទសូរ្យវរ្ម័នទី ២, ១០
សៀវ-យី រាជទីប្រទេសហ្វូណន, . . . ២
សូរ្យវរ្ម័ន ទី ១, . . . . . . . . . ១០
សូរ្យវរ្ម័ន ទី ២, . . . . . . . . . ១១
ហរ្សវរ្ម័ន ទី ៣, . . . . . . . . . ១១
ហុន · ធៀន, . . . . . . . . . . ២


## ព្រះនាមអ្នកតាសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនា


អវលោកិតេស្វរៈ ពោធិសត្វលទ្ធិមហាយាន, . . . . ១៤
អាទិត្យៈ ព្រះអាទិត្យ ទេវតាសាសនាព្រាហ្មណ៍, . . . ២៦
ឥន្ទ្រៈ ព្រះឥន្ទ្រ ទេវតាសាសនាព្រាហ្មណ៍, . . . . . . . . ២៦
ឥស្វរៈ ព្រះឥស្វរ ទេវតាធំក្នុងសាសនាព្រាហ្មណ៍, . . . . . . ៧, ២៤, ២៥,
ឧមា ទេវីព្រះឥស្វរ, . . . . . . . . ២៥
ក្រឹស្ណៈ ទេវតាក្នុងសាសនាព្រាហ្មណ៍ អវតារនៃព្រះវិស្ណុ, . . . . . ២៤


១ លេខក្នុងទីនេះ សម្រាប់ចង្អុលទំព័រក្នុងសៀវភៅនេះ ។

គង្គា ទេពីព្រះឥសូរ, . . . . . . ២៨
គណេសៈ នរសព្រះឥសូរ. . . . . ២៦
ចន្ទ្រ: ព្រះចន្ទ្រ ទេពតាក្នុងសៈសនា-
ព្រាហ្មណ៍, . . . . . . . . ២៦
ទុគ៌ា ទេពីព្រះឥសូរ, . . . . . . ២៨
ទេវរាជ: នាមទេពតាដែលព្រះរាជា
សម័យនគរទ្រង់លើកតំកើងព្រះ
អង្គ, . . . . . . . . . . . ៩, ១៣
នន្ទិកេឝ: នាមព្រះឥសូរ ព្រោះព្រះឥសូរ
ជាស្តេចឈ្មោះពាហនៈគោក្នុងស្ថានសួគ៌, ២៨
បរ្វតី ទេពីព្រះឥសូរ, . . . ២៨

ប្រាជ្ញាបារមិតា ឈ្មោះទេពតានិងគម្ពីរ
លទ្ធិមហាយាន, . . . ១៤
ព្រហ្មៈ ព្រះព្រហ្ម, ទេពតាធំក្នុង
សាសនាព្រាហ្មណ៍, . . . . ២៤, ២៨
លក្ស្មី ទេពីព្រះវិស្ណុ, . . . . . . ២៨
លោកេស្វរៈ ពោធិសត្វលទ្ធិមហាយាន, ១៤
វិស្ណុ ទេពតាធំក្នុងសាសនា-
ព្រាហ្មណ៍, . . . . ៧, ២៤, ២៨
ស្រី ទេពីព្រះវិស្ណុ, . . . . . ២៨
សក្តិ ទេពីព្រះឥសូរ, . . . . . ២៨
ហរិហរៈ ទេពតាសម័យប្រទេសហ្វូណន,
ព្រះឥសូរនឹងព្រះវិស្ណុលាយគ្នា. ៧

## ប្រាសាទនិងស្ថាន

ឥន្ទ្របត្តបុរី បុរីព្រះបាទអាទិច្ចវង្ស, . . . ៣
គ្លាសបុរៈ បុរីព្រះបាទគ្លាសេវរ្ម័ន
(សម្បូណ៌ព្រៃគុក) . . . . ៧
ប៊ិន-ឡូ ពាក្យខ្មែរក្លាយទៅតាមភាសាចិន
គឺកម្ពុជា, . . . . . . . ២៧
ទ្វារវតី ក្រុងសៀមបុរាណ, . . . . ១១, ១២
យសោធរបុរៈ បុរីទ្រង់ព្រះនាមយស(នគរធំ). ៩

វិជ័យ ក្រុងប្រទេសចាម, . . . . . ១២
វៀងចន្ទន៍ ក្រុងលាវ, . . . . . . . . ១២
ស្រីវិជ័យ ស្រុកជ្វាបុរាណ, . . . . . ៨
ព្យាធបុរៈ ក្រុងខ្មែរបុរាណសម័យហ្វូណន ៣
ហរិហរាល័យៈ ស្ថានព្រះហរិហរៈ(បាគង), ៩
ហ្វូណន ក្រុងខ្មែរបុរាណ . . . ២, ៣, ៥

## ពាក្យសំស្ក្រឹត

អវតារៈ កិរិយាច្យុតចុះមកចាប់កំណើត, ២៤
អារ្យធម៌ អារ្យធម៌, . . . . . . . ៣

កៅណ្ឌិន្យៈ ព្រាហ្មណ៍ម្នាក់នៅប្រទេសឥណ្ឌា
មកប្រទេសហ្វូណនមុនដំបូង, ២

គោបុរៈ ខ្លោងទ្វារ, . . . . ៩៣
គាណ្ឌារៈ ល្ហោចក្នុងស្ថានសួគ៌, ២៨
ត្រៃវិក្រមៈ កិរិយាឈានទៅ៣ជំហាននៃព្រះវិស្ណុ កាលច្បាំងក្នុងត្រៃភព, ២៦
ធម៌សាលា សាលាធម៌ ដែលព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់សាងតាមមាគ៌ាជាបួជនីយស្ថាននៃអ្នកដំណើរ, ១៦
បូជនីយស្ថាន ស្ថានជាទីគោរពបូជា, ១
ប្រវត្តិការ សេចក្ដីភយការ, . . . . ៣១
ប្រវត្តិសាស្ត្រ វិជ្ជាពង្សាវតារ, . . . ៣
ពង្សាវតារ រឿងរ៉ាវតាមលំដាប់ត្រកូល, ៣
ភូមិសាស្ត្រ វិជ្ជាផែនដី, . . . . . ១
មហាយាន ពុទ្ធសាសនាប៉ែកខាងជើង, ១៤, ២៩
រាពណ៍ យក្សជាគូសត្រូវនឹងព្រះរាមក្នុងរឿងរាមកេរ្តិ៍, . . . ២៤
រាមៈ ក្សត្រិយ៍ទេវវង្សជាគូសត្រូវនឹងរាពណ៍, . . . . . . . . ២៤
វ្រ្តៈ ខ្ទះ, . . . . . . . . . ២៦
សតវត្សរ៍ (សតវស្សៈ) មួយរយឆ្នាំ
សីតា ទេវីព្រះរាម ក្នុងរឿងរាមកេរ្តិ៍, ២៤
សម្ពង្សមនោរស ការផ្សំផ្គុំ, វិវាហមង្គល, ៣
ហីនយាន ពុទ្ធសាសនាប៉ែកខាងត្បូង, ២១

## ពាក្យបាលី

កិត្តិនាម កេរ្តិ៍ឈ្មោះ, . . . . . . . ១៥
កិត្តិយស កេរ្តិ៍យស, . . . . . . ១៥
កោណ្ឌញ្ញ ព្រាហ្មណ៍ម្នាក់ជាតិឥណ្ឌាមកកាន់ប្រទេសខ្មែរមុនដំបូង, . . . ២
បុព្វបុរស> បុព្វបុរិស បុរសដើម, . . ៩
បច្ឆាជនតាជន ជនកើតមកក្នុងកាលខាងក្រោយ, . . . . . . ៦
យុវជន ជនកំពុងនៅក្នុងបឋមវ័យ, . . ១
វង្សសាសនោបាយ ឧបាយថែរក្សាជាតិ, ៨
វង្សបុរស>វង្សបុរិស បុរសថែរក្សាជាតិ, មន្ត្រី, ១២
រាជធានី ក្រុង, . . . . . . . . ៧, ៨
វីរបុរស> វីរបុរិស បុរសក្លៀវក្លា, បុរសមានព្យាយាម, បុរសប្រសើរ, ១២

## ពាក្យបរទេស

គ. កូរ៉ាល់ រេមូសាត់ G. Coral Rémusat. . . . . . . ៣
គ. សឺដេស G. Cœdès, . . . . ២៣
ជ. កូម៉ៃយ៍ J. Commaille, ១៩, ៣០

ប. ស៊ីវ្រើយ P. Chevreuil, . . ២៨
ហ. ឌិក្កាសុង H. Dickason, . . ក.
ឲរុប Europe, . . . ២៧
ប. គាប្រិយែល ឌឺ សង់តោ អង់តោ
និយោ P. Gabriel
de Santo Antonio, . . ២៨
ហ. គោលូបែវ H. Goloubew, ៤៨
ឥណ្ឌូណេសៀង Indonésiens, ១
ស. ការប៉ឺឡែស S. Karpelès, . . ១
ហ. ម៉ារសាល់ H. Marchal, . . ០
ហ. មូហុត H. Mouhut, ក, ២៨
ប. ប៉ែល្លិយោត៍ P. Pelliot, . . . ២
ប. រីបាដេនៃរា P. Ribadeneyra, ២៧
ចៀវ-តា-ក្វាន់ Tchiêu-ta-Kouan, ១៧
ល. ហ្វីណូត៍ L. Finot, . . . ១៣

# បញ្ជីរឿង


| | ទំព័រ |
|---|---|
| ពាក្យប្រារព្ធ | ក |
| វគ្គទី ១ | ៤ |
| គោលពង្សាវតារខ្មែរបុរាណដោយសង្ខេប | ៥ |
| ព្រះរាជអង្គរះសម័យនគរ | ៦ |
| បញ្ជីរាយព្រះនាមស្តេចសម័យនគរ | ១៩ |
| លទ្ធិសាសនា | ២១ |
| ព្រះពុទ្ធសាសនា | ២១ |
| លទ្ធិមហាយាន | ២២ |
| លទ្ធិហីនយាន | ២៣ |
| សាសនាព្រាហ្មណ៍ | ២៣ |
| កេរ្តិ៍ឈ្មោះនគរ | ២៧ |
| សៀវភៅនគរ | ២៧ |
| អំពីការរៀបចំនគរ | ២៩ |
| ការរចនាខ្មែរបែបផ្សេងៗ តាមលំដាប់ប្រវត្តិការ | ៣១ |
| វគ្គទី ២ | ៤១ |
| គមនាគមន៍ | ៤១ |
| ការទស្សនានគរ | ៤២ |
| ការមើលបន្ទាយចែកចាត់ជា ២ ផ្នែក | ៤៣ |
| ចំងាយប្រាសាទមួយៗរាប់ពីមុខមាត់ទៅ | ៤៣ |
| ពេលមើលប្រាសាទ | ៤៨ |

# បញ្ជីសៀវភៅដែលព្រះរាជបណ្ណាល័យបោះពុម្ពផ្សាយ

| | | |
|---|---|---|
| ព្រះត្រៃបិដក (បាលីនិងប្រែ) ១ ចប់ | ចំនួន ១០០ | សៀវភៅថ្លៃ ២៥០១,០០ |
| ព្រះចន្ទមកែវ | ១ | សៀវភៅថ្លៃ ០១,១០ |
| អក្ខរោសកថា | — | ០,០៥ |
| អនត្តលក្ខណសូត្រ | — | ០,៦០ |
| អភិធម្មត្ថសង្គហ បាឡី | — | ០,៧១ |
| អភិធម្មត្ថសង្គហ សម្រាយ | — | ០,៩០ |
| អរិយសច្ចកថា | — | ០,៨០ |
| អំពីព្រះពុទ្ធសាសនា | — | ១,៨១ |
| អំពីប្រាសាទខ្ទះនៅនគរ | — | ០,២៥ |
| កាលាមសូត្រនិងបរាភវសូត្រ | — | ០,១៥ |
| គិរិមានន្ទសូត្រ | — | ០,១៥ |
| ច្បាប់ថ្មី | — | ០,១៥ |
| ញាណកថា | — | ០,១០ |
| ដំណាលពុទ្ធចេតិយ | — | ០,៩១ |
| ធម្មប្បទីប | — | ០,២០ |
| ភាណវារ | — | ១,៨០ |
| ទានោបមាទិកថា | — | ០,០៤ |
| បករណវិសេសោ | — | ១,០០ |
| បាយាសិរាជញ្ញសូត្រ | — | ០,០៤ |
| ពាក្យកាព្យក្រមង៉ុយ | — | ០,០៧ |
| មនោបុញ្ញកថា | — | ០,១៥ |
| មរណានុស្សតិ | — | ០,២១ |
| មាតាបិតុឧបដ្ឋានកថា | — | ០,៣៥ |

| | | |
|---|---|---|
| ១០០ គាថា | ១ សៀវភៅថ្លៃ | ០រ, ១០ |
| វិជ្ជាចរណកថា | — | ០, ៣០ |
| វុត្តោទយ | — | ០, ២៥ |
| សប្បុរិសធម៌ | — | ០, ០៥ |
| សត្តបរិត្តនិងទ្វាទសបរិត្ត | — | ០, ៥០ |
| សីមាវិនិច្ឆ័យ | — | ០, ១០ |
| សុរិយាត្រទៀងស័ក | — | ០, ៣០ |
| សុភាសិតប្បកាសិនី | — | ០, ៤០ |
| សេចក្ដីជាស់តឿន | — | ០, ០៦ |
| បច្ចុគណនាវិធី និងប័ក្ខសង្ខេប | — | ០, ៣០ |
| សទ្ទន្ធមាលា | — | ១, ២៥ |
| សីលនិទ្ទេស | — | ០, ៨០ |
| សារទេសនា | — | ០, ០៧ |
| អក្សរខ្មែរជាប់និងរូបសត្វ | — | ០, ២០ |
| ប្រស្នាវិនយបិដកសង្ខេប | — | ១, ០០ |
| រតនប្បកា | — | ០, ៤០ |
| វិធីបង្ការរោគ | — | ០, ០៣ |
| ឧភទបាតិមោក្ខ | — | ០, ៧០ |
| គោលសមថកម្មដ្ឋាន | — | ០, ១៥ |
| ពុទ្ធមាមកវិធី (បែបធម្មយុត្តិ) | — | ០, ៤០ |
| សាមណេរវិន័យ | — | ០, ៤០ |
| បញ្ចអភិណ្ហប្បច្ចវេក្ខណៈ | — | ០, ១០ |
| សង្គាលោភិទសូត្រ | — | ០, ៣០ |
| អនុមោទនាវិធី | — | ០, ៥០ |
| ព្រះត្រៃលក្ខណ៍ និងសង្វេគវត្ថុ | — | ០, ១០ |

| | | | |
|---|---|---|---|
| ពាក្យកាព្យថ្លៃងរឿងពុទ្ធប្រវត្តិ ................ | ១ សៀវភៅថ្លៃ | | ០ រ. ១៥ . |
| វេសសន្ត្រ ................ | | — | ០; ១៨ |
| នានាជាតក ................ | | — | ០, ៦០ |
| សតិបដ្ឋានសូត្រ ................ | | — | ០, ៥០ |
| អវសានកិច្ច ................ | | — | ០, ៤៥ |
| វិជ្ជាប្រាំបីប្រការ ................ | | — | ០, ៦៥ |
| រឿងកាកី ................ | | — | ០, ២៥ |
| ទសបារមីកថា ................ | | — | ០, ៧៥ |
| ជាតិមោក្ខសង្ខេប ................ | | — | ០, ៤០ |
| សៀវភៅយានជំនិះខ្មែរ ................ | | — | ០, ៤៥ |
| វេជ្ជសារ ................ | | — | ០, ៦០ |
| ទានកថា ................ | | — | ០, ៦០ |
| វេយ្យាករណ៍សំស្ក្រឹត ................ | | — | ០, ៦៥ |
| សិលាចារឹកនគរវត្ត ................ | | — | ១, ០១ |
| ដយវ្ល៊ង ទី ៣ (អក្សរខ្មែរ) ................ | | — | ០, ១០ |
| " ០ " (អក្សរបារាំង) ................ | | — | ០, ៣១ |
| បទានុក្រមភាមកើ ................ | | — | ០, ០៨ |
| ភាមកើ លក់ភាយ ................ | | — | ០, ១០ |
| " លក់រួម ................ | ១៣ | — | ១, ៥០ |
| ឧស្សាវត្តី (១ ឆ្នាំ) ................ | ២៤ | — | ៦, ៥០ |
| សាសនកិច្ចានុក្រម (១ ឆ្នាំ) ................ | ១២ | — | ១, ៥០ |
| វចនានុក្រមខ្មែរ ក្របរឹង ................ | ១ | — | ៩, ៥០ |
| " ក្របទន់ ................ | | — | ៣, ០១ |
| គិហិបដិបត្តិសង្ខេប ................ | | — | ០, ១៥ |
| គិហិបដិបត្តិពិស្តារ ................ | | — | ០, ៥០ |

| | | | |
|---|---|---|---|
| បញ្ញាទន្ទេញសង្ខេប | .................. | ១ សៀវភៅថ្លៃ | ០រ, ៥៨ |
| សុភាទោសកថា | .................. | — | ០, ១០ |
| មិត្តទេសក៍ធគរ | ភាគទី ១ .................. | — | ០, ៤៥ |
| " | ភាគទី ២ .................. | — | ០, ០០ |
| ក្រុងសុភមិត្រ | ភាគទី ១ .................. | — | ០, ០០ |
| " | ភាគទី ២ .................. | — | ០, ០០ |
| " | ភាគទី ៣ .................. | — | ០, ០០ |
| មិលិន្ទបញ្ហា | ភាគទី ១ .................. | — | ០, ៥០ |
| " | ភាគទី ២ .................. | — | ០, ៧០ |
| មង្គលត្ថទីបនី | ភាគទី ១ .................. | — | ២, ០០ |
| " | ភាគទី ២ .................. | — | ២, ៥០ |
| " | ភាគទី ៣ .................. | — | ៣, ០០ |
| " | ភាគទី ៤ .................. | — | ០, ០០ |
| កច្ចាយនូបត្ថម្ភក | ភាគទី ១ .................. | — | ០, ៨០ |
| " " | ភាគទី ២ .................. | — | ១, ៤០ |
| ធម្មបទដ្ឋកថា | ភាគទី ១ .................. | — | ០, ៩០ |
| " | តាំងពីភាគទី ២ ដល់ភាគទី ៨ .......... | -- | ០, ៦៥ |
| គតិលោក | ភាគទី ១ .................. | — | ០, ១៥ |
| " | ភាគទី ២-៣ .................. | — | ០, ១២ |
| " | ភាគទី ៤-៥-៦-៧-៨-៩ .......... | — | ០, ២៥ |
| រឿង ១ ពាន់ ១ យប់ | ភាគទី ១ .................. | — | ១, ១២ |
| " | ភាគទី ២-៣-៤-៥-៦-៧ .......... | — | ០, ២៥ |

# រូបផ្តិតពុម្ពផ្សេងៗ

| | | | |
|---|---|---|---|
| ព្រះពុទ្ធរូបមានអគ្គសាវកគូ (រូបតាណាំ) | ១ សន្លឹកថ្លៃ | | ១រ, ០៥ |
| " ចិញ្ចាន | | — | ០, ០៥ |
| " ៣ ព្រះអង្គ | | — | ០, ០៥ |
| " មានព្រះឥន្ទ្រនិងព្រះព្រហ្មឈរអមៗ | | — | ០, ០៥ |
| ព្រះរូបព្រះបាទសម្ដេច ព្រះស៊ីសុវត្ថិមុនីវង្ស ក្រដាសរឹង | | — | ០, ១៥ |
| " " ក្រដាសទន់ | | — | ០, ១០ |
| " ព្រះស៊ីសុវត្ថិ | | — | ០, ២០ |
| " ព្រះចៅក្រុងកម្ពុជា ៦ ព្រះអង្គ | | — | ០, ៤០ |
| រូបព្រះពុទ្ធបាទ | | — | ០, ០៥ |
| រូបព្រះឥន្ទ្រឈរសំពត់រឿងពុទ្ធប្រវត្តិ | | — | ០, ០៥ |
| រូបវេស្សន្តរជាតក ១៣ សន្លឹក | | — | ០, ០៦ |
| រូបតេមិយជាតក | ១០ | — | ០, ៤៥ |
| " មហាជនកជាតក | ១០ | — | ០, ២៥ |
| " សុវណ្ណសាមជាតក | ១០ | — | ០, ២៥ |
| ប្រក្រតិទិនឆ្នាំថ្មី (បន្ទះ) | ១ | — | ០, ២០ |
| " (បក) | | — | ០, ៦៥ |

# មគ្គុទ្ទេសក៍ឆតច

## ភាគ ២



# មង្គលត្ថទីបនី

## ភាគទី ២


អាចារ្យ ប៉ាង-ខាត់ គ្រូបង្រៀនសំស្ក្រឹត
នៅសាលាបាលីជាន់ខ្ពស់ រៀបរៀង


គណៈរដ្ឋមន្ត្រីនិងសម្តេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ


បោះពុម្ពលើកទី ១

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព. ស. ២៤៨៤

# MAGGUDDESAKANAGARA

(Guide d'Angkor)

2ème Partie

Les monuments

par

L'Achar PANG-KHAT Professeur de Sanscrit,

a l'École Supérieure de Pali

Cette publication a reçu l'approbation du Conseil des Ministres
et des deux Chefs de Sectes

1ère Édition

PHNOM-PENH
Éditions de l'Institut Bouddhique
1941



ព្រះសិរព្រះពុទ្ធរូប មានព្រះភក្ត្រញញឹម
ការរចនាបែបនគរវត្ត រវាង ព. ស. ១.៦៥០
(តាមរូបថត ស.ប.ប.)

## វគ្គទី ៣

## ប្រាសាទនគរវត្ត

នគរវត្ត ជាប្រាសាទមួយល្អជាងគេ បណ្ដាប្រាសាទទាំងឡាយនៅនគរ គេកសាងក្នុងសម័យនៃវិទ្យាសាស្ត្រកំពុងចំរើនបរិបូណ៌ ព្រោះមានទ្រង់ទ្រាយល្អនិងទ្រង់ស័ក្តិសមនៃភាពកង លេចស្រស់ឡើងក្នុងកាលគេចូលទៅជិត ហើយគេអាចយកទៅខ្នាតនឹងវិស្វកម្មនៃប្រទេសអស្ដង្គតបាន, ប្រាសាទនេះ មានខ្នាតទំរង់ទ្រង់ទ្រាយនិងលំអដ៏លើស ដូចនៅក្នុងរាជវង្សល្វីទី ១៤ នៃប្រទេសបារាំងសែស, ក្នុងរាជវង្សនេះ មានការលេងសួនដាំផ្កាលេចស្មៅ ស្រះ សណ្ឋានល្អមើលពីចម្ងាយ និងមានគាំទខ្លួលាយៗ ។

ប្រាសាទនគរវត្តនេះ ព្រះបាទសូរ្យវរ្ម័នទី២ ស្ដេចកសាង ក្នុងរវាងសតវត្សរ៍ទី ១៧ នៃពុទ្ធសករាជ (ព.ស. ១៦៩៣?) ដើម្បីឧទ្ទិសថ្វាយព្រះវិស្ណុ, លុះដល់ស្ដេចទិវង្គតទៅ គេថ្វាយព្រះនាមព្រះអង្គថា ព្រះបរម-វិស្ណុលោក ។ មានមនុស្សជាច្រើនយល់ថា ប្រាសាទនេះសម្រាប់ស្ដេចគង់, ប៉ុន្តែបើតាមពិនិត្យមើលទ្រង់ទ្រាយបន្ទប់ហុចមកនាំឲ្យយល់ថា ស្ដេចមិនទ្រង់គង់នៅទីនេះទេ, បើជាមន្ទីរនៃសាសនាឃើញសមជាង; ប្រស្នានេះអាចសម្រេចបានថា ជាចេតិយ សម្រាប់បញ្ចុះព្រះអដ្ឋិនៃ

ព្រះកេដាធិកដ, តាមសេចក្ដីរាយការណ៍នៃអ្នកប្រវត្តិសាស្ត្រចិនម្នាក់ឈ្មោះ ចៀវ តាក្វាន់ (Tchéou Takouan) គេហៅថាទេពិយ លូ-ប៉ាន់ (Lou-Pan); ប៉ុន្តែលោក សឺដែស លោកសរសេរថា: "ប្រាសាទនគរវត្តនេះ គេឧទ្ទិសថ្វាយដល់ព្រះវិស្ណុ" ។

ប្រាសាទនគរវត្ត ស្ថិតនៅខាងត្បូងប្រាសាទនគរធំ ចំនួន១៨០០ ម៉ែត្រ, បែរមុខទៅកាន់ទិសបស្ចិម មានផ្លូវចូលពីខាងលិចខុសពីច្បាប់កសាងប្រាសាទទាំងពួង; តាមលោក ហ. ម៉ារសាល លោកសរសេរទុកក្នុងសៀវភៅលោកថា: "ព្រោះមកពីមានស្ទឹងនៅខាងកើត ហើយប្រាសាទនេះស្ថិតនៅចំផ្លូវធំទៅកាន់នគរធំផង" ។

បើតាមទំនៀមខ្មែរថា: ការកប់ខ្មោចឬដម្កល់ខ្មោចលើជើងថ្កលសម្រាប់ធ្វើឈាបនកិច្ច គេច្រើនដាក់ក្បាលបែរទៅកាន់ទិសខាងលិច បែរមុខមកខាងកើតទាំងអស់, ឯប្រាសាទដែលគេឧទ្ទិសថ្វាយព្រះបរមវិស្ណុលោក ក៏ត្រូវបែរមុខទៅកាន់ទិសបស្ចិមដូចគ្នា (១) ។ ប្រាសាទនេះ មានស្រះបោក្ខរណីជីកទឹកជុំវិញប្រាង្គខ្លួនប្រាសាទ ចំពោះក្រាលថ្មដាក់ក្បាច់ រៀបជាថ្នាក់ព័ទ្ធជុំវិញទាំង ៤ ទិស បណ្ដោយ ១៥០០ ម៉ែត្រ ពីខាងកើតទៅខាងលិច, ទទឹង ១៣០០ ម៉ែត្រ ពីខាងជើងទៅខាងត្បូង; តពីស្រះបន្តិចមានទីដី

---

១ ព្រោះគេឧទ្ទិសថ្វាយព្រះបាទសូរ្យវរ្ម័ន (បរមវិស្ណុលោក) ដែលទ្រង់ទិវង្គតទៅហើយ តាមទំនៀម មនុស្សកើតឡើងហើយ ត្រូវស្លាប់លិចបាត់ទៅវិញ ដូចព្រះអាទិត្យរះឡើងហើយ លិចបាត់ទៅទិសបស្ចិមវិញដូច្នោះ ។



ភាពប្រាសាទអង្គរវត្តទាំងមូល
ការរចនាបែបអង្គរវត្ត រវាង គ. ស. ១.៦៥០
(តាមរូបថត ព. ស. ប.)

កបស្ពា បានដល់ទៅកំពែងខាងក្រៅ ធ្វើពីថ្មបាយក្រៀមព័ទ្ធជុំវិញ, បណ្ដោយប្រហែល ១០០០ ម៉ែត្រ, ទទឹង៨១៥ម៉ែត្រ ៗ មានតែផ្លូវធំ១ ក្រាលថ្ម បណ្ដោយ ២០០ ម៉ែត្រ ចូលពីខាងទិសបស្ចិម កាត់ឆ្លងស្រះ ទៅកាន់គោបុរៈ ( ខ្លោងទ្វារធំ ) នៃកំពែងខាងក្រៅ ខាងជើងនឹងខាងត្បូង មិនមានផ្លូវចូលទៅទេ, ខាងកើតមានទំនប់ដីកាត់ចូលទៅកំពែងខាងក្រៅ ៗ នៅទិសខាងជើង,. ខាងកើត, ខាងត្បូង មានគោបុរៈ (ខ្លោងទ្វារ) ជាតូប្រាសាទ មានកំពូលខ្ពស់ឡើង តែក្បាច់បែកខ្លះ គេធ្វើមិនទាន់ហើយស្រេច ឯគោបុរៈ (ខ្លោងទ្វារ)ទាំង ៣ ទិសនេះ មានផ្លូវចូលទៅដល់ប្រាសាទធំកណ្ដាលបាន ៗ ស្ពានថ្មធំចូលពីទិសបស្ចិម កាត់ឆ្លងស្រះបោក្ខរណីហួតទៅដល់ទ្វារធំខាងលិច មានបង្កាន់ដៃនាគប្រកបសីហៈធំសំបើម ងើយមុខស្ងើន, តែឥឡូវនេះ បាក់បែកស្ទើរតែអស់ហើយ ៗ កាលណាគេចូលទៅដល់ខ្លោងទ្វារធំខាងលិច ទ្រង់ទ្រាយរុង-រឿងឆើតឆាយ, ទ្រង់ទ្រាយមាំទាំ, ទាំងតេជះនៃប្រាសាទនេះ អាចធ្វើឲ្យអ្នកដំណើរស្ញប់ស្ញែងក្នុងចិត្ត ៗ ទិសខាងលិចនេះ មានរោងរងមួយវែង មានដំបូលជាប់គ្នា ប្រដាប់ដោយគោបុរៈ៣ មានដំណើរ ៣ ឡើងទៅ ដំណើរកណ្ដាលលយមកខាងមុខបន្តិច, មានរូបវិស្ណុពីរនៅខាងក្នុង អមសងខាងទ្វារកណ្ដាលនោះ, នៅគោបុរៈមួយៗ សុទ្ធតែមានកំពូលខ្ពស់ឡើង, ខ្លោងទ្វារធំកណ្ដាលកំពូលខ្ពស់ជាងគេ; នៅចុងរោងទងទាំងសង-

ខាង មានទ្វារដំរីពីរម្ខាងទៀតសម្រាប់ពាហនៈផ្សេងៗនៃព្រះរាជដំណើរ ។ សព្វថ្ងៃនេះ, គេឡើងចុះតាមគោបុរៈធំកណ្ដាល ព្រោះគោបុរៈនេះចំទៅលើប្រាសាទធំ, នៅជញ្ជាំងរោងទងមានចម្លាក់ផ្កាវង់មូលៗស្ដើងៗជារបនាបិទ និងរូបយក្ស, ទេពតាចេញឆាំ ឬ ជិះគោ, សេះ, ដំរី ។ នៅជ្រុងមានរូបស្រីអប្សរាមានផ្ទៃសក់របនាល្អប្លែកគួរចាប់ចិត្ត ។ ឈប់មើលមួយស្របក់ហើយ, ឈានដើរចុះតាមជណ្ដើរទៅកាន់លានខាងកើតបន្តិច ហើយឈប់ងាកមុខបែរមកមើលខាងក្រោយវិញ គេនឹងឃើញរូបស្រីអប្សរាបែបទន់ភ្លន់, បញ្ចាក់សរសើរ, អ្នកជិះលើសត្វផ្សេងៗនៅជញ្ជាំង និងទន់ទ្រាយពាំងមូលគួរឲ្យគាត់ជញ្ជក់មាត់មិនបាត់ ៗ តទៅ, ត្រូវដើរទៅតាមផ្លូវក្រាលថ្មនោះប្រហែល ៣៥០ ម៉ែត្រ គេឃើញមានធម្មមន្ទីរពីរ, វត្តពីរ និងស្រះពីរទៀត; ដល់ទៅប្រាសាទនគរវត្ត មានចំលានខ្ពស់ ប្រ-កបដោយជណ្ដើរបង្កាន់ដៃនាគ, មុខនាគនិងសីហៈសំបើមឈរក្រអឹត, មានជណ្ដើរទៅទិសខាងជើងខាងត្បូងនិងខាងលិច, ចំលានចេញមកខាងក្រៅនេះ សម្រាប់ជាទីទទួលនៃនាម៉ឺនសព្វមុខមន្ត្រី ឬទ្រង់តក្បួនហែដែលមានពិធីបុណ្យផ្សេងៗ ។ ដើរបន្តិចទៅនឹងដល់ទៅទ្វារធំនៃប្រាសាទ, ត្រង់នេះ គេធ្វើជាគូប្រាសាទមានដំបូលខ្ពស់បន្តិចឡើង ហើយមានដំបូលជាយចេញមកខាងលិច, នៅហោជាងមានក្បាច់របនាសាសនាព្រាហ្មណ៍ ។



ភាគប្រាសាទនគរវត្ត មើលពីទិសនិរតី
ការរចនាបែបនគរវត្ត រវាង ព. ស. ១.៦៥០

(តាមរូបថត ព. ស. ប.)

អ្នកមើល, កាលណាមកដល់កន្លែងនេះ ក៏នឹកស្ញប់ស្ញែងយ៉ាងសែនរន្ធត់ចិត្ត, ណាមួយនឹកស្តាយ ព្រោះរូបនាគបាក់ដៃ, សីហៈតូចធំជាគ្រឿងលំអ បាក់បែកបាត់អស់នាំឲ្យបាត់លំអជាច្រើន ។ ការមើលប្រាសាទនេះ, សូមរំឭកថា ត្រូវមើលពេលព្រឹកនឹងពេលល្ងាច ពេលថ្ងៃក្តៅមើលទៅលើដុំថ្ម ចាំងស្រាំងភ្នែក, ហើយដើរមើលពីឆ្វេងទៅស្តាំ ព្រោះការបន្ទាំងអស់ សុទ្ធតែមានចំនងពីឆ្វេងទៅស្តាំ ឲ្យសមជាបទតិយ គេឧទ្ទិសថ្វាយព្រះបរមវិស្ណុលោក ។

នគរវត្ត មាន ៣ ជាន់ គឺ ជាន់ទី ១ ជាន់ទី ២ នឹងជាន់ទី ៣ ។ នៅជ្រុងអនុទិសគ្រប់ជាន់ទាំងបីនេះ សុទ្ធតែមានកំពូលខ្ពស់ស្រួចជាតួប្រាង្គ មានជណ្តើរពីរបែកបរដោយសីហៈ ចុះទៅកាន់ទិសរបស់ខ្លួនគ្រប់ៗជ្រុង, នៅជាន់ទី ៣ ខាងលើឈ្មោះ បាកាន មានកំពូលខ្ពស់ស្រួចទៅកាន់អាកាស មើលពីចម្ងាយឃើញខ្ពស់ធំស្កឹមស្កៃដូចភ្នំព្រះសុមេរុ ឃើញតែកំពូលច្រើនត្រាងដូចវិមានអណ្តែត ។ នៅថ្នាក់ទី ១ ត្រង់មាត់ទ្វារធំ មានផ្លូវបែកជា ៣ ផ្នែក ផ្លូវធំកណ្តាលសម្រាប់ឡើងទៅថ្នាក់ទី ២ ផ្លូវមួយបែកទៅខាងត្បូង មួយបែកទៅខាងជើង ។ នៅជញ្ជាំងព័ទ្ធជុំវិញនៃថ្នាក់ទី ១ នេះ សុទ្ធតែមានរូបចម្លាក់រំលេចរឿងក៏នឹងសិលាចារឹកផ្សេងៗ និយាយពីរឿងព្រេងនៃសាសនាព្រាហ្មណ៍ខ្លះ, រឿងពង្សាវតារខ្មែរជាន់នគរវត្តខ្លះ ដូចមានសេចក្តីសង្ខេបតទៅនេះ ។

## រោងទងខាងលិច ជញ្ជាំងខាងត្បូង (ពីខាងជើងទៅខាងត្បូង)

និយាយរឿងមហាភារតៈ ត្រង់ចម្បាំងបាណ្ឌវៈនិងកោរវៈ ។ កងទ័ពកោរវៈយាត្រាទ័ពចេញពីខាងជើង, កងទ័ពបាណ្ឌវៈពីខាងត្បូង; កងទ័ពទាំងពីរផ្នែកនេះដើរលុកចូលទៅប្រទះគ្នា, មានពលថ្មើរជើងកាន់អាវុធយុទ្ធភណ្ឌ ខែល, ត្រីសូល៍, ធ្នូ, សរ, មេទ័ពជិះរទេះ, ជិះសេះ, ជិះដំរី, មេទ័ពធំយឺតកៅវណ្ឌធ្នូសរបែបយ៉ាងស្ទាត់ជំនាញ, ទាំមាត់ក្រអឺត, សេនាពាហនត្រូវសរ របួសស្លាប់ដេកដួលរនេល, មេទ័ពធំខាងកោរវៈ ឈ្មោះ ភីស្មៈ ត្រូវសរស៊ុសសព្វពេញខ្លួន ទាំមាត់ក្រអឺត មិនគក់ស្លុត ពេញជាជាតិអ្នកចម្បាំង មានញាតិសន្តានហោមកោមជាបរិវារ; ពាក់កណ្តាលកេងទង កងទ័ពទាំងពីរចល់ប្រយុទ្ធគ្នាយ៉ាងសាហ័ស សេនាពាហនទាំងពីរផ្នែក មើលទៅឃើញមានការស្ទាត់ជំនាញជាញជ័យក្នុងយុទ្ធវិធី ពេញទំជាជាតិអ្នកចម្បាំង ។ ឯកងទ័ពបាណ្ឌវៈឃើញមេទ័ពឈ្មោះ អជ៌ុនៈ ជិះលើរទេះ មានក្រិស្នៈជាប្រធានជាមគ្គនាយក រឿងនេះមាននៅក្នុងគម្ពីរភគវទ្គីតៈ ជារឿងព្រេងក្នុងប្រទេសឥណ្ឌា មុនសម័យពុទ្ធកាល ។

## នៅជ្រុងទិសនិរតី កាត់ជាក្រឡាបត្រង្គ

មានរូបចម្លាក់យ៉ាងសំខាន់ និយាយរឿងផ្សេងៗ មានដានខ្លះទឹកភ្លៀងលេចមកលើសៅខូចអស់ ៗ ត្រង់នេះនៅចែកជាបួនដាន គឺ:



កាលព្រះរាមសម្លាប់យក្សមារីច ដែលក្លែងខ្លួនជាម្រឹគ ក្នុងរឿងរាមកេរ្តិ៍ នៅជ្រុងនិរតីប្រាសាទអង្គរវត្ត,
ការរចនាបែបអង្គរវត្ត រវាង ព. ស. ១.៦៨០

(តាមរូបថត ស. ប. ប.)

១. ជាន់ខាងជើង, ជញ្ជាំងខាងកើត និយាយកាលព្រះវិស្ណុអវតារជាក្រឹស្ណៈ ជាទេពតាគង្វាលគោជាមួយនឹងនាងគោបីនឹងហ្វូងសត្វ, ថ្ងៃនកាលកំពុងទ្រភ្នំគោវទ្ធនៈ ដើម្បីបាំងទឹកភ្លៀងកុំឲ្យទឹកហ្វូងសត្វ ។ ជញ្ជាំងខាងលិច ត្រង់លើបង្អួច, និយាយរឿងកូរសមុទ្រទឹកដោះ ថ្ងៃនត្រង់ទេព-តានឹងអសុរកំពុងទាញនាគកូរសមុទ្រ ។

២. ជាន់ខាងត្បូង, ជញ្ជាំងខាងកើតភាគខាងលើ និយាយរឿងសុគ្រីពនឹងពាលិទច្បាំងគ្នា, ថ្ងៃនត្រង់ព្រះរាមថ្ងៃនសរត្រូវពាលិទស្លាប់ ។ ជញ្ជាំងខាងលិចភាគខាងលើ និយាយពីព្រះឥសូរក្លែងជាព្រះឥសីគង់លើភ្នំ ប្រដាប់ដោយផ្គាំ កំពុងអង្គុយសមាធិ, នាងឧមាតែងខ្លួនជាក្សត្រិយ៍អង្គុយនៅជិតខាង; កាមៈក្រោម, ថ្ងៃនកាលទេពតាឈ្មោះកាមៈ មានសេចក្តីប្រែណន លើកកោងធ្នូសរផ្កាបាញ់ព្រះឥសូរ, ឃើញទេពតាឈ្មោះកាមៈដេកស្លាប់ដោយតេជះព្រះឥសូរ ។

៣. ជាន់ខាងលិច ជញ្ជាំងខាងត្បូង, និយាយត្រង់ព្រះឥសូរគង់លើកំពូលភ្នំកៃលាស ថ្ងៃនត្រង់ក្រុងពណ៍ទសមុខ ដៃ ២០ កំពុងចាប់ភ្នំកៃលាសអង្រួន ។

៤. ជាន់ខាងកើត ជញ្ជាំងខាងជើង, ឃើញមានរូបតីរេចនាយ៉ាងល្អ មានទេពតាហោះលើអាកាស, មានរឿងស្វាមីភរិយាប្រលែងនឹងកូន,

រឿងប្រផល់មាន់ជារឿងកាលជាន់នគរវត្ត; ទ្វារខាងជើង រឿងរាមកេរ្តិ៍, ត្រង់ព្រះរាមសម្លាប់ម្រឹគ ដែលរាពណ៍ដំណែងមកលួចយកនាងសីតា; ទ្វារខាងលិច, រឿងក្រឹស្ណៈ ម្ដាយចងជាប់នឹងគល់ឈើ ក្រឹស្ណៈទាញរំលំឈើពីរដើម; ទ្វារខាងត្បូង វិស្ណុស្ថិតនៅក្នុងនៃព្រៃ; ទ្វារខាងកើត រឿងមនុស្សជាច្រើនគ្នា យកផ្កាយទៅថ្វាយព្រះវិស្ណុ ។

## រោងទងខាងត្បូង បែកខាងលិច (ពីខាងលិចទៅខាងកើត)

និយាយពីពង្សាវតារខ្មែរ ថ្ងៃពីអ្នកនាយកប្ចុបណ្ឌិត យកផ្កាយទៅថ្វាយស្ដេច, ព្រះបាទសូរ្យវរ្ម័នទី ២ ដែលទ្រង់កសាងប្រាសាទនគរវត្ត ប្រថាប់នៅក្រោមស្វេតច្ឆត្រ ដែលមានលំអដោយរូបនាគរាជ នៅលើគិរីបទ ទ្រង់ត្រាស់បង្គាប់ឲ្យគេណូសេនាពាហន; ខាងឆ្វេង, នៅខាងក្រោមមានក្បួនហែព្រះរាជវង្សានុវង្ស ទំងរាជបរិពារគាត់ជូនដៃព្រៃព្រឹក្សា, នៅខាងលើ មានសេនាពាហនអង្គុយប្រជុំគ្នា, នៅជិតស្ដេច មានពួករាជបណ្ឌិត រាជបុរោហិត មានអ្នកកាន់ក្ស័ជាអមេទកហោមកោមជាបរិវារ; នៅខាងស្ដាំ, ជិតស្វេតច្ឆត្រ នាម៉ឺនធំម្នាក់ឈ្មោះ ស្រីជយៈ (តាមសិលាចារឹក) ដៃមួយដាក់នៅលើទ្រូង បែរមុខឈមទៅរកស្ដេច ដោយសេចក្ដីគោរពកោតក្រែង, នៅខាងក្រោម ក្បួនហែព្រះអគ្គមហេសីគង់លើព្រះវរ ឬ ព្រះអង្រឹងស្នែង មានរាជបរិពារកាន់សៃហែហមៈតាមក្រោម;

តទៅទៀត, សេនាទាហានពាក់មួកក្បាលសត្វ យាត្រាទ័ពចុះពីលើភ្នំទៅកាន់ទីវាល, ពួកមេទ័ពទាំងឡាយជិះលើដំរី ប៉ាំងក្លស់ព្រោងព្រាត ឯពលថ្មើរជើងមានកងទ័ពសេះហែហម; តទៅទៀត, ព្រាហ្មណ៍បួងសក់វាយឃ្មោះ នាយពេហ្វាយជិះលើអង្រឹង មានសេនាទាហានសែងជើង-ក្រានភ្លើងស័ក្តិសិទ្ធិ ដើម្បីបូជាទេពតារក្សាទាហានក្នុងចម្បាំង មានទា-ហានផ្លុំត្រែ វាយស្គរនៅផ្លូវខាងមុខ ដូចក្បួនទ័ពដែលយើងឃើញសព្វថ្ងៃនេះដែរ; ជិតដល់មាត់ក្ដារខាងត្បូង, មាននិយាយពីកងទ័ពសៀមស្យាមកុក (តាមសិលាចារឹក) ទាហានសៀមនោះស្លៀកពាក់ប្លែកពីទាហានខ្មែរ ។

## រោងទងខាងត្បូង បែកខាងកើត (ពីកណ្ដាលទៅខាងកើត)

រោងទងនេះ, និយាយពីស្ថានសួគ៌និងស្ថាននរក, មានសិលាចារឹកខ្លីៗ ប្រាប់ឈ្មោះនរកដែលប្រព្រឹត្តអំពើអាក្រក់ ត្រូវបានទទួលសេចក្ដីរងទុក្ខវេទនាដូច្នេះដូច្នោះ ស្ថានសួគ៌នៅខាងលើ ស្ថាននរកនៅខាងក្រោម, នៅចន្លោះស្ថានទាំងពីរនេះ មានចម្លាក់រូបគ្រុឌមានដៃប្រដាប់ដោយផ្កា, អ្នកមើល កាលណាដើរមកដល់កន្លែងនេះ នឹងឃើញព្រះយមរាជមានដៃ ១៨ ជិះលើគោ; តទៅទៀត, តាមសិលាចារឹក ប្រាប់ថា ត្រង់កន្លែងនេះ "ព្រះធម៌ជាធំ" សម្រាប់កាត់ទោសនៃអ្នកដែលមានទោស; នៅជិតនុះ ឃើញស្មៀនព្រះយមរាជឈ្មោះ ចិត្រគុប្ត កាន់

ដំបងធំកើតជន្លៀតពួកសត្វនរក; តទៅទៀត, មានចម្លាក់រូបភាពនៃសត្វនរក ដែលរងទុក្ខវេទនា ហើយសរសេរឈ្មោះទុកខាងក្រោម ប្រាប់ឈ្មោះនរកនិងអំពើដែលសត្វនោះប្រព្រឹត្ត ពេញទាំងជញ្ជាំងនេះ(១) ។

## រោងទងខាងកើត ប៉ែកខាងត្បូង (គឺខាងត្បូងទៅខាងជើង)

ត្រង់នេះ, និយាយពីរឿងកូរសមុទ្រទឹកដោះ, ចម្លាក់នេះប្លែកពីកន្លែងឯទៀត ព្រោះផ្ទៃជញ្ជាំងទាំងអស់បណ្ដោយ ៥០ ម៉ែត្រ គេឆ្លាក់តែរឿងមួយ គួរឲ្យកោតស្ងើចដល់វិស្វករដែលជាអ្នកប្រតិស្ឋឲ្យកើតឡើង ព្រោះរឿងនេះ មានស្ទើរតែគ្រប់កន្លែង តែមិនល្អឆើតដូចកន្លែងនេះឡើយ ។

តាមរឿងនេះ, មានសេចក្ដីដំណាលថា ទេវតានិងអសុរចង់បានទឹកអម្រឹត គឺទឹកដែលសម្រាប់ផឹកការពារមិនឲ្យស្លាប់ នេះជាហេតុនាំឲ្យកូរទឹកសមុទ្រ, គេយកភ្នំមន្ទរជាស្នូល យកនាគវាសុកិជាព្រ័ត្រ សម្រាប់ទាញ ពួកអសុរទាញខាងក្បាល ទេវតាខាងកន្ទុយ, ភ្នំមន្ទរស្ថិតនៅលើខ្នងអណ្ដើក ដែលជាអវតារនៃព្រះវិស្ណុ, ពួកទាំង២ផ្នែកនេះទាញបង្វិលភ្នំយ៉ាងខ្លាំងក្លា; ការកូរទឹកសមុទ្រនេះ ជាភ័យធំសម្រាប់សត្វសមុទ្រទាំងឡាយ; ផ្ទៃកណ្ដាលឃើញសត្វសមុទ្រជាច្រើន ដូចត្រី, យក្ខ, គន្ធព្វ ដាច់ខ្ទេចខ្ទីស្លាប់អស់ជាច្រើន; កូរជាង ១០០០ ឆ្នាំ ទើបកើតមានសត្វ

---

១ បើចង់ដឹងឈ្មោះនរកនេះ ត្រូវមើលសៀវភៅ «អំពីប្រាសាទអង្គរវត្ត» ឆ្នាំ ១៩២៨ របស់ព្រះតេជព្រះគុណព្រះគ្រូសំរិទ្ធិ គឺព្រះសាក្យវង្ស សព្វថ្ងៃនេះ ។

ជាច្រើនទីងស្ត្រីអប្សរ កើតចេញមកអំពីការកូរសមុទ្រនេះ ហោះហើរព្រោងព្រាតនៅខាងលើ; នាងលក្ស្មីជានាងបញ្ចពិធកល្យាណី ក៏កើតពីការកូរសមុទ្រនេះដែរ, ទឹកអម្រឹតត្រូវបានទៅពួកទេពតាដែលឈ្លោះពួកអសុរ, នៅត្រង់ផ្នែកកណ្តាល ឃើញព្រះវិស្ណុអវតារជាមនុស្សជួយពួកទេពតា ពួកអសុរក្នែកមូលក្រឡេត ពាក់ក្បាំងកំពូល ពួកទេពតាពាក់មកុដស្រួច, សត្វស្វាដែលកាន់កន្ទុយនាគពជ តាមលោកសីដែលលោកថា ហណុមាណ, នៅខាងក្រោម នាគពជឈ្មោះវាសុកិ ដែលពួកទេពតានឹងអសុរ មិនទាន់យកមកប្រើជាព្រ័ត្រតាញកូរទឹកសមុទ្រ, នៅចុងម្ខាងឃើញពួកបរិពារអសុរនឹងទេពតា ត្រៀមចាំម្ចាស់គេរៀងខ្លួន ដែលទៅកូរទឹកសមុទ្រ ។

## រោងទងខាងកើត ប៉ែកខាងជើង (ពីខាងត្បូងទៅខាងជើង)

ដើរបន្តិចទៀត ដល់កន្លែងមួយ ប្រែមាត់ទ្វារធំខាងកើត, មានសិលាចារឹកទៅហ្វាយនៃត្រឡែងម្នាក់ ឆ្លាក់ចុកក្នុងសតវត្សរ៍ទី១៨នៃពុទ្ធ-សករាជ និយាយពីបុណ្យទាន ដែលបានកសាងក្នុងព្រះពុទ្ធសាសនា នឹងកសាងចេតិយមួយធ្វើអំពីឥដ្ឋ បញ្ចុះអដ្ឋិបុត្រភរិយា; តទៅ, ឃើញរូបចម្លាក់កងទ័ពពួកអសុរ យាត្រាទ័ពទៅច្បាំង, ព្រះវិស្ណុជិះលើក្រុឌ, (ព្រះឥសូរកាន់ត្រីសូល៍ ក្បាល ១០០០ កូនឈ្មោះគណេសនឹងក្រិស្ណៈដៃប្រណម្យ) រូបចម្លាក់ត្រង់នេះ ថ្វីដៃមិនចំណាននេ នាំឲ្យសង្ស័យថាជា

ស្នាដៃជាងជាតិចិន ព្រោះរូបដំរី, រូបសេះ ឬរូបផ្សេងៗដែលជារចនាចិន សុទ្ធ ៗ មិនមែនជាស្នាដៃខ្មែរឡើយ, អ្នកមើលគួរពិនិត្យ ៗ

## រោងទងខាងជើង ប៉ែកខាងកើត (ពីខាងកើតទៅខាងលិច)

ត្រង់នេះ, ការរចនាក៏មិនចំណានដូចគ្នា ដែលជាថ្វីដៃជាងចិនដែរ; តាមលោកស៊ីដែសជាអ្នកប្រាជ្ញបារាំងសែស លោកសរសេរប្រាប់រឿងថាៈ ត្រង់នេះ, ជាចម្បាំងទេពតា គេស្គាល់បានដោយមានមកុដកំពូលស្រួច យាត្រាទ័ពមានកងទ័ពភ្លើងដើរមុខ ព្រះវិស្ណុក្បាល ១០០០ ជិះលើគ្រុឌ មានដៃ ៨, ផ្នែកកណ្តាលជាសមរភូមិ មានភ្លើងមួយគំនរ យាំងកងទ័ពទាំងសងខាង ភ្លើងនេះត្រូវសំដែងឫទ្ធិ យកទឹកទន្លេគង្គាជាគ្រឿងរំលត់អស់ ហើយធ្វើដំនរភ្លើងនោះទៅ; តទៅទៀត, គេឃើញយក្សក្បាល ៦ ជើង ៤ ជិះលើរមាស ប្រឹងប្រែងច្បាំង ៗ កងទ័ពនៃក្រឹស្នៈអវតារព្រះវិស្ណុ លុកចូលទៅវាយទ័ពអសុរឈ្មោះពាណៈនៅក្នុងក្រុង ៗ ត្រង់នេះ ក្រឹស្នៈជិះលើគ្រុឌមានដៃ ៦, ទៅបន្តិចទៀត ព្រះវិស្ណុមានក្បាល ១០០០ ដៃ ៨ ជិះលើរថទឹមដោយសីហៈ មានស្នំពីរនាក់លុកចូលទៅ ទល់មុខគ្នានឹងអសុរឈ្មោះពាណៈ, (រឿងនេះមាននៅក្នុងគម្ពីរ ហរិវង្សៈ); តបន្តិចទៅ, ឃើញ **ព្រះឥសូរទឹងខានចរិត** កូនប្រុសឈ្មោះគណេសក្បាលជាដំរី, ឫសី, កិន្នរី **នៅលើភ្នំ.** ព្រះក្រឹស្នៈក្បាល ១០០០ មានជ័យឈ្នះអសុរឈ្មោះពាណៈ

ក្រាបនមស្សការព្រះឥសូរ ៗ ព្រះឥសូរជួយអសុរឈ្មោះពាណៈ មានបន្ទូលទៅនាងក្រឹស្ណៈថា: “នែក្រឹស្ណៈ ឯងមានឫទ្ធិអំណាចណាស់នៅក្នុងលោកសន្និវាស ឥតមានអ្នកណាមួយឈ្នះអ្នកឯងទេ, តែឯងនឹកមើល, ឥឡូវនេះ, អញបាននិយាយថាជួយអសុរពាណៈហើយ, សំដីអញមិនឥតប្រយោជន៍ទេ”, ក្រឹស្ណៈឆ្លើយតបវិញដោយសេចក្ដីឆ្លាតថា: “សូមឲ្យអសុរពាណៈមានជ័យចុះ ព្រោះខ្ញុំបានកំណត់ថាស្រោចស្រង់គេហើយ..., ឯខ្ញុំព្រះអង្គមិនចង់បានគ្រាន់បើជាងគេទេ, ខ្ញុំសព្វព្រះទ័យដូចម្ដេច ខ្ញុំទូលបង្គំតាមទាំងអស់ ៗ '

## រោងទងខាងជើង ប៉ែកខាងលិច (ពីខាងកើតទៅខាងលិច)

រោងទងនេះក៏រចនាមិនទាន់វិសេសដែរ តែគ្រាន់បើជាងខាងកើត, និយាយពីរឿងចម្បាំងក្នុងសាសនាព្រាហ្មណ៍, តាមលោកសឺដែសលោកថា មានទេវតា ២១ អង្គ ទេវតាម្នាក់ច្បាំងនឹងអសុរម្នាក់ ដែលគេសំគាល់បានបែកគ្នាដោយមកុដនឹងក្បាំង ហើយច្បាំងតតាំងគ្នា, ទេវ-តាដែលស្គាល់បាននោះ គឺទេវតាឈ្មោះ គុវេរៈ ជាទេវតាខាងទ្រព្យសម្បត្តិជិះលើយក្ខ, ទេវតាចម្បាំងឈ្មោះ ស្កន្ទៈ មុខ ៦ ដៃ ១០ ជិះលើក្ងោក, ឥន្ទ្រៈ ជិះលើដំរីឰរាវ័ណ្ណក្បាល ៤ ចាប់ព្រួចបច្ចាមិត្រក្នុងប្រ-មោយ, គេឃើញមានយក្សគន្ធព្វស្លាប់ក្នុងសមរភូមិ, ឃើញមាននាគក្បាល ៩, ឃើញវិស្ណុជិះលើគ្រុឌ; តទៅទៀត, យមៈ ជិះលើរថ

ទឹមគោ, ព្រះឥសូរយឹតកោទណ្ឌធ្នូ, ព្រហ្មៈជិះលើហង្ស ទេពតាឈ្មោះ សូរ្យៈ មានរស្មីព័ទ្ធជុំវិញខ្លួនជិះលើរថ សារថីមានខ្លួនពាក់កណ្តាលជាមនុស្សពាក់កណ្តាលជាសត្វ ។ ខាងចុងកេងទង ទេពតាឈ្មោះ វរុណៈ ទេពតាខាងទឹកភ្លៀងជិះលើនាគ, សង្គ្រាមនៃកងទ័ពទាំងពីរមានសភាពរឹតតែខ្លាំងឡើងៗ ។

## នៅជ្រុងរោងទងទិសពាយ័ព្យ កាត់ជាក្រឡាបត្រង្គ (ចែកជា៤ជាន)

១. ជានខាងកើត ផ្ទាំងខាងត្បូង, វិស្ណុជិះលើគ្រុឌ តាមលោកសីដែសលោកថា កុងពេលដែលវិស្ណុអវតារជាក្រឹស្ណៈ, មានជ័យជំនះត្រឡប់មកពីច្បាំងវិញ មានសេនាពាហនដឹកនាំគ្រឿងឧបករណ៍ផ្សេងៗដែលរឹបជាន់ពីបច្ចាមិត្រ ដៃស្តាំគ្រុឌទ្រអគ្គមហេសីព្រះវិស្ណុ ។

នៅខាងលើបន្ទប់ខាងជើង, វិស្ណុគង់លើនាគហៃលនៅលើទឹក, អគ្គមហេសីស្ថិតនៅខាងចុងព្រះបាទ, ផ្កាឈូកផុសចេញអំពីខ្លួនព្រះវិស្ណុ ទេពអប្សរហោះកាន់ផ្កាពីខាងលើ, នៅខាងក្រោមមានទេពតា៩អង្គគឺ សូរ្យៈគង់លើរទេះ, កុវេរៈគង់លើយក្ស, ព្រហ្មៈគង់លើហង្ស, ស្កន្ទៈគង់លើក្ងោក, ទេពតាមួយអង្គទៀតនៅលើសេះ? ឥន្ទ្រៈគង់លើដំរីឰរាវណ្ណ, យមៈគង់លើគោ, សិវៈគង់លើគោ ។

២. ជានខាងជើង នៅខាងលើបន្ទប់ខាងលិច, រឿងកាលព្រះរាមយកនាងសីតាទៅដុតនៅគំនរភ្លើង ដើម្បីបញ្ជាក់សេចក្តីបរិសុទ្ធនៃនាង



រូបស្ត្រីទេពអប្សរ មានសក់សំយាកពាក់មកុដ នៅជាងទងខាងលិច
ប្រាសាទនគរវត្ត

(តាមរូបថត ស.ប.ប.)

សិតា កាលដែលរាពណ៍លួចយកទៅនៅកោះលង្កា, ព្រះរាមគង់នៅក្នុងប្រាសាទ, ពួកទាហានស្វាលើកដៃបង្ហួលទៅនាងសិតាដោយសេចក្តីអស្ចារ្យ ។

៣. ដានខាងលិច នៅលើបង្អួចខាងជើង, ថ្ងៃកាលព្រះរាមច្បាំងឈ្នះរាពណ៍នៅក្រុងលង្កា ចុះគង់លើរាជរថឈ្មោះបុស្បកៈ ត្រឡប់មកក្រុងអយុធ្យាវិញ ពួកទាហានស្វាសប្បាយរីករាយលេងល្បែងផ្សេងៗ ។

នៅលើបង្អួចខាងត្បូង, ថ្ងៃកាលនាងសិតានៅទីប្រាសាទរាពណ៍, ព្រះរាមប្រើហនុមានទៅមើលនាងសិតា, ស្រីដែលថែរក្សានាងសិតាសុទ្ធតែយក្ខិនី មានសំលៀកបំពាក់មិនល្អ, ខ្លះមានចំពុះផង ។

៤. ដានខាងត្បូង ជញ្ជាំងខាងកើត, ថ្ងៃកាលព្រះរាមប្រយុទ្ធ ដើម្បីទឹងយកនាងសិតា, នាងសិតាពាក់មកុដកំពូល ៣, ឃើញពួកពល-បរិវារនៅហែហម ។

បង្អួចខាងកើត, ត្រង់កណ្តាល ព្រះរាមកាន់ធ្នូ ព្រះលក្ស្មណ៍កាន់ព្រះខាន់ និយាយចងស្ពានមេត្រីនឹងសុគ្រីព; បង្អួចខាងជើង យក្សឈ្មោះរក្ខសៈ ជាបងរាពណ៍លួចយកនាងសិតាបញ្ចុះលើភ្លៅ ច្បាំងតនឹងព្រះរាមព្រះលក្ស្មណ៍; បង្អួចខាងលិច ថ្ងៃកាលចងស្ពានមេត្រីព្រះរាមនឹងយក្សឈ្មោះវិភីសណៈ ជាបងរាពណ៍ (គឺពិភេក្ស) ។

## រោងទងខាងលិច បែកខាងជើង (ពីខាងជើងទៅខាងត្បូង)

រឿងចម្បាំងរាមកេរ្តិ៍ ត្រង់ព្រះរាមនឹងសេនាព្រះរាម វាយយកក្រុងលង្កា មានស្វាជាសេនាទាហាន ដើម្បីដណ្ដើមយកនាងសីតា; នៅក្នុងផ្ទាំងនេះ គេមើលឃើញព្រះរាមជិះលើហណុមាណចេញធ្លា, ខាងក្រោយព្រះលក្ស្មណ៍និងវិភីសនៈ (ពិភេក្ស); គេទៅទៀត ក្រុងរាពណ៍ ទសមុខ ដៃ ២០ ជិះលើរថ ។ ការរចនាទាំងអស់នេះ ជាទីស្ងើចដល់ពួកវិស្វករសម័យបច្ចុប្បន្ននេះពន់ពេកណាស់ ។

ដើរមើលរោងទងជុំវិញហើយ ត្រូវឡើងទៅថ្នាក់ព្រះពាន់ តាមជណ្ដើរពីរនៅអមសងខាងទ្វារធំក៏បាន ឡើងផុតជណ្ដើរមួយជាន់ទៅដល់រោងទងប្រទាក់គ្នាខ្វាត់ខ្វែងជាក្រឡាចត្រង្គ នៅចន្លោះរោងទងទាំង៤ទិសមានស្រះតូច៤ ។ នៅក្នុងរោងទងបណ្ដោយខាងត្បូង មានព្រះពុទ្ធ-រូបបុរាណច្រើន រចនាជាលទ្ធិហីនយានខ្លះ មហាយានខ្លះ គេយកមកដំ-កល់ទុកក្នុងវេលាក្រោយការកសាងប្រាសាទ ។ កាលបើចេញផុតពីរោងទងទៅខាងត្បូងក្ដី ខាងជើងក្ដី នឹងឃើញធម្មទ្ធិរពីរ, លុះបានមើលត្រង់នេះស្ពតគ្រប់ហើយ ត្រូវឡើងតាមជណ្ដើរធំខាងលិចទៅដល់ជាន់ទី២, ឯជណ្ដើរឡើងទៅជាន់ទី២ មានគ្រប់ជ្រុងអស់ទិស តែពិបាកឡើង, ក្នុងរោងទងមានព្រះពុទ្ធរូបជាច្រើន គេដម្កល់ទុករៀបរៀងគ្នាជុំវិញ, នៅប្រចទ្វារធំខាងលិច មានរូបព្រះនារាយណ៍ជាច្រើន ខ្លះមានដៃ៤ ។



រូបស្ត្រីទេពអប្សរ មានផ្នួងសក់ជាមកុដ នៅជម្មមន្ទីរទិសខាងកើត
ប្រាសាទអង្គរវត្ត
ការរចនាសម័យប្រាសាទអង្គរវត្ត រវាង ព. ស. ១.៦៨០
( តាមរូបថត ស. ប. ប. )

ថ្នាក់ទី ២

ចេញផុតពីកំពែងទី ២ នឹងឃើញទឹកបស្មើស្រឡះ, មើលទៅលើហាក់ដូចជាវិមានអណ្តែត, តាមទំនងនេះ បើចូលទៅលេងពេលយប់ដែលមានព្រះចន្ទពេញវង់ សមនឹងសប្បាយរីករាយអស្ចារ្យ, គេអាចដើរមើលជុំវិញបាន ហើយសឹមឡើងទៅជាន់ទី៣ នៅចំមាត់ទ្វារធំកណ្តាលខាងលិច មានស្ពានតទៅភ្ជាប់នឹងជណ្តើរធំខាងលិច នឹងមានជម្ពូទ្វារពីរនៅអម ។

ថ្នាក់ទី ៣

ការឡើងទៅកាន់ថ្នាក់ទី ៣ នេះ ត្រូវឡើងតាមជណ្តើរទិសខាងត្បូង ព្រោះមានបង្កាន់ដៃដែលគេទើបធ្វើថ្មីៗ មិនព្រឺស្រយ៉ើបប៉ុន្មាន, ប៉ុន្តែសម្រាប់អ្នកដែលមានស្មារតីល្អ ឡើងតាមជណ្តើរធំខាងលិចក៏បាន ព្រោះជណ្តើរនេះមិនសូវចោតដូចជណ្តើរឯទៀត, ថ្នាក់ទី ៣ លើបំផុតឈ្មោះថា ភាដ នេះល្អអស្ចារ្យ, ត្រង់កណ្តាលមានប្រាសាទធំខ្ពស់ មានកំពែងព័ទ្ធជុំវិញតភ្ជាប់ទៅតាំង ៤ ទិស កាត់មកចួបនឹងកំពែងខាងក្រៅ នៅត្រង់ចន្លោះជ្រុងកំពែងមានស្រះ ៤ ។

នៅមាត់ទ្វារទាំង ៤ ទិសនៃប្រាសាទកណ្តាល មានព្រះពុទ្ធរូបទ្រង់ឈរ មានអគ្គសាវកពីរអង្គនមស្ការ គេឆ្លាក់ភ្ជាប់នឹងថ្មដែលស្ទះបិទទ្វារនោះៗ នៅខាងមុខមានព្រះពុទ្ធរូបជាច្រើន ខ្លះគង់នៅល្អ ខ្លះបាក់

បែកខ្ទូចអស់, នៅខាងត្បូង គេពោះយកព្រះពុទ្ធរូបដែលធ្លាក់នៅទ្វារ ចេញ រូបនោះសអស់ គួរឲ្យនឹកស្តាយ ។ អ្នកមើលទាំងឡាយគួរគប្បីជ្រាបថា ប្រាសាទនគរវត្តនេះ ព្រះបាទសូរ្យវរ្ម័នទី ២ កសាងក្នុងសត-វត្សរ៍ទី ១៧ នៃពុទ្ធសករាជ ដើម្បីឧទ្ទិសថ្វាយព្រះនារាយណ៍ក្នុងសាសនាព្រាហ្មណ៍ ដូចបានពោលមកហើយ ។

វេលាព្រះអាទិត្យទៀបអស្តង្គត, ពន្លឺក្រហមព្រាលឆ្ពោះលាលមកលើប្រាសាទ ដើរមើលលើ, ពពករសាត់លឿនលយលើកំពូលប្រាង្គប្រាងនៃប្រាសាទ មើលមកក្រោមឃើញដំបូលរុក្ខប្រែកបដោយហោជានិមានក្បាច់សំរេក អ្នកមើលសប្បាយរីករាយក្រៃខ្លួនប្រាណ អណ្តែតអណ្តូនចិត្ត, ហេតុនេះសូមជំរាបអ្នកមើលទាំងអស់ ឲ្យមើលប្រាសាទនេះ នៃពេលល្ងាចទើបល្អមើល ។

## ប្រាសាទតាព្រហ្មកិល

ចម្ងាយពីមុខនាគ៤០០ម៉ែត្រ នៅជាខាងឆ្វេងដៃ ប្របផ្លូវដល់ប្រ-ហែល៤០ម៉ែត្រ, មើលទៅឃើញប្រាសាទមួយបាក់បែកស្ទើរតែអស់រលីង ប្រាសាទនេះឈ្មោះ តាព្រហ្មកិល ។

ប្រាសាទនេះ គេកសាងឧទ្ទិសថ្វាយព្រះពុទ្ធសាសនាលទ្ធិមហាយាន ព្រោះមានរូបចម្លាក់នៅហោជាងទាំង ៤ ទិស សុទ្ធសឹងជារឿងក្នុងព្រះពុទ្ធសាសនា តែរូបចម្លាក់នោះឃើញមានខ្លះគេកោះចោលទៅវិញ ប្រហែលជាអ្នកកាន់សាសនាព្រាហ្មណ៍ ? ។ តាមដែលពួកអ្នកប្រាជ្ញគេពិនិត្យមើលរូបក្នុងប្រាសាទ និងក្បាច់ចនាផ្សេងៗ ដែលមាននៅនារូបប្រាសាទ គេស្គាល់បានថា គេកសាងសម័យប្រាសាទបាយ័ននិងនគរធំ ព្រោះមានព្រះពុទ្ធរូបនៅហោជាងខាងជើងជាឡាក់ហានៗ ខាងក្នុង, មានព្រះពុទ្ធរូបផ្គត់រៀបរៀងគ្នា ។ កាលពីដើម, ប្រហែលជាមានថែវចេញមកខាងមុខ ហើយប្រទាក់គ្នាជាក្រឡាចត្រង្គ ព្រោះមាននៅសល់គ្រឹះខាងក្រោម ។ កាលដែលគេជីកដីមើលជុំវិញ គេឃើញរូបជាច្រើនប៉ែកខាងព្រះពុទ្ធសាសនា ។

## ភ្នំបាខែង

ចេញពីមុខខាង, តាមផ្លូវវង់ធំទៅនគរធំ ដែលអមដោយព្រៃព្រឹក្សាធំមានម្លប់ត្រជាក់ត្រឈៃ នៅប្រហែល ៤០០ ម៉ែត្រ ទឹងផុតគោបុរៈខាងត្បូងនៃនគរធំ, នៅខាងឆ្វេងដៃមានសត្វសីហៈឈរក្រអឺត, គេនឹងឃើញភ្នំមួយហៅថា ភ្នំបាខែង ត្រូវឈប់រថយន្តហើយឡើងតាមផ្លូវខាងមុខ ។ សូមរំឭកថា: បើទៅមើលត្រូវទៅពេលល្ងាចត្រជាក់ឬពេលព្រឹក ព្រោះត្រូវឡើងភ្នំខ្ពស់បន្តិច នាំឲ្យហត់អស់កម្លាំង ស្រេកទឹកផង; សម្រាប់អ្នកដែលមានទ្រព្យសម្បត្តិទឹងជួលដំរីជិះឡើងទៅមើលក៏បាន ។ លុះឡើងទៅដល់ខាងលើភ្នំហើយ ឃើញមានទីរាបស្មើ មានពុទ្ធបាទគេធ្វើពេងបែកពីលើ; តទៅ, ដល់ទៅប្រាសាទបាខែង គេកសាងជា ៥ ថ្នាក់ កំពស់ ៦៥ ម៉ែត្រ មានជណ្តើរតាមទិសៗត្រង់ទាំង៥ថ្នាក់, នៅក្បាលជណ្តើរមានសត្វសីហៈជាទ្វារបាល ទឹងមានប្រាសាទតូចជាច្រើនជាជួរវៀងគ្នាព័ទ្ធជុំវិញ តាំងពីថ្នាក់ក្រោមរហូតទៅដល់ថ្នាក់លើ ។ ថ្នាក់លើជាទី ៤ ជ្រុងរាបស្មើ ក្រាលសុទ្ធតែថ្ម ប្រាសាទធំស្ថិតនៅកណ្តាល ប្រាសាទតូចស្ថិតនៅត្រង់ជ្រុងអនុទិស; ប្រាសាទកណ្តាលឥឡូវនេះ, បាក់បែកកំពូលអស់ហើយ មានក្បាច់រចនាដ៏វិសេស ទ្វារបាលពីរល្អឆើតនៅអមមាត់ទ្វារ ។ ពេលល្ងាចព្រះអាទិត្យលិច, ពេលពន្លឺព្រាលឆ្អៅ ខ្យល់បក់មកហើយត្រជាក់រំភើយៗសប្បាយពន្ទឹក, គេឈរឬអង្គុយមើលទៅទិជុំវិញបាន

ចាំងអស់, មើលទៅនគរវត្តមានកំពូលប្រាំប្រាង្គខ្ពស់ធំស្កឹមស្កៃ, មើលទៅផ្សារសៀមរាប, មើលទៅបារាយទឹកថ្លានៅទិសខាងលិច ឬមើលទៅប្រាសាទបាយ័ន នៅទិសខាងជើង, មើលទៅឆ្ងាយបែកផ្សែង, ដល់ទៅភ្នំគូលែន, ភ្នំបូក និងជួរភ្នំដងរែក ។

ភ្នំបាខែងនេះ, ជាគោលចារឹកនៃក្រុងនគរធំ ក្រោយដែលបានផ្លាស់ក្រុងចាស់ពីបាគងមក ។ តាមប្រវេណីបុរាណខ្មែរ, គេច្រើនកសាងប្រាសាទធំខ្ពស់ ឬប្រាសាទនៅលើកំពូលភ្នំ ដើម្បីឧទ្ទិសថ្វាយទេវតាដែលគេគោរព; ភ្នំបាខែងនេះ គេកសាងដំណាងភ្នំព្រះសុមេរុ (ភ្នំហិមាលយា?) ស្ទឹងសៀមរាប ដំណាងទន្លេគង្គា តាមប្រទេសឥណ្ឌា ។ ចូរអ្នកមើលសង្កេតចុះ ប្រាសាទកណ្តាលជាតួភ្នំព្រះសុមេរុ ប្រាសាទតូចៗ គ្រប់ថ្នាក់ ជាភ្នំសត្តបព៌ត, ចន្លោះថ្នាក់មួយៗ គឺសមុទ្រសត្តសិទន្តរ, ពួកទេវតាធំៗ ដូចព្រះឥសូរ ព្រះព្រហ្ម ព្រះនារាយណ៍ជាដើម តែងស្ថិតនៅលើភ្នំអស់នេះៗ តាមសិលាចារឹក, និយាយថា ប្រាសាទបាខែងនេះឈ្មោះ ឥន្ទ្រាទ្រិ ប្រែថា: “ភ្នំសម្រាប់បូជាទេវតាធំៗ” ព្រះបាទយសោវរ្ម័នទី ១ កសាងក្នុងសតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ (ព.ស.១៤៣៣) ទុកជាគោលប្រទង់ជ័យនៃនគរធំក្នុងសម័យនោះ ដើម្បីឧទ្ទិសថ្វាយដល់ព្រះឥសូរ អាស្រ័យហេតុដែលព្រះបាទសុរ្យវរ្ម័នទី ១ ឧទ្ទិសប្រាសាទនេះដល់ព្រះឥសូរ ទើបគេហៅភ្នំបាខែងនេះថា: “យសោធរេស្វរៈ” ។

## ប្រាសាទបក្សីចាំក្រុង

អ្នកផងទាំងពួងច្រើនទៅមកម្ដងមិនចូលមើល ដោយគិតស្មានថា ប្រាសាទនេះមិនសំខាន់អ្វីឡើយ តែតាមពិតមិនដូច្នោះទេ, ប្រាសាទបក្សីចាំក្រុង ស្ថិតនៅជាចន្លោះភ្នំបាខែងនិងនគរធំ, មានទ្រង់ទ្រាយស័ក្តិសម គេសាងជា ៤ ថ្នាក់ពីថ្មបាយក្រៀម បន្ទាប់ប្រាសាទឥដ្ឋខាងលើ មានជណ្ដើរឡើងគ្រប់ទាំង ៤ ទិស ទ្វារបញ្ឆោត ៣ ទិស, ក្បាច់របនាសម្រាប់បិទពីក្រៅវិនាសបាត់អស់ហើយ នៅសល់តែក្បាច់ផ្តែលើខ្លោងទ្វារល្អចំណាប់ មានព្រះឥន្ទ្រគង់លើដំរីឰរាវ័ណ្ណ ចុងទាំងសងខាងមានគណេស; នៅមាត់ទ្វារខាងកើតមានសិលាចារឹកនិយាយថា ព្រះបាទរាជេន្ទ្រវរ្ម័នទី២ កសាងក្នុងសតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ (ព.ស. ១៤៩០); ស្តេចបានសាងរូបព្រះឥសូរដោយមាសសុទ្ធ ដម្កល់ទុកក្នុងប្រាសាទនេះ ដើម្បីឧទ្ទិសថ្វាយព្រះឥសូរ, តែឥឡូវនេះមិនឃើញរូបព្រះឥសូរនោះទេ គេមើលឃើញព្រះពុទ្ធរូបចូលនិព្វានវិញ, តាមចំនងនេះ ប្រហែលកាលជាន់សៀមមកកាយកស្រុកខ្មែរ កាល ព.ស.២១៦៣ ឬ? កាលពីដើមមានកំពែងព័ទ្ធជុំវិញ ព្រោះឃើញមានសំណល់ខ្លះ ។ នៅជិតប្រាសាទនេះ ទៀងខាងជើង មានប្រាសាទពីរបីធ្វើពីឥដ្ឋដូចគ្នា គេឲ្យឈ្មោះថា "ប្រា-សាទកាខ្ទង" ។



ទ្វារជ័យ ភាគខាងកើតនគរធំ

ការរចនាបែបប្រាសាទបាយ័ន រវាង គ.ស. ១.២០០

(តាមរូបថត ស.ខ.ប.)

## វគ្គទី.៤

## រាជធានីនគរធំ

ចេញពីមុខនាគចំនួន ១៧០០ ម៉ែត្រ កាត់មុខភ្នំបាខែង តាមផ្លូវវង់ធំប្រកបដោយម្លប់ឈើត្រជាក់ ទើបដល់ទៅគោបុរៈ (ខ្លោងទ្វារ) ទិសខាងត្បូងនៃនគរធំ ។ នគរធំនេះ, មានស្រះ (សិន្ធុ) ព័ទ្ធជុំវិញទាំង ៤ ទិស, មានគោបុរៈ៥ ខ្លោងទ្វារនៅទិសខាងកើត ២ គឺ ខ្លោងទ្វារនៅចំមុខព្រះលានឈ្មោះ ទ្វារជ័យ នៅចំមុខបាយ័នឈ្មោះ ទ្វារខ្មោច ។ ខ្លោងទ្វារទាំងអស់ ប្រកបដោយបង្កាន់ដៃអសុរនិងទេវតាទាញនាគយ៉ាងល្អឆើត ប្លែកពីប្រាសាទឯទៀត; ទេវតានិងអសុរនេះ មានមុខមាត់សំបើមៗ ភ្នែកលៀនចេញក្រឡោតៗ; គោបុរៈទាំង៥នេះ ជាតួប្រាសាទមួយ កំពស់ ២០ ម៉ែត្រ ក្បាច់ចនាទាំងក្នុងទាំងក្រៅ កំពូលជាក្បាលលោកេស្វរៈមានមុខ៤; នៅសងខាងច្រកទ្វារ មានក្បាលដំរីបីៗ ប្លែកពីប្រាសាទតាព្រហ្ម, ប្រាសាទបន្ទាយក្ដី ដែលមានជារូបគ្រុឌជុំវិញ ។ សូមជ្រាបថា ប្រាសាទដែលមានកំពូលជាក្បាលលោកេស្វរៈមានមុខ៤ សុទ្ធតែគេឧទ្ទិសថ្វាយដល់ព្រះពុទ្ធសាសនា ។ កំពែងព័ទ្ធពីក្រៅនេះ ធ្វើពីថ្មបាយក្រៀម កំពស់ ៨ ម៉ែត្រ, ទទឹងបណ្ដោយជុំវិញ ១២ គីឡូម៉ែត្រ, គេអាចដើរលេងកំសាន្តជុំវិញបាន ឬជិះសេះលើកំពែងនោះក៏បាន, មិនស្អុះក្ដៅទេ ព្រោះមានមែកឈើត្របមួយចំហៀងនាំឲ្យត្រជាក់ ។

ក្រុងនគរធំ ដែលយើងមើលឃើញសព្វថ្ងៃនេះ មិនមែនជាក្រុងចាស់ពីបុរាណកាលមកទេ, កាលដើម ព្រះបាទយសោវរ្ម័នទី១ ជាព្រះរាជបុត្រព្រះបាទឥន្ទ្រវរ្ម័នទី១; កាលដែលទ័ពចាមចូលមកលុកដុតក្រុងបាគង ស្តេចទ្រង់មកកសាងក្រុងនគរធំនេះវិញ មុនគេបង្អស់ ក្នុងវាងសតវត្សរ៍ទី១៥នៃពុទ្ធសករាជ (ព.ស ១៤៣៦-១៤៥៣) ទ្រង់ប្រទានឈ្មោះក្រុងថ្មីនេះថា យសោធរបុរៈ ប្រែថា "បុរីនៃព្រះឥស្សូរទ្រទ្រង់នូវយស"; ព្រះរាជាដែលកសាងក្រុងនគរធំនេះច្រើនព្រះអង្គ គពីព្រះបាទយសោវរ្ម័នទី១មក ។ ក្រុងនគរធំនេះ ស្កុកស្គម មានកេរ្តិ៍ឈ្មោះរន្ទឺឆ្ងាយណាស់, អ្នកដំណើរចិនម្នាក់ឈ្មោះ ចេវតាក្វាន់ និយាយថា: "ក្រុងនគរធំជាក្រុងធំណាស់ បរិបូណ៌ដោយទ្រព្យសម្បត្តិ ប្រាសាទល្អៗជាច្រើន នឹងកុះករដោយមហាជនជាអនេក" ។ ចូលតាមផ្លូវត្រង់ទៅទៀត ចំនួន ១.៨០០ ម៉ែត្រ គេនឹងទៅដល់ប្រាសាទបាយ័ន ។



ភាគខាងក្រៅនៃប្រាសាទបាយ័ន មើលពីទិសខាងកើត
ការរចនាបែបប្រាសាទបាយ័ន រវាង គ. ស. ១.២០០

( តាមរូបថត ព. ស. ប. )

## ប្រាសាទបាយ័ន

ស្តាយអើយសែនស្តាយ! ល្អអ្វីម្ល៉េះ! កាលណាគេក្រឡេកមើលប្រាសាទបាយ័ននេះ គេឃើញទ្រង់ទ្រាយមានឫទ្ធិអស្ចារ្យ ទ្រង់ទ្រាយល្អឆេត ធំខ្ពស់ស្កឹមស្កៃសំបើម មុខលោកេស្វរៈធំៗ នៅលើកំពូលច្រើន ប្រាងខ្ពស់ត្រដួច ញញឹមស្រស់ប្រិមប្រិយ បែរមុខមករកយើង ដូចជាស្រឡាញ់យើងណាស់, បែរខាងនេះឃើញញញឹមស្រស់ បែរខាងនោះឃើញញញឹមពព្រាយ ងាកមើលទៅខាងណាក៏ឃើញដូចគ្នា នាំឲ្យយើងសប្បាយរីករាយ ចួនកាលភ័យស្ញប់ស្ញែងជាមួយផងៗ

ត្រូវឈប់រថយន្តខាងត្បូង, ហើយបង្គាប់ឲ្យរថយន្តទៅចាំខាងជើងប្រាសាទ ចូលទៅប្រាសាទពីខាងត្បូង, ការដើរមើលប្រាសាទនេះ ត្រូវតាប់មើលពីទិសខាងកើត ខាងជើង, ខាងលិច, វិលមកខាងត្បូង ហើយសឹមឡើងទៅថ្នាក់ទីពីរ, ថ្នាក់ទីពីរត្រូវមើលដូចគ្នា ព្រោះមានរូបចម្លាក់ពង្សាវតារខ្មែរ រឿងចម្បាំងតាមទឹកខ្មែរ នឹងទំនៀមទម្លាប់ខ្មែរបុរាណជាន់នគរធំ, ថ្នាក់ទីពីរក៏មានចម្លាក់ពង្សាវតារខ្មែរដែរ មានក្បាច់រចនាដេរជាសពាសពេញ, លុះមើលរួចហើយ សឹមឡើងទៅថ្នាក់ទី ៣ តាមជណ្ដើរខាងត្បូងឬជណ្ដើរខាងជើង, ប្រាសាទកណ្ដាល ធំខ្ពស់ស្ថិតនៅជាកណ្ដាល មានទ្វារចូលទាំង ៤ ទិស, តែគេហាមមិនឲ្យចូលព្រោះដុំថ្មធ្លាក់រលំជាច្រើន, មានយ៉ាជាកេងទងចេញមកខាងកើត, មានទីលានដើរលេង

នៅជុំវិញយ៉ាងសប្បាយ, រួចហើយសឹមចុះទៅតាមទ្វារខាងជើង កាត់រហូតទៅកាន់រថយន្តនៅជល់ខាងជើង ។

ប្រាសាទបាយ័ន តាំងនៅពាក់កណ្តាលក្រុងនគរធំ ឈ្មោះយសោធរគិរី ប្រែថា "ភ្នំទ្រទ្រង់យស". ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់កសាងក្នុងរវាងសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ (ព.ស. ១៧២៤-១៧៤៤), សព្វថ្ងៃនេះ ប្រាសាទបាយ័នបាក់បែកស្ទើរតែអស់ហើយ នៅសល់តែសសរច្រើន ជញ្ជាំងកេងទងនៅសល់ខ្លះ, ដុំថ្មដែលបាក់ធ្លាក់មកលើដី គេរើសគរទុក មានកំពស់ស្ទើរតែប៉ុនប្រាសាទ ។ ការនិយាយអំពីប្រាសាទបាយ័នឲ្យអស់ដើងនុះ ផុតវិស័យនឹងរេះនិយាយបាន, ខ្ញុំក៏មិនទទួលកប់រើងនិយាយទៀយ ខ្ញុំគ្រាន់តែដកដៃស្រស់អ្នកទាំងពួងមើលប៉ុណ្ណោះ ។ ទ្វារធំសម្រាប់ចូលពីខាងកើត មានទីលានខ្ពស់ មានបង្កាន់ដៃនឹងជណ្តើរខាត់ខ្ចង ឡើងពីទិសខាងណាក៏សឹងតែបាន, មានធម្មនូរពីរនៅអមសងខាងនៃទ្វារធំនោះ; កាលពីដើម ព្រៃព្រឹក្សាដុះជិត គេទើបនឹងកាប់ចោលចេញ, សព្វថ្ងៃនេះ, បើយើងចូលទៅដល់ ទីនេះឃើញតែព្រះពុទ្ធរូបនាគប្រក់ជាស្នាដៃយ៉ាងចំណាន គេដាក់រៀបរៀងគ្នា ទ្វារបាលធំសម្បើម ប្រសសរថ្មបួនជ្រុងធំៗ មានស្ត្រីទេពអប្សរកំកាន់ផ្កានៅតួសសរនោះ ។

អ្នកប្រាជ្ញបារាំងសែស ដែលជាអ្នកត្រួតត្រាប្រាសាទនគរ បានពិនិត្យមើលឃើញថា: "ប្រាសាទបាយ័ននេះ មានកិច្ចការជួសជុលច្រើន



មុខលោកេស្វរៈ នៅលើកំពូលប្រាសាទបាយ័ន
ការរចនាប្រាសាទបាយ័ន រវាង គ. ស. ១.២០០

(តាមរូបថត ស.ប.ប.)

ប្រការណាស់, គេមិនមែនកសាងតែម្ដងហើយស្រេចទេ" ។ ពិតមែន, បើយើងមើលដោយសង្កេតហើយ ឃើញថាការកសាងនេះដូច្នោះមែន ដោយមានការផ្លាញ់ផ្លាលនិងឈ្នានីសប្រណាំងប្រជែងលទ្ធិសាសនាគ្នា, គេអាចស្គាល់បាន ដោយការកសាងបន្ថែមគ្រប់គ្រឿងទៀត, និងការពោះគោសលុបរូបអ្វីទីមួយដែលគេមិនពេញចិត្ត, ព្រោះថាដែលកសាងប្រាសាទបាយ័ននេះច្រើនព្រះអង្គ ចែកជា ៣ កាល គឺ កាលព្រះបាទជយវរ្ម័នទី ៧ មួយ, កាលព្រះបាទយសោវរ្ម័នមួយ, កាលសៀមមួយ ។ មុនដំបូងព្រះបាទជយវរ្ម័នទី៧ស្ដេចកាន់ព្រះពុទ្ធសាសនាកសាង, ក្រោយមក ព្រះបាទយសោវរ្ម័នកសាងបង្គ្របថែមទៀត បំបាំងឲ្យក្លាយទៅជាប្រាសាទសាសនាព្រាហ្មណ៍វិញ, ប៉ុន្តែគោលដែលយើងត្រូវយល់នោះគឺប្រាសាទបាយ័ននេះ គេកសាងឧទ្ទិសថ្វាយព្រះពោធិសត្វអវលោកិតេស្វរៈ ឬ លោកេស្វរៈ មានមុខ៤ ជាគោលគំនិតក្នុងព្រះពុទ្ធសាសនាលទ្ធិមហាយាន ។ សូមចំណាំទុកថាៈ ប្រាសាទឯណាដែលគេកសាងមានកំពូលជាក្បាលមានមុខ ៤, ដូចបាយ័ន, តាព្រហ្ម, បន្ទាយក្ដី ជាដើម ប្រាសាទនោះ សុទ្ធតែគេឧទ្ទិសថ្វាយព្រះពុទ្ធសាសនាលទ្ធិមហាយានទាំងអស់, កុំកាន់ច្រឡំដូចយើងពីដើមថាមុខព្រហ្មឡើយ, ភស្តុតាងដទៃទៀតដែលនាំឲ្យយល់ច្បាស់លាស់ ដោយបានឃើញរូបអវលោកិតេស្វរៈ ដែលព្រះបាទយសោវរ្ម័ន សន្ធប់គ្រប់ពីខាងលើនៅថ្នាក់ទី៣ ខាងទិស

ឡៀសានប្រាសាទកណ្ដាល ហើយនឹងព្រះពុទ្ធរូបនាគប្រក់ ដែលគេគាស់ យកបានពីខាងក្នុងប្រាសាទកណ្ដាលកាល ព.ស. ២៤៧៨ ហើយដែល គេយកមកដំកល់ទុកនៅមុខព្រះលាន ។ តមក, ព្រះរាជាដែលសោយ រាជ្យតព្រះវង្ស ជាអ្នកកាន់សាសនាព្រាហ្មណ៍ គោរពពប់អានព្រះឥសូរ មានព្រះបាទយសោវរ្ម័នជាដើម ក៏សាងបន្ទុមបិទប្រកាសព្រះពុទ្ធរូប ចោលចេញ ។

បើប្រសិនជាចូលតាមទ្វារធំខាងកើត, វេលាដែលទៅដល់ថ្នាក់ទី ១ ហើយ នឹងឃើញមានរូបជាច្រើន ដែលឆ្លាក់នៅសសរនឹងជញ្ជាំង, នៅ សសរមានរូបទ្វារបាល ស្ត្រីកាន់ក្បាច់នឹងខ្នាំ, រូបអ្នកស្រុកជម្នា, ដល់ មកត្រង់នេះ ត្រូវបត់ទៅខាងជើង ។

ថ្នាក់ទី ១

រឿងរាជក្សត្រិយ៍

## ជញ្ជាំងខាងកើត ភាគខាងជើង (ពីខាងត្បូងទៅខាងជើង)

នៅជញ្ជាំងនេះឃើញមានរឿងចំបាំងចាមនឹងខ្មែរ កំពុងប្រយុទ្ធគ្នាយ៉ាង សម្បើម ខ្លះដេកដួលស្លាប់ដេរដាសពាសពេញ ទ័ពចាមអបរាជ័យចាញ់ ទ័ពខ្មែរ; ក្នុងសមរភូមិ ឃើញសេនាពាហនទាំង ២ ខាង ច្បាំងគ្នាគួរ ខ្លាច មានគ្រឿងសាស្ត្រាវុធយុទ្ធភណ្ឌ, ទង់ជ័យ, ក្លស់ព្រោងព្រាត ។ នៅ



រូបស្ត្រីទេពអប្សរ រាំបែបទន់ភ្លន់លើផ្កាឈូក នៅសសរ ៤ ជ្រុង
ទ្វារចូលខាងកើត ប្រាសាទបាយ័ន

(តាមរូបថត ស.ប.ប.)

ជ្រុងក្លៀសាន មានយោធាទាំង២ នាក់កាន់តែមានសណ្ឋានជាវង់មូល ទាំងព្រះពុទ្ធរូបនាគប្រក់ គេទើបយកមកដំកល់ទុកក្នុងកាលឥឡូវនេះ ។

## ជញ្ជាំងរោងទងខាងជើង ភាគខាងកើត (ពីខាងកើតទៅខាងលិច)

មានរឿងចម្បាំងតាមទំនងខ្មែរទៀត, ថ្ងៃកាលព្រះបាទយសោវរ្ម័នអបរាជ័យតាញ់តាម; តទៅទៀត មើលមិនច្បាស់ ព្រោះកាលយូរអង្វែងធ្វើឲ្យពុកថ្មអស់, ស្តាយដោយមិនអាចនឹងទាញយករឿងពីដុំថ្មនោះបាន ។ ដល់ទ្វារទិសខាងជើង, ត្រូវចូលទៅមើលរូបចម្លាក់ភាគខាងលិចទៀត ។

## ជញ្ជាំងរោងទងខាងជើង ភាគខាងលិច (ពីខាងកើតទៅខាងលិច)

ដំណាលរឿងស្តេចគង់ក្រសាលសប្បាយក្នុងព្រះរាជវាំង; ក្នុងពិធីបុណ្យ មានរឿងល្បែងខ្មែរបុរាណជាន់នគរវត្តគឺ ល្បែងប្រដាល់, ល្បែងចំបាប់, ល្បែងបង្វិលកង់ដោយជើងគួរល្អមើល ដែលសម័យយើងនេះមិនមានដូច, ល្បែងកុល មានស្រីឈរនៅលើបាតដៃចាំងសងខាង ទាំងឈរនៅលើក្បាលមនុស្សម្នាក់ ហើយតាក់ក្បាច់គួរស្ងើច ដូចល្បែងសៀកដែលយើងឃើញក្នុងបច្ចុប្បន្ននេះ ទាំងមានល្បែងផ្សេងៗជាច្រើនទៀត ។

## ជញ្ជាំងរោងទងខាងលិច ភាគខាងជើង (ពីខាងជើងទៅខាងត្បូង)

មានរូបចម្លាក់មិនទាន់ស្រេច រឿងចម្បាំងនិយាយត្រង់មានជ័យខ្លះ ត្រង់អបរាជ័យខ្លះ; ដល់ទ្វារធំខាងលិច ចូលទៅមើលចម្លាក់នៅជញ្ជាំងរោងទងខាងលិចជ្រៀងខាងត្បូង ។

### ជញ្ជាំងរោងទងខាងលិច ភាគខាងត្បូង (ពីខាងជើងទៅខាងត្បូង)

មានរឿងចម្បាំង, រឿងស្តេចកំសាន្តព្រះទ័យក្នុងព្រះរាជវាំង, មេទ័ពខ្មែរមានជ័យឈ្នះទ័ពចាម មានសេចក្តីរីករាយសប្បាយ, មានរឿងកសាងប្រាសាទ កំពុងដឹកជញ្ជូនដុំថ្មយកទៅកសាង ។ នៅជ្រុងខាងទិសនិរតីមិនទាន់មានរូបអ្វីទេ ។

### ជញ្ជាំងរោងទងខាងត្បូង ភាគខាងលិច (ពីខាងលិចទៅខាងកើត)

មានរឿងចម្បាំងកំពុងយាត្រាទ័ព លើករេហ៍ពលសកលយោធាចេញទៅកាន់សមរភូមិ ។

### ជញ្ជាំងរោងទងខាងត្បូង ភាគខាងកើត (ពីខាងលិចទៅខាងកើត)

មានរឿងកសាងប្រាសាទ, ពួកកម្មករកំពុងកាប់អារថ្ម កាប់ឈើ, ខ្លះកំពុងរៀបចំស្លដណ្តាំគ្រឿងភោជនាហារ នៅកណ្តាលព្រៃតាមរបៀបខ្មែរបុរាណ ដូចយើងបច្ចុប្បន្ននេះដែរ ។ តទៅទៀត មានរឿងចំបាំងត្រង់ទ័ពខ្មែរនឹងទ័ពចាមកំពុងប្រយុទ្ធគ្នា, ពួករេហ៍ពលសកលយោធាខ្លះពាក់មួកមានកំពូលដូចផ្កាត្រឡប់ចុះក្រោម, ទាហានចាមអបកដោយចាញ់ទ័ពខ្មែរ ត្រូវរបួសខ្លះ រួសដួលស្លាប់ខ្លះ, ពួកទាហានកាត់សក់ខ្លី ជាទាហានខ្មែរ មានជ័យឈ្នះទ័ពចាម ។ ភជនារី (ពួកកងទ័ពជើងទឹក) ឃើញសុទ្ធតែទូកពេញដោយសេនាទាហាន, កងទ័ពមួយពួកដែលពាក់



រូបស្ត្រីទេពអប្សរ រាំបែបល្ហាសល្ងន់លើផ្កាឈូក នៅសសរ ៤ ជ្រុង ទ្វារចូលខាងកើត ប្រាសាទបាយ័ន

(តាមរូបថត ស.ប.ប.)

ឬក៏មានកំពូលជាទាហានចាម លើកមកពីប្រទេសចម្ប៉ា តាមដងទឹកមកវាយយកប្រទេសខ្មែរ, ឃើញទ័ពខ្មែរចូលលុកវាយទ័ពចាម, ហើយពលសកលយោធាចាមចាញ់ស្លាប់ធ្លាក់ពីទូក ជាចំណីត្រីក្រពើធ្លាយមករ ៗ តទៅទៀត, និយាយពីល្បែងខ្មែរបុរាណផ្សេងៗ, មានល្បែងប្រដាល់គ្នា ឬពិធីហាត់ប្រាណ, រឿងការលក់ដូរត្រីសាច់នឹងទំនិញផ្សេងៗ, ល្បែងប្រជល់មាន់, រឿងនេសាទ, ចាប់ត្រីមានសំណាញ់, មង, រឿងព្រានព្រៃបាញ់សត្វ, ត្រូវខ្លាដេញខាំ, រឿងទំនៀមឈាបនកិច្ច ដែលជាទំនៀមខ្មែរបុរាណ ។ អ្នកមើលត្រូវសង្កេតឲ្យជាក់ច្បាស់ ដើម្បីប្រៀបធៀបគ្នានឹងទំនៀមខ្មែរបុរាណនឹងបច្ចុប្បន្ននេះ ។

នៅជ្រុងកែងខាងទិសអាគ្នេយ៍ មានរឿងសាសនាព្រាហ្មណ៍ គេធ្លាក់ក្រោយព្រះពុទ្ធសាសនា រឿងអ្នកផឹកស្រា រឿងបារគូបុរោហិត ។

## ជញ្ជាំងរោងទងខាងកើត ភាគខាងត្បូង (ពីខាងត្បូងទៅខាងជើង)

សេនាទាហានមេទ័ពជិះលើដំរី, មានទង់ជ័យ, រឿងច្បាំងមានជ័យជំនះ មានសេចក្ដីត្រេកអរសប្បាយ, មេទ័ពជិះលើដំរី ហែហមដោយពលសកលយោធាតាមជុំជិត យាត្រាទ័ពកាត់ព្រៃព្រឹក្សាមានដើមត្នោត, ដើមឈើធំ, ដើមពោធិ៍, ឃើញទាហានចាមគេចាប់ជាឈ្លើយបាន មានរទេះគោ, ក្របី, សេះ, ដំរី, ការសម្លាប់ក្របីជាគ្រឿងបូជា, ដល់មកកន្លែងត្រង់នេះអស់ថ្នាក់ទី ១ ហើយ ។

កាលណាបើបានមើលថ្នាក់ទី១រួចហើយ, ត្រូវឡើងទៅកាន់ថ្នាក់ទី២តាមជណ្ដើរខាងកើត ។ ការនាំមើលថ្នាក់ទីពីរនេះជាការពិបាកពេក, នឹងនិយាយតែត្រង់រឿងក៏ខ្លះដែលជាគោល, ព្រោះរឿងនៅជញ្ជាំងថ្នាក់ទី២នេះ មានច្រើនជាអនេក មិនអាចនឹងពន្យល់ឲ្យអស់បានឡើយ, អ្នកមើលត្រូវបត់ទៅៈមើលពេញខាងកើត ភាគខាងជើងជាមុនសិន (ពីខាងត្បូងទៅខាងជើង) ។

## ថ្នាក់ទី ២

## រោងទងខាងកើត ភាគខាងជើង (ពីខាងត្បូងទៅខាងជើង)

នៅជញ្ជាំងខាងក្នុង ព្រះបាទយសោវរ្ម័នប្រថាប់នៅក្នុងប្រាសាទ ទតព្រះនេត្រឆ្ពោះទៅរកល្ខោន, អ្នកលេងក្បួននឹងអ្នកដេញពិណ, មានស្រីស្នំក្រមការកាន់ផ្តិតបក់ នឹងគ្រឿងប្រដាប់ឯទៀតជាច្រើន នៅពោមពេមគាល់ហ្វៅ ដូចស្ដេចដែលយើងឃើញសព្វថ្ងៃនេះដែរ, នៅសងខាងផ្ទៃនោះឃើញអគ្គមហេសីប្រថាប់លើគ្រែ មានស្រីគាល់ហ្វៅជាបរិវារ ។ នៅផ្ទៃកណ្ដាល, ខាងស្ដាំទេពតាគង់នៅក្នុងប្រាសាទ, ព្រះបាទយសោ-វរ្ម័នកំពុងច្បាំងនឹងពស់ថ្លាន់, អ្នកមើលអង្គុយជាជួរៗរៀងពួយដោយសេចក្ដីសប្បាយរីករាយ ខ្លះហាក់ដូចជាទះដៃផង មានសេនាពាហននៅចាំថែរក្សាដោយមធ្យ័ត ។ នៅខាងស្ដាំរឿងនេះ, ព្រះបាទយសោវរ្ម័នប្រថាប់ក្នុងប្រាសាទ ទ្រង់ព្រះខាន់ត្រាស់បង្គាប់ឲ្យលើកដុំថ្ម ។ តាមជញ្ជាំងពេញទង



រូបស្ត្រីទេពអប្សរ នៅជញ្ជាំងប្រាសាទកណ្ដាលនៃប្រាសាទបាយ័ន

(តាមរូបថត ព.ស.ប.)

ដែលបត់បែននេះ ទីងឃើញមានរូបផ្សេងៗជាច្រើន, មានសេនាពាហាន, ទ័ពដំរី ទ័ពសេះ ទាំងទ័ពដឹកនាំទ្រព្យសម្បត្តិ, ទីងត្រៃស្នង; នៅចុងខាងជើង ឃើញក្សត្រិយ៍ជិះអង្រឹងស្នងខ្ពស់ជាក្បាលនាគ, មានគេទះទឹមដោយមនុស្ស ។

## រោងទងខាងជើង ភាគខាងកើត (ពីខាងកើតទៅខាងលិច)

ស្តេចស្ថិតនៅក្នុងប្រាសាទ ព្រះហស្តច្រត់លើព្រះខាន់, នាម៉ឺនមុខមន្ត្រីឧបដៃដោយសេចក្តីគោរព ស្តេចទ្រង់គោរពបូជាយញ្ញ, នៅខាងឆ្វេង, ស្តេចទតល្ខោន មានអ្នកវាយស្គរ មានគុក អ្នកដេញពិណ, ស្តេចរៀបទីងឡើងកាន់ថែទឹមដោយមនុស្ស, ឃើញប្រាសាទទទេ ស្តេចទ្រង់ចរចេញយាត្រា សេនាពាហានយាត្រាទ័ព, ឃើញព្រះឥសូរប្រថាប់ក្នុងប្រាសាទកំពុងខ្ទួនាន់សាកែ, ស្តេចគេបាំងដោយក្លស់ត្រានត្រែក ឃើញព្រះនារាយណ៍ទីងនាងលក្ស្មី ។ តាមកេងទងដែលបត់បែន មានរូបជាច្រើនទៀត រូបខ្លះមិនសូវល្អ ឃើញព្រះឥសូរ ព្រះនារាយណ៍ ក្រុងរាពណ៍ទសមុខ ដៃមួយពាន់ កំពុងចាប់ក្តីកៃលាសអង្រួនដោយសេចក្តីពញ្ញាទីស; តទៅទៀត, ព្រះឥសូរជិះគោនន្ទិ ឧបនាងបត្តីនៅលើភ្លៅ ល្ខោនកំដោយសូរភ្លេង ។

## រោងទងខាងជើង ភាគខាងលិច (នៅចន្លោះទ្វារធំនិងទ្វារតូចខាងលិច)

ខាងត្បូង ព្រះឥសូរជិះលើគោនន្ទិ, នៅផ្ទៃកណ្ដាល ទេពតាកាមៈ កំពុងបើកធ្នូបាញ់ព្រះឥសូរ, ព្រះឥសូរបើកភ្នែកត្រឡែកទៅឆេះទេពតាកាមៈជាផេះ ៗ តាមរឿងទងដែលបត់បែន, ខាងត្បូង ព្រះឥសូរនៅលើភ្នំកៃលាស ព្រះព្រហ្មមានមុខ៤ និងព្រះនារាយណ៍នៅអមសងខាង ៗ នៅផ្ទៃកណ្ដាល ព្រះឥសូរដៃ១០ មានព្រះព្រហ្មនិងព្រះនារាយណ៍នៅអមទៀត, ឃើញមានពួកល្ខោនតាណ្ឌវៈ ដែលល្បីឈ្មោះក្នុងស្ថានសួគ៌តាមសម័យបុរាណ មានល្បែងប្រណាំងទូក មានទូកបី មានក្បាលនិងកន្ទ្យ ធ្លាក់ក្បាច់យ៉ាងល្អឆើត ៗ

## រោងទងខាងលិច ភាគខាងជើង (ពីខាងជើងទៅខាងត្បូង)

មានរឿងកូរសមុទ្រទឹកដោះ តែជញ្ជាំងរោងទងនេះ ពុករលេះត្រង់ចំពាក់កណ្ដាល ត្រង់នេះជាកន្ទួងល្អវិសេសក្នុងប្រាសាទបាយ័ន គួរស្ដាយណាស់, គេឃើញពួកអសុរនិងពួកទេពតា ឃើញនាគវាសុកិពេទរុំភ្នំ ដែលជាស្នូលសម្រាប់ទាញបង្វិលកូរសមុទ្រទឹកដោះ ស្វាដែលទាញកន្ទុយនាគនោះប្រហែលជាហនុមាណ ព្រោះស្វាជាបក្សពួកនៃអសុរ ៗ ស្នូលដែលសម្រាប់ទាញនោះ មានទ្រង់ទ្រាយជាសសរ មានកំពូលជាផ្កាឈូក



ព្រះនារាយណ៍ដៃ ៤ មានទេពធីតានឹងមនុស្សប្រណម្យ ប្រាសាទបាយ័ន ។

( តាមរូបថត ព. ស. ប. )

ហើយស្ថិតនៅលើវិស្ណុ ដែលអវតារជាអណ្ដើក; នៅសងខាងកន្លែងកូរ សមុទ្រ ឃើញមានសត្វច្រើនយ៉ាង ដូចសេះ ដំរីជាដើម ដែលកើតចេញ មកអំពីការកូរសមុទ្រ ៗ នៅលើខ្លួននាគ, គេមើលឃើញដបសម្រាប់ ដាក់ទឹកអម្រឹត, រង់មូលនៅសងខាង ជាតួព្រះអាទិត្យនិងព្រះចន្ទ្រ, ឯ ពួកទេវតាឯទៀតក៏យោះហោះគេឃ្លាតខ្ទី រូបបម្រាក់មានសណ្ឋានដូចយើង ឃើញនៅនគរវត្ត ៗ តទៅទៀត, មានរឿងថ្លែងពីពួកខ្លាំងធ្វើចេញនាំ សំដែងសេចក្ដីក្លៀវក្លា ក្នុងការប្រយុទ្ធសង្គ្រាម; តទៅទៀត, ពួកសេនា ទាហាន និងពួកក្មេងកាយស្គរ ជាទីសំរើបចិត្ត, ផ្នែកកណ្ដាល មានរឿង យាត្រាចំពងទឹងចមកពលជិះលើរទេះ ៗ

## រោងទងខាងលិច ភាគខាងត្បូង (ពីខាងជើងទៅខាងត្បូង)

នៅខាងលើ, ពួកឫសីចំរើនធម៌ក្នុងគុហា មានអ្នកហែលទឹក សត្វ ម្រឹគបោលយ៉ាងលឿន មានបក្សីពាំផ្លែ, ភាគខាងក្រោម ផ្ទៃព្រះកដក់ង; នៅផ្នែកកណ្ដាល, រឿងចំពងនឹងទឹក រឿងវិស្ណុ ៗ ខាងស្ដាំ, មានរឿងក សាងផ្ទះថ្មល់ មានពួកកម្មករកំពុងតាក់តែងការងារតាមមុខក្រសួង; តទៅ ទៀត, មានរឿងស្រីមុជលេងក្នុងទឹក ខ្លះហែល ខ្លះតែងខ្លួន; ផ្នែកកណ្ដាល មានរឿងកំនៅក្នុងប្រាសាទ អ្នកដេញពិណាបែបបុកណា ខ្សែពិណាគេ មើលឃើញច្បាស់; នៅខាងក្រោម, ខាងស្ដាំទ្វារ មានរឿងចម្បាំងជំរែង

ពួកពលថ្មើរជើង, នៅកណ្ដាលសមរភូមិ ឃើញវិស្ណុជិះលើគ្រុឌ ពួករបាំ ពលសេះពលយោធាទាំងសងខាង ស្ទើរតែពាក់មួកមានកំពូលដូចផ្កា សាគ ខាងក្រោមពួកសេនាពាហន ។

## រោងទងខាងត្បូង ភាគខាងលិច (ពីខាងលិចទៅខាងកើត)

បើនៅប្រាសាទ ស្ដេចប្រថាប់កណ្ដាលពួកសេវកាមាត្យ ទ្រង់ត្រាស់បង្គាប់កិច្ចការរាជការ, ភាគខាងក្រោម ពួកអ្នកចាត់ចែងគ្រឿងបូជាយញ្ញ; គេមើលឃើញថាមានកន្ច្បាស់ទ្រង់សម ជារថសម្រាប់ព្រះរាជដំណើរ ប្រហែលជាក្បួនព្រះរាជដំណើរទៅនមស្ការព្រះវិស្ណុ ពួកអ្នកគោរពក្រាបសំពះគ្រៀបត្រា នៅខាងមុខមានស្រះ ។ នៅក្រោមដើមឈើ មានពួកឫសី, ពួកបក្សីហើរត្រៀលធ្លាក់នៅខាងលើ, ទីបំផុតផ្ទៃ ព្រះឥស្សូរសណ្ឋិតឈរ; តទៅទៀត, ខាងឆ្វេង ឃើញព្រះឥស្សូរទាបកន្ទៀកាន់ត្រីសូល៍ ទីងពួកអ្នកលេងភ្លេង, នៅផ្ទៃកណ្ដាល ព្រះឥស្សូរប្រថាប់នៅលើផ្កាឈូកធំ មានពួកបរិពារនៅហែហមជុំវិញ; ខាងស្ដាំ, រឿងផ្ទៃព្រះរាជវាំង មាននាម៉ឺនម្នាក់ដេក គេមើលឃើញតែក្បាល ហាក់ដូចជាព្រួយចិត្តជួសអ្នកដែលអង្គុយនៅប្របខាង; ដល់មកត្រង់នេះអស់ថ្នាក់ទី២ហើយ ។ នៅថ្នាក់ទី២ បើមានឧកាសល្អ គួរទៅមើលអណ្ដូងក្នុងប្រាសាទ តែត្រូវឲ្យមានបះផ្នៀងពិល ឬភ្លើងអ្វីមួយបំភ្លឺមើល អណ្ដូង



រូបសីហៈនៅគោបុរៈខាងជើងនៃប្រាសាទបាយ័ន

( តាមរូបថត ព. ស. ប. )

នេះស្ថិតនៅជ្រុងឦសាន ត្រូវដើរចូលតាមមាត់ទ្វារធំខាងកើត បត់ទៅខាងជើងបន្តិច ចូលទៅក្រោមកន្លែងងងឹតៗបន្តិច ទៅដល់អណ្តូងនោះ មានបង្កាន់ដៃកាំងកុំឲ្យមានគ្រោះថ្នាក់ ចេញទៅខាងលិចទើបមានពន្លឺ ។ មើលរួចហើយ ត្រូវដើរចេញតាមក្រោមកន្លែងនេះទៅខាងលិច ទៅឡើងជណ្តើរខាងជើងទៅថ្នាក់ទី ៣ ។

លុះអ្នកមើលបានដើរមើលជាន់ទីពីរហើយ គួរឡើងទៅមើលជាន់ទី ៣ ជាជាន់លើបង្អស់ទៀត តែសូមរំឭកថា កាលដែលដើរមើលព័ទ្ធជុំវិញប្រាសាទនោះ អ្នកពល់គ្នាតែងបានឃើញជណ្តើរនៅទិសខាងត្បូង១ ខាងជើង១ ជណ្តើរទាំងពីរទិសនេះគេឡើងបានដោយស្រួល, សូមកុំឡើងតាមជណ្តើរទិសខាងកើតនិងខាងលិច ព្រោះជណ្តើរទាំងពីរទិសនេះសឹករលិលអស់ហើយ អាចឲ្យគ្រោះថ្នាក់ដល់អ្នកឡើងស្ទើរតែគ្រប់ពេល, ម្យ៉ាងទៀត សូមប្រយ័ត្នព្រោះប្រាសាទបាយ័ននេះ ផកគ្រាំគ្រាជាងប្រាសាទទាំងពួង អាចឲ្យគ្រោះថ្នាក់ច្រើនប្រការណាស់ ។

ថ្នាក់ទី ៣

ថ្នាក់ទី ៣ នេះ, មានប្រាសាទជាច្រើន ទាំងតូចទាំងធំចំនួន ៦១ ប្រាសាទ នៅព័ទ្ធជុំវិញប្រាសាទធំកណ្តាល, ប្រាសាទមួយៗមានទ្វារ ៤ ស៊ុម ៤ កំពូលជាក្បាលលោកេស្វរៈមានមុខ ៤ មានមកុដទ្រដោយផ្កាឈូក

មានទំហូពាក់ទៅត្រចៀក; នៅទិសឦសានប្រាសាទធំកណ្ដាល, គេបាន រើថ្មសន្ទប់ចេញ ហើយឃើញរូបលោកេស្វរៈយ៉ាងល្អដូចជាថ្មីៗ គេយល់ ថា ព្រះបាទយសោវរ្ម័ន បិទសន្ទប់បំបាត់រូបព្រះពុទ្ធសាសនា, ផ្ទៃខាងលើ បែបនេះ ព្រះបាទយសោវរ្ម័នស្ដេចកសាងថែមគ្របសង្កត់ពីលើ លាត ទៅដល់លើប្រាសាទជាន់មុន បាត់មុខទ្វារអស់, មានឆ្មាំទ្វារពីរ នៅអម យ៉ាដែលលយចេញមកខាងមុខ; ត្រង់នេះ, គេឃើញមុខលោកេស្វរៈធំ សំបើមៗនៅក្បែរខ្លួន មើលទៅមុខញញឹមពព្រាយដូចផ្កាឈូកសព្វ ទិសនានា, មុខមួយៗមានទំហំ១ម៉ែត្រ៧៥ ឬ២ម៉ែត្រ៥០ មើលទៅ កំពូលប្រាសាទកណ្ដាលខ្ពស់ត្រដូចជាប់អាកាស បាក់មុខធ្លាក់អស់ ឃើញតែដុំថ្មដំរួតលើគ្នា ទ្រេតហាក់ដូចជាគេគល់រលំមកសង្កត់លើ គួរ ទីកស្ដាយណាស់, ងើយមើលទៅខាងលើ ឃើញពពកសោត់លៀនលយ គួរស្រងេះស្រងោច គួរឲ្យទឹកភ្នែកសប្បាយរីករាយ, បើប្រសិនជាពេល កក្រិមានព្រះចន្ទ្រពេញវង់រះត្រចង់ចេញគេធាយ ទីងរឹតរឹងតែសប្បាយឥត ឧបមាគួរឲ្យតែទឹកប្រៀងអនិច្ចាឧណា... បន្ថែមកំសាន្ដចិត្តទៀត ។

បណ្ដាក្បាច់ចម្លាក់ដែលមាននៅប្រាសាទបាយ័ននេះ សុទ្ធតែជា ក្បាច់យ៉ាងល្អៗ. ដូចក្បាច់នៅអមសងខាងទ្វារ បង្អួចទីងក្រោមទ្វារ នៅសុំមទ្វារ ឬហោជាង អាចទាញភ្នែកអ្នកមើលឲ្យឈប់ឈរមើល មាន អាការហាក់ដូចជាទទួលអ្នកដំណើរគ្រប់គ្នា ។ ទីបាយ័នខាងលើ បើឃើង



ពេ. ប៉ុរៈនៃរោងទងខាងជើង ប្រាសាទបាយ័ន

( តាមរូបថត ព. ស. ប. )

បានមើលក្នុងវេលាដែលព្រះអាទិត្យទៀបអស្ដង្គត ខ្ទុះក៏រឹងរឹតតែល្អមើលណាស់ដែរ ព្រោះប្រាសាទទាំងអស់ ហាក់ដូចជាផុសលេចចេញមកអំពីព្រៃព្រឹក្សលតាជាតិ កាលពន្លឺព្រះអាទិត្យចាំងមកប៉ះក៏លេចចេញមុខលោកេស្វរៈហាធំ ញញឹមពព្រាយគ្រប់មុខមកទទួលយើងទាំងអស់គ្នា ៗ

លុះមើលសព្វគ្រប់ហើយ ត្រូវចុះទៅតាមទ្វារខាងជើង, ត្រូវធ្វៀតចូលមើលព្រះពុទ្ធរូបធំនៅទិសទិរតី, តាមថ្នល់ខាងឆ្វេងដៃ, តទៅខាងលិចបន្តិច · មានចេតិយជាទីរឭកដល់លោក ជ. កុម្មៃយ៍ (J. Commaille) ស្លាប់ដោយចោរប្លន់ក្នុងវ័យអាយុ ៤៨ ឆ្នាំ នៅថ្ងៃ ៣០ ខែអាវ៉ិល ឆ្នាំ១៩១៦; តាមផ្លូវខាងលិចប្រាសាទបាយ័ន មានសិលាចារឹកនិយាយអំពីក្រុងចាស់មុននគរធំ ដោយហេតុនេះ បានជាគេដឹងរឿងនគរធំនេះ; តពីចេតិយលោក ជ. កុម្មៃយ៍ ប្រហែល ២០០ ម៉ែត្រមកដល់រូបលោកការប៉ូ (Carpeau) ស្លាប់ក្នុងឆ្នាំ ១៩០៤ ដោយរោគគ្រុនចាញ់, លោកនេះជាជាតិបារាំងសែសម្នាក់ ដែលខ្នះខ្នែងក្នុងការស្រាវជ្រាវរករឿងក្នុងនគរធំ; តមកទៀត ២៥ ម៉ែត្រ, ឆៀងខាងទិសពាយ័ព្យ មកដល់ឃ្លាំងសម្រាប់ដាក់របស់បុរាណ ដែលគេរើសយកមកដំកល់ទុក, នៅឃ្លាំងនេះមានរូបចម្លាក់ប្លែកៗ គួរទៅពិនិត្យមើល មានរូបខ្លះគេមិនទាន់ស្គាល់ថាជារូបអ្វីនៅឡើយ, នៅខាងជើងប្រាសាទបាយ័ន

មានទីវត្តចាស់មួយ មានសន្ទឹកសីមា មានព្រះពុទ្ធរូបធំមួយអង្គ, ខាងមុខ
មានព្រះពុទ្ធរូបចូលនិព្វានកង់ស័ក្តិសម, វិហារឈើនេះ គេទើបនឹងធ្វើថ្មី
ទេ ដើម្បីនឹងគ្របលើព្រះពុទ្ធរូបនេះ ។



រឿងចម្បាំងព្រះរាមនឹងរាពណ៍ គោបុរៈខាងជើង កំពែងទី ២

យ៉ៈខាងកើត មុខខាងជើង ប្រាសាទបាពួន

( តាមរូបថត ស. ប. ប.)

# ប្រាសាទបាពួន

លុះបានមើលប្រាសាទបាយ័ននិងអនុស្សាវរីយ៍ ដែលនៅជុំវិញប្រាសាទរួចស្រេចហើយ ត្រូវចេញទៅតាមផ្លូវធំចំទៅលើព្រះលានតែបន្តិច ប្រហែល២០០ម៉ែត្រត្រូវឈប់ ហើយចុះពីរថយន្ត, គ្រាន់តែងាកក្រែកមើលទៅខាងលិចនឹងឃើញប្រាសាទបាពួនធំខ្ពស់ស្កឹមស្កៃ ចុះដើរទៅខាងលិចបន្តិចនឹងដល់គោបុរៈ (ខ្លោងទ្វារ) ទី ១ ជាខ្លោងទ្វារធំខាងកើត មានកំពែងប្រកបដោយខ្លោងទ្វារ ជាប់គ្នាដឹកមកពីទីព្រះលានដែលស្ថិតនៅខាងជើង ខ្លោងទ្វារធំនេះ បាក់បែកអស់ហើយ នៅសល់តែសសរប្រាង, ចូលត្រង់កាត់សំដៅទៅខាងលិច ដើរលើស្ពានថ្មដែលបាក់បែកគ្រាន់តែមានបង្គោលថ្មរៀងគ្នា ក្រាលថ្មមួយសន្លឹកៗជាប់គ្នា ប្រហែល ៣០០ ម៉ែត្រហួសទៅដល់គោបុរៈទី ២ គឺខ្លោងទ្វារកំពែងក្រៅ ខ្លោងទ្វារនេះ ជាប្រាង្គខ្ពស់ឡើងហើយមានយ៉ាលយចេញទៅ៤ទិស, ឆ្លងខ្លោងទ្វារចូលទៅមានស្ពានទៀត, តែស្ពាននេះបាក់ហើយ នៅសល់តែបង្គោលថ្ម បាត់សន្លឹកថ្មក្រាលអស់ ឆ្លងទីស្ពានផុតទៅដល់គោបុរៈទី ៣ នៅខ្លោងទ្វារនេះ មានរោងទងជាកំពែងព័ទ្ធជុំវិញ, ឆ្លងផុតទៅដល់ថ្នាក់ទី ១ ដែលត្រូវឡើងទៅកាន់ថ្នាក់ទី២ ត្រូវដើរសៀតតាមគូប្រាសាទទៅជណ្ដើរខាងត្បូង ជណ្ដើរនេះចោតបន្តិចតែស្រួលឡើង ។ ថ្នាក់ទី២នេះមាន

កេងទង ប្រកបខ្លោងទ្វារព័ទ្ធជុំវិញប្រាសាទធំ តែបាក់បែករលំអស់ហើយ, នៅសល់តែខ្លោងទ្វារគ្រប់ទិស ឃើញមានរូបចម្លាក់រឿងរាមកេរ្តិ៍និងមហាភារតៈខ្លះ ៗ ផ្សំគ្នានឹងរឿងខ្មែរសម័យនគរ ។

## គោបុរៈខាងត្បូង

មុខខាងត្បូង យ៉ាងលិចៈ ដំណាលអំពីក្រឹស្ណៈកាលនៅជាកុមារ ភាគខាងក្រោម ខាងឆ្វេង ថ្លែងពីការសម្លាប់កុមារ, ក្រឹស្ណៈកាប់នាគក្បាល ៦ ជាពីរកំណាត់ ។

មុខខាងត្បូង យ៉ាងកើតៈ និយាយពីរឿងចម្បាំង, ឥសីនិងជ្រូកព្រៃ, សេនាពាហនទនឹងយក្ខ, ឥសីអង្គុយក្រោមដើមឈើ ដៃកាន់ក្បាលដាច់ក ដែលត្រូវសរ ។

មុខខាងជើង យ៉ាងកើតៈ រឿងរាមកេរ្តិ៍, ស្វាសម្ពន្ធមិត្រព្រះរាម ច្បាំងតតាំងនឹងយក្ខ, គេស្គាល់បានដោយក្អែកក្រឡេកនឹងសក់ក្រញាញ់; ភាគខាងលើ, នាងសីតាស្ថិតនៅក្នុងព្រៃអសោក មានយក្ខិនីពីរនាក់ថែរក្សា ព្រះនាងទទួលហនុមាណដែលព្រះរាមបញ្ជូនមក; ភាគខាងក្រោម មិនប្រាប់ថារឿងអ្វី ដូចឥសីកូរទឹកក្នុងពាង ដំណាងកូរសមុទ្រទឹកដោះ, មនុស្សឈើ និងព្រះវិស្ណុ ... ។

មុខខាងជើង យ៉ាងលិចៈ ចម្បាំងមនុស្សនឹងសត្វ. និងរឿងនៅក្នុងព្រៃ... ។

# គោបុរៈខាងកើត

មុខខាងកើត យ៉ខាងត្បូងៈ រឿងកមកេរ្តិ៍ៈ នៅថ្នាក់ពីខាងលើ លោកហ៊្វីណូត៍ពន្យល់ថា រូបមួយជាព្រះកម, មួយទៀតនាងសិតា ប្រថាប់នៅកណ្តាលព្រៃព្រឹក្សៈ នៅថ្នាក់ទី ៣ ការផុតនាងសិតា ព្រោះឃើញនាងសិតាស្ថិតនៅកណ្តាលភ្លក់ភ្លើង ដៃប្រណម្យស្ទើទីងព្រះសិរ ៗ ខាងស្តាំទេពតាឈ្មោះអគ្និចូលទៅរកព្រះកម ធ្វើជាសាក្សីនិយាយពីសេចក្តីបរិសុទ្ធិនៃនាងសិតាៈ មហេស្វរៈ (ព្រះឥស្វរ) ជិះគោហែហមដោយបរិពារ ស្តេចទតព្រះនេត្ររឿងនេះៈ ភាគខាងក្រោម ព្រះកមនាងសិតា ស្វាមីភរិយានៅចួបជុំគ្នាៈ ភាគខាងក្រោម មានរឿងស្ត្រីជំនិត មានគេប្រថាប់ទីងតែងកាយឲ្យ, តទៅទៀត រឿងចម្បាំង ៗ

មុខខាងកើត យ៉ខាងជើងៈ រឿងសេនាទាហានក្នុងរឿងមហាភារតៈ, គេមើលឃើញមេទាហានត្រូវសរធ្លាក់ពីលើរទេះ រូបនេះគឺលោកមេទ័ពពួកកៅរវៈឈ្មោះភីស្មៈ; ខាងក្រោម, សេនាទាហានលេងភ្លេងៈ នៅស៊ុមទ្វារ មានមនុស្សសំពតស្រីម្នាក់ ស្រីនេះប្រហែលជានាងទេវី? ៗ

មុខខាងលិច យ៉ខាងជើងៈ ខាងក្រោម, គេយកដំរីពីរទៅចាប់ដំរីព្រៃមួយផ្សាំងៈ ភាគលើ ពួកឥសីអង្គុយក្រោមដើមឈើ, នៅខាងត្បូងស្រីម្នាក់ត្រូវសរ ៗ

# គោបុរៈខាងជើង

មុខខាងជើង យ៉ាងកើត. រឿងរាមកេរ្តិ៍, លោកហ្វីណូត៍សរសេរថា៖ នៅផ្ទាំងលើ, រាពណ៍ឈរលើព្រះរាជរថ ច្បាំងតតាំងនឹងព្រះរាម, ព្រះរាមជិះលើហនុមាណ ច្បាំងកាប់សេះទឹមរថរាពណ៍ឲ្យធ្លាក់ក, ការច្បាំងនេះក្តៅក្រហាយណាស់ ព្រោះនៅផ្ទាំងក្រោម ឃើញហនុមាណលោតទៅលើរថរាពណ៍ ដែលទឹមដោយមករក្បាលជាមនុស្ស; ផ្ទាំងក្រោមទៀត, ព្រះរាមយកធ្នូបាញ់បណ្តាមិត្រ ៗ នៅផ្ទាំងលើមានរឿងខ្លះទៀត, និយាយពីស្វានឹងយក្សច្បាំងគ្នា, នៅផ្ទៃកណ្តាល លោកហ្វីណូត៍ពន្យល់ថា៖ នាងសិតាដែលរាពណ៍លួចយកទៅលាក់ទុកក្នុងប្រាសាទ, នាងគង់នៅក្នុងព្រៃអសោក, ខាងឆ្វេង ពួកយក្ខិនីនៅចាំថែរក្សា, ខាងស្តាំ កាលហនុមាណស្វែងរកព្រះនាង បានចួបនឹងព្រះនាង ក្រាបទូលអំពីរឿងព្រះរាមជាព្រះរាជស្វាមី, បង្ហាញនៅដៃហនុមាណនោះ គឺចិញ្ចៀន ដែលនាងសិតាផ្ញើទៅថ្វាយព្រះរាម ជាភស្តុតាងឲ្យដឹងថា ហនុមាណបានចួបនឹងព្រះនាងសិតាហើយ; ផ្ទៃក្រោម, ព្រះរាមជិះរថទឹមដោយសេះក្បាលមនុស្ស បាញ់សរព្រោងព្រាត ៗ

មុខខាងជើង យ៉ាងលិច៖ ភាគខាងលើ ខ្មាក់បរជ័រទៅប្រជល់គ្នា, រឿងកូរទឹកក្នុងពានជាតំណាងកូរសមុទ្រទឹកដោះ; ខាងក្រោម, រឿង

ព្រះរាមនឹងព្រះលក្ស្មណ៍ ចងស្ពានមេត្រីនឹងសុគ្រីព ។ លុតជង្គង់ទៅរក ពាលីដែលត្រូវសរ; នៅខាងក្រោម, ចម្បាំងសុគ្រីពនឹងពាលី ឃើញពាលីស្លាប់ ។ នៅខាងឆ្វេង បែរទៅខាងស៊ុមត្រា មានរឿងរាមកេរ្តិ៍ទៀត, លោកហ្វ៊ីណូត៍ពន្យល់ថា: កាលច្បាំងនៅក្រុងលង្កា បុត្រភពណ៍ម្នាក់សែកមន្ត បាញ់សរសំដៅទៅព្រះរាមនឹងព្រះលក្ស្មណ៍ ហើយក្លាយទៅជាពស់ រុំព័ទ្ធព្រះរាមនឹងព្រះលក្ស្មណ៍ដួលដេកនៅលើផែនពសុធា ហើយមានសេនាទាហានតាមរោមជាបរិវារ; គេមើលឃើញស្វាដែលទៅត្រេចរកដើមឈើធ្វើជាថ្នាំ នៅក្នុងសមុទ្រទឹកដោះ ដើម្បីនឹងយកមកប្រោះព្រះរាមនឹងព្រះលក្ស្មណ៍ឲ្យរស់ឡើងវិញ, ក្នុងកាលនោះ, នៅលើអាកាសឃើញពពកខ្មួលទៅដូចខ្យល់ព្យុះ គឺគ្រុឌបក្សីដែលហោះកៀកក្នុងមួយជំពាស់ដៃ ឯពស់ឃើញគ្រុឌមកដូច្នោះ ក៏ភ័យហើយហោះរត់ទៅវិញបាត់អស់, គ្រុឌយកដៃស្ទាបស្ទាមរបួសព្រះរាមព្រះលក្ស្មណ៍ធ្វើឲ្យជាឡើងវិញ; គេមើលឃើញព្រះរាមនឹងព្រះលក្ស្មណ៍ដែលមានជន្មាយុហើយ និយាយគ្នាជាមួយនឹងគ្រុឌឥតដៃ, នៅខាងលើ ឃើញហង្សហោះទៅប្រាសាទ ហង្សនេះជំណាងរថបុស្បកដែលយើងឃើញនៅអង្គរវត្ត (ជ្រុងពាយ័ព្យ); លុះរាយក្រុងលង្កាឈ្នះហើយ, ព្រះរាមលើកក្បួនទ័ពយាត្រាត្រឡប់មកកាន់ក្រុងអយុធ្យា ព្រមដោយរេហ៍ពលសកលយោធាវិញ ។

មុខខាងត្បូង យ៉ាខាងលិចៈ រឿងចម្បាំងនៃសេនាពាហនៈ ដែលមានសត្វពាហនៈទៅជាមួយផង, នៅកៀន, ឃើញខាងសំពាអន្ទុយនៅក្នុងព្រៃសោកទៀត ។

មុខខាងត្បូង យ៉ាខាងកើតៈ ប្រហែលជារឿងកាមកេរ្តិ៍ទៀត ខាងស្តាំ ឃើញសេះ នៅជើងសេះឃើញទន្សាយពោល ។

## គោបុរៈខាងលិច

មុខខាងលិច យ៉ាខាងជើងៈ ស្វាទំនងយក្សច្បាំងគ្នា រឿងចម្បាំងផ្សេងៗ ។

មុខខាងលិច យ៉ាខាងត្បូងៈ មានមនុស្សបាញ់យក្សសក់ក្រញាញ់, ពាហនម្នាក់ៈលាតទៅលើបច្ចាមិត្រ ចាប់សក់ទាញហើយសម្លាប់ចោល, ខាងក្រោម អ្នកលេងភ្លេង, នៅខាងឆ្វេង ដូចជាមនុស្សខ្លាំងពូកែម្នាក់ចាប់ដំរីគ្រវ៉ី ។

មុខខាងកើត យ៉ាខាងត្បូងៈ ចម្បាំងសត្វ, ខាងលើឃើញសេះ, គមក ស្វាទំនងពាហនច្បាំងគ្នា; រឿងល្អមើល, ឃើញមនុស្សម្នាក់ត្រូវរបួសដួល មានដំរីតូចមួយចាំទ្រពំខាងក្រោម ។

មុខខាងកើត យ៉ាខាងជើងៈ រឿងចម្បាំងផ្សេងៗ ។

ដើម្បីនឹងឡើងទៅថ្នាក់លើបន្ទស់ ត្រូវឡើងតាមជណ្តើរនៅទិសខាងត្បូង ព្រោះមានជណ្តើរគេធ្វើថ្មីទៀត ស្រួលឡើងមិនមានគ្រោះថ្នាក់

ឡើយ ៗ ខ្ទាំងថ្មទីងកេងទន្ទ័ត្ចជុំវិញ បាក់ធ្លាក់អស់ហើយ, ឯប្រាសាទកណ្ដាលក៏រលំអស់ហើយដែរ កាលពីដើមមានដើមព្រៃមួយដុះនៅពីលើគួរឲ្យស្ដាយណាស់ បើប្រសិនណាជាបានចិតថែរនៅសមនឹងល្អណាស់ ៗ តាមអ្នកដំណើរចិនឈ្មោះចៅតាក្វាន់, កាលចុងសតវត្សរ៍ទី ១៩ នៃពុទ្ធ-សករាជ និយាយថា "ប្រាសាទបាពួននេះល្អណាស់ កំពូលស្រោបដោយស្ពាន់ក្ដីផ្ទុក មើលទៅឃើញល្អអស្ចារ្យ" ៗ

ពិតមែន, ប្រាសាទបាពួននេះ ជាក្រុងទី ៣ មុននគរធំ, កាលពីដើមឈ្មោះ ហិមាទ្រិ "កំមាស" សមដូចពាក្យអ្នកដំណើរចិន ៗ កាលណាបើគេបានឡើងទៅដល់ថ្នាក់លើហើយ នឹងឃើញទ្រង់ល្អធើក ជំនួសស្ទឹមស្រែម៉ាសំបើម ករមូលដូចព្រះស្តូបឬដូចក្ដួ ដូចជាផុសកណ្ដាលព្រៃព្រឹក្សា មើលទៅខាងជើងឃើញប្រាសាទវិមានអាកាស ទៅខាងកើតឃើញទីព្រះលាន ។ តាមសិលាចារឹក, ប្រាសាទបាពួននេះ ព្រះបាទឧទយាទិត្យវរ្ម័នទី ២ ទ្រង់កសាងក្នុងសតវត្សរ៍ទី ១៧ នៃពុទ្ធសករាជ (ព.ស.១៦០៣) ដើម្បីឧទ្ទិសថ្វាយទេពតាខាងសាសនាព្រាហ្មណ៍ឈ្មោះ ហោមស្រីវដ្តស្វរៈ ប្រែថា "ទេពតាធំមានស្នងមាស" ៗ កាលពីមុន, មានព្រះពុទ្ធរូបចូលនិព្វាន ប្រហែលជាកាលគេមក, អ្នកសាសនាពួកហីនយានយកមកដម្កល់ទុក ៗ

លុះមើលរួចហើយ ត្រូវចុះមកវិញតាមជណ្ដើរខាងត្បូង ដល់មកថ្នាក់ខាងក្រោម សឹមបត់មកខាងកើត តាមខ្លោងទ្វារធំខាងកើត ហើយដើរកាត់ទៅខាងជើង តាមផ្លូវជើងសៀរតាមកំពែងប្រាសាទបាពួននិងវិមានអាកាស ឆ្លងកំពែងនេះចំទៅខាងជើង តំរង់ទៅប្រាសាទវិមានអាកាស ។ បើពុំនោះ ត្រូវត្រឡប់មកទីព្រះលានខាងកើតវិញក៏បាន ដើរបត់ទៅខាងជើងព្រះលានរហូតទៅដល់ខ្លោងទ្វារធំ សឹមចូលទៅមើលផ្ទៃព្រះរាជវាំង ឬ វិមានអាកាសក៏បាន ។

## ទីលានជិតវិមានអាកាស

នៅខាងជើងប្រាសាទបាពួនបន្តិច ជាស្ថានព្រះរាជវាំង មានកំពែងថ្មបាយក្រៀមពីរជាន់ ពីទិសកើតទៅទិសលិចចំនួន៦០០ម៉ែត្រ ពីទិសត្បូងទៅទិសជើងចំនួន៣០០ម៉ែត្រ ។ មានអ្នកខ្លះកាន់ប្រឡំថា ទីក្នុងកំពែងពីរជាន់នេះ គេហៅវិមានអាកាស (អាកាសវិមាន?). សេចក្ដីនេះមិនដូច្នោះឡើយ ផ្ទៃទាំងមូលនេះហៅថា ព្រះរាជវាំង, ដែលហៅថាវិមានអាកាសនោះ ចំពោះតែប្រាសាទមួយដែលស្ថិតនៅក្នុងផ្ទៃព្រះរាជវាំងនោះប៉ុណ្ណោះទេ ។ កំពែងទាំងពីរជាន់នេះ កំពែងខាងក្រៅមិនសូវមាំមួន បាក់បែកធ្លុះធ្លាយជាច្រើនកន្លែង, ខាងកើតជាប់គ្នានឹងទីព្រះលានដែលកាត់បណ្ដោយតាំងពីខាងមុខប្រាសាទបាពួន រហូតដល់ទីលានស្ដេចគំលង់, កំពែងខាងក្នុងស្ថិតថេរនៅឡើយ ព្រោះការកសាងមាំដោយការពិនិត្យពិច័យ, កំពស់៦ម៉ែត្រព្រមទាំងមានបន្ទល់ផង; នៅចន្លោះកំពែងទាំងពីរនេះ មានស្រះមួយមានជណ្ដើរជាថ្នាក់ៗចុះទៅ ។ ទ្វារសម្រាប់ចូលទៅកាន់ផ្ទៃព្រះរាជវាំងនេះមាន៥, ទ្វារពីរចូលពីខាងត្បូង, ពីរពីខាងជើង, មួយពីខាងកើត, ទ្វារទាំង៥កន្លែងនេះ សុទ្ធសឹងប្រកបដោយកំពូលជាតួប្រាសាទដ៏មានក្បាច់របនាពិចិត្រ; មុខព្រះលានទទឹង ១៤ម៉ែត្រ បណ្ដោយ ៣៥០ម៉ែត្រ ជាទីខ្ពស់ មានជណ្ដើរទាបៗ

ឡើងចំពីខាងកើតត្រង់កន្លែងលយចេញទៅមុខ ។ តាមអ្នកដំណើរចិនឈ្មោះចៀវតាក្វាន់និយាយថា: "ទីព្រះលាននេះ ជាទីប្រជុំគណៈរដ្ឋមន្ត្រីជាធម្មតា ឬកាលមានធ្វើបុណ្យផ្សេងៗ, មានក្របបង្អួចមាស មានកញ្ចក់ច្រើននៅជុំវិញបង្អួច ភ្លឺផ្លេកៗ, នៅខាងក្រោម មានដំរីជាច្រើនឈរជាជួររៀងកាយ", ដូចយើងមើលឃើញរូបនៅទីលានសព្វថ្ងៃនេះ ។

ទីលាននោះ មានទីលយចេញមកខាងកើត៥កន្លែង ទីលយ៣កន្លែងនៅត្រង់ទីកណ្តាល, ពីរទៀតនៅទីបំផុតសងខាង នៅត្រង់កើយនៃទីលយបំផុតទាំងសងខាង មានចម្លាក់ជារូបដំរីកាន់ផ្កាឈូក, ត្រង់កើយទីលយកណ្តាល មានចម្លាក់រលេចជារូបគ្រុឌទ្រទីនោះ, ត្រង់កើយទីលយតូចៗទាំងសងខាង មានចម្លាក់រលេចជារូបដំរីដែរ ។ នៅទីលយខាងជើង មានចម្លាក់ជារូបសេះក្បាល៥, ត្រង់ទីលយខាងជើងនេះ, ត្រូវពិនិត្យមើលផង ព្រោះមានរូបល្បែងផ្សេងៗប្លែកពីសព្វថ្ងៃនេះ ។ តាមលោក ហ. ម៉ារសាល់ លោកសរសេរថា: "ទីលាននេះមានការរុះរើនិងការកសាងបន្ថែមជាច្រើនដង ដោយព្រះរាជាដែលទ្រង់សោយរាជ្យតៗគ្នា" ។

មុខព្រះលាននេះ ជាទីសប្បាយមួយកន្លែង ប្រែបរីករាយ ផ្ទះថ្លាក្នុងចិត្ត មានសត្វសីហៈជាទ្វារបាល, មានបង្កាន់ដៃនាគ សមជាទីទតព្រះនេត្រព្រះរាជាមែនៗ ។ ត្រូវមើលពេលព្រឹកឬពេលល្ងាចដែលត្រជាក់, សព្វថ្ងៃ

នេះ មានដើមឈើធំៗ មានម្លប់ត្រឈៃ មើលទៅខាងកើត មានទីលានស្រឡះ; តទៅខាងជើង គេឃើញប្រាសាទព្រះពិធូរ ខាងកើតឃើញឃ្លាំង, សួព្រ័ត្រ ស្ថិតជាជួរវៀងគ្នាក្នុងកណ្ដាលព្រៃ មើលទៅឃើញរក្ខតៗ

លុះបានមើលទីលានរួចហើយ ត្រូវចូលទៅតាមគោបុរៈខាងកើត ដើម្បីទៅមើលវិមានអាកាស, នៅគោបុរៈនេះ មានសិលាចារឹក៨ប្រការ ជាក្រឹត្យសំបថ ដែលពួកនាម៉ឺនមុខមន្ត្រីត្រូវគោរពប្រតិបត្តិចំពោះម្ចាស់ផែនដី, សិលាចារឹកនេះ ព្រះបាទសូរ្យវរ្ម័នទី១ ទ្រង់កសាង ក្នុងឆ្នាំ១៥៥៤ នៃពុទ្ធសករាជ; ក្រឹត្យនេះ មានបទខ្លះគេប្រើក្នុងពេលបុណ្យតាំងគុសព្វ ថ្ងៃនេះដែរ ។ នៅក្នុងព្រះរាជវាំងនេះ មិនឃើញមានអ្វីនៅសល់ទេ ព្រះរាជដំណាក់ឬគេហស្ថាននៃព្រះរាជអគ្គមហេសី ឬស្រីស្នំក្រមការក៏វិនាសអន្តរាយបាត់អស់ហើយ នៅសល់តែកន្លែងខ្លះដែលគេអាចសន្និដ្ឋានបាន លោក ហ. ម៉ាសាល់ លោកសរសេរថា: "ក្នុងផ្ទៃព្រះរាជវាំងនេះ គេអាចបែកចេញជា៥កន្លែង តាំងពីខាងកើតទៅទល់ខាងលិច សម្រាប់ជាលំនៅនៃព្រះរាជាម្ចាស់ផែនដី, ព្រះអគ្គមហេសី, ព្រះរាជបរិពារ រៀងរហូតដល់អ្នកគ្រួសារផ្សេងៗជាទីបំផុត ។

កន្លែងទី១ នៅទិសអគ្នេយ៍ ចំនួន៧០ ម៉ែត្រ, មានប្រាសាទតូចមួយឋិតថេរនៅឡើយ ប្រហែលជាធម្មមន្ទីរ? ក្រៅពីនោះប្រហែលជាកន្លែងធ្វើការរាជការ, ជាឃ្លាំង... តែឥឡូវនេះបាត់បែកអស់ហើយ ។

កន្លែងទី ២ ចំនួន ៦៨០ ម៉ែត្រ, មានកំពែងថ្មបាយក្រៀមឃាំងខាងកើត, គេអាចសន្និដ្ឋានបានថា កន្លែងនេះជាកន្លែងសំខាន់ ប្រហែលជាព្រះរាជដំណាក់? កន្លែងតពីទីនេះ ជាទីប្រតិស្ឋាននៃប្រាសាទវិមានអាកាស ។ ប្រាសាទវិមានអាកាសនេះ មាន ៣ ថ្នាក់ មានសណ្ឋានដូចប្រាសាទប្រទេសអស្ស៊ីរី (Assyrie) បុរាណ ឬដូចប្រាសាទបុរាណខ្លះនៅលង្កា-ទ្វីប, នៅថ្នាក់លើបង្អស់ គេកសាងជារោងទងភ្ជាប់ខ្វែង ជាក្រឡាចត្រង្គមានមុខជាយចេញទៅទាំង ៤ ទិស, ភាគខាងលើនៃប្រាសាទនេះ បាក់បែកអស់ហើយ, គេកសាងពីថ្មបាយក្រៀមនឹងថ្មប្រផះ ។ នៅផ្ទៃកណ្ដាលនៃប្រាសាទនេះ ស្ដេចទ្រង់តែងក្រសាលជាមួយនឹងនាងនាគីកាលដែលនាងនាគីឡើងមកម្ដងៗ, ដែលនាងនាគីឡើងមកម្ដងៗនេះ តាមពាក្យនិយាយថា ស្រុកទេសនឹងមានសិរីសួស្ដីក៏ចំរើន ។ តាមសិលាចារឹកថា: "ប្រាសាទនេះ គេកសាងឧទ្ទិសថ្វាយព្រះវិស្ណុ ក្នុងរវាង ព.ស. ១៦៥៣" ។ អ្នកដំណើរចិនបាននិយាយថា: "ប្រាសាទនេះជាប្រាសាទមាស ដូចគ្នានឹងប្រាសាទបាពួនដែរ," តែសព្វថ្ងៃមិនឃើញមានអ្វីទេ, តាមជណ្ដើរគ្រប់ថ្នាក់មានសីហៈជាទ្វារបាល នៅជ្រុងអនុទិសមានដំរី; បើបង់ឡើងមើលត្រូវឡើងតាមជណ្ដើរខាងលិច ព្រោះមានកាំជណ្ដើរខ្លះគេទើបធ្វើថ្មី ។ នៅខាងជើងប្រហែល ៥០ ម៉ែត្រឆ្ងាយ មានស្រះមួយទ្រង់

៤ ជ្រុងទ្រវែង, ខាងត្បូងមានក្ដីខ្ពស់ជាងខាងជើង មានផ្ទាក់ជារូបផ្សេងៗ នៅជិតមាត់ទឹក មានចម្លាក់ជារូបត្រី ឬសត្វទឹកជាច្រើន, នៅខាងលើ មានរូបនាគ នាងនាគីនិងរូបពស់ជាច្រើន មានមករ គ្រុឌ, ខ្លះទៀត គេឆ្លាក់ហាក់ដូចជាចេញមកពីក្នុងថ្ម ។ នៅទិសអគ្នេយ៍នៃវិមានអាកាស មានទីវាលខ្ពស់ មានប្រាសាទកាត់ថ្មជាក្រឡាចត្រង្គ ប្រហែលជាកន្លែងដែលស្ដេចទ្រង់ទទួលសព្វមុខមន្ត្រី? ជញ្ជាំងប្រាសាទនេះ មានសសរមូលទ្រពុងផ្សែងខាងក្រៅ, នៅចន្លោះប្រាសាទនេះនិងទ្វារខាងត្បូង មានប្រាសាទតូច ៤ កនបួនជ្រុងទ្រវែង មានទ្វារចូលតែពីខាងលិច, ប្រាសាទតូចអស់នេះ គេធ្វើសុទ្ធតែពីឥដ្ឋ ថ្មបាយក្រៀមនិងថ្មប្រែផេះ ។ អ្នកស្រុកនគរគេជឿថា: "កន្លែងនេះ ជាឃ្លាំងសម្រាប់ដាក់របស់មានដំឡៃ" ។

កន្លែងទី ៣ ចំនួន ១៥០ ម៉ែត្រ, បែកជាផ្នែកតូចច្រើនផ្នែក ចំណែកខាងត្បូង ជាកន្លែងនៃគ្រួសារ, ផ្ទះបាយ; តទៅទៀត ជាដំណាក់, សួនច្បារនៃព្រះអគ្គមហេសី និងស្រីស្នំក្រមការ, នៅខាងលិចត្រង់ពីស្រះធំ មានស្រះមួយទៀត ប្រកបដោយជណ្ដើរនិងក្រាលថ្មជុំវិញ ។ តាមពិនិត្យមើល កន្លែងទី ៣ នេះ មិនមានទ្វារចេញចំមកខាងក្រៅឡើយ, មានប្រឡាយទឹកមួយជាប់ពីស្រះ · ចេញមកស្រះដែលនៅចន្លោះកំពែង

ចាំងពីរ ៗ ទីកន្លែងជាភ័ស្តុតាងពីរទៀត ជាការពិបាកមិនអាចនឹងពន្យល់ឲ្យងាយបានឡើយ ៗ

បើត្រូវការចេញទៅតាមខ្លោងទ្វារខាងលិចនៃកំពែងខាងជើង មានផ្លូវមួយកាត់ចំទៅប្រាសាទបាល័លេយ្យ ហើយគេអាចចេញមកលើព្រះទេពប្រណម្យ ដើរហូតមកដល់ទីលានស្តេចគំលង់, បើពុំនោះ ត្រូវថយក្រោយមកវិញ ហើយចេញតាមខ្លោងទ្វារធំខាងកើត មកលើមុខព្រះលានដើរបត់ទៅខាងជើង ទៅមើលទីលានស្តេចគំលង់ក៏បាន ៗ

## ទីព្រះលានស្ដេចគំលង់

លុះមើលទីលានរួចហើយ ត្រូវបត់ទៅខាងជើងបន្តិច គេនឹងឃើញរូបស្ដេចគំលង់អង្គុយបញ្ឈរជង្គង់ម្ខាង ដៃទាំងពីរដាក់លើក្បាលជង្គង់ទាំងសងខាង ។ ទីលានស្ដេចគំលង់នេះ ជាកន្លែងខ្ពស់ធំប្លុក ទំនងកាលពីដើមប្រហែលជាស្ពានសម្រាប់ចុះទៅកាន់ស្រះ ដូចគ្នានឹងទីស្ពានស្រះស្រង់ៗ ព្រោះទីលយចេញទៅខាងជើងបិតថេរនៅឡើយ ទីលយខាងត្បូងវិនាសហើយ, ទីលយខាងជើងដែលនៅសល់នោះ ឃើញមានរូបចម្លាក់សត្វទឹកផ្សេងៗល្អមើលណាស់ដែរ, មានរឿងស្ដេចប្រថាប់ក្រសាលក្នុងប្រាសាទ ដូចគ្នានឹងរូបចម្លាក់នៅប្រាសាទបាយ័ន ខ្លះលេងល្បែងបោះកង់ចក្រ លេងលេបដាវ ត្រីនាគក្បាល ៦ ជាដើម; លោក ហ. ប៉ារម៉ង់ទេរ (H Parmentier) លោកថា: "ជាស្រះធំដែរ តែព្រះបាទជយវរ្មទំលាយចោល ក្នុងកាលធ្វើទីលាន ព.ស.១៧២៨–១៧៤៣" ។ ទៅដល់ហើយ, អ្នកមើលត្រូវចូលតាមច្រកតូចនៅខាងត្បូង មានស្នាមជើងគេដើរទក់ៗ មានកំពែងទាំងពីរខាង ដើរបត់ចុះបត់ឡើងជាច្រើនជាន់, កាលកំពុងដើរមើល ហាក់ដូចជាស៊ើបខ្វាបរកគល់តែចេញ, ព្រោះរូបនាគ រូបត្រី រូបយក្ស រូបស្រីទេពអប្សរបរកញ្ញាដោះចចើល នៅក្បែរខ្នងទឹងពោះយើង, បន្តិចទៅទៀត មានជណ្ដើរជាថ្នាក់ឡើងទៅខាងលើ

មកដល់ស្តេចគំលង់ ៗ រូបនេះ នៅមានប្រស្នាជជែកគ្នាច្រើនប្រការណាស់, តាមខ្មែរយើងនិយាយគ្នាថា: "ស្តេចនេះ គឺព្រះបាទយសោវរ្ម័នស្តេចកើតរោគឃ្លង់ហើយទ្រង់ទិវង្គតទៅដោយរោគនេះ," តាមពិត, សព្វថ្ងៃនេះ យើងទាំងអស់គ្នាក្តី អ្នកប្រាជ្ញបារាំងមានលោក ជ. កុម្មៃ ជាដើមក្តី បានពិនិត្យមើលមិនឃើញមានហេតុអ្វីនៅរូបនោះសោះ ជាព័ស្តុតាងល្មមថាកើតរោគឃ្លង់មែន, អ្នកប្រាជ្ញបារាំងខ្លះ ដូចលោក ហ. ម៉ាសាល់លោកថាជារូបឥសីចំរើនឈាន ៗ តាមសៀវភៅលោក ហ. ប៉ារម៉ង់ទេរលោកថា: "មានសិលាចារឹកនៅជើងសសរខាងក្រោម អាចកាត់សេចក្តីសង្ស័យដែលជាប្រស្នាជជែកគ្នានេះបានថា: "រូបនេះជារូបយមរាជជាអ្នកកាត់ក្តីនៅស្ថាននរក" ៗ លុះដើរមើលរូបហើយ, ត្រូវចេញទៅតាមច្រកទិសពាយ័ព្យ មានផ្លូវដើរកាត់ទៅរកទេពប្រណម្យ ៗ

# ព្រះទេពប្រណម្យ

ទេពប្រណម្យ ជាស្ថានវិហារពុទ្ធសាសនាបុរាណ បណ្ដោយ៨២ម៉ែត្រ ទទឹង៣៤ម៉ែត្រ, នៅខាងលិចប្រតិស្ឋានព្រះពុទ្ធរូបធំមួយអង្គ ទ្រង់ស័ក្តិសម កំពស់៤ម៉ែត្រ ៗ ជុំវិញ, តាមមើលទំនង, មានបង្កាន់ដៃនាគ សព្វថ្ងៃនេះ មិនឃើញមានអ្វីសល់នៅទេ ឃើញតែថ្មដែលគេក្រាលនៅកន្លែងនោះ, តទៅខាងលិចបន្តិច មានព្រះពុទ្ធរូប១អង្គទៀត ទ្រង់សណ្ឋានឈរទ្រង់ព្រះហស្តជាអភយមុទ្រៈ បំណែកព្រះភក្ត្រវិនាសរកមិនឃើញ ៗ នៅខាងលិចតទៅទៀត មានស្រះមួយធំ ក្នុងស្រះក្រាលថ្មជុំវិញដែរ ៗ ទេពប្រណម្យនេះ តាមសិលាចារឹកនៅសសរបួនជ្រុងនិយាយថា: "ទីនេះ គេកសាងនៅចុងបំផុតនៃសតវត្សរ៍ទី១៥នៃពុទ្ធសករាជ ដោយព្រះបាទយសោវរ្ម័ន, តាមលោក ហ. ប៉ារម៉ង់ទេរ លោកនិយាយថា: "សិលាចារឹកនេះ គេយកមកពីបាកយបុព្វទិស ដោយស្ដេចអង្គណាមួយដែលមានជំនឿដូចគ្នា ឯសិលាចារឹកដើមនុ៎ះវិនាសបាត់បង់ហើយ" ពាក្យនេះគួរជឿបាន ព្រោះព្រះបាទយសោវរ្ម័នមិនមែនជាពុទ្ធសាសនិកជនទេ ៗ .

## ប្រាសាទបាលិលេយ្យ

តពីទេពប្រណម្យទៅ មានផ្លូវមួយចេញទៅខាងលិច ចំពោះទៅលើប្រាសាទបាលិលេយ្យ, ប្រាសាទបាលិលេយ្យនេះ, មានកំពែងថ្មបាយក្រៀមមួយជាន់ ចំនួន ៥០ ម៉ែត្រ ៤ ជ្រុង ខាងកើតមានទីលានពីរជាន់ លយចេញមកប្រទាក់គ្នាជាក្រឡាបត្រង្គ លានទីមួយទាប លយផុតចេញមកខាងកើត, លានទីពីរខ្ពស់ មានបង្កាន់ដៃនាគបិតបេរនៅឡើយ មានលំអគួរចាប់ចិត្តអ្នកមើល ព្រោះជារចនាខ្មែរសុទ្ធ, ទីលានមួយៗ មានទ្វារបាលមួយគូនិងសិង្ហ:មួយគូ; ផុតពីទីលាន មានទ្វារបាលមួយគូទៀតនិងព្រះពុទ្ធរូបធំមួយអង្គ គង់ពត់ព្រះភ្នែនពែនព្រះបាទជាភូមិស្សប៉ិមុទ្រ:ព្រះកក្រញាញមសម័យទេពព្រណម្យដែរ ។

នៅគោបុរៈចូលពីខាងកើត មានទ្វារចូល ៣, គោបុរៈនេះ គេធ្វើលើទីខ្ពស់ ចំនួន ៧ ម៉ែត្រ ឥតមានក្បាច់រចនាអ្វីជាសំខាន់ទេ នៅហោជាង, មានរូបចម្លាក់ផ្នែកពុទ្ធសាសនាសុទ្ធ, តាមលោក ហ. ម៉ារសាល់ លោកថា: “រូបចម្លាក់នេះ ជារូបចម្លាក់ពុទ្ធសាសនាខ្លះ ជាសាសនាព្រាហ្មណ៍ខ្លះ”, តែតាមពិនិត្យមើល ខ្ញុំយល់ថា រូបចម្លាក់នៅហោជាងនេះ សុទ្ធតែរឿងពុទ្ធសាសនា ដូចមានតទៅនេះ:



គោបុរៈទិសខាងកើតនៃប្រាសាទបាលិលេយ្យ
ការរចនាបែបប្រាសាទនគរវត្ត រវាង ព. ស. ១.៦៥០

( តាមរូបថត ព. ស. ប. )

## មុខខាងកើត

១ – នៅលើទ្វារកណ្ដាល ភាគលើ ព្រះពុទ្ធរូបទ្រង់សណ្ឋិតឈរ ទ្រង់ព្រះហស្តជាអភយមុទ្រៈ មានមនុស្សទេពតានមស្សការជាបរិវារ, ភាគក្រោម ព្រះពុទ្ធទ្រង់ចូលព្រះនិព្វាន,

២ – នៅលើទ្វារខាងជើង ព្រះពុទ្ធរូបគង់ពត់ព្រះភ្នែនពែនព្រះបាទ មានដំរីបាលិលេយ្យ នឹងសត្វស្វាកំពុងថ្វាយផ្ទិតឃ្មុំ,

៣ – នៅលើទ្វារខាងត្បូង ព្រះពុទ្ធអង្គទ្រង់ទទួលភោជនាហារពីឈ្មួញពីរនាក់ គឺ តបុសៈនឹងភលិកៈ, នៅហោជាងខាងមុខខាងជើង, ភាគលើ រឿងមារវិជ័យ, ភាគក្រោម ទ្រង់ទូន្មានដំរីនាឡាគិរី ។

## មុខខាងលិច

១ – នៅលើទ្វារកណ្ដាល ថ្ងៃកាលព្រះពុទ្ធអង្គស្ដេចទៅជួបនាងពិម្ពាយសោធរា នឹងរាហុលកុមារ, មានដំរីចងក្ដប,

២–នៅលើទ្វារខាងជើង ព្រះពុទ្ធអង្គទទួលមធុបាយាសនាងសុជាតា,

៣ – នៅលើទ្វារខាងត្បូង ព្រះពុទ្ធអង្គទ្រង់សំដែងធម៌ទេសនា

## នៅហោជាងខាងត្បូង

ព្រះពុទ្ធអង្គទ្រង់ស្ដេចទៅកាន់ប្រាសាទនាងពិម្ពាយសោធរាទ្រង់ព្រះកន្សែង មានពួកស្រីស្នំជាបរិវារ ។

ខាងក្នុងប្រាសាទ មានព្រះពុទ្ធរូបជាច្រើន បែបមហាយាន ព្រះពុទ្ធរូបមួយអង្គធំ ទ្រង់ជាភូមិស្បើមុទ្រ: រាងស័ក្តិសម, មួយអង្គទៀតធំដែរ ទ្រង់ជាអភយមុទ្រ: វិនាសបាត់ព្រះកេសនឹងព្រះបាទអស់ហើយ ព្រះពុទ្ធរូបដទៃសុទ្ធតែតូចៗ ។

ប្រាសាទបាលិលេយ្យនេះ មានសណ្ឋានប្លែកគួរពិនិត្យមើល ព្រោះប្រាសាទដែលឧទ្ទិសថ្វាយព្រះពុទ្ធសាសនាប៉ែកមហាយាន សុទ្ធតែមានរូបលោកេស្វរៈជាគ្រឿងលំអ, ឯប្រាសាទនេះ មិនមានរូបលោកេស្វរៈទេ បែបទំនងជាឧទ្ទិសថ្វាយព្រះពុទ្ធសាសនាប៉ែកហីនយាន, តាមលោក ហ. ប៉ារម៉ង់ទីយេរ លោកនិយាយថា: ប្រាសាទនេះ ព្រះបាទជយវរ្ម័នទី ៧ ទ្រង់កសាងបន្ថែមជាខាងក្រោយ កាលដែលមានអគ្គិភ័យនៅក្រុងនគរធំ ព្រោះពិនិត្យឃើញការធ្វើបន្ថែមជាច្រើន ក្នុងរាងសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ ។



សិវលិង្គ ប្រាសាទព្រះពិធូរ

*( តាមរូបថត ព . ស . ប . )*

## ព្រះពិធូរ

នៅខាងកើតទីមុខព្រះលានចៀងខាងជើង នៅខាងមុខទេពប្រណម្យ មានប្រាសាទ៥ខ្នង ស្ថិតនៅជិតៗគ្នា ហៅថា ក្រុមប្រាសាទព្រះពិធូរ ។

ប្រាសាទព្រះពិធូរនេះ កសាងនៅលើទីខ្ពស់ បែរមុខមកកាន់ទិសខាងលិចទាំងអស់ មានទីលានលយចេញមកខាងលិច ប្រកបដោយបង្កាន់ដៃនាគ មានក្បាលងើយស្ទើន សុទ្ធតែល្អមើលគួរចាប់ចិត្ត, អ្នកមើលទាំងឡាយ គួរទៅមើលខានមិនបាន ព្រោះក្បាច់ចនាទាំងអស់នេះ បើយើងបានចំឡងយកមកប្រើ ឬធ្វើលក់ចំណាយក៏កើតទ្រព្យសម្បត្តិបរិបូណ៌មិនខាន ។ ប្រាសាទព្រះពិធូរទាំង ៥ ខ្នងនេះ គេកសាងដើម្បីឧទ្ទិសថ្វាយព្រះឥសូរខ្លះ ព្រះពុទ្ធសាសនាខ្លះ ព្រោះគេបានរកមើលឃើញក្នុងប្រាសាទខ្លះ មានសិវលិង្គ ខ្លះមានព្រះពុទ្ធរូប ។

ប្រាសាទទី ១ ដែលស្ថិតនៅខាងលិចបង្អស់ ឥឡូវនេះវិនាសអន្តរាយអស់ហើយ នៅសល់តែគគ្រឹះ ក្បាច់ចនាដែលសព្វនៅល្អសំខាន់ណាស់, ក្បាច់ដែលគេរើសយកមកគរទុក មានសទ្ទឹកក្បៀវឆ្លាក់វល្លិ៍ដ៏គួរស្ងើច ៗ ក្បាច់ចនាមុខហោជាង ដែលគេរកឃើញនៅដី មានរឿងកូរសមុទ្រទឹកដោះ, ក្បាច់នៅជ្រុងប្រាសាទ មានរូបទេវតាផ្សេងៗ ដូចមាននៅនគរវត្តនិងបាយ័ន, ប្រាសាទនេះ បើប្រសិនជានៅដូចដើម ក៏ឲ្យមាន

ស្មៅដុះរុំដូច្នេះ សមបើនឹងល្អឥតឧបមា ។ នៅខាងកើត មានប្រាសាទមួយទៀតតូចតែមួយជាន់ ស្ថិតលើគ្រឹះខ្ពស់ ទឹងកំពែងមួយជាន់ ក្បាច់រចនាប្រាសាទនេះក៏ល្អណាស់ដែរ ប៉ុន្តែឥឡូវនេះ ការវិនាសអន្តរាយជ្រុលទៅមុខហើយ មិនអាចពិនិត្យមើលឲ្យសព្វគ្រប់បាន, នៅទ្វារចូលមានទ្វារបាលពីរ ដែលរលំនៅជ្រុងអគ្នេយ៍ នៅហោជាងមានព្រាហ្មណ៍គោរពសិវលិង្គ, នៅលើទ្វារ វិស្ណុជិះលើគ្រុឌ ព្រះឥសូរមានដៃច្រើនកំពុងរាំ, ប្រាសាទទាំងពីរនេះ មានស្រះមួយយ៉ាង, មានផ្លូវដើរមួយកាត់ទៅខាងកើត ចំទៅលើប្រាសាទទី ៣ ។

ប្រាសាទទី ៣ មានការកសាងប្លែកគ្នាបន្តិច, គេកសាងនៅលើគ្រឹះខ្ពស់ហើយស័ក្តិសម-បែបមាំតែមិនទាន់ហើយស្រេច ។ នៅខាងក្នុងប្រាសាទ មានចម្លាក់ព្រះពុទ្ធរូបជាជួរ មានថ្វីដៃមិនចំណាន មានព្រះមូលីជាគេជះដូចជាអណ្តាតភ្លើង ។ នៅខាងកើតប្រាសាទនេះ មានកន្លែងវិហារពុទ្ធសាសនាចាស់មួយនៅចុងគ្រឹះខាងកើត មានជណ្តើរតូចឋស្តុទ្ធបែបយ៉ាងល្អ មានសីហៈជាទ្វារបាល, ក្បាលនាគ តែឥឡូវនេះ វិនាសស្ទើរតែអស់ហើយ ។

នៅខាងជើងប្រាសាទទាំង ៣ នេះ ជាទីប្រតិស្ឋានប្រាសាទទី ៤ ស្ថិតនៅលើគ្រឹះខ្ពស់ មានជាន់ពីរ មានក្បាច់រចនាយ៉ាងល្អវិសេស ទ្រង់ទ្រាយបែបឈ្មួន, តែមានការកសាងបន្ថែមក្រោយទៀត, ការកសាង

ខាងក្រោយនេះ មិនមានស្នាដៃល្អទេ ។ នៅខាងជើងប្រាសាទទី៤ ជាទីប្រតិស្ឋានប្រាសាទទី៥ ។

ប្រាសាទទី៥នេះ ប្លែកពីប្រាសាទទាំង ៤ ដែលបានពណ៌នារួចមកហើយ មានសណ្ឋានបែបជាកន្លែងសម្រាប់អ្នកដំណើរមកពីឆ្ងាយ ដូចជាប្រាសាទតូចៗ ដែលគេបានឃើញនៅប្រាសាទព្រះខាន់ និងប្រាសាទតាព្រហ្ម, ពងរៅប្រាសាទនេះ បួនជ្រុង, ហើយមានប្រាង្គនៅពីលើ ។

ការដើរមើលប្រាសាទក្រុមព្រះពិធូរនេះ ចប់ចុះដោយការកាន់យកផ្លូវដែលកាត់ព្រៃព្រឹក្សលតាជាតិ ប្រកបដោយសូរសំឡេងបក្សីបក្សាយាសយ៉ាងរំពង ពីកោះដូចក្រុង ជាទីកំសាន្តសប្បាយ ដើរកាត់ត្រង់ទៅខាងជើងទៅលើស្រះមួយ បណ្ដោយ៩០ម៉ែត្រ ទទឹង៦០ម៉ែត្រ ដ៏មានទីទៅនៅព្រៃព្រឹក្សទៀតស្រងាត់ព័ទ្ធជុំវិញ ទឹកថ្លាយង់គួរជាទីបន្ទាបន់ញ៉េសក្អុល បើប្រសិនជាមានអាហារយកទៅបរិភោគ គួរយកទៅបរិភោគនៅក្រោមដើមឈើមាត់ស្រះនោះ ក៏រឹងរឹតតែមានរសឆ្ងាញ់ពិសាអនេក ព្រោះត្រូវគេមើលទៅទឹកស្រះថ្លា ប្រកបដោយសារាយ សត្វតាក្រពាកហើរវិលវង់ព្រោងព្រាត ចុះហែលលលៃប្រឡែងគ្នាជាកំសាន្ត ព្រៃព្រឹក្សមានសត្វកទៀតស្រស់ មានម្លប់ត្រឈឹងត្រៃឈ មានរ៉ៅយោបក់មកល្ហើយត្រសៀក បន្ទំដោយភ្លេងគឺសូរសំឡេងសត្វចាបស្លាបតោកក្រួកគាវ់ ទឹងសត្វផ្សេងៗដ៏អនេក ។

## ប្រាសាទសួព្រ័ត្រនិងឃ្លាំង

នៅខាងមុខទីព្រះលាន ខាងកើតស្ពានកណ្តាលនៃនគរធំ មានប្រាសាទ ១០ ធ្វើពីថ្មបាយក្រៀម មានសណ្ឋានជាចេតិយ មានកំពូលតាល ស្ថិតជាជួរវៀងរាយគ្នាពីខាងជើងទៅខាងត្បូង នៅចន្លោះផ្លូវធំទៅទ្វារជ័យ; តាមជំនឿខ្មែរយើងយល់ថា: ប្រាសាទសួព្រ័ត្រ គឺកាលជាន់នគរ គេលេងល្បែងសួព្រ័តនៅប្រាសាទនេះ សម្រាប់ស្តេចទ្រង់ទតក្នុងពិធីបុណ្យមួយៗ" តែពាក្យនេះ តាមដែលពិនិត្យមើលមិនមានខ្លឹមសារអ្វី ទីងយកមកធ្វើជាភស្តុតាងគោលចារឹកមិនបាន; តាមអ្នកដំណើរចិន ចៅតាក្វាន់ និយាយថា: "កន្លែងនេះជាទីដកល់ទេពតាស័ក្តិសិទ្ធិ សម្រាប់ជាទីស្បថនៃអ្នកដើមចោទនិងអ្នកចុងចោទ ក្នុងការវិវាទគ្នា," សេចក្តីនេះឃើញសម ព្រោះវិធីស្បថក៏ជាកិច្ចមួយជាប់ជាមរតកស្ថិតក្នុងចិត្តខ្មែរជាតិយើងនេះ ។ ប្រាសាទនេះ បែរមុខមកខាងលិច ក្បាច់របនាខ្លះធ្វើមិនទាន់ហើយស្រេច, ខាងកើតបន្តិច មានប្រាសាទដូចគ្នាពីរទៀត, នៅចន្លោះប្រាសាទនេះ មានស្រះមួយ មានជណ្តើរថ្ម ។

នៅខាងកើតប្រាសាទសួព្រ័ត្របន្តិច, មានប្រាសាទពីរនៅអមផ្លូវទៅទ្វារជ័យ មួយខាងជើង មួយខាងត្បូង, មានក្បាច់របនាវិសេស គេហៅថា ប្រាសាទឃ្លាំង ។ ប្រាសាទឃ្លាំងនេះ គួរមើលណាស់ដែរ

ព្រោះថ្មីដែកសាន់នោះដោយធារពិនិត្យពិច័យណាស់, តាមទំនងនេះ មិនសមឈ្មោះថា យ៉ាំង ដូចសេចក្ដីយល់របស់យើងឡើយ ។ តាមពិត គួរជាទីទទួលសំណាក់នៃក្សត្រិយ៍ឬនាម៉ឺនជាន់ខ្ពស់ៗ ។ នៅប្រាសាទយ៉ាំងខាងជើង គេបានរកឃើញរូបស្ទិតសម្រិទ្ធ ១ ។

លុះបានមើលប្រាសាទសួព៌ត្រទឹងយ៉ាំងរួចហើយ ត្រូវឡើងរថយន្តទៅតាមផ្លូវចំទៅទ្វារជ័យខាងកើត ដើម្បីទៅមើលព្រះពុទ្ធរូប ដែលគេគាស់បានពីក្នុងកណ្ដាលប្រាសាទបាយ័ន ដូចបាននិយាយរួចមកហើយក្នុងប្រាសាទបាយ័ន· ទៅតែបន្តិចប្រហែល២០០ម៉ែត្រដល់ហើយ ។ ព្រះពុទ្ធរូបនេះ គេយកមកដម្កល់ទុកជាខាងត្បូងផ្លូវនេះ នៅលើកន្លែងវិហារបុរាណ តែសព្វថ្ងៃនេះ, គេបានរៀបចំជាថ្មី ហើយធ្វើជារោងតូចសម្រាប់ជាទីជ្រកនៃព្រះពុទ្ធរូបនេះ ។ លុះមើលរួចហើយ ហួសទៅខាងកើតបន្តិចទៀត ដើម្បីទៅមើលប្រាសាទតូចមួយ ដែលបាក់បែកអស់ហើយ ឈ្មោះ មង្គលដិ ។

# ប្រាសាទមង្គលថិ

ប្រាសាទនេះ ស្ថិតនៅចន្លោះទ្វារជ័យនឹងទ្វារខ្មោច, ចុះពីរថយន្ត ហើយដើរចូលទៅបន្តិច តាមផ្លូវតូចខាងស្តាំដៃនឹងឃើញប្រាសាទមង្គលថិនេះ ។ គេកសាងពីថ្មសុទ្ធ បែរមុខមកខាងកើត មានទ្វារបញ្ឆោតទាំង ៣ ទិស ឥឡូវនេះបាក់បែកស្ទើរអស់ហើយ; បណ្តុំថ្មធ្លាក់ជាក្បាច់ដែលគេរើសបាន មានថ្ម១ដុំកំពស់១ម៉ែត្រ៤៦ មានវិស្ណុដេកនៅលើពស់អនន្តៈនឹងព្រះព្រហ្មគង់លើផ្កាឈូក, វិស្ណុដៃ៤នៅលើស្មាគ្រុឌ, ខាងលើក្រឹស្ណៈពាក់មកុដកំពូល ៣ ទ្រភ្នំការពារហ្វូងគោនឹងគង្វាល, ព្រះរាមកាន់ធ្នូ, នៅថ្មនេះ គេមើលឃើញអវតារនៃវិស្ណុសព្វគ្រប់, មានថ្មមួយដុំទៀត, គេឆ្លាក់រូបលោកេស្វរៈដៃ ៤ នាងបរិតនឹងមករក្លាយជាក្រពើ; នៅហោជាង ព្រះឥសូរជិះមករ, ព្រះឥសូររាំជាមួយនឹងអគ្គមហេសីឈ្មោះនាងសក្តិ ។ ប្រាសាទនេះ គេកសាងថ្វាយសាសនាព្រាហ្មណ៍, តាមសិលាចារឹកមួយ គេរើចរកឃើញមានសេចក្តីថា: "ប្រាសាទនេះ គេកសាងក្នុងសតវត្សរ៍ទី ២០ នៃពុទ្ធសករាជ" ។

ផ្សេងក្រៅពីប្រាសាទមង្គលថិនេះ មានកន្លែងបុរាណជាច្រើន ដូចជាកំពែង, ស្រះ, ទឹកបន្ទស់ ជាដើម ដេរដាសកក់កយពាសពេញនៅក្នុងកំពែងនគរធំ, បុរាណវត្ថុដែលសល់នៅ គេមិនទាន់រកឃើញ

នោះច្រើនណាស់ សព្វថ្ងៃ ការថែរក្សានគរក៏ចេះតែរៀបចំតទៅ ។ ចំណែកខ្មែរយើង, មិនគួរលះបង់ប្រាសាទទាំងអស់ពោលសោះ ព្រោះប្រាសាទអស់នេះ ជាកេរ្តិ៍នៃបុព្វបុរសខ្មែរយើង ហើយជាទ្រព្យសម្បត្តិខ្មែរយើងផង បើយើងបានរៀនចំណេះវិជ្ជាអំពីប្រាសាទនេះអស់ហើយ យើងនឹងកើតទ្រព្យសម្បត្តិបរិបូណ៌ ហើយដើរតាមស្នាមជើងដូនតាជាន់ទនគរបាន ។

វគ្គទី ៤

# វង់តូច

## ប្រាសាទធម្មនន្ទ និងប្រាសាទចៅសាយ

នៅកិឡូម៉ែត្រលេខ១២ ផ្លូវវង់តូច ដែលចេញតាមទ្វារជ័យនគរធំ មានប្រាសាទពីរទន្ទឹមគ្នា, ប្រាសាទស្ថិតនៅខាងជើងផ្លូវឈ្មោះ ធម្មនន្ទ ខាងត្បូងផ្លូវឈ្មោះ ចៅសាយ ។

ប្រាសាទធម្មនន្ទ សណ្ឋានជាប្រាង្គមួយ មានយ៉លយ៉ៈចេញទៅខាងមុខ មានធម្មទ្ទីរមួយស្ថិតនៅទិសអាគ្នេយ៍, កំពែងព័ទ្ធជុំវិញ បណ្ដាយ ៦០ម៉ែត្រ ទទឹង៤០ម៉ែត្រ, តួប្រាសាទបណ្ដាយប្រហែល២០ម៉ែត្រ ។ ការរចនាប្រាសាទនេះ ក៏ល្អសំខាន់ណាស់ដែរ ខ្លោងទ្វារចូលពីទិសខាងលិច មានចម្លាក់ដោយស្នាដៃពិសេស អ្នកផងទាំងពួងគួរមើល, ក្បាច់ដែលនៅស៊ុមទ្វារបញ្ឆោតក៏ល្អ ឯសសរខាងកើតនៃទ្វារមុខខាងត្បូងក៏គួរមើល, នៅខាងក្នុងប្រាសាទ ត្រង់យ៉ជាប់គនឹងប្រាង្គ មានផ្ដែរលើទ្វារល្អណាស់ ប្រកបដោយព្រះឥន្ទ្រជិះលើដំរីឰរាវ័ណ្ណក្បាល ៣, នៅហោជាងពាលីន់ជាស្ដេចស្វាស្លាប់, រាពណ៍ចាប់អង្រួនភ្នំកៃលាស, ក្រឹស្ណៈទ្រភ្នំ និងរឿងកូរសមុទ្រទឹកដោះ ។

ប្រាសាទនេះ ចំនងជាគេឧទ្ទិសថ្វាយព្រះនារាយណ៍ តាមដែលមានរឿងរ៉ាវជាប់នឹងប្រាសាទ, ព្រោះមើលឃើញរឿងរាមកេរ្តិ៍ គេមើលឃើញព្រះរាមនឹងព្រះលក្ស្មណ៍, ចម្បាំងពាលីនឹងសុគ្រីព, ពួកស្វាញីពោមពោមជាបរិវារ សេនាស្វាយាសយំអឺងកង ។

លុះមើលរួចហើយត្រូវដើរទៅខាងត្បូង ដើម្បីទៅមើលប្រាសាទចៅសាយ ចម្ងាយប្រហែល ៣០ ម៉ែត្រពីផ្លូវថ្នល់ ។

ប្រាសាទចៅសាយនេះ គេឧទ្ទិសថ្វាយព្រះឥសូរ ព្រោះមានគោនន្ទិជាជំនិះព្រះឥសូរ, មានសណ្ឋានក្បាច់ចនាស្អាតដូចគ្នានឹងប្រាសាទធម្មនន្ទ ប៉ុន្តែមានធម្មន្ទីរមួយដែលនៅទិសអគ្នេយ៍ មានទ្វារចូលពីខាងលិច, ឥឡូវនេះ ធម្មន្ទីរនោះបាក់បែកអស់ហើយ នៅសល់តែគ្រឹះ; យ៉ដែលលយចេញពីប្រាង្គមានគ្រឹះខ្ពស់បណ្ដុសសរមូល ក្បាច់ចនាក៏ល្អ; តែប្រាសាទនេះដកត្រាំត្រាច្រើនជាងគេ ដុំថ្មដែលគេរើសគរទុកនៅខាងជើង ពិនិត្យទៅឃើញមាននាគមានក្បាលច្រើន ក្បាច់ចនាដែលធ្លាក់ចុះពីហោជាងម៉តក៏បាក់បែកជាច្រើន ។

ប្រាសាទទាំងពីរនេះ មិនទាន់ឃើញមានសិលាចារឹកពិតប្រាកដទេ តែតាមលោក ហ. ប៉ារម៉ង់ទេរ លោកនិយាយថា: "ក្បាច់ចនាមានសណ្ឋានដូចនគរវត្ត, ប្រហែលជាកសាងក្នុងរវាងសតវត្សរ៍ទី ១៧ នៃពុទ្ធសករាជ" ។

## ស្ពានថ្ម

នៅក្នុងក្រុងនគរធំ មិនមានស្ពានថ្មទេ មានតែស្ពានមួយស្ថិតនៅខាងកើតនគរធំ ចម្ងាយពីទ្វារជ័យប្រហែល ៧០០ ម៉ែត្រ, គឺស្ពានធ្នង់ស្ពឹង សៀមរាបនេះឯង, តាមលោក ហ. ម៉ារសាល់ លោកនិយាយថា: "ខ្មែរមិនចេះវិជ្ជាធ្វើស្ពានទេ ព្រោះស្ពានថ្មនេះ ទុកដូចជាទំនប់សំរាប់ទប់ទឹកតែម្តង គេរៀបថ្មច្រើនជាតួសសរជាប់ពីបាតស្ទឹងមកដល់ផ្ទៃស្ពានខាងលើ ទុកប្រហោងតូចៗ ចុះបើមានសំណាត់ដែលហូរមកតាមស្ទឹង ទុះរាំមិនប៉ះស្ពានបាក់ខូចហើយ?" ។

កន្លែងស្ពានថ្មសព្វថ្ងៃនេះ មិនមែនកន្លែងស្ពានបុរាណទេ កន្លែងស្ពានបុរាណ ស្ថិតនៅខាងជើងទៀងខាងលិចបន្តិច, ដោយស្ទឹងដើរឃ្លាតទៅខាងកើតបន្តិច គេទើបនឹងធ្វើស្ពានថ្មីទៀត តែគេយកថ្មប្រាសាទមកធ្វើដែរ ស្ពាននេះល្អចំណានរបស់គេ ។



ភាពប្រាសាទតាកែវទាំងមូល មើលពីទិសឦសាន្ត
ការរចនាបែបប្រាសាទឃ្លាំង រវាង គ.ស.១៥៣៣-១៦៥៣

( តាមរូបថត ស.ប.ប. )

## ប្រាសាទតាកែវ(១)

ប្រាសាទតាកែវ ស្ថិតនៅជិតគីឡូម៉ែត្រលេខ ៣ តាមផ្លូវធំតូច កាលណាគេក្រឡេកមើលមុនដំបូង គេនឹងឃើញប្លុកក្លុកជានិមើល ប្រាសាទទាំងតួង, ប្រាសាទនេះពង់ស័ក្តិសម កសាងត្រឹមត្រូវតាមខ្នាត, សណ្ឋានទ្រង់ទ្រាយល្អឈ្នះ លេចត្រដែតឡើងកណ្ដាលទ្រនំព្រៃ ប្រកបដោយកំពូលប្រាង្គទាំង៥ ខ្ពង់ខ្ពស់ស្កឹមស្កៃ ទាញភ្នែកអ្នកមើលឲ្យបាញ់ត្រង់ទៅភេ, ហើយមិនមានក្បាច់ចនាអ្វី មើលទៅឃើញស្អាតផង ។ លោក ហ.ម៉ាស្សាល់ និយាយថា: "បណ្ដាប្រាសាទនៅនគរធំ ប្រា-សាទនេះល្អយ៉ាងឯក ពិតមែនតែមិនមានក្បាច់ចនា ឬ ចម្លាក់រឿងរ៉ាវអ្វី" ។

ប្រាសាទតាកែវនេះ មានថ្នាក់ ៣ ជាន់, ថ្នាក់លើបង្អស់ ជាទីប្រតិស្ឋានប្រាសាទកណ្ដាលដែលខ្ពស់ជាងគេ ប្រាសាទ៤ ស្ថិតនៅគ្រប់ជ្រុងអនុទិស; កាលណាគេបានទៅដល់ហើយ ត្រូវចូលពីខាងកើតប្រាសាទ ឈប់ថយន្តហើយ ចុះដើរចូលទៅ ។

ថ្នាក់ក្រោម បណ្ដោយ១២០ម៉ែត្រ, ទទឹង១០០ម៉ែត្រ, ថ្នាក់ទី២ បណ្ដោយ៨០ម៉ែត្រ, ទទឹង៧៥ម៉ែត្រ, ប្រតិស្ឋាននៅលើជាន់ទី១ កំពស់ ៥ ម៉ែត្រ ៥០, មានជំណាក់ជាច្រើន មានកេងទទឹងព័ទ្ធជុំវិញ, ថ្នាក់

១ ប្រាសាទកែវ ។

ម៉ែ ៣ ជាទីប្រតិស្ឋានប្រាសាទទាំង ៥ ។ តាមដែលខ្មែរយើងនិយាយតៗគ្នាថា: "ប្រាសាទនេះបានជាមិនមានក្បាច់រចនាទុំ, ព្រោះកាលពីដើម, គេស្រោចទង់ដែងប្រកបក្បាច់រចនាផ្សេងៗ ឥឡូវនេះរបកអស់ហើយ", តែលោក ហ. ម៉ារសាល់ និយាយថា: "ប្រាសាទនេះ បានជាគេមិនឆ្លាក់ក្បាច់ដូចប្រាសាទទាំងពួងនោះ ព្រោះថ្មនេះមានសាច់រឹងណាស់ មិនទន់ដូចថ្មទាំងពួង", ការដែលកទាំងពីរនេះ នៅជាប្រស្នាដែកគ្នាទៀត មិនទាន់ដាច់ស្រេចដូចម្តេចឡើយ ។

ប្រាសាទតាកែវនេះ គេកសាងឧទ្ទិសថ្វាយដល់ព្រះឥសូរ តាមសិលាចារឹកដែលគេបានរកឃើញ, ម្យ៉ាងទៀត មានគោនន្ទិជាគោលផង; ព្រះបាទសូរ្យវរ្ម័នទី១ [១]ស្តេចកសាងក្នុងសតវត្សរ៍ទី១៦ នៃពុទ្ធសករាជ (ព. ស. ១៥៤៣) ។

អ្នកមើលត្រូវឡើងប្រាសាទនេះ ក្នុងពេលត្រជាក់ស្រួល ពេលព្រឹកឬល្ងាច, តាមជណ្តើរខាងកើត ត្រូវប្រយ័ត្ន ព្រោះប្រាសាទខ្ពស់ ជណ្តើរចោទលឹកកាំជាច្រើនកន្លែង, ឡើងដល់ខាងលើហើយ, គេអាចមើលឃើញជុំវិញខ្លួនបាន, ព្រោះប្រាសាទខ្ពស់ត្រដួចផុតចុងឈើ ហាក់ដូចជានៅកណ្តាលអាកាស, មើលទៅឆ្ងាយ ឃើញជួរភ្នំគូលេនវែងឆ្ងាយ ឃើញហុយផ្សែងជាប់កន្ទុយភ្នែក ។

១ អ្នកស្រី កូរាល រេមូសាត់ (Coral Rémusat) សៀវភៅ (L'Art Khmer) ទំព័រ ១២ និយាយថា ប្រាសាទតាកែវនេះ ព្រះបាទជយវរ្ម័នទី ៥ ស្តេចកសាង ។



ដើមឈើផុះចាក់ឫសព័ទ្ធព័ទ្ធ លើកំពូលប្រាសាទតាព្រហ្ម

( តាមរូបថត ស.ប.ប. )



កាលព្រះពោធិសត្វទ្រង់គង់លើកណ្ឋកពាជីមានទេវបុត្រជាបរិវារ
ទ្រង់ចេញសាងអភិនិស្ក្រមណ៍, ហោជាងប្រាសាទខាងក្នុងកំពែង
ទី ៣ ប្រាសាទតាព្រហ្ម

( តាមរូបថត ព. ស. ប. )

## ប្រាសាទតាព្រហ្ម

សព្វថ្ងៃនេះ ប្រាសាទតាព្រហ្ម គេមិនកាប់ឆ្ការព្រៃឲ្យរល់ស្រឡះដូចជាប្រាសាទឯទៀតទេ គេចង់ទុកឲ្យឃើញច្បាស់ថា សភាពប្រាសាទដែលត្រូវគេចោលតាជាតិលុកលុយទន្ទ្រាននុះតើបែបដូចម្ដេច? ដូច្នេះទើបឃើញក្នុងប្រាសាទនេះ មានដើមឈើខ្លះ មានឫសរុំព័ទ្ធក្ដោបកៀរជាប់នៅនឹងដុំថ្ម; តាមផ្លូវដែលចូលទៅខាងក្នុង គេគ្រាន់តែកាប់ឆ្ការបន្តិចបន្តួចល្មមនឹងដើរមើលបានប៉ុណ្ណោះ ។ ប្រាសាទដែលមានភាពសណ្ឋានទ្រង់ទ្រាយប្រហែលគ្នា មាន ៣ គឺ ប្រាសាទតាព្រហ្ម, ប្រាសាទបន្ទាយក្ដីនិងប្រាសាទព្រះខ័ន ដែលត្រូវនិយាយតទៅខាងមុខ, ឯប្រាសាទតាព្រហ្មនេះ ក៏មានកិច្ចការផ្សេងជាច្រើនត្រូវនិយាយ អ្នកប្រាជ្ញបារាំងខាងបុរាណ-វត្ថុ មានសេចក្ដីសរសើរជាច្រើនអំពីប្រាសាទនេះដែរ ។

មានកំពែង៥ជាន់, កំពែងក្រៅ, បណ្ដោយពីខាងកើតទៅខាងលិច ១០០០ ម៉ែត្រ ទទឹងពីខាងត្បូងទៅខាងជើង ៦០០ ម៉ែត្រ, មានគោបុរៈគ្រប់ទិសទាំងបួន, គោបុរៈដែលចូលមើលបានកាលឥឡូវនេះមានតែពីរ គឺ ខាងកើតនិងខាងលិច, បើឈប់ខាងកើត ឲ្យរថយន្តទៅឈប់ចាំខាងលិច, បើឈប់ខាងលិច ឲ្យរថយន្តទៅចាំខាងកើត, ហើយសឹមចូលទៅ ។ គោបុរៈទាំង៤ទិសនេះ សុទ្ធសឹងប្រកបដោយមុខលោកេស្វរៈបែរទៅកាន់

ទិសទាំង ៤ នៅផ្នែកនៃគោបុរៈមួយៗប្រកបដោយរូបគ្រុឌបញ្ចាំ ៗ លុះចូលផុតគោបុរៈខាងកើតហើយ ត្រូវដើរចូលទៅតាមផ្លូវជើង, បន្តិចទៅដល់ស្ពានថ្មតូចឆ្លងកាត់ស្រះ ដែលមាននៅជុំវិញកំពែងទីពីរ, គោបុរៈនៃកំពែងទីពីរនេះ គេធ្វើជាគូប្រាសាទមានកំពូល មានទ្វារតូចពីរនៅអមសងខាងទ្វារធំ, ដំបូលមានសណ្ឋានជាកេងកង នៅសងខាងទ្វារមានរូបចម្លាក់រឿងផ្កាញីមារ ៗ ចូលផុតពីកំពែងទីពីរទៅ នឹងឃើញប្រាសាទមួយបណ្ដោយប្រហែល ៣០ ម៉ែត្រ, ទទឹង ២០ ម៉ែត្រ, មានទ្រនំព្រាយដូចសាលា តែវិនាសអន្តរាយជាច្រើន នៅសល់តែសសរទ្រនំផ្ញាំង, ជាន់ខាងលើនឹងបន្ទោះបង្អួចមួយៗមានក្បាច់ចនាល្អណាស់ ៗ កំពែងទី ៣ មានសណ្ឋានជាកេងកងព័ទ្ធជុំវិញ មានទ្វារប៉ោវតាំងបួនទិស ខាងលើទ្វារគេធ្វើជាកំពូលខ្ពស់ឡើង ប្រកបទៅដោយក្បាច់ចនាយ៉ាងល្អ ៗ ឆ្លងពីកំពែងទី ៣ ទៅនឹងឃើញកេងកងទី៣ផ្លូវ ដែលជាផ្លូវចូលទៅកាន់កំ-ពែងទី ៤, នៅចន្លោះកំពែងទី ៣ នឹងទី ៤ សងខាងផ្លូវបែកទៅខាងកើតមានប្រាសាទជាច្រើន នៅផ្ដែលើទ្វារប្រាសាទមុខខាងត្បូង មានរូបចម្លាក់ព្រះពោធិសត្វទ្រង់ប្រសូតចេញតាមក្លៀក នៃព្រះនាងសិរីមហាមាយា នៅព្រៃលុម្ពិនី មានរូបព្រះឥន្ទ្រនឹងទេវតាជាច្រើន, នៅសងខាងផ្លូវបែកខាងលិច មានប្រាសាទពីរ មួយខាងត្បូងធ្វើដោយថ្ម, មួយខាងជើងធ្វើដោយថ្មបាយក្រៀម, នៅខាងជើងនឹងខាងត្បូង មានកេងកងពីរផ្លូវ



រូបភិក្ខុប្រណម្យ ប្រាសាទតាព្រហ្ម

*(តាមរូបថត ព. ស. ប.)*



កាលព្រះពោធិសត្វប្រសូត ព្រះព្រហ្មនឹងព្រះឥន្ទ្រទទួល
ហោជាងប្រាសាទខាងត្បូង ក្នុងកំពែងទី ៣ ប្រាសាទតាព្រហ្ម

( តាមរូបថត ស. ប. ប )

កជាប់ពីរោងទងជាន់ទី ៣ ទៅជាប់នឹងរោងទងជាន់ទី ៤ ។ កំពែងទី ៤ មានសណ្ឋានជារោងទងព័ទ្ធជុំវិញ ហើយមានរោងទងគេទៅជាប់នឹងកំពែងទី ៥, កំពែងទី ៥ នេះ ក៏មានសណ្ឋានជារោងទងថែវ, ទីកណ្តាលជាទីប្រតិស្ឋានប្រាសាទធំខ្ពស់ជាងប្រាសាទទាំង៨ ដែលមានទៅនឹងរោងទងជុំវិញ ហើយមានរោងទងជាប់ពីរោងទងខាងកើតនឹងខាងលិច ត្រង់ទៅដល់ប្រាសាទកណ្តាល, ឯប្រាសាទកណ្តាលនេះ មានល្វែង ៤ ជ្រុង ហើយមានទ្វារទៅកាន់ទិសទាំង ៤, គេដើរកាត់ពីទ្វារខាងកើតទៅទ្វារខាងលិច ត្រង់បំរហូតទៅកាន់គោបុរៈទិសខាងលិចបាន ។

នៅរោងទងប្រាសាទតាព្រហ្មនេះ គេមើលឃើញសិលាចារឹកនៅសសរថ្មមួយ និយាយប្រាប់ថា ព្រះបាទជ័យវរ្ម័នទី៧ បានទ្រង់ត្រាស់បង្គាប់ឲ្យឆ្លាក់សិលាចារឹកនេះ ក្នុង ព.ស. ១៧២៩ ជាទីនមស្សការដល់ព្រះរតនត្រ័យ គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ, ព្រះពោធិសត្វអវលោកិ-តេស្វរៈ, ប្រាប់អំពីទ្រង់ធ្វើសឹកសង្គ្រាមមានជ័យជំនះ និងនិយាយពីប្រាសាទទាំងប៉ុន្មានដែលទ្រង់កសាង ។

សេចក្តីម្យ៉ាងទៀតថា: "ប្រាសាទតាព្រហ្មនេះ ជាអាកមសម្រាប់ព្រះមហាថេរៈ ១៨ អង្គ សម្រាប់ភិក្ខុ ២.៧៤០ រូប, នៅក្នុងកំពែងប្រាសាទនេះ មានសាវក ២.២៣២ រូបព្រមទាំងស្រីល្មោន ៦១៥ នាក់នឹង

ស្រី-ប្រុសឯទៀត ៦៦.៦២៩ នាក់ផង ជាអ្នកធ្វើនូវគ្រឿងសក្ការបូជាទាំងឡាយ ។

ទីប្រាសាទតាព្រហ្មនេះ មានកន្លែងពិបាកចូលមើលជាច្រើនកន្លែងច្រើនប៉ែកខាងត្បូង, បើប្រសិនជាចូលទៅមើលក្នុងវេលាយប់ ក្នុងថ្ងៃដែលមានព្រះចន្ទ្រពេញវង់ ទើងឃើញប្រាសាទនេះល្អមើលណាស់ ប៉ុន្តែត្រូវតែមនុស្សអ្នកនាំផ្លូវទៅជាមួយផង ហើយត្រូវឲ្យមានភ្លើងបួចភ្លៀងអ៊ុយ៉ាំងក្នុងពេលដែលចូលទៅមើល; បើចូលពីគោបុរៈខាងលិច ហើយហួសទៅដល់គោបុរៈខាងកើត, នៅខាងជើងទើងឃើញធម្មសាលាមួយ គេធ្វើសង្ហាយព្រះពោធិសត្វលោកេស្វរៈ ទើងសម្រាប់ជាទីជ្រកនៃអ្នកទៅនមស្សការ, កាលចេញផុតពីកំពែងប្រាសាទតាព្រហ្មនេះហើយ បែរមើលទៅទិសអគ្នេយ៍ ទើងឃើញកំពែងប្រាសាទបន្ទាយក្តី ព្រោះប្រាសាទនេះស្ថិតនៅជិតគ្នា មួយទិសអគ្នេយ៍ មួយទិសពាយ័ព្យ ។

ប្រាសាទតាព្រហ្មនេះ ព្រះបាទជ័យវរ្ម័នទី៧ ទ្រង់សាងក្នុងសករាជ្យទី១៨ នៃពុទ្ធសករាជ (ព.ស.១៧២៩) ថ្វាយព្រះវររាជមាតា ដើម្បីធ្វើសង្ហាយព្រះពុទ្ធសាសនា, ស្តេចបានសាងព្រះរូបព្រះវរមាតាជា "ទេវរាជ" ស្ទួងព្រះប្រាជ្ញាបារមិតាដម្កល់ទុកក្នុងទីនេះ ។



រូបទ្វារបាល នៅគោបុរៈកំពែងទី ៣ ទិសខាងលិច
ប្រាសាទតាព្រហ្ម
ការរចនាបែបបាយ័ន រវាង ព. ស. ១៧០០

( តាមរូបថត ស. ច. ប. )

## ប្រាសាទបន្ទាយក្តី

ប្រាសាទនេះ មានសណ្ឋានដូចប្រាសាទតាព្រហ្ម ដែលបានពោលរួចហើយ ប៉ុន្តែមានទំហំតូចជាង, មានកំពែងព័ទ្ធជុំវិញ បណ្តោយ ៩០០ម៉ែត្រ ទទឹង៥០០ម៉ែត្រ, មានគោបុរៈគ្រប់ទាំងបួនទិស គោបុរៈខាងកើតជាខ្លោងទ្វារធំចម្បងជាងគេ ដ៏ប្រកបដោយកំពូលមានមុខលោកេស្វរៈ បែរទៅកាន់ទិសទាំង៤, នៅត្រង់ជ្រុងទាំង៤នៃខ្លោងទ្វារនោះមានរូបគ្រុឌបញ្ជាំ ។

សព្វថ្ងៃនេះ គេចេញចូលតាមគោបុរៈខាងលិចនិងខាងកើត, ឈប់រថយន្តហើយដើរចូលទៅ ដើរបន្តិចដល់ទៅមុខប្រាសាទ មានហោន ប្រកបដោយបង្កាន់ដៃនាគមានក្បាលងើយស្រឹង ក្រាលសុទ្ធថ្ម, តទៅបន្តិច ដល់កំពែងទីពីរ ។ កំពែងទីពីរព័ទ្ធជុំវិញជាប់តគ្នារហូតដល់ប្រាសាទកណ្តាល ហើយមានទ្វារ៣ សម្រាប់ចេញចូលទាំងខាងលិចនិងខាងកើត, ទ្វារកណ្តាលជាទ្វារធំ មានកំពូលខ្ពស់ ហើយមានពេងវង់ជាប់តគ្នារៀងរហូតទៅដល់ប្រាសាទកណ្តាល ។ តាមដែលពិនិត្យមើល, ប្រាសាទនេះឃើញបាក់បែកជាច្រើន នៅសល់តែសសរនឹងជញ្ជាំង, តទៅទៀត, មានផ្លូវចំនួន៥០ម៉ែត្រ តជាប់នឹងកំពែងទី៣, កំពែងនោះមានសណ្ឋានជាពេងវង់ព័ទ្ធជុំវិញ ត្រង់កន្លែងទ្វារគេធ្វើជាតួប្រាសាទ មាន

កំពូលខ្ពស់ ហើយមានរោងទងខ្វាត់ខ្វែងជាក្រឡាចត្រង្គ ជាប់គ្នានឹងប្រាសាទកណ្ដាល, ឯប្រាសាទកណ្ដាលនេះ ធំខ្ពស់ជាងប្រាសាទតាំង៨ដែលស្ថិតនៅក្នុងទីជុំវិញ ។

ក្នុងប្រាសាទបន្ទាយក្ដីនេះ ឃើញមានស្នាមគោសលុបព្រះពុទ្ធ-រូប ដែលគេឆ្លាក់នៅសសរ ឬនៅហោជាង ហើយឆ្លាក់ជារូបសាសនាព្រាហ្មណ៍វិញ សេចក្ដីឲ្យឃើញថា ប្រាសាទនេះ គេកសាងឧទ្ទិសថ្វាយព្រះពុទ្ធសាសនា, លុះចំណេរតមក ពួកសាសនាព្រាហ្មណ៍មានអំណាច គោសលុបរូបប៉ែកពុទ្ធសាសនាចោលចេញ ហើយឆ្លាក់រូបសាសនាព្រាហ្មណ៍វិញ, នៅត្រង់កន្លែងខ្លះ ឃើញមានរូបចម្លាក់ត្រង់មារវិជ័យ, ត្រង់គេបីព្រះសិទ្ធត្ថកុមារពោធិសត្វ ឲ្យទៅថ្វាយបង្គំព្រះកាលតាបស, ត្រង់កន្លែងខ្លះ ឃើញគេគោសលុបរូបសាសនាព្រាហ្មណ៍ចោលវិញ សេចក្ដីនេះនាំឲ្យយល់ថា សាសនាទាំងពីរមានឫទ្ធិអំណាចម្ដងម្នាក់ លិចអណ្ដែតៗ ហើយប្រណាំងប្រជែងគ្នា, តមកក្រោយទៀតប្រហែលជាមានពុទ្ធសាសនាហីនយានចូលមក បានជាមានព្រះពុទ្ធរូបពុទ្ធសាសនាហីនយានជាច្រើនអង្គ ស្ថិតនៅសព្វថ្ងៃនេះ ។

បើចូលតាមទ្វារខាងកើត ត្រូវឲ្យរថយន្តទៅឈប់ចាំនៅខាងលិច បើចូលពីខាងលិច ត្រូវឲ្យរថយន្តមកចាំនៅខាងកើត, កាលបើបានមើល



រូបឥសីសាសនាព្រាហ្មណ៍ អង្គុយចំរើនធម៌ ឆ្លាក់មិនទាន់ហើយ
កន្លែងឥសីនេះ កាលមុនគេឆ្លាក់ជាព្រះពុទ្ធរូបៗនេះគេកោសលុបទៅ

(តាមរូបថត ព. ស. ប.)

រួចសព្វគ្រប់ហើយ ត្រូវចេញមកខាងកើតតាមគោបុរៈធំ ហើយហួសទៅមើលស្រះស្រង់ ព្រោះស្រះស្រង់ស្ថិតនៅជិតចំពោះមុខប្រាសាទបន្ទាយក្តីនេះ ។ ប្រាសាទនេះ ព្រះបាទជ័យវរ្ម័នទី៧ទ្រង់កសាង ដើម្បីឧទ្ទិសថ្វាយព្រះពុទ្ធសាសនា ក្នុងសតវត្សរ៍ទី ១៨នៃពុទ្ធសករាជ (ព.ស.១៧២៤-១៧៦៤) ។

## ស្រះស្រង់

ស្រះស្រង់នេះ, ជាស្រះមានសណ្ឋានបួនជ្រុងទ្រវែង ប្រកបដោយក៏ក្រាលថ្មជាជណ្តើរចុះទៅកាន់ទឹក, នៅមាត់ស្រះមានដើមឈើដុះព័ទ្ធជុំវិញ មានម្លប់ត្រជាក់ត្រឈៃ បណ្តោយ៨០០ម៉ែត្រ ទទឹងប្រហែល ៤០០ម៉ែត្រ ។ កាលពីដើម ប្រហែលជាជាប់គ្នាពីប្រាសាទបន្ទាយក្តីដ៏នា? តាមសេចក្តីសន្និដ្ឋានអ្នកប្រាជ្ញបារាំងសែសជាច្រើន យល់ថាស្រះស្រង់នេះ ជាប់គ្នានឹងប្រាសាទបន្ទាយក្តី សេចក្តីយល់នេះសមណាស់ ។

ទិសខាងលិច ជាកំពង់, គេកសាងជាទីលានខ្ពស់ប្រកបដោយបង្កាន់ដៃនាគស្ទើរប្រួងប្រាងចុះទៅកាន់ទឹក, ពេលព្រះអាទិត្យលិចចុះកាន់អស្តង្គតប្រទេស, បញ្ចេញពន្លឺព្រាលរន្ទាលប៉ះមកលើទីលាននេះ បើជាយើងឈប់សំរាកបន្តិច ឈរមើលទៅខាងកើតនៅពេលនោះ រឹងរឹតតែល្អមើលណាស់ ។ នៅកណ្តាលស្រះ មានប្រាសាទតូចមួយ តែឥឡូវនេះវិនាសហើយ មើលទៅឃើញដុំថ្មទៅៗ ។ នៅខាងត្បូងកំពង់ជាទីលាន មានសាលាប្រក់ក្បឿងមួយ ជាទីសំចតឬសម្រាប់បរិភោគអាហារ ។

បើមានពេលតិច មិនអាចទឹងមើលទៅទៀតបាន ត្រូវត្រឡប់ទៅវិញតាមផ្លូវបែកទៅខាងត្បូង ប្រហែល៤០០០ម៉ែត្រដល់នគរវត្ត, តាមផ្លូវនេះ មានប្រាសាទ ៥ ស្ថិតនៅខាងត្បូងផ្លូវ គួរឈប់ចុះមើល ប្រាសាទនេះឈ្មោះ ប្រាសាទក្រវ៉ាន់ ។



ភាគទីលានស្រះស្រង់ មើលពីទិសពាយ័ព្យ

ការរចនាបែបប្រាសាទបាយ័ន រវាង ព.ស. ១៧០០

(.តាមរូបថត ស.ច.ប.)

## ប្រាសាទក្រវ៉ាន់

តាមផ្លូវវង់តូច ដែលចេញពីសៀមរាប ពីខាងត្បូងនគរវត្តទៅស្រះស្រង់ នៅចន្លោះគីឡូម៉ែត្រលេខ៧ទី៨ មានប្រាសាទ៥ល្វែងនៅខាងត្បូងជិតផ្លូវថ្នល់ រៀងគ្នាជាជួរពីខាងជើងទៅខាងត្បូង មានផ្លូវថ្នល់តូចចូលទៅមើលរួចប្រាំងរួចវស្សាបាន ។

ប្រាសាទនៅខាងជើងបាក់បែកអស់ហើយ នៅសល់តែប្រាសាទ ៤, ប្រាសាទទាំងអស់ គេកសាងដោយឥដ្ឋ ប្រកបស៊ុមទ្វារដោយថ្មឆ្លាក់ក្បាច់ បែរមុខទៅខាងកើតទាំងអស់, ប្រាសាទខាងជើង មានរូបចម្លាក់ព្រះនារាយណ៍ដៃ៤ មានទេពប្រណម្យនៅជញ្ជាំងខាងលិច, ព្រះនារាយ-ណ៍ឈរ មានទេពតាប្រណម្យពីរអង្គទៀត, នៅកណ្តាលប្រាសាទ មានយោនីមានទុមាភោគវតី, នៅទ្វារមានសិលាចារឹក ។

ប្រាសាទបន្ទាប់ខាងជើងមិនមានអ្វីនិយាយទេ ។ នៅប្រាសាទកណ្តាល មានទ្វារបាលពីរនាក់ ឆ្លាក់ជាប់នៅជញ្ជាំងឥដ្ឋ, ខាងក្នុងប្រាសាទ ជញ្ជាំងខាងជើង ព្រះនារាយណ៍ដៃ៨ជិះលើគ្រុឌ មានទេវបុត្រទេវធីតាឈរនមស្ការ, នៅខាងលើ ព្រះនារាយណ៍អវតារជាក្រពើ, ជញ្ជាំងខាងត្បូង ព្រះនារាយណ៍ដៃ៤ឈរនៅលើជើងទ្រ មានទេវបុត្រទេវធីតានមស្ការ, ស្រីម្នាក់ទៀតយកផ្កាឈូកទ្រជើង គឺនាងលក្ស្មី,

ឃើញខ្សែទឹករលកកក្រាញ់ក្នុងសមុទ្រ សំដែងឲ្យឃើញថា កាលព្រះនារាយណ៍ត្រាច់ទៅក្នុងត្រៃភព; នៅកណ្ដាលមានសិវលិង្គ, នៅទ្វារមានសិលាចារឹក ប្រាសាទខាងត្បូងបង្អស់មិនមានអ្វីនិយាយទេ ។

ប្រាសាទនេះ ព្រះបាទហរ្សវរ្ម័នទី១ ទ្រង់កសាងក្នុងសតវត្សរ៍ទី១៥ នៃពុទ្ធសករាជ (ព. ស. ១៤៥៣-១៤៦៥) ដើម្បីឧទ្ទិសថ្វាយដល់ព្រះនារាយណ៍ ។

អ្នកដំណើរដែលមានឱកាសច្រើន ត្រូវឡើងរថយន្តបរសំដៅទៅស្រះស្រង់ ចំនួន ១២០០ ម៉ែត្រដល់ហើយ, បើមិនមានពេលច្រើនទេ ត្រូវត្រឡប់មកសៀមរាប ហើយអញ្ជើញទៅតាមប្រាថ្នាចុះ ។



ភាពប្រាសាទប្រែរូបទាំងមូល មើលពីទិសខាងកើត
ការរចនាបែបប្រាសាទបាខែង រវាង ព. ស. ១៤៩៣
( តាមរូបថត ស.ប.ប. )

វគ្គទី ៦

# វង់ធំ

## ប្រាសាទប្រែរូប

ប្រាសាទប្រែរូប ស្ថិតនៅជិតគីឡូម៉ែត្រលេខ១៦ នៃវង់ធំ គពី បន្ទាយក្តី២៥០០ម៉ែត្រ, បណ្តោយកំពែង១២០ម៉ែត្រ ទទឹង១០៨ម៉ែត្រ ។ ប្រាសាទប្រែរូបនេះ គេកសាងពីឥដ្ឋសុទ្ធ ប្រកបស៊ុមទ្វារដោយថ្ម មើលពីចំងាយឃើញឥដ្ឋព័ណ៌ក្រហមប្រផេះ, កំពូលទាំង៥ខ្ពស់ត្រដែតកណ្តាលអាកាស ។

មានថ្នាក់៣ មានជណ្តើរចុះទៅកាន់ទិសទាំង៤, នៅក្បាលជណ្តើរមួយៗ មានសត្វសីហៈជាទ្វារបាល, តែជណ្តើរដែលឡើងបានស្រួលនោះ បានតែជណ្តើរខាងកើត, នៅថ្នាក់ទី ៣ ជាទីប្រតិស្ឋានប្រាសាទទាំង៥ ប្រាសាទកណ្តាលធំខ្ពស់ ប្រាសាទទាំង៤នៅអមគ្រប់ជ្រុងអនុទិស ហើយបែរមុខទៅកាន់ទិសខាងកើត, បីទិសទៀត មានតែទ្វារបញ្ឆោត ។

នៅថ្នាក់ទី២ មុខជណ្តើរ កណ្តាលផ្លូវឡើងទៅកាន់ថ្នាក់ទី ៣ មានស្នូកថ្មសណ្ឋាន៤ជ្រុងទ្រវែង នៅជុំវិញមានបង្គោលថ្មទំនងជាជើងថ្ករ, តាមទំនងនេះ, នាំឲ្យគេយល់ថា ប្រាសាទនេះគេប្រើសម្រាប់បូជាសពស្តេច បានជាគេឲ្យឈ្មោះថា ប្រាសាទប្រែរូប ។

ក្បាច់រចនាប្រាសាទនេះក៏ល្អចំណានណាស់ដែរ ដូចប្រាង្គមួយនៅខាងត្បូង ត្រង់ផ្តែរលើខ្លោងទ្វារ មានចម្លាក់ព្រះនារាយណ៍អវតារជាសីហៈ (នរសិង្ហៈ) ចាប់ហែកយក្សស៊ុ, ក្បាច់ខ្លះទៀតគេធ្វើមិនទាន់ហើយស្រេច ។

ប្រាសាទនៅប្រែរូបនេះ ព្រះបាទរាជេន្ទ្រវរ្ម័នទី ២ ទ្រង់កសាងក្នុងខាងចុងសតវត្សរ៍ទី១៥ នៃពុទ្ធសករាជ (ព.ស. ១៦៥៦) ដើម្បីឧទ្ទិសថ្វាយដល់សាសនាព្រាហ្មណ៍ ។

លុះមើលរួចហើយ ត្រូវឡើងរថយន្តទៅមើលប្រាសាទមេបុណ្យទៀត នៅចំងាយចំនួន១៦០០ម៉ែត្រ ពីប្រាសាទនេះ ។



រូបព្រះវិស្ណុផ្ទេកផ្អៀង ធំអស្ចារ្យ គេជីកឃើញនៅប្រាសាទមេបុណ្យទិសខាងកើត
ការរចនាសម័យប្រាសាទបាពួន រវាង ព.ស. ១៥៩៣

( តាមរូបថត ស.ប.ប. )

# ប្រាសាទមេបុណ្យ

ប្រាសាទមេបុណ្យ ស្ថិតនៅចន្លោះគីឡូម៉ែត្រលេខ១០ និងលេខ១១ នៃផ្លូវធំ កណ្ដាលស្រះធំរីងហួតទឹកអស់, ស្រះនេះបណ្ដោយ ៧ គីឡូម៉ែត្រ ពីខាងកើតទៅខាងលិច ទទឹង ១៨០០ ម៉ែត្រ ពីខាងជើងទៅខាងត្បូង មានភ្លឺព័ទ្ធជុំវិញ ជាស្រះសម្រាប់ទុកទឹកប្រើប្រាស់ក្នុងក្រុង, ហើយប្រហែលជាគេបង្ហូរទឹកពីស្ទឹងសៀមរាបចូលមកផង, ប្រាសាទនេះ គេហៅថា "មេបុណ្យខាងកើត" ។

តាមសិលាចារឹកជាច្រើនកន្លែង មាននិយាយថា: "ព្រះបាទយសោវរ្ម័នទី ១ ទ្រង់កសាងស្រះមួយឈ្មោះ យសោធរតដាកៈ ស្រះទ្រទ្រង់ទូលាយ នៅកណ្ដាលស្រះនោះ ទ្រង់បានកសាងភ្នំព្រះសុមេរុ គឺប្រហែលជាប្រាសាទមេបុណ្យនេះឯង ក្នុងខាងចុងសតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ" ។

នៅគោបុរៈចូលទៅនេះ មានសិលាចារឹកនិយាយពីព្រះបាទរាជេន្ទ្រវរ្ម័ន ទ្រង់កសាងប្រាសាទមេបុណ្យនេះ ជាស្ដេចទ្រទ្រង់នូវឫទ្ធិអំណាចបកផស័ក្តិដ៏ខ្ពង់ខ្ពស់ ផ្សាយអំណាចទួទៅដល់សមុទ្រ... ។

ប្រាសាទនេះ គេកំពុងរៀបធ្វើឡើងជាថ្មីវិញ មានកំពស់ទាបជាងប្រាសាទប្រែរូប, របស់ដែលគួរមើល គឺប្រាសាទនេះ គេច្រើនធ្វើពីឥដ្ឋ ស៊ុមទ្វារពីថ្ម ហើយមានដំរីនៅគ្រប់ជ្រុងអនុទិសគ្រប់ទាំង៤ថ្នាក់ ដំរីនេះ.

មានវៀកនឹងកណ្ដឹង, នៅថ្នាក់ទី១ មានប្រាសាទ៤, នៅថ្នាក់ទី២ មានប្រាសាទតូចជាច្រើនព័ទ្ធជុំវិញ, ថ្នាក់ទី៣ ប្រាសាទកណ្ដាលធំខ្ពស់ មានជណ្ដើរឡើងបានទាំង៤ទិស ហើយមានប្រាសាទតូចៗ ស្ថិតនៅត្រង់ជ្រុងអនុទិស មានសីហៈជាទ្វារបាលនៅតាមត្រង់ជណ្ដើរ; នៅលានថ្នាក់ទី២ មានទឹកធ្លាក់ជាក្បាលសីហៈសម្រាប់បង្ហូរទឹកចេញ ។

ប្រាសាទមេបុណ្យនេះ ព្រះបាទរាជេន្ទ្រវរ្ម័នទី២ ទ្រង់កសាងក្នុងខាងចុងសតវត្សរ៍ទី១០ នៃពុទ្ធសករាជ (ព. ស. ១៤៨៥) ដើម្បីឧទ្ទិសថ្វាយសាសនាព្រាហ្មណ៍ ។

លុះមើលរួចហើយ ត្រូវឡើងរថយន្តទៅទៀត ទៅបន្តិចដល់ស្ទឹងសៀមរាប មានស្ពានស៊ីម៉ង់ត៍ មើលទៅឃើញទឹកថ្លាយង់គួរមុជជំរះកាយ, តពីស្ពានទៅទៀត មានប្រាសាទមួយស្ថិតប្របថ្នល់ខាងកើត មើលឃើញគោបុរៈក្រៅ មានដើមឈើដុះពុះពាក់កណ្ដាលដូចជាសក់ មានមែកត្រសុំត្រសាយ គេឲ្យឈ្មោះថា ប្រាសាទតាសោម ។

# ប្រាសាទតាសោម

ប្រាសាទតាសោម ស្ថិតនៅជិតកិឡូម៉ែត្រលេខ៨នៃផ្លូវវង់ធំ មានគោបុរៈប្រែកបមុខលោកេស្វរៈទាំង៤ ដូចបានឃើញនៅប្រាសាទនគរធំ, ប្រាសាទតាព្រហ្ម, ប្រាសាទបន្ទាយក្ដី ការរចនាសម័យជាមួយគ្នា ។

អ្នកមើល, ត្រូវឈប់រថយន្តហើយ ចូលតាមគោបុរៈខាងលិចនៃកំពែងខាងក្រៅ ដែលមានកំពូលដុះសក់វែងគឺដើមជ្រៃ, កំពែងនេះ បណ្ដោយ ២៤០ម៉ែត្រពីខាងលិចទៅខាងកើត, ទទឹង២០០ម៉ែត្រពីខាងជើងទៅខាងត្បូង, តទៅ គេត្រូវឆ្លងស្រះមួយទៀត តែរីងហួតទឹកអស់ហើយ ។ ប្រាសាទនេះ គេមិនទាន់កាប់ឆ្ការព្រៃទេ គេទុកឲ្យនៅតាមសភាពដើម ដែលមានរុក្ខលតាជាតិញាំញី តែអាចដើរចូលមើលបានយ៉ាងស្រួលមិនពិបាកឡើយ ។ អ្នកមើល, លុះឆ្លងផុតស្រះទៅកំពែងជាន់ទី២ហើយ ត្រូវចូលទៅតាមទ្វារតូចនៅទិសនិរតី ទ្វារតូចទិសពាយ័ព្យ ដើមជ្រៃដុះចាក់ឫសជិតចូលមិនបាន, នៅហោជាងនៃកេងទងព័ទ្ធជុំវិញប្រាសាទកណ្ដាល មានផ្ទាក់រឿងរ៉ាវព្រះពុទ្ធសាសនា, នៅខាងកើតទីវាល, ក្នុងកំពែងទី២មានធម្មសាលាពីរ ។ លុះមើលរួចហើយ គេអាចចេញមកវិញ តាមផ្លូវទិសឦសាន តាមទ្វារកេងទងខាងកើត ហើយដើរត្រឡប់មកខាងលិចសៀរបែរទៅខាងជើង ។

គោបុរៈខាងកើត មានសណ្ឋានដូចគោបុរៈខាងលិចដែលបានពោលរួចហើយ ។

នៅខាងក្នុងកំពែងក្រៅ មានដើមឈើដុះដេរដាសពាសពេញ មានដើមធ្នៀវ ដល់ផ្លូវចុងវិហារបេត្រ, មានផ្លែធំ មានរសជាតិឆ្ងាញ់ពិសា ។

ប្រាសាទតាសោមនេះ ព្រះបាទជ័យវរ្ម័នទី៧ ទ្រង់កសាងក្នុងសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ (ព.ស. ១៧២៤-១៧៦៦) ដើម្បីឧទ្ទិសថ្វាយដល់ព្រះពុទ្ធសាសនា ។

លុះមើលរួចហើយ ត្រូវឡើងរថយន្តសំដៅទៅតាមផ្លូវវង់ធំ ត្រង់ទៅខាងជើង ទៅបន្តិច បត់ត្រង់ទៅខាងលិចចំនួនពីរគីឡូម៉ែត្រ នឹងឃើញផ្លូវដើរមួយ នៅខាងជើងផ្លូវថ្នល់ ចុះដើរកាត់ព្រៃបន្តិច នឹងដល់ប្រាសាទមួយអន្តរាយអស់ ឈ្មោះ ប្រាសាទក្រោលគោ ។

## ប្រាសាទក្រោលគោ

ប្រាសាទនេះ, មានការរចនាប្រហែលគ្នានឹងនាគព័ន្ធ មានរូបលោកេស្វរៈ, នៅហោជាងខ្លះមានរឿងព្រះនារាយណ៍, នៅហោជាងដែលបាក់ធ្លាក់មកលើដីខាងទិសអគ្នេយ៍ មានរឿងក្រិស្ណៈទ្រភ្នំ ដើម្បីការពារហ្វូងសត្វពាហនៈនឹងគង្វាល ។

កំពែងព័ទ្ធខាងក្រៅ ធ្វើពីថ្មបាយក្រៀម បណ្តោយ៣៥ម៉ែត្រ ទទឹង២៥ ម៉ែត្រ មានទីលាននឹងគោបុរៈចូលពីខាងកើត, នៅខាងត្បូង, ខាងលិច, ខាងជើង មានស្រះព័ទ្ធជុំវិញ ។

លុះមើលរួចហើយ ត្រូវថយត្រឡប់មកវិញ ឡើងរថយន្តបត់ទៅខាងលិចបន្តិច នឹងឃើញថ្នល់ខាងឆ្វេងដៃ ជាប់ពីផ្លូវធំ ផ្លូវនេះទៅប្រាសាទនាគព័ន្ធ ។



ភាពប្រាសាទតាគព៌ុំ ដែលគេកាប់ឆ្ការព្រៃហើយ
ការរចនាបែបប្រាសាទបាយ័ន រវាង ព. ស. ១៧០០

*(តាមរូបថត ស. ព. ប.)*

## ប្រាសាទនាគព័ន្ធ

តាមផ្លូវធំ នៅចំកិឡូម៉ែត្រលេខ៦ មានផ្លូវបែរវៀចខ្ទេតជាប់ពីផ្លូវធំ រហូតដល់កំពែងខាងជើង ឥឡូវនេះឃើញតែទំនប់ដីខ្ពស់, កំពែងក្រៅនេះ ទំហំ ៣៥០ ម៉ែត្របួនជ្រុងស្មើ ៗ ជ្រុងកំពែងទាំង៤ទិស តាមលោក ហ. មាំរសាល់ លោកសន្និដ្ឋានថា ប្រហែលជាមានរូបដំរីនៅគ្រប់ជ្រុងទាំងអស់ ដូចប្រាសាទមេបុណ្យ ព្រោះឃើញមានរូបដំរីនៅជ្រុងពាយ័ព្យ, លោកយល់ម្យ៉ាងទៀតថា ទីប្រាសាទនាគព័ន្ធនេះ ស៊ីអស់បណ្ដោយ ៣ កិឡូម៉ែត្រ ទទឹង៩០០ម៉ែត្រ ហើយជាប់គ្នាពីប្រាសាទព្រះខាន់មក ដូចស្រះស្រង់ជាប់គ្នានឹងបន្ទាយក្ដី ។

នៅក្នុងកំពែងខាងក្រៅ មានស្រះធំ បួនជ្រុងស្មើ នៅគ្រប់ទិស, គពីស្រះធំនេះ មានស្រះតូចៗស្ថិតនៅគ្រប់ទិសទៀត ទើបដល់ស្រះធំកណ្ដាល ដែលជាទីប្រតិស្ឋានប្រាសាទនាគព័ន្ធ, ស្រះអស់នេះ សុទ្ធតែមានថ្នាក់ជាជណ្ដើរចុះទៅកាន់ទឹក ។ ឯស្រះធំកណ្ដាល មានប្រាសាទតូចៗគ្រប់ទិសទាំងបួន ជាទីបង្ហូរទឹកទៅកាន់ស្រះតូចៗដែលស្ថិតនៅគ្រប់ទិសទាំង៤, ប្រាសាទតូចៗនេះ បែរមុខចេញក្រៅ មានសណ្ឋានជាខ្ទមបើកមុខ ហើយផ្ទាក់ថ្មជាទមានសណ្ឋានដូចផ្កាឈូក កាលបើចាក់ទឹកទៅ ទឹកនឹងហូរចូលទៅកាន់ស្រះទាំង៤ តាមថ្មដែលគេឆ្លាក់ជាក្បាលផ្សេងៗគ្នា

ខាងកើតជាក្បាលមនុស្ស, ខាងត្បូងជាក្បាលសីហៈ, ខាងលិចជាក្បាលគោ[១] ខាងជើងជាក្បាលដំរី, កាលបើទឹកស្រះធំកណ្ដាលច្រើន ក៏ហៀរហូរចេញមកកាន់ស្រះតូចៗ ដែលនៅគ្រប់ទិស ៗ នៅទិសខាងកើត មានសិវលិង្គ កាលគេចាក់ទឹកតាមទទឹកនោះ ទឹកក៏ហូរតាមទៅលើយោនីនាងឧមាគោគវតី ហើយហូរធ្លាក់ចុះមកក្រោម បើមានមនុស្សចុះនៅអង្គុយពីក្រោមទឹកហូរធ្លាក់លើក្បាលល្មមស្រួល ៗ នៅហោជាងប្រាសាទតូចៗទាំង៤ទិស មានរូបលោកេស្វរៈកំពុងធ្វើសេចក្ដីសង្គ្រោះមនុស្សក្រីក្រមនុស្សឈឺចាប់ និងកំពុងប្រទានថ្នាំ ៗ

នៅកណ្ដាលស្រះធំ ជាទីប្រតិស្ឋានប្រាសាទនាគព័ន្ធ មានសណ្ឋានជាកោះមូលខ្ពស់ឡើង, ប្រាសាទនេះ ស្ថិតនៅលើខ្លួននាគពីរមូលយ៉ាងធំ កន្ទុយនាគទាំងពីរមករុំព័ទ្ធព័ន្ធគ្នា ត្របាញ់ឡើងលើនៅទិសខាងលិច, ក្បាលនៅទិសខាងកើត ៗ ប្រាសាទនេះតូច មានសណ្ឋានដូចជាប្រាង្គ បែរមុខទៅខាងកើត ស្ថិតនៅលើស្រទាប់ផ្កាឈូក ទ្រង់ស័ក្តិសម ៗ កាលពីដើម មានគ្រាងមួយដើមដុះចំពីលើប្រាសាទ ចាក់ឫសព័ទ្ធជុំវិញប្រាសាទ, មានមែកសំយាកត្រសាយដូចជាសក់ ឬ ឆត្របាំងពីលើ, ឥឡូវនេះ ទន្ទះបាញ់បាក់ខ្ទេចអស់ គួរឲ្យស្ដាយ-ព្រោះអស់គ្រឿង

(១) សៀវភៅ ហ. ម៉ារសាល់ (H. Marchal) ថាក្បាលសេះ; សៀវភៅព្រះតេជព្រះគុណព្រះសុភាក្សរវង្សថា តាមអ្នកដំណើរចិន ចៅ តាក្វាន់ ថា ក្បាលគោវិញ ។



រូបលោកេស្វរៈនៅទ្វារបញ្ឆោត, នៅហោជាងខាងលើ
ថ្ងៃងកាលពោធិសត្វទ្រង់គង់លើកណ្ឋកភជចេញសាងអភិនិស្ក្រមណ៍
ប្រាសាទតាគព៌ុ

( តាមរូបថត ស.ប.ប. )

អលង្ការជាគ្រឿងលំអ ហើយគេកាប់រើចោលចេញនៅសល់តែប្រាសាទ ទទេ ។

នៅលើសុមទ្វារខាងកើត, មានរូបចម្លាក់កាលព្រះពោធិសត្វកាត់កោរព្រះកេសា ទ្រង់ព្រះផ្នួស ខាងក្រោម, សេះកណ្ឋកៈនិងឆន្នអាមាត្យ សងខាងទ្វារមានរូបដំរី, នៅបន្ទួចបញ្ចោតខាងជើងនិងខាងលិច មានរូបលោកេស្វរៈ, ខាងត្បូង រូបលោកេស្វរៈនិងព្រះអាទិត្យព្រះចន្ទ្រ, ក្បាច់ចម្លាក់នេះ សុទ្ធសឹងតែល្អចំឡែក; ខាងក្នុងប្រាសាទ មានព្រះពុទ្ធរូបនាគប្រក់ ដែលគេយកមកដម្កល់ទុកជាខាងក្រោយ ។

នៅខាងមុខប្រាសាទនេះ សេះមួយកំពុងហោះលឿនស្ទៅ, ទ្រង់ព្រាយបញ្ចូនខ្លួន មានចង្កោមមនុស្សគោងកន្ទុយ ហាក់ដូចជាមានមេត្តាករុណា ស្រោចស្រង់ហោះនាំទៅកាន់សិវស្ថាន, សេះនេះឈ្មោះ ពលាហកៈ(១) ។ សេះពលាហកៈនេះ តាមលោក ល. ហ្វីណូត៍ និង វ. គោលូបេវ លោកនិយាយថា មានសិលាចារឹកនៅវិមានអាកាស សេចក្តីថា ពោធិសត្វលោកេស្វរៈ ជំណែងជាសេះពលាហកៈ ហោះទៅស្រោចស្រង់មហាជនស្រីប្រុស ដែលធ្លាយសំពៅលិចលង់នៅកណ្តាលមហាសមុទ្រ បានទៅជ្រកអាស្រ័យនៅកោះនាងយក្ខិនីមួយ, នាងយក្ខិនីនេះ ចាប់បណ្តាជនខ្លះបរិភោគជាអាហារ បានពោធិសត្វលោកេស្វរៈ ដែលជំណែង

(១) ក្នុងគម្ពីរបាលី មានជាតកមួយ ឈ្មោះពលាហកជាតក មានសេចក្តីដូចគ្នានឹងរឿងនេះ ។

ជាសេះពលាហកៈ ហោះទៅស្រោចស្រង់នាំយកបណ្ដាជននោះមកកាន់ជម្ពូទ្វីប ដែលជាស្រុកទេសរៀងខ្លួន បានសេចក្ដីសុខសប្បាយ ។ រូបសេះពលាហកៈនេះ គួរអស្ចារ្យដល់គំនិតអ្នកគិតប្រតិស្ឋានឡើងណាស់ ព្រោះមានថ្វីដៃយ៉ាងសំខាន់ ពិបាកបាប់គួរប្រៀប ។

កាលបើជញ្ជឹងគិតមើល, គេនឹងលេចគំនិតឡើងថា ប្រាសាទនាគ-ព័ន្ធនេះ គេកសាងតំណាងចក្រវាឡមួយ មានទ្វីប៤, មហាសមុទ្រ៤ ជាខឿនទ្រ កណ្ដាលប្រតិស្ឋានភ្នំព្រះសុមេរុ មានភ្នំសត្តបរិភ ៧ជាន់ និងសត្តសិន្ធុ ៧ ជាន់ ជុំវិញភ្នំព្រះសុមេរុ តាមជំនឿនៃជនជាន់បុរាណ ។

ប្រាសាទនាគព័ន្ធនេះ ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់កសាងក្នុងកណ្ដាលសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ (ព.ស.១៧២៤-១៧៤៤) ដើម្បីឧទ្ទិសថ្វាយដល់ពោធិសត្វលោកេស្វរៈ ។

លុះមើលរួចហើយ ត្រូវថយចេញមកតាមផ្លូវដដែល ដល់មកផ្លូវធំត្រង់មកខាងលិចបន្តិច នឹងឃើញផ្លូវបត់មួយទៀត ហើយចូលទៅមើលប្រាសាទព្រះខាន់ តាមទិសខាងកើត ។



មុខលោកេស្វរៈ នៅលើកំពូលប្រាសាទព្រះខាន់ ទ្វារចូលខាងលិច
ការរចនាបែបបាយ័ន រវាង គ.ស. ១៣៨០

(តាមរូបថត ព.ស.ប.)

# ប្រាសាទព្រះខាន់

ផ្លូវធំ ចេញតាមគោបុរៈនគរធំខាងជើង, នៅចន្លោះគីឡូម៉ែត្រលេខ ២ និងលេខ៣ មានប្រាសាទធំយ៉ាងល្អវិសេសមួយ ឈ្មោះ ព្រះខាន់ ។

វិជ្ជាកសាងប្រាសាទនេះ ដូចប្រាសាទតាព្រហ្ម និងប្រាសាទបន្ទាយក្តី ប៉ុន្តែមានទ្រង់ទ្រាយសមជាង កំពែងខាងក្រៅធ្វើពីថ្មបាយក្រៀម បណ្តោយ ៨០០ម៉ែត្រ ទទឹង៧០០ម៉ែត្រ, មានស្ទឹងព័ទ្ធជុំវិញ លើកតែផ្លូវចូលទាំង ៤ ទិស, ផ្លូវចូលទាំង ៤ ទិសនេះ ប្រកបដោយបង្កាន់ដៃអសុរនិងទេពតាទាញនាគធ្វើជាព្រ័ត្រ; ទិសខាងកើត, តពីបង្កាន់ដៃអសុរនិងទេពតាទាញព្រ័ត្រនេះ មានបង្គោលសីមាពីរជួរអមផ្លូវផង ។

គោបុរៈទាំងអស់នៃកំពែងខាងក្រៅ ថែកពីយើងធ្លាប់មើល សុទ្ធតែមានទ្វារ៣, ទ្វារមួយៗ មានកំពូលខ្ពស់ប្រដាប់ដោយត្របកផ្កាឈូក, កំពូលទ្វារកណ្តាលនៃគោបុរៈខាងលិច រលំបាក់ខូចហើយ, ទ្វារអមទាំងសងខាង មានស៊ុមទាំងក្នុងទាំងក្រៅ, គោបុរៈកណ្តាល សម្រាប់ក្បួនទ័ព ក្បួនពិធីបុណ្យផ្សេងៗ; នៅសងខាងគោបុរៈ មានរូបគ្រុឌចេញដៃ ធ្វាក់ភ្ជាប់នៅជញ្ជាំងកំពែង ។

លុះចូលផុតខ្លោងទ្វារទៅ គេត្រូវដើរតាមផ្លូវតូច អមដោយព្រៃព្រឹក្សាលតាជាតិ ប្រកបដោយសូរសំឡេងបក្សីបក្សាបាសយំអឺងកងរំពងពាសពេញព្រៃ, នៅមុខប្រាសាទប្រហែល២០ម៉ែត្រ មានធម្មសាលា

ក្នុងរង្វង់ផ្នែកខ្ពស់គេឆ្លាក់ជាព្រះពុទ្ធរូបដែរ នុ៎ះក៏ត្រូវគេកោសលុបចោលអស់ទៅវិញ ឃើញនៅសល់តែស្នាមកោសលុបនោះ ត្រង់កន្លែងខ្លះគេឆ្លាក់ថែមជារូបឥសីទៀតវិញ ។

នៅក្នុងកំពែងទី២, ប្រាសាទខ្លះ មានហោជាងឆ្លាក់ជារូបលោកេ-ស្វរៈ ហោជាងខ្លះមានរឿងព្រះពុទ្ធសាសនា ។ នៅក្នុងកំពែងទី៣, ផ្តែរលើទ្វារ មានរូបស្ត្រីអប្សរកំល្ហាសល្ហន់, មានសសរមូល កន្លែងនេះប្រហែលជាធម្មន្ទរឬ? ។ នៅក្នុងកំពែងទី៤ គេកំពុងរៀបចំធ្វើ មានរូបខ្លះជារូបកិន្នរី នៅចន្លោះព្រះពុទ្ធរូបដែលគេកោសលុបចោលទៅ ។ ខាងលិច, ប្រាសាទមួយខាងជើង, នៅហោជាងមុខខាងត្បូង មានរូបព្រះឥសូរ មានផ្កាឈូកចេញពីខ្លួន អគ្គមហេសីប្រថាប់ជើង ជិះលើមករ មានត្រីនៅក្រោម មានមនុស្សឈរនៅអម, មុខខាងកើត មានរូបព្រះឥសូរអង្គុយកណ្ដាលព្រះព្រហ្ម ។ នៅហោជាងដែលធ្លាក់មកក្រោម, មានរឿងកម-ទេព្ត ត្រង់ព្រះកាមទឹងកពណ៌ច្បាំងគ្នា, ហោជាងមួយទៀត, ឃើញព្រះរាម ហនុមាណទឹងព្រះលក្សណ៍, ហោជាងខ្លះមានរូបព្រះអាទិត្យ ព្រះចន្ទ្រ ព្រះនារាយណ៍ ទឹងរឿងកូរទឹកសមុទ្រ ។ លុះចេញផុតមក តាមទ្វារខាងជើង មានទ្វារបាលពីរនាក់ធំសំបើម ដៃជើងមាំៗ មានដុំសាច់ធំៗ នាំឲ្យយល់ថា សេនាទាហានសម័យនគរ មានវិធីហាត់ប្រាណយ៉ាងវិសេស ដូចប្រទេសទុរុបសម័យនេះដែរ ។

ការមើលប្រាសាទនេះ គេអាចចូលពីគោបុរៈខាងជើងក៏បាន បើចូលពីខាងជើង ត្រូវឲ្យរថយន្តទៅឈប់ខាងកើត, បើចូលពីខាងកើត ឲ្យរថយន្តទៅឈប់ចាំខាងជើង ។

ប្រាសាទព្រះខាន់នេះ ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់កសាងដើម្បីឧទ្ទិសថ្វាយព្រះពុទ្ធសាសនា ក្នុងកណ្ដាលសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ (ព.ស.១៧២៤-១៧៤៤) ។ តាមសិលាចារឹក ដែលទើបរកឃើញថ្មីក្នុងប្រាសាទនេះ, លោក គ.សឺដែស តាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស បានពន្យល់ថា: "ប្រាសាទនេះ ព្រះបាទជ័យវរ្ម័នទី៧កសាងក្នុងព.ស.១៧៣៤, ដើម្បីឧទ្ទិសថ្វាយពោធិសត្វលោកេស្វរៈ, ទ្រង់កសាងព្រះបរមរូបព្រះបាទធរណីន្ទ្រវរ្ម័ន ជាព្រះវររាជបិតា ជាទេវរាជតំណាងលោកេស្វរៈ, ដូចគ្នានឹងប្រាសាទតាព្រហ្ម, ស្ដេចទ្រង់កសាងព្រះបរមរូបព្រះវររាជជននី តំណាងនាងប្រាជ្ញាបារមីតា ក្នុងរវាង ៨ ឆ្នាំក្រោយប្រាសាទព្រះខាន់នេះ" ។

លុះមើលរួចហើយ ត្រូវឡើងរថយន្តមកតាមផ្លូវវង់ធំ ចូលមកនគរធំ ជិតដល់នគរធំនៅ៤០០ម៉ែត្រ គួរចូលមើល ក្រោលដំរី, តាមផ្លូវតូចចូលទៅ ។

## ក្រោលដំរី

ក្រោលនេះ មានកំពែងថ្មបាយក្រៀម រាងមូល កំពស់ ៣ ម៉ែត្រ មានផ្លូវចូលពីរកន្លែង, ជាកន្លែងសម្រាប់ផ្សាំងដំរីដែលទើបនឹងចាប់បានៈ នៅប្រទេសសៀម មានក្រោលដំរីដូចគ្នាដែរ គឺនៅក្រុងលុពបុរី ។ លុះមើលរួចហើយត្រឡើងរថយន្តចូលទៅតាមទ្វារអង្គរធំ ខាងជើង កាត់អង្គរធំ បាយ័ន អង្គរវត្ត មុខនាគ ទៅសៀមរាបវិញ ។



ភាពប្រាសាទវត្តអធ្វា ដែលដល់នូវជរាភាពហើយ
ការរចនាសម័យប្រាសាទនគរវត្ត រវាង ព.ស. ១.៦៥០

(តាមរូបថត ព.ស.ម.)

វគ្គ ទី ៧

# ប្រាសាទផ្សេងៗ

## ប្រាសាទវត្តអធ្វា

តាមផ្លូវខាងលិចដងស្ទឹង ចុះពីផ្សារសៀមរាបទៅភ្នំក្រោម នៅចន្លោះគីឡូម៉ែត្រលេខ ៤ និងលេខ ៥ មានផ្លូវមួយបែកចេញទៅខាងលិច, ត្រង់ផ្លូវបែកនេះ មានខ្លោងទ្វារឈើមួយដាក់ឈ្មោះថា "វត្តអធ្វា" ។ ផ្លូវនេះ, គេអាចទៅដោយរថយន្តតូច-ធំបាន, កាត់វាលស្រែចំនួនជា ៥០០ ម៉ែត្រ គេនឹងដល់ទៅវត្តមួយឈ្មោះ វត្តអធ្វា, វត្តនេះគេកសាងថ្មី នៅជាប់នឹងកំពែងទិសខាងជើង ។

ប្រាសាទវត្តអធ្វា ជាប្រាសាទមួយល្អណាស់ដែរ មានសណ្ឋានទ្រង់ទ្រាយស្ទើរដូចប្រាសាទនគរវត្ត, គេកសាងបែរមុខទៅខាងលិចដូចគ្នា, មានកំពែងថ្មបាយក្រៀមព័ទ្ធជុំវិញ ។ ប្រាសាទធំស្ថិតនៅកណ្ដាលមានទ្វារ៤, មានយ៉លយចេញទៅខាងលិច, នៅយ៉ានេះ គេមើលឃើញព្រះពុទ្ធរូបខ្លះ គេលាបព័ណ៌ផ្សេងៗ; មានប្រាង្គស្ថិតនៅគ្រប់ជ្រុងអនុទិស ។ សព្វថ្ងៃ ប្រាសាទនេះវិនាសអន្តរាយទៅច្រើនហើយ, គេមិនទាន់អាចរកដើមកំណើតប្រាសាទបានថា គេកសាងពីកាលណា ឬស្ដេចណាកសាង, បើតាមទំនង គួររាប់បញ្ចូលក្នុងពួកប្រាសាទនគរវត្ត ។ លុះមើលរួចហើយ, ឡើងរថយន្តទៅមើល ប្រាសាទភ្នំក្រោម ទៀត ។



ភាពប្រាសាទភ្នំក្រោម មើលចំពាក់កណ្ដាល
ការរចនាបែបប្រាសាទបាខែង រវាង ព.ស. ១៤៤៣

( តាមរូបថត ស.ប.ប. )

# ប្រាសាទភ្នំក្រោម

ត្រូវធ្វើដំណើរទៅតាមផ្លូវដងស្ទឹងតរៀងទៅ, បើគិតចំងាយពីផ្សារសៀមរាបទៅភ្នំក្រោមនេះ ប្រហែល ១៣ គីឡូម៉ែត្រ, ទៅដល់ភ្នំក្រោមមានផ្លូវឡើងទៅលើភ្នំ, ត្រូវប្រយ័ត្ន បើមានរថយន្តតូចសំរាប់ឡើង រថយន្តធំត្រូវឈប់នៅក្រោម, ព្រោះផ្លូវឡើងទៅនេះមានគ្រោះថ្នាក់ច្រើន ។

ភ្នំក្រោមជាភ្នំត្រងិល ត្រង់ទីខ្ពស់គេកសាងជាប្រាសាទ ៣ ខ្ទមគ្នា បែរមុខទៅខាងកើត, មានទេវស្ថានតូច ៤ ខ្នងបែរមុខទៅកើត, មានកំពែងព័ទ្ធជុំវិញ; កាលដែលកំពុងរៀបចំ, គេបានរកឃើញទេវរូបដែលបាត់បង់ទៅ គឺ ព្រះព្រហ្ម ព្រះឥសូរ និងព្រះវិស្ណុ, ឥឡូវនេះ, គេយកមកដំកល់ទុកនៅប្រាសាទនោះវិញ; នៅមុខប្រាសាទ, មានទ្វារបាលមួយធំ ៗ ប្រាសាទនេះល្អណាស់ដែរ, តែដោយប្រាសាទនេះស្ថិតនៅកណ្ដាលវាល· ត្រូវភ្លៀងត្រូវខ្យល់ខ្លាំងក៏ពុកផុយ របេះរបកក្បាច់របនាស្ទើរតែអស់ នាំឲ្យខាតលំអជាច្រើន ។ នៅខាងមុខប្រាសាទនេះ តាមទីទំនាបកបស្ទឹង មានវត្តមួយ, ខាងមុខវត្តនេះ មានទ្វារបាលមួយទៀត រូបស័ក្តិសម, មានអលង្ការដ៏វិចិត្រ ។

ការមើលប្រាសាទនេះ ត្រូវមើលពេលព្រឹកឬពេលល្ងាចត្រជាក់, ព្រោះពេលថ្ងៃក្ដៅណាស់ ហើយគ្មានដើមឈើជាម្លប់ជ្រកផង; កាលដែល

គេនៅលើភ្នំ គេអាចមើលទៅជុំវិញភ្នំបាន មើលទៅទិសត្បូង ឃើញទន្លេសាបឆ្ងាយសន្ធឹមជាប់កន្ទុយភ្នែក ឃើញតែមេឃជាប់នឹងទឹកដូចមើលសមុទ្រ; មើលទៅទិសជើង ..ឃើញប្រាសាទនគរវត្ត, ឆ្ងាយទៅទៀតឃើញភ្នំគូលែន, ភ្នំបូក, ភ្នំដងរែក ជាប់គ្នាវែង; មើលទៅទិសកើត, ទិសលិច, ឃើញវាលស្រែជាប់ដោយស៊ុមទ្រុមគួរឲ្យសប្បាយសម្រាប់លំ-ហែចិត្ត, ពុំនោះ ងើបមើលទៅលើអាកាស, ឃើញពពករសាត់លឿនលយផុតៗលើក្បាល ហាក់ដូចជាវិមានអណ្តែតទៅលើនភាល័យ, មុខគួរសប្បាយអ្វីម្ល៉េះទេ! ។



រូបទ្វារបាល គេទើបនឹងជីកបាននៅប្រាសាទភ្នំក្រោម
ការរចនាបែបប្រាសាទបាខែង រវាង ព. ស. ១៤៤៣

( តាមរូបថត ស. ប. ប. )

## ព្រះឥន្ទ្រកោសីយ៍

កាលយើងត្រឡប់មកដល់សៀមរាបហើយ, គួរទៅមើលប្រាសាទតូចមួយនៅវត្តព្រះឥន្ទ្រកោសីយ៍ ដែលជាវត្តមួយស្ថិតនៅខាងលិចផ្សារ, ត្រូវឡើងរថយន្តតាមផ្លូវខាងលិចដងស្ទឹង, ហួសស្ពានថ្ម តាមមាត់ស្ទឹង ប្រកបដោយព្រឹក្សាមានសន្ធឹកខៀវខ្ចី, ត្រជាក់ត្រឈឹងត្រឈៃ ផុតទៅដល់មន្ទីរថែរក្សានគរ មានស្ពានឈើមួយរថយន្តទៅបាន ឆ្លងស្ពានទៅដល់វត្តព្រះឥន្ទ្រកោសីយ៍ ។ នៅខាងកើតវត្ត មានប្រាសាទ ២ ខ្នង, ស៊ុមទ្វារមានក្បាច់របនាដ៏ពិចិត្រ, មានសិលាចារឹកនៅមាត់ទ្វារ, ខាងក្នុងប្រាសាទមានព្រះពុទ្ធរូបជាច្រើនមានសណ្ឋានថ្លៃកាពត្តា ខ្លះស្ទើរតែយើងមិនដែលបានឃើញ ។ នៅខាងកើតផ្ទាល់ មានស្ថានវិហារចាស់ឃើញតែកំពូលខ្ពស់ មានសន្ធឹកសីមា ។

## មេបុណ្យខាងលិច (បារាយ)

ពេលល្ងាច, ក្រោយដែលបានដើរមើលប្រាសាទបុកណរូបហើយ គួរទៅមុជទឹកជម្រះកាយ ជាទីកំសាន្ត នៅស្រះបារាយខាងលិច កុំភ្លេច ត្រូវយកសំពត់ងូតទឹងប្រដាប់សំរាប់ងូតគ្រប់យ៉ាងទៅផង, មានកន្លែងសម្រាប់ផ្លាស់សំពត់ ទីកន្លែងសម្រាប់សប្បាយប្រចាំស្រាប់ មានទូកសម្រាប់អុំលេងកំសាន្តមួយ ៗ ឯស្រះបារាយនេះ, ជាកន្លែងមុជទឹកជាទីរីករាយសប្បាយណាស់ ពេលរថយន្តចូលដល់ ឃើញទឹកថ្លាហ្វង់ ទាញភ្នែកឲ្យបាញ់ត្រង់ទៅរក នៅមាត់ស្រះ មានព្រឹក្សាទៀវស្រងាត់ ជុំដោយសំឡេងសត្វយាសយំពីរកេះរងំ នាំឲ្យអ្នកមើលសប្បាយចិត្តចង់តែងកាព្យ ឬឲ្យចិត្តចង់ស្រែកច្រៀងថា អឺយនៃ... ៗ

ស្រះបារាយនេះ មានប្រាសាទមួយស្ថិតនៅចំកណ្ដាលស្រះ ឈ្មោះប្រាសាទ "មេបុណ្យ" ដូចប្រាសាទមេបុណ្យតាមផ្លូវវង់ធំដែរ តែប្រាសាទមេបុណ្យតាមផ្លូវវង់ធំគេឲ្យឈ្មោះ "មេបុណ្យខាងកើត", ប្រាសាទនេះ គេឲ្យឈ្មោះ "មេបុណ្យខាងលិច" ៗ តាមដែលពិនិត្យមើល ឃើញមានតួប្រាសាទធ្វើពីថ្ម ស្ថិតនៅលើកោះតូចកណ្ដាលស្រះ មានកំពែងព័ទ្ធជុំវិញ មានបង្កាន់ដៃនាគលយចេញវែងទៅខាងកើត, សព្វថ្ងៃនេះ ព្រៃព្រឹក្សាដុះទទ្រានវិនាសអន្តរាយអស់ហើយ, គេឃើញ

មានតែទឹកថ្លាឈ្វេងល្អបពាសពេញ, ត្រង់កន្លែងដែលជ្រៅ មានជម្រៅពី៤ម៉ែត្រទៅដល់៥ម៉ែត្រ; ស្រះនេះកង់៤ជ្រុងទ្រវែង បណ្ដោយ៨គីឡូម៉ែត្រ ទទឹង២គីឡូម៉ែត្រ ។ តាមសេចក្ដីយល់អ្នកខ្លះថា ស្រះបារាយនេះជាស្ពានកជនារី (ទ័ពដើងទឹក) អ្នកខ្លះថា ជាទីប្រជុំចុះនៃផ្លូវទឹកដែលគេសំកប់ប្រើប្រាស់នៅក្នុងក្រុង ក្នុងកាលនោះ ។ អ្នកទៅមើលស្រះបារាយនេះ ត្រូវចេញទៅតាមផ្លូវពីក្រុងសៀមរាបទៅបាត់ដំបង ដល់គីឡូម៉ែត្រលេខ ១៣ ត្រូវបត់ទៅតាមខាងស្ដាំដៃ ចូលទៅប្រហែល ៣០០ ម៉ែត្រ ដល់ស្រះបារាយនោះ, គេទៅដោយយានគ្រប់បែបបានយ៉ាងស្រួល ។ តាមមាត់ស្រះខាងត្បូង ចម្ងាយពីសាលាឈប់សម្រាកប្រហែល ១០០០ម៉ែត្រ, មានប្រាសាទតូចណាមួយបាក់បែកអស់, គេលើកក្ដីស្រះបារាយនេះត្របត្បាក់, គេទើបនឹងគេឃើញស្ទូវនេះឯង ។

## ប្រាសាទលលៃ · ប្រាសាទព្រះគោ
## និង ប្រាសាទបាគង

ប្រាសាទទាំង៣ នេះ ស្ថិតនៅជាជួររៀងគ្នាពីខាងជើងទៅខាងត្បូង ចម្ងាយពីគ្នាក្នុងមួយៗប្រហែល ១.៦០០ ម៉ែត្រ; អ្នកដំណើរដែលបាន ទៅដល់គីឡូម៉ែត្រលេខ ៣០១ តាមផ្លូវពីកំពង់ធំទៅសៀមរាប, បែរមើល ទៅខាងជើង, នៅកណ្ដាលវាលស្រែ នឹងឃើញកំពូលប្រាសាទលលៃ ខ្ពស់ នៅខាងក្រោយវិហារវត្ត ដែលគេកសាងថ្មីនេះ ។

### ប្រាសាទលលៃ

ប្រាសាទលលៃនេះ គេកសាងជាប្រាង្គបួន(១) រៀងជាពីរជួរខាង មុខខាងក្រោយ ស្ថិតនៅលើទួលខ្ពស់ កណ្ដាលបឹងព្រះថ្កូវ មានកំ-ពែង៤ ជាន់, ជាន់ទី២ ធ្វើពីឥដ្ឋបូកបាយអឆ្លាក់ជាក្បាច់រស់រវើក មាន សណ្ឋានដូចប្រាសាទប្រែរូប មានសិលាចារឹកដូចប្រាសាទព្រះគោ បែរ មុខទៅខាងកើត ហើយមានទ្វារបញ្ឆោតទាំង៣ ទិស ផ្ដែរលើទ្វារមាន ក្បាច់របនាយ៉ាងល្អចំឡែកជាងប្រាសាទឯទៀត គួរឲ្យនឹករស្ងើចដល់វិស្វករ ដែលនឹកប្រតិស្ឋានធ្វើឡើង, នៅអមមាត់ទ្វារ ក្នុងប្រអប់ មានចម្លាក់ជា

(១) កាលពីដើម ប្រហែលជាមានប្រាសាទ៦ ស្ថិតនៅជាពីរជួរ តែលោកកសាងវត្តក្រោយ លោករំលាយប្រាសាទ ២ ចោលទៅនៅសល់តែ ៤ ។

រូបប្រាសាទ មានទ្វារបាលដៃកាន់សែបត្រីសូល៍, នៅកណ្ដាលចន្លោះប្រាសាទមានទងទឹកធ្វើពីថ្ម បែកពីប្រាសាទឯទៀត, ទងនេះវែងជាជើងក្អែកសម្រាប់បង្ហូរទឹកទៅកាន់ស្រះព្រះឥស្សរទាំង៤ទិស ដែលនៅជុំវិញប្រាសាទ, ឯទីស្រះដែលនៅជុំវិញប្រាសាទ រលាយបាត់អស់ហើយក្លាយទៅជាវាលស្រែមើលមិនឃើញ ។

តាមសិលាចារឹកថា "ប្រាសាទនេះ ព្រះបាទយសោវរ្ម័នទី ១ កសាងក្នុងរវាងសតវត្សរ៍ទី១៥នៃពុទ្ធសករាជ (ព.ស. ១៤៣៦) ដើម្បីឧទ្ទិសថ្វាយដល់ព្រះឥស្សរ ក្នុងសាសនាព្រាហ្មណ៍" ។



សសរក្រឡឹងមូល គោបុរៈខាងកើតនៃប្រាសាទព្រះគោ
ការរចនាសម័យប្រាសាទព្រះគោ រវាង ព.ស. ១៤២៤

( តាមរូបថត ព.ស.ប. )



រូបទ្វារបាលី នៅច្រកចំទ្វារបញ្ឆោត ប្រាសាទព្រះគោ

( តាមរូបថត ព.ស.ប. )

# ប្រាសាទព្រះគោ

កាលបានមើលប្រាសាទលលៃហើយ ត្រូវត្រឡប់ថយក្រោយ ហើយធ្ងន់កាត់ថ្នល់ធំទៅខាងត្បូង តាមផ្លូវតូច ដើម្បីទៅមើលប្រាសាទព្រះគោនឹងបាគង ។ ប្រាសាទនេះ គេហៅថា ប្រាសាទព្រះគោ ស្ថិតនៅពាក់កណ្ដាលផ្លូវកណ្ដាលព្រៃ ជាបន្ទោះប្រាសាទលលៃនឹងបាគង ។ អ្នកដំណើរត្រូវឈប់ហើយចុះទៅមើល ឬបង្ហួសទៅមើលប្រាសាទបាគងឲ្យហើយសិន សឹមត្រឡប់មកមើលវិញក៏បាន ។ ប្រាសាទព្រះគោមានកំពែង ៤ ជាន់ធ្វើពីថ្មបាយក្រៀម, កំពែងខាងក្រៅបណ្ដោយ ៨០០ ម៉ែត្រ ទទឹង ៤៥០ ម៉ែត្រ មានស្រះពីរនៅខាងក្នុង, កំពែងទី ២ ជិតគ្នានឹងកំពែងទី ១ ប្រហែល ៩៥ ម៉ែត្របួនជ្រុង, មានធម្មន្ធំមួយខ្នងស្ថិតនៅខាងត្បូង, តទៅ ៦០ ម៉ែត្រ បានដល់ទៅកំពែងទី ៣ មានស្រះមួយនឹងប្រាសាទមានសសរមូលប្រកបក្បាច់, កំពែងទីបួន ៦០ ម៉ែត្រ ៤ ជ្រុងស្មើ, នៅក្នុងកំពែងនេះ, មានប្រាសាទ ៦ ខ្នង សង់រៀងគ្នាជាពីរជួរនៅលើទួលជាមួយគ្នា បែរមុខទៅខាងកើត ធ្វើពីឥដ្ឋបូកបាយអឆ្លាក់ក្បាច់ ស៊ុមទ្វារធ្វើពីថ្ម ទ្វារបញ្ឆោត ៣ ទិស មានជណ្ដើរតូចៗឡើងទៅប្រាសាទ, អមទ្វារមានយក្ខិនីជាទ្វារបាល ដៃកាន់ត្រីសូល៌ នៅមុខប្រាសាទមានគោនន្ទិ ៣ ក្រាបគោរពបែរមុខទៅរកប្រាសាទ អាស្រ័យដោយហេតុនេះបាន

ជាឲ្យឈ្មោះថា ប្រាសាទព្រះគោ ។ សត្វថ្មចាយគដែលគេបូកនៅ ផ្ញាំងប្រាសាទ របេះធ្លាក់មកជាច្រើនកន្លែង ដែលមាននៅសល់ខ្លះ គេ អាចមើលឃើញក្បាច់ឆ្លាក់ល្អិតដ៏មានទីទៅគូរលំអដ៏លើស, ផ្តែលើទ្វារ ក្ដារផ្ដាក់ទីងថ្មក៏ល្អសំខាន់ណាស់ដែរ ។

មានទេវរូបមួយល្អចំណាប់ ជារូបមហាយាន គេរកឃើញហើយគេ ទុកនៅទីងប្រាសាទទីមួយខាងលិច, តាមពិនិត្យមើលរូបនេះ គេស្គាល់ថា មិនមែនធ្វើឡើងក្នុងកាលពីដើមប្រាសាទនេះទេ ប្រហែលជាព្រះបាទជ័យវរ្ម័ន យកមកដំកល់ទុកខាងក្រោយ ដែលបានលើកទ័ពមកច្បាំងវាយយកនគរ ធំ កាលពីពុទ្ធសករាជ១៧២០; ក្នុងសិលាចារឹកនិយាយថា: ប្រាសាទ៣ ខាងកើត គេធ្វើសម្ភាយព្រះឥសូរ ដែលមានគោតន្តិជាអាជាទេយ្យ, ប្រា-សាទ៣ខាងលិច គេធ្វើសម្ភាយព្រះអគ្គទេពី ព្រះឥសូរឈ្មោះខាង គៅរី ។ ប្រាសាទនេះ ព្រះបាទឥន្ទ្រវរ្ម័នទី១ កសាងក្នុងរវាងសតវត្សរ៍ ទី១៥ នៃពុទ្ធសករាជ (ព.ស.១៤២៤) ។



រូបព្រះឥសូរ នាងឧមានិងនាងគង្គា មើលពីខាងក្រោយ
ទិសឦសានប្រាសាទបាគង
(តាមរូបថត ស.ច.ប.)



រូបព្រះឥសូរ នាងឧមានឹងនាងគង្គា មានដោះបបើល

មើលពីមុខ ទិសឦសាន ប្រាសាទបាគង,

ការរចនាសម័យប្រាសាទព្រះគោ រវាង ព. ស. ១.៤២៤

(តាមរូបថត ស.ប.ប.)

# ប្រាសាទបាគង

ប្រាសាទដែលស្ថិតនៅខាងត្បូងបំផុត ក្នុងចំណោមប្រាសាទរលួស គឺ ប្រាសាទបាគង; អ្នកមើល, កាលបើបានទៅដល់ទិសខាងជើងនៃកំពែងខាងក្រៅហើយ ត្រូវបត់ចូលទៅតាមខ្លោងទ្វារទិសខាងកើត មានផ្លូវសម្រាប់ថយន្តចូលទៅបានស្រួល, សព្វថ្ងៃប្រាសាទនេះ គេកំពុងរៀបចំឡើងជាថ្មី ជិតហើយៗ; កាលពីដើម, ប្រាសាទកណ្ដាលបាក់បែកស្ទើរតែអស់ សូម្បីដុំថ្មបែកបាក់ក៏វិនាសបាត់បង់ទៅជាច្រើន ៗ កំពែងខាងក្រៅធ្វើពីថ្មបាយក្រៀម មួយចំណែកកប់បាត់នៅក្នុងព្រៃ មួយចំណែកទៀតបាក់បែកខូចអស់ មានបណ្ដោយ ៨៥០ ម៉ែត្រ ទទឹង ៦៥០ ម៉ែត្រ: កំពែងទីពីរបណ្ដោយ ៣៥០ ម៉ែត្រ ទទឹង ៣១០ ម៉ែត្រ មានប្រាសាទតូចៗជាច្រើន ដែលបាក់បែកខូចអស់ ក្នុងកំពែងនេះ មាននៅសល់ខ្លះ គេអាចមើលឃើញក្បាច់ចនាយ៉ាងចេក; មានស្រះ (សិន្ធុ) ធំព័ទ្ធជុំវិញ ទទឹង ៦០ ម៉ែត្រ នៅសល់តែទិសខាងកើត: មានផ្លូវធំពីរ មួយខាងកើត មួយខាងលិច, ផ្លូវនេះកាលពីដើម សុទ្ធតែមានបង្កាន់ដៃនាគទីងគោលសីមា, ឥឡូវនេះ វិនាសបាត់អស់ហើយ ។ កំពែងទី ៣ បណ្ដោយ ១៥០ ម៉ែត្រ, ទទឹង ១១៥ ម៉ែត្រ មានប្រាសាទជាច្រើននៅព័ទ្ធជុំវិញប្រាសាទធំ; ប្រាសាទធំកណ្ដាលនេះ ស្រោបដោយដុំថ្មប្រផេះ

ត្រឹះក្រោមទំហំ ៦០ ម៉ែត្រ, មានប្រាសាទ ៨ នៅព័ទ្ធជុំវិញ សុទ្ធតែកសាងបែបរចនាខ្មែរសុទ្ធ ផ្ដែរលើខ្លោងទ្វារល្អប្លែកៗ សសរអមទ្វារបង្អួចត្រកបក្បូរក់ស់រវើក, ទ្វារបាលនឹងក្បាលយក្ខមុខសំបើម ឆ្លាក់ភ្ជាប់នៅក្រអប់ទ្វារបង្អួច ដូចប្រាសាទព្រះគោនិងលលៃដែរ, សំដែងឲ្យឃើញស្នាដៃឆ្លៀវឆ្លាត និងការប៉ិនប្រសប់នៃវិស្វករក្នុងសម័យនោះៗ នៅទិសខាងកើត មានប្រាសាទជាច្រើនទៀតពងទងខ្ចាត់ខ្ចង ធ្វើពីថ្មបាយក្រៀមឬថ្មប្រផែះ ប៉ុន្តែប្រាសាទអស់នេះ បាក់បែកស្ទើរទាំងអស់ហើយ, មានរូបព្រះឥសូរមួយនៅប្រាសាទទិសត្បូងសានកាងស័ក្តិសមល្អណាស់ ដៃបួន ពោះធំកញ្ចើងបន្តិច ឃើញមានដៃទបពីខាងក្រោយ, រូបនាងឧមានិងនាងគង្គាក៏ល្អណាស់ដែរ មើលហើយគួរឲ្យចាប់ចិត្ត, រូបនេះប្រហែលជាចម្លងតាមបែបស្រុកជ្វា ។ ខាងក្រៅនៃកំពែងខាងក្នុង មានវត្តមួយដែលគេនឹកស្មានមិនខុសថា ការកសាងវត្តនេះ នាំឲ្យខូចខាតបុរាណវត្ថុជាច្រើន ហើយបណ្ដាជនទាំងពួងមិនត្រូវយកតម្រាប់ឡើយ ។

ប្រាសាទកណ្ដាលជាតួកំពូលមាន ៥ ថ្នាក់ មានថ្នាក់តូចៗជាន់គ្នាជាលំដាប់ទៅដល់ថ្នាក់លើបំផុត មានជណ្ដើរឡើងទៅលើគ្រប់ទិសទាំង ៤, តែអ្នកឡើងមើល ត្រូវឡើងតាមជណ្ដើរទិសខាងកើត ព្រោះមានជណ្ដើរឡើងស្រួលៗ តាមផ្លូវដើរចូលទៅ តាំងពីគោបុរៈខាងកើត គេនឹងប្រទះឃើញរូបគោ, ទ្វារបាលកាន់គ្រឿងក្រអាញ តាំងប្រាសាទនៅអមសង



រូបយក្ស នៅគ្រឹះថ្នាក់ទី ៥ នៃប្រាសាទបាគង
ការរចនាបែបប្រាសាទព្រះគោ រវាង ព.ស. ១៤២៤

( តាមរូបថត ស. ប. ប. )

ខាង ក៏មានសណ្ឋានក្រអាញដូចគ្នាដែរ, តាមជណ្តើរឡើងទៅលើ, គ្រប់ទាំង៤ថ្នាក់ គេមើលឃើញទ្វារបាល តែបស្នាដៃមិនទាន់ចំណាន ខ្ពក់ភ្ជាប់នឹងជុំថ្មក្បែរជណ្តើរឡើង, នៅជ្រុងអនុទិស មានរូបដំរី, នៅជ្រុងទិសធំ មានសត្វសីហៈ, នៅថ្នាក់ទី ៣ មានប្រាសាទ ១២ ព័ទ្ធជុំវិញ, នៅភ្ជាប់នឹងជញ្ជាំងថ្នាក់នីមួយៗ សុទ្ធតែមានរូបចម្លាក់រឿងសាសនាព្រាហ្មណ៍ តែរូបនេះរលុបស្ទើរនឹងអស់ហើយ, នៅថ្នាក់លើបំផុត ជាទីប្រតិស្ឋាននៃប្រាសាទកណ្តាល, ប្រាសាទនេះ មានជណ្តើរឡើងទៅកាន់ទិសទាំង៤បាន មានស្តម្ភប្រដាប់ទ្វារបាលី នៅតាមទ្វារដូចប្រាសាទបាខែង ។ នៅហោជាងទ្វារខាងជើង មានរូបចម្លាក់កាលកពណ៌ថ្ងៃសរកើតជាខាត រុំព័ទ្ធព្រះលក្ស្មណ៍ មានស្មាតោមកោមជុំវិញជាបរិពារ ហោជាងខាងលិច វិស្ណុជិះលើមករ, ហោជាងខាងត្បូងរលុបមើលមិនច្បាស់, ហោជាងខាងកើត ព្រះវិស្ណុដៃបួន ។

ប្រាសាទបាគង់នេះ ជាគោលចារីកធំ ជាទីប្រតិស្ឋាននៃក្រុងបុរាណ មុននគរធំ ឈ្មោះ ហរិហរាលយៈ ដូចប្រាសាទបាខែង ឈ្មោះ យសោធរបុរៈ ជាគោលចារីកធំនៃក្រុងនគរធំ, ព្រះបាទឥន្ទ្រវរ្ម័នទី១ ទ្រង់កសាងនេះសតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ (ព.ស.១៤២២) ដើម្បីឧទ្ទិសថ្វាយដល់សាសនាព្រាហ្មណ៍, តមកខាងក្រោយ, ទើបមានលទ្ធិពុទ្ធសាសនាមហាយាន ចូលមកលាយឡំ ។



គោបុរៈកំពែងទី ៣ ប្រាសាទបន្ទាយស្រី

ការរចនាបែបប្រាសាទបន្ទាយស្រី រវាង ព. ស. ១.៥២៣

( តាមរូបថត ព. ស. ប. )

# ប្រាសាទបន្ទាយស្រី

ប្រាសាទបន្ទាយស្រីនេះ ស្ថិតនៅកណ្ដាលទ្វនៃព្រៃធំ ខាងទិសឦសាននគរធំចំងាយ ២១ គីឡូម៉ែត្រ ។ ការទៅមើលប្រាសាទបន្ទាយស្រី, គេទៅមើលបានស្រួលតែត្រូវរដូវ តាមរថយន្តតូចធំ តែក្នុងរដូវវស្សា ពេលដែលមានភ្លៀងធំ ធ្លាក់ជ្រាំច្រើនពេកទើបពិបាក បើភ្លៀងបង្អុរល្មមទេ បែរទៅជាស្រួលវិញ ព្រោះផ្លូវទៅកាន់ប្រាសាទនេះ មានដីខ្សាច់នាំឲ្យរឹងហួតឆាប់ស្រស់ដី ។ អ្នកដំណើរត្រូវចេញទៅតាមផ្លូវវង់ធំ ត្រង់គីឡូម៉ែត្រលេខ ១១ បត់តាមផ្លូវទៅភ្នំគូលែន, ប្រហែល ១.៨០០ ម៉ែត្រ ដល់ទៅភូមិខ្មែរមួយឈ្មោះ ភូមិប្រដាក ហើយបត់ទៅខាងឆ្វេងដៃ តាមផ្លូវតទៅខាងជើង កាត់ត្រង់ទៅលើស្ទឹងធំ គឺស្ទឹងសៀមរាប, ផ្លូវត្រង់នេះសុទ្ធដីខ្សាច់ អ្នកកាន់ចង្កូតរថយន្តត្រូវប្រយ័ត្ន ។ ត្រូវឈប់នៅមាត់ស្ទឹងខាងត្បូង បើមានរថយន្ត, ហើយឆ្លងស្ពានឈើទៅ ត្រូវដើរតាមផ្លូវជើង មានព្រៃព្រឹក្សានៅអមសងខាង បន្តិចទៅដល់ ប្រាសាទបន្ទាយស្រី ដែលស្ថិតនៅខាងស្ដាំស្ទឹង ។ ផ្លូវនេះ កាត់ចំពីខាងត្បូង គោបុរៈខាងកើតកំពែងខាងក្រៅ ។ អ្នកដើរមើល កាលបើបានចូលដល់ហើយ ត្រូវដើរទៅមើលទីលាននិងគោបុរៈខាងកើតសិន សឹមត្រឡប់ចូលទៅមើលប្រាសាទនៅខាងលិច ។

បណ្ដាប្រាសាទនៅនគរ ប្រាសាទបន្ទាយស្រីនេះ ជាប្រាសាទល្អវិសេសមួយ មានឈ្មោះល្បីជាងគេ មានក្បាច់ល្អិតឆ្មារស់រវើកជាងប្រាសាទទាំងអស់ ។ គេសាងបែរមុខទៅខាងបូព៌ទិស, តាមសិលាចារឹកប្រាសាទនេះ ឈ្មោះ ឥស្វរបុរៈ(១) ប្រែថា: "បុរីនៃព្រះឥសូរ" មិនមែនឈ្មោះ បន្ទាយស្រី ដូចយើងស្គាល់ទេ, ព្រះបាទជយវរ្ម័នទី៥ទ្រង់កសាងឧទ្ទិសថ្វាយដល់ព្រះឥសូរ ក្នុងខាងដើមសតវត្សរ៍ទី ១៦ នៃពុទ្ធសករាជ (ព.ស.១៥១០) ។ ប្រាសាទនេះ មានកំពែងថ្មបាយក្រៀមព័ទ្ធ ៣ ជាន់ មានទីលានក្រាលថ្មវែងទៅទិសខាងកើត, មានគោបុរៈប្រកបដោយក្បាច់ដ៏វិចិត្រ នៅចំពាក់កណ្ដាលទីលាន មានរោងទងខ្វាត់ខ្វែងជាក្រឡាចត្រង្គ ចេញទៅខាងជើង១ ចេញទៅខាងត្បូង៣ សុទ្ធសឹងប្រកបក្បាច់ចនាល្អពិចិត្រ; សព្វថ្ងៃនេះ បាក់ធ្លាក់អស់ហើយ សល់តែសសរប្រងព្រាងគួរឲ្យស្ដាយ; លុះមើលទីលានហើយ ត្រូវចូលទៅតាមគោបុរៈខាងកើតនៃកំពែងខាងក្រៅ មានទីលានកាត់ពីខាងកើតចូលទៅដល់ខាងលិច, មានសិទ្ធអមខាងជើងខាងត្បូង ។ ត្រង់នេះ អ្នកមើលនឹងឃើញប្រាសាទជាច្រើន ទំងគោបុរៈមានហោជាងប្រកបដោយក្បាច់ចនា មានសន្ទឹកក្បាលវិលវង់គួរ

(១) សៀវភៅលោក ហ. ម៉ារសាល់ (H. Marchal) ឈ្មោះ ត្រិភុវនមហេស្វរៈ ប្រែថា "ស្ថាននៃព្រះឥសូរ ជាធំក្នុងត្រៃភព" ។



គោបុរៈកំផែងទី ៣ ខាងលិច មុខខាងកើត ប្រាសាទបន្ទាយស្រី

(តាមរូបថត ព. ស. ប.)

ឲ្យស្រួច, តទៅទៀត នឹងឃើញប្រាសាទ ៣ ទន្ទឹមគ្នា ៗ ប្រាសាទនេះ កាលពីដើម, ដើមឈើដុះស្រោបបាក់បែកអស់ តែឥឡូវនេះ គេកាប់គ្ក ៃព្រុះរើរៀបចំជាថ្មីវិញបានល្អដូចដើម, គេសង់ជាតួប្រាង្គ ៣ ខ្នង(១) ថ្មស្មុទ ជាប់ទន្ទឹមគ្នា ពីខាងជើងទៅខាងត្បូង មានទ្វារចូលពីខាងកើត ៣ ទិស ជាទ្វារបញ្ឆោត, ប្រាសាទកណ្ដាល មានយ៉ីលយចេញមកខាងកើត, ខាងមុខមានធម្មទ្វីរមួយបេតូ នៅទិសឦសាន១ ទិសអគ្នេយ៍១, ធម្មទ្វីរ នេះបែរមុខទៅខាងលិច ៗ ប្រាសាទបន្ទាយស្រីនេះ ជាប្រាសាទមួយ ដែលមានក្បាច់ចនាយ៉ាងបញ្ចង់ចេតណាយ មានសន្ទឹកក្បូរល្អវិលវង់ល្អិត ផ្ការល្អស្រស់ស្រើក ដែលគួរឲ្យនឹកគិតដោយឥតមានសន្ទិះសង្ស័យថា ទេពតានិម្មិត ៗ សន្ទឹកក្បាច់មួយទងៗដែលវិលវង់មូលក្រឡង់ អាចទាញភ្នែកឲ្យគយគន់មៀងមើលម្ដងហើយម្ដងទៀត នឹងឲ្យឈរទ្រឹងគាំង ក្បូចខ្លួនដញ្ញក់មាត់ដោយសេចក្ដីស្ងើចថ្លៃ សំដែងឲ្យឃើញថា សម័យកសាងប្រាសាទបន្ទាយស្រីនេះ ជាសម័យនៃការចេះដឹងស្ទាត់ជំនាញយ៉ាងចាស់ក្លារបស់គណៈជាងក្នុងសម័យនោះ ៗ

---

(១) តាមសណ្ដាប់សាសនាព្រាហ្មណ៍ គេមានត្រៃទេវរូបជាទីគោរព ហេតុនេះ បានជាគេកសាងប្រាសាទ ៣ ខ្នងសម្រាប់ថ្វាយ គឺ ព្រះឥសូរកណ្ដាល, ព្រះនារាយណ៍ខាងជើង, ព្រះព្រហ្មខាងត្បូង ៗ



រូបទេពតា ឆ្លាក់ជាប់នៅជញ្ជាំងប្រាសាទខាងជើង ទិសនិរតី
ប្រាសាទបន្ទាយស្រី

(តាមរូបថត ស. ប. ប.)

## រូបចម្លាក់នៅយោជាង

១. ធម្មន្ទីរខាងជើង ហោជាងខាងកើត, និយាយពីរឿងក្រិស្នៈទីង ពលរាមៈជាប្អូន ប្រហារព្រៃព្រឹក្សកណ្ដាលហ្វូងសត្វ, ខាងលើព្រះឥន្ទ្រ គង់លើដំរីឰរាវណ៍ក្បាល ៣ ទ្រង់សំដែងឫទ្ធិឲ្យកើតជាភ្លៀងធំ ជាទី ស្រោចស្រប់ព្រឹក្សាលតាជាតិទីងម្រឹគបក្សី ដែលត្រាច់ទីងហើរធ្លៀល ធ្លាក់ ក្នុងរដូវអំណត់ទឹកភ្លៀង ។

២ ធម្មន្ទីរខាងជើង ហោជាងខាងលិច, និយាយពីរឿងក្រិស្នៈ សម្លាប់ស្ដេចកាម្សៈ នៅក្នុងប្រាសាទច្រើនជាន់ ឃើញមានស្រីស្នំក្រម-ការពជបរិពារជាច្រើន, ខាងក្រោម ឃើញមនុស្សស្លាប់ដោយស្នាដៃ ក្រិស្នៈទីងពលរាមៈជាប្អូន, នៅអមសងខាងឃើញមេទ័ពជិះលើរថ ។

៣. ធម្មន្ទីរខាងត្បូង ហោជាងខាងកើត, និយាយពីរឿងកយកេរ្ដ គ្រង់ក្រុងរាពណ៍ទសមុខ ចាប់ភ្នំកៃលាស ជាព្រះរាជដំណាក់ព្រះឥសូរ អង្រួនដោយសេចក្ដីឈ្នានីស ឃើញព្រះឥសូរចាប់ពនាងឧមា ដែលភិត ភ័យឲ្យគង់លើភ្លៅ ឃើញពួកពជបរិពារភ័យស្ទុះស្ទារត់ខ្វាត់ខ្វាយ ។

៤. ធម្មន្ទីរខាងត្បូង ហោជាងខាងលិច, និយាយពីរឿងទេពតា កាមៈបាញ់ព្រះឥសូរដោយសរផ្កា ព្រះឥសូរគង់លើកំពូលភ្នំ នាងសក្តិគង់ ជិតខាង, ស្ដេចទ្រង់សម្លឹងមើលទេពតាកាមៈ ដោយភ្នែកកណ្ដាលថ្ងាស, ទេពតាកាមៈនេះខ្ទេចជាផង់ធូលី ។



ធម្មមន្ទីរ ប្រាសាទបន្ទាយស្រី

*(តាមរូបថត ស ប.ប.)*

## ប្រាសាទបន្ទាយសំរែ

ដើម្បីទៅមើលប្រាសាទនេះ គេត្រូវចេញទៅតាមផ្លូវធំ ដល់គីឡូ-ម៉ែត្រលេខ ១១ បត់តាមផ្លូវទៅភ្នំគូលែន កាត់ភូមិប្រទាក ត្រង់ទៅខាងកើត (កុំបត់ទៅខាងជើងតាមផ្លូវទៅភ្នំគូលែនទៀត) ទៅហួសពីទំនប់ស្រះបា-រាយខាងកើត ចំនួន ៣៧៥ ម៉ែត្រ បត់ទៅខាងត្បូងខាងស្តាំដៃ តែបន្តិច ទើបដល់គោបុរៈ ខាងជើងនៃកំពែងខាងក្រៅ ត្រូវឈប់រថយន្ត ហើយ ដើរសៀរតាមកំពែងទៅខាងកើត ផុតកំពែងបត់បន្តិចទៅខាងត្បូង ទើបដល់ទៅគោបុរៈធំខាងកើត ។

ប្រាសាទបន្ទាយសំរែ ទ្រង់ទ្រាយធំមាំ កសាងពីថ្មប្រៃផះ កំពែងក្រៅធ្វើពីថ្មបាយក្រៀម; ខាងមុខ មានទីលានប្រកបដោយបង្កាន់ដៃនាគ ក្បាលបើកពពារស្ញើនចេញទៅកាន់ទិសផ្សេងៗ មានសីហៈធំៗជាទ្វារបាលនៅចាំគ្រប់ទាំងអស់ ។ អ្នកផងទាំងពួង គួរទៅមើលហួតដល់ គោ-បុរៈខាងកើតបំផុត កាលណាត្រឡប់មកវិញ មើលមកប្រាសាទទើបឃើញ ទ្រង់ទ្រាយសំបើមដូចភ្នំ ។

គោបុរៈខាងកើតធំមាំអស្ចារ្យណាស់ តែក្បាច់ចម្លាក់ពុកវិនាសអន្ត-រាយទៅច្រើន, កាលណាគេចូលហួសទៅក្នុងកំពែង គេទើបឃើញប្រា-សាទធំនៅកណ្តាលខ្ពស់ត្រដែត មានយ៉ាលយចេញមកខាងមុខ មានធម្ម-មន្ទីរពីរបែរមុខទៅខាងលិចអមសងខាង, ទាទរោងទងព័ទ្ធជុំវិញប្រាសាទៗ

រូបចម្លាក់ជាគ្រឿងអលង្ការល្អវិសេស ខាងក្នុងប្រាសាទក៏សមរម្យណាស់ ក្បាច់ផ្តែរលើទ្វារធំទ្វារ· របនាទ្វារធំហោជាងច្រើននិយាយពីរឿងក៏ព្រះវិស្ណុ, រឿងក្រឹស្ណៈស្ថិតនៅក្នុងបឋមវ័យ, រឿងក្រឹស្ណៈទ្រភ្នំគោវធនៈ, រឿងទេពតានិងអសុរកូរសមុទ្រទឹកដោះជាដើម ។

ប្រាសាទបន្ទាយសំរែនេះ មិនទាន់មានសេចក្តីឃើញប្រាកដថា គេកសាងជំនាន់ប្រាសាទណា ឬស្តេចអង្គណាកសាង, តាមសង្កេតមើលទ្រង់ទ្រាយនិងការរចនាគួរនឹងកប់បញ្ចូលក្នុងពួកប្រាសាទនគរវត្ត ក្នុងរវាងសតវត្សរ៍ទី ១៧ នៃពុទ្ធសករាជ ។



សីហៈ ធំនៅទីលានខាងកើត ប្រាសាទបន្ទាយស្រី

(តាមរូបថត ព.ស.ប.)



ផ្តែរលើខ្លោងទ្វារខាងក្នុងនៃប្រាសាទកណ្តាល ប្រាសាទបន្ទាយសំរែ

(តាមរូបថត ស.ប.ប.)

## សៀមរាប

បណ្ដាក្រុងទាំងឡាយ ដែលជាទីរួមខេត្ត ក្នុងកម្ពុជរដ្ឋ បើនិយាយតាមទីកន្លែងជារមណីយដ្ឋាន ក៏មិនមានក្រុងខេត្តណាយកឈ្នះក្រុងសៀមរាបបាន ពិតជាក្រុងសៀមរាបតូចជាងគេ ៗ តាមដងស្ទឹង, មានផ្ទះនៅត្រើយទាំងសងខាង ប្រកបដោយព្រៃព្រឹក្សាជាដំណាំ មានស្លឹកខៀវខ្ចី ត្រជាក់ត្រឈឹងត្រឈៃគួរជាទីកំសាន្ត, ទឹកស្ទឹងថ្លាថ្លង់ ពេញព្រៀបមាត់ច្រាំង ហូររំៗ, មានរហាត់ទឹកវិលរគោងឮសូរលើតអែប... តាំងពីខាងលើផ្សារហូតទៅខាងក្រោមផ្សារគួរឲ្យគយគន់ ៗ

នៅតាមដងស្ទឹងមានវត្តជាច្រើន ត្រើយខាងកើត តាំងពីលើស្ទឹងមកខាងក្រោម មានវត្តព្រះឥន្ទ្រកោសិយ៍, វត្តព្រះឥន្ទ្រកោសា, វត្តពោធិលង្កា, វត្តកជបូពិ, វត្តដំណាក់, វត្តស្វាយ, វត្តពោធិ៍ក្រៅ, វត្តគង់មុជ ៗ ត្រើយខាងលិច, ពីខាងលើទៅខាងក្រោម វត្តយួនឈ្មោះវត្តលង្កា, វត្តចិន, វត្តព្រះព្រហ្មរ័ត្ន, វត្តអញ្ញា; បណ្ដាវត្តទាំងអស់នេះ វត្តដែលគួរចូលមើលនោះ គឺវត្តព្រះព្រហ្មរ័ត្ន និងវត្តដំណាក់ ។ វត្តព្រះព្រហ្មរ័ត្នជាវត្តបុរាណ គេប្រកបក្បាច់នគរជាន់ថ្មីល្អបំណាន, ក្នុងវិហារ មានពុទ្ធរូបបរិនិព្វានធំមួយអង្គ; នៅវត្តដំណាក់ មានសាលាបាលីរង, មានធម្មមន្ទីរ, មានចេតិយ

ខ្ពស់, មានយុវសាលា, ក្នុងវិហារមានពិពិធភណ្ឌ មានរបស់ប្លែកៗគួរចូលមើល គួរឲ្យសរសើរស្នាដៃលោកគ្រូមេគណ តាម ទិឋ ជាចៅអធិការ លោកខំប្រឹងប្រែងធ្វើឲ្យកើតឡើង ។

នៅស្ពានថ្ម មានទីកន្លែងសម្រាប់ចិញ្ចឹមសត្វព្រៃប្លែកៗទុកមើល ដូចខ្លាធំជាដើម; នៅត្រង់កន្លែងនេះ មានមន្ទីរលក់របស់ផ្សេងៗ ដូចរូបថត, ក្បាច់រចនាផ្សេងៗ លោក-អ្នកត្រូវការគួរអញ្ជើញចូលមើលកុំខាន ។


ផែនទីប្រាសាទបុរាណនៅអង្គរ
អង្គរធំ
អង្គរវត្ត
បារាយ
សៀមរាប

# បញ្ជីព្រះនាមស្តេច ទេវតា ឈ្មោះប្រាសាទនឹងទីស្ថាន នឹងពាក្យផ្សេងៗ

## ព្រះនាមស្តេច


អង្គិរៈ មេទ័ពពួកបាណ្ឌវៈ, ..... ១២
កាម្យៈ ព្រះរាជាក្នុងរឿងព្រេង, .... ២០៧
កៅរវៈ កងទ័ពនៃដែនកុរុ, ..... ១៦
ចិត្រគុប្តៈ ឈ្មោះស្មៀនព្រះយមរាជ, .. ១៣
ជយរាជទេវី អគ្គមហេសីព្រះបាទជយវម៌្ម ទី ៧, ......... ១៦០
បរមវិស្ណុលោក ព្រះនាមក្នុងព្រះកោដ្ឋនៃ ព្រះបាទសូរ្យវម៌្មទី ២, ៣, ១៩
បាណ្ឌវៈ កងទ័ពពួកបាណ្ឌុ, ...... ១២
ពលរាមៈ ប្អូនក្រឹស្ណៈ, ........ ២០៧
ពាណៈ ឈ្មោះអសុរជាសត្រូវនៃទេវតា, ២០
ពាលីន៍ <ពាលិន៑, ស្តេចស្វា ក្នុងរឿង រាមកេរ្តិ៍, .......... ១៥,៧៧
ភីស្មៈ មេទ័ពពួកកៅរវៈ, ..... ១២,៧៥
ក្បេសៈ បងរាពណ៍, ដែលលួចនាង សិតា ក្នុងរឿងរាមកេរ្តិ៍, ... ២៥
រាពណ៍ យក្សជាគូសត្រូវនឹងព្រះរាម. .. ១៥
វិភីសនៈ ឬ ពិភេក្ស ប្អូនរាពណ៍ ជាហោរ ព្រះរាម, ......... ២៥
ត្រីវិធិនៈ ឈ្មោះរាជ៉ុនធំ ក្នុងរាជ្យព្រះបាទ សូរ្យវម៌្មទី ២, ....... ១៦
សិតា ទេពីព្រះរាមក្នុងរឿងរាមកេរ្តិ៍, ១៦,២២
សុគ្រីព ប្អូនពាលីន៍ ស្តេចស្វាសេនា ព្រះរាម, ...... ១៥,៧៧


## ព្រះនាមទេវតាសាសនាព្រាហ្មណ៍និងពុទ្ធសាសនា


ឥន្ទ្រៈ ព្រះឥន្ទ្រ ទេវតាសាសនាព្រាហ្មណ៍, ២៩
ឥស្វរៈ ព្រះឥស្វរទេវតាសាសនាព្រាហ្មណ៍, ១៩
ឧមា សក្តិព្រះឥស្វរ, ........ ១៥
កាមៈ ទេវតាខាងកាមារម្មណ៍, ១៥, ៥៨, ២០៧
កុវេរៈ ទេវតាទ្រព្យសម្បត្តិ, ស្តេចនៃពួក យក្ស, ............ ២១, ២២
ក្រឹស្ណៈ អវតារព្រះវិស្ណុ ក្នុងរឿងមហា- ភារតៈ, .......... ១៥,២០
គង្គា សក្តិព្រះឥស្វរ; ឈ្មោះទន្លេនៅ ប្រទេសឥណ្ឌា, ... ៣៣, ១៩២
គណេសៈ ឱរសព្រះឥស្វរ និងនាង បារ្វតី, ............. ១៩

## ព្រះនាមទេពតាសាសនាព្រាហ្មណ៍និងពុទ្ធសាសនា

នារាយណ៍ ឈ្មោះមួយនៃព្រះវិស្ណុ,.. ១៣៥
បរិតី សក្តិព្រះឥសូរ,....... ២០
ព្រហ្មៈ ព្រះព្រហ្ម ទេពតាជាអ្នកបង្កើតលោក,........... ២២
មហេន្ទ្រៈ នាមមួយនៃព្រះឥសូរ,... ៧៥
យមៈ ព្រះយមរាជ ស្ដេចស្ថាននរក, ២១,២២
លក្ស្មី សក្តិព្រះវិស្ណុ,...... ១៩
លោកេន្ទ្រៈ ពោធិសត្វមហាយាន,. ៣៧
វរុណៈ ទេពតាខាងទឹកភ្លៀង,.... ២២
គិរិៈ នាមព្រះឥសូរ,....... ២២
សិរិមហាមាយា អគ្គទេពីព្រះសិទ្ធត្ថកុមារ,.......... ១០៦
សូរ្យៈ ព្រះអាទិត្យ ទេពតាសាសនាព្រាហ្មណ៍,.......... ២៦
ស្កន្ទៈ (កុមារ) ឱរសព្រះឥសូរ ទេពតាចម្បាំង,......... ២១,២២
ហេមស្រីរង្គេន្ទ្រៈ នាមព្រះឥសូរ,ជាទេពតាធំមានស្នែងមាស,...... ៧៩

## ឈ្មោះប្រាសាទនិងទីស្ថាន

អយុធ្យា ឬ អយោធ្យា រាជធានីព្រះរាមក្នុងរឿងរាមកេរ្តិ៍,....... ២៥
អស្តង្គតប្រទេស ឬ ប្រទេសអស្តង្គត ប្រទេសខាងទិសបស្ចិម,ទ្វីបឧរុប ... ៣,១៣២
ឥន្ទ្រាទ្រិ ភ្នំធំសម្រាប់បូជាទេពតាធំ, ឈ្មោះភ្នំបាខែង,....... ៣៣
ឥន្ទ្របុរៈ បុរីនៃព្រះឥសូរ, ឈ្មោះប្រាសាទបន្ទាយស្រី,......... ១៩៨
កៃលាសៈ ស្ថានព្រះឥសូរ,..... ១៥
គោវរ្ធនៈ ឈ្មោះភ្នំដែលព្រះក្រឹស្ណៈទ្រការពារហ្វូងសត្វ,....... ១៥,២១០
បាកាន ឈ្មោះប្រាសាទនគរវត្តថ្នាក់ទី ៣,........ ១១,២៩
លុម្ពិនី ឈ្មោះសួនដែលព្រះសក្យមុនីគោតមទ្រង់ប្រសូត,.... ១០៦
មន្ទរ ឈ្មោះភ្នំដែលពួកទេពតានិងអសុរយកធ្វើជាស្នូលទាញកូរសមុទ្រ, ៦៨
យសោធរគិរី ភ្នំទ្រទ្រង់នូវយស,ឈ្មោះប្រាសាទបាយ័ន,........ ៤២
យសោធរេន្ទ្រៈ ព្រះឥសូរទ្រទ្រង់នូវយស, ឈ្មោះភ្នំបាខែង,....... ៣៣,១៩៥
យសោធរេន្ទ្របុរៈ បុរីនៃព្រះឥសូរ ទ្រទ្រង់នូវយស, ឈ្មោះរាជធានីនគរធំ, . ៣៨

## ឈ្មោះប្រាសាទនិងទីស្ថាន


គិរិបទៈ ឈ្មោះភ្នំជាទីក្បែរមហាក្សត្រ, ភ្នំគូលែន ឬ?, . . . . . . . . . . . . ១៦

សុមេរុ ឈ្មោះភ្នំក្នុងរឿងព្រេង, ១១, ៣៣, ១៥៦

ហរិហរាលយៈ ស្ថានព្រះហរិហរៈ,

ឈ្មោះប្រាសាទបាគង, . . . . . ១៩៥

ហិមាទ្រិ ភ្នំមាស, ឈ្មោះប្រាសាទបាពួន, ៧៩

ហិមាលយៈ ឈ្មោះភ្នំធំក្នុងលោក នៅ ប្រទេសឥណ្ឌៀ, . . . . . . . . ៣២


## ពាក្យសំស្ក្រឹតនិងពាក្យបាលី


អម្ឫតៈ ទឹកអម្រឹត, . . . . . . . ១៨

អស្តង្គត ដែលលិចទៅកាន់ទិស បស្ចិម, . . . . . . . . . . . ៣, ៣០

គោបុរៈ ខ្លោងទ្វារ, . . ៧, ៣៧, ៧៣, ១៥៩

ពាណ្ណារៈ ល្ខោនក្នុងស្ថានសួគ៌, . . . . . ៥៨

ប្រវត្តិកាស្ត្រ វិជ្ជាពង្សាវតារ, . . . . . . ៤

ភគវទ្គីតៈ ឈ្មោះគម្ពីរដែលនិយាយពីរឿង មហាភារតៈ, . . . . . . . . . . ១២

មហាភារតៈ រឿងចម្បាំងធំរវាងពួកកៅ-រវៈនឹងពួកបាណ្ឌវៈ, . . . . . . . . ១២

វាសុកិ នាគដែលទេពតានិងអសុរយកធ្វើជា ព្រ័ត្រទាញក្វាលសមុទ្រ, . . ១៨, ៦៩, ៥៨

វិទ្យាសាស្ត្រ វិជ្ជាផ្សេងៗ, . . . . . . . . ៣

វិស្សុកម្ម ឈ្មោះទេវបុត្តជាមេជាង នៅ ស្ថានសួគ៌, . . . . . . . . . . . . ៣

វិស្សុករ មេជាង, . . . . . . . . . . ១៨

សត្តបរិភ ភ្នំស្ថិតនៅព័ទ្ធភ្នំព្រះសុមេរុ ៧ ជុំ, . . . . . . . . . ៣៣, ១៥៦

សត្តសិន្ធុរ សមុទ្រស្ថិតនៅព័ទ្ធភ្នំព្រះសុមេរុ ៧ ជុំ, . . . . . . . . . . ៣៣, ១៥៦

ឥសស្ថាន ស្ថានព្រះឥសូរ, . . . . ១៥៥

ហរិវង្ស ឈ្មោះគម្ពីរដែលនិយាយពីរឿង ក្រឹស្ណៈ, . . . . . . . . . . . ២០


## ពាក្យបរទេស


ប. ការប៉ូ P.Carpeau, . . . . . . ៦៩

គ. សឺដែស G. Cœdès, . . ៤, ២០, ១៦២

ជ. កុម្មៃយ៍ J. Commaille, . . . . ៦៩

ល. ហ្វីណូត៍ L.Finot, . . . ៧៦, ១៥៥

វ. គោលូបេវ V. Goloubew, . ១៥៥

ស. ការប៉ឺឡែស S. Karpelès, . . . . ១៦១

ល្វូពាន, . . . . . . . . . . . . . ៤

ហ. ម៉ាសាល់ H. Marchal, . . ៤, ៨៨

ហ. ប៉ាម៉ង់ទៀ H. Parmentier, ៨៧, ៨៨

បៀវពាគ់, . . . . . ៤, ៣៩, ៧៩, ១២០

# បញ្ជីរឿង


| | | |
|---|---|---|
| | | ទំព័រ |
| វគ្គទី ៣ | ប្រាសាទនគរវត្ត | ៣ |
| | ថ្នាក់ទី ១ រឿងរាជ្យត្រ័យ | ១១ |
| | ថ្នាក់ទី២ ព្រះពាន់ | ២៨ |
| | ថ្នាក់ទី៣ បាកាន | ២៩ |
| | ពព្រហ្មកិល | ៣១ |
| | បាខែង | ៣២ |
| | បក្សីចាំក្រុង | ៣៤ |
| វគ្គទី ៤ | ភពជាតិនគរធំ, គោបុរៈ | ៣៧ |
| | ប្រាសាទបាយ័ន | ៤១ |
| | ថ្នាក់ទី ១ រឿងរាជ្យត្រ័យ | ៤៦ |
| | ថ្នាក់ទី ២ រឿងរាជ្យត្រ័យ | ៥៤ |
| | ថ្នាក់ទី ៣ ប្រាសាទកណ្ដាល | ៦៥ |
| | ប្រាសាទបាពួន | ៧៣ |
| | គោបុរៈខាងត្បូង រឿងរាជ្យត្រ័យ | ៧៤ |
| | គោបុរៈខាងកើត រឿងរាជ្យត្រ័យ | ៧៥ |
| | គោបុរៈខាងជើង រឿងរាជ្យត្រ័យ | ៧៦ |
| | គោបុរៈខាងលិច រឿងរាជ្យត្រ័យ | ៧៨ |
| | ទីលាននឹងវិមានអាកាស | ៨០ |
| | ទីលានស្ដេចគំលង់ | ៨៣ |
| | ព្រះទេពប្រណម្យ | ៨៩ |
| | ព្រះបាលិលេយ្យ | ៩០ |
| | ព្រះពិធូរ | ៩៧ |
| | ប្រាសាទសួព្រ័ត្រ, ឃ្លាំងនឹងព្រះពុទ្ធរូបបាយ័ន | ១០០ |
| | ប្រាសាទមង្គលចំ | ១០២ |

| | | ទំព័រ |
|---|---|---|
| វគ្គទី ៥ | រង្វង់តូច | ១០៤ |
| | ធម្មនន្ទ នឹងចៅសាយ | ១០៤ |
| | ស្ពានថ្ម | ១០៦ |
| | ប្រាសាទតាកែវ | ១០៧ |
| | ប្រាសាទតាព្រហ្ម | ១០៨ |
| | ប្រាសាទបន្ទាយក្ដី | ១២៧ |
| | ស្រះស្រង់ | ១៣២ |
| | ប្រាសាទក្រវ៉ាន់ | ១៣៥ |
| វគ្គទី ៦ | រង្វង់ធំ | ១៣៩ |
| | ប្រែរូប | ១៣៩ |
| | មេបុណ្យខាងកើត | ១៤៣ |
| | តាសោម | ១៤៥ |
| | ក្រោលគោ | ១៤៧ |
| | នាគព័ន្ធ | ១៥១ |
| | ព្រះខាន់ | ១៥៩ |
| | ក្រោលដំរី | ១៦៣ |
| វគ្គទី ៧ | ប្រាសាទផ្សេងៗ | ១៦៧ |
| | វត្តអធ្វា | ១៦៧ |
| | ភ្នំក្រោម | ១៧១ |
| | ព្រះឥន្ទកោសីយ៍ | ១៧៤ |
| | មេបុណ្យខាងលិច (បារាយ) | ១៧៦ |
| | លលៃ | ១៧៨ |
| | ព្រះគោ | ១៨៥ |
| | បាគង | ១៩១ |
| | បន្ទាយស្រី | ១៩៩ |

ទំព័រ

បន្ទាយស៊ីរៃ . . . . . . . . . . . . . . . . . . . . . . . ២១០
សៀមរាប . . . . . . . . . . . . . . . . . . . . . . . . . ២១៣
បញ្ជីព្រះនាមស្តេច, ទេវតា, ឈ្មោះប្រាសាទនិងទីស្ថាននិងពាក្យផ្សេងៗ . . ក
ព្រះនាមស្តេច . . . . . . . . . . . . . . . . . . . . . . . ក
ព្រះនាមទេវតាសាសនាព្រាហ្មណ៍និងពុទ្ធសាសនា . . . . . . . . . ក
ប្រាសាទនិងទីស្ថាន . . . . . . . . . . . . . . . . . . . . ខ
ពាក្យសំស្ក្រឹតនិងពាក្យបាលី . . . . . . . . . . . . . . . . . គ
ពាក្យបរទេស . . . . . . . . . . . . . . . . . . . . . . . ឃ
បញ្ជីរឿង . . . . . . . . . . . . . . . . . . . . . . . . ង
បញ្ជីរូបថត . . . . . . . . . . . . . . . . . . . . . . . ឈ

ទំព័រ

១៨ — ស៊ីវលិង្គ ប្រាសាទព្រះពិធូរ . . . . . . . . . . . . . . . . . . . ៩៥

១៩ — ភាពប្រាសាទតាកែវទាំងមូល មើលពីទិសអគ្នេយ៍ . . . . . . . . . . . ១០៧

២០ — ដើមឈើដុះចាក់ឫសព័ទ្ធព័ន្ធលើកំពូលប្រាសាទតាព្រហ្ម . . . . . . . . . ១១១

២១ — កាលពោធិសត្វទ្រង់កណ្ឋកាជី, មានទេវបុត្រជាបរិវារ, ចេញសាងអភិ-
និស្រ្កមណ៍ ហោជាងប្រាសាទខាងត្បូង ក្នុងកំពែងទី៣ ប្រាសាទតាព្រហ្ម... ១១៣

២២ — រូបភិក្ខុប្រណម្យ ប្រាសាទតាព្រហ្ម . . . . . . . . . . . . . . . . ១១៧

២៣ — កាលព្រះពោធិសត្វប្រសូត ព្រះព្រហ្មនិងព្រះឥន្ទ្រទទួល ហោជាងប្រាសាទ
ខាងត្បូង ក្នុងកំពែងទី ៣ ប្រាសាទតាព្រហ្ម . . . . . . . . . . . . ១១៩

២៤ — រូបទ្វារបាល នៅគោបុរៈនៃកំពែងទី៣ ទិសខាងលិច ប្រាសាទតាព្រហ្ម . . ១២៣

២៥ — គោបុរៈខាងកើត នៃកំពែងខាងក្រៅ ប្រាសាទបន្ទាយក្តី . . . . . . . . ១២៥

២៦ — រូបឥសីសាសនាព្រាហ្មណ៍ អង្គុយបំពេញធម៌ ឆ្លាក់មិនទាន់ហើយ កន្លែងឥសី
នេះកាលមុនគេឆ្លាក់ព្រះពុទ្ធរូប ៗនេះគេកោសលុបចោលទៅ . . . . . . . ១២៩

២៧ — ភាពទីលានស្រះស្រង់ មើលពីទិសពាយ័ព្យ . . . . . . . . . . . . . ១៣៣

២៨ — ភាពប្រាសាទប្រែរូបទាំងមូល មើលពីខាងកើត . . . . . . . . . . . ១៣៧

២៩ — រូបព្រះវិស្ណុផ្ទំផ្តៀងធំអស្ចារ្យ គេជីកឃើញនៅប្រាសាទមេបុណ្យខាងកើត.. ១៤១

៣០ — ភាពប្រាសាទនាគព័ន្ធ ដែលគេកាប់ឆ្ការព្រៃហើយ . . . . . . . . . . ១៤៩

៣១ — រូបលោកេស្វរៈ នៅទ្វារបញ្ចោត, នៅហោជាងខាងលើ ថ្ងែងកាលពោធិសត្វ
ទ្រង់កណ្ឋកាជី ចេញសាងអភិនិស្រ្កមណ៍ ប្រាសាទនាគព័ន្ធ. . . . . . . ១៥៣

៣២ — មុខលោកេស្វរៈ នៅលើកំពូលប្រាសាទព្រះខ័ន ទ្វារចូលខាងលិច . . . . ១៥៧

៣៣ — ភាពប្រាសាទវត្តអធ្វា ដែលផល់នូវផិកភាព . . . . . . . . . . . . ១៦៥

៣៤ — ភាពប្រាសាទភ្នំក្រោម មើលចំពាក់កណ្តាល . . . . . . . . . . . . ១៦៩

៣៥ — រូបទ្វារបាល គេទើបជីកបាន នៅប្រាសាទភ្នំក្រោម . . . . . . . . . ១៧៣

៣៦ — សសរក្រឡឹងមូល គោបុរៈខាងកើតនៃប្រាសាទព្រះគោ . . . . . . . . ១៨១

# បញ្ជីរូបថត


ទំព័រ

១ – ព្រះសិរព្រះពុទ្ធរូប មានព្រះភក្ត្រស្រស់ញញឹម ប្រាសាទនគរវត្ត . . . . . . ១

២ – ភាពប្រាសាទនគរវត្តទាំងមូល . . . . . . . . . . . . . . . . ៥

៣ – ភាពប្រាសាទនគរវត្ត មើលពីទិសនិរតី . . . . . . . . . . . . . ៩

៤ – កាលព្រះរាមសម្លាប់យក្សមរីចិ ដែលក្លែងខ្លួនជាម្រឹគ ក្នុងរឿងរាមកេរ្តិ៍នៅជ្រុងទិសនិរតី ប្រាសាទនគរវត្ត . . . . . . . . . . . . . . . . . . ១៣

៥ – រូបស្រីទេពអប្សរពាក់មកុដចេញសក់សំយាក រោងទងខាងលិច ប្រាសាទនគរវត្ត . . . . . . . . . . . . . . . . . . . . . . ២៣

៦ – ស្រីទេពអប្សរមានផ្នួងសក់ជាមកុដ ជម្មចន្ទ្រទិសនិរតី ប្រាសាទនគរវត្ត. . . ២៧

៧ – ទ្វារជ័យ (ទ្វារធំកំពែងខាងកើត) រាជធានីនគរធំ . . . . . . . . . . . ៣៥

៨ – ភាពជាន់ក្រៅនៃប្រាសាទបាយ័ន មើលពីទិសនិរតី . . . . . . . . . ៣៩

៩ – មុខលោកេស្វរៈ នៅលើកំពូលប្រាសាទបាយ័ន . . . . . . . . . ៤៣

១០ – រូបស្រីទេពអប្សររាំបែបទន់ភ្លន់លើផ្កាឈូកនៅសសរបួនជ្រុង ទ្វារចូលខាងកើត ប្រាសាទបាយ័ន . . . . . . . . . . . . . . . . . . . ៤៧

១១ – រូបស្រីទេពអប្សររាំបែបល្វាសល្វន់លើផ្កាឈូក នៅសសរ៤ជ្រុង ទ្វារចូលខាងកើតប្រាសាទបាយ័ន . . . . . . . . . . . . . . . . . . ៥១

១២ – ស្រីទេពអប្សរ នៅជញ្ជាំងប្រាសាទកណ្តាល ប្រាសាទបាយ័ន . . . . . ៥៥

១៣ – ព្រះនារាយណ៍ដៃ៤ មានទេពតាគង្គមនុស្សប្រណម្យ ប្រាសាទបាយ័ន . ៥៩

១៤ – រូបសីហៈ នៅគោបុរៈខាងជើងនៃប្រាសាទបាយ័ន . . . . . . . . . . ៦៣

១៥ – គោបុរៈនៃរោងទងខាងជើង ប្រាសាទបាយ័ន . . . . . . . . . . . . ៦៧

១៦ – រឿងចម្បាំងព្រះរាមនឹងរាពណ៍ គោបុរៈខាងជើង កំពែងទី២ យ៉ាងកើត មុខខាងជើង . . . . . . . . . . . . . . . . . . . . . . . . . ៧១

១៧ – គោបុរៈខាងកើត នៃប្រាសាទបាលិលេយ្យ . . . . . . . . . . . . . ៩១

ទំព័រ

៣៧ – រូបទ្វារបាលនៅប្រអប់ទ្វារបញ្ឆោត ប្រាសាទព្រះគោ .......... ១៨៣

៣៨ – រូបព្រះឥសូរនាងឧមានិងនាងគង្គាមើលពីខាងក្រោយ ទិសឦសាន ប្រាសាទបាគង .......................... ១៨៧

៣៩ – រូបព្រះឥសូរ នាងឧមានិងនាងគង្គាមើលពីមុខ ទិសឦសាន ប្រាសាទបាគង .......................... ១៨៩

៤០ – រូបយក្ស នៅគ្រឹះថ្នាក់ទី ៥ នៃប្រាសាទបាគង .............. ១៩៣

៤១ – គោបុរៈកំពែងទី៣ ប្រាសាទបន្ទាយស្រី .............. ១៩៧

៤២ – គោបុរៈកំពែងទី ៣ ខាងលិច មុខខាងកើត ប្រាសាទបន្ទាយស្រី .... ២០១

៤៣ – ទេពតា ឆ្លាក់ជាប់នៅជញ្ជាំង ប្រាសាទខាងជើងទិសនិរតី ប្រាសាទបន្ទាយស្រី .......................... ២០៥

៤៤ – ធម្មមន្ទីរ ប្រាសាទបន្ទាយសំរែ ................ ២០៩

៤៥ – សីហៈធំ នៅទីលានខាងកើត ប្រាសាទបន្ទាយសំរែ .......... ២១៣

៤៦ – ផ្តែរឈើខ្លោងទ្វារខាងក្នុងនៃប្រាសាទកណ្តាល ប្រាសាទបន្ទាយសំរែ ... ២១៥

# បញ្ជីសៀវភៅដែលព្រះរាជបណ្ណាល័យបោះពុម្ពផ្សាយ

| | | |
|---|---|---|
| ព្រះត្រៃបិដក (បាលីនិងប្រែ) ១ ចប់ | ចំនួន ១០០ | សៀវភៅថ្លៃ ២៥០រ. ០០ |
| ព្រះបន្ទូលកែវ | ១ | សៀវភៅថ្លៃ ០រ. ១០ |
| អក្កោសកថា | — | ០, ០៥ |
| អនត្តលក្ខណសុត្ត | — | ០, ១០ |
| អភិធម្មត្ថសង្គហ បាលី | — | ០, ៥០ |
| អភិធម្មត្ថសង្គហ សម្រាយ | — | ០, ៩០ |
| អរិយសច្ចកថា | — | ០, ៥០ |
| អំពីព្រះពុទ្ធសាសនា | — | ១, ៥០ |
| អំពីប្រាសាទខ្ទះនៅឧតរ | — | ០, ២៤ |
| កាលាមសុត្តនិងបរាភវសុត្ត | — | ០, ១៤ |
| គិរិមានន្ទសុត្ត | — | ០, ១៥ |
| ច្បាប់ថ្មី | — | ០, ១៤ |
| ញាណកថា | — | ០, ១០ |
| ដំណាលពុទ្ធចេតិយ | — | ០, ៨១ |
| ធម្មប្រទីប | - | ០, ៦០ |
| ភាណវារ | — | ១, ៥០ |
| តាគោបមាទិកថា | — | ០, ០៧ |
| បករណវិសេសោ | — | ១, ០០ |
| បាយាសិរាជញ្ញសុត្ត | — | ០, ០៧ |
| ពាក្យកាព្យក្រមង្វិរ | — | ០, ០៣ |
| មនោបុព្វកថា | — | ០, ១៥ |
| មរណានុស្សតិ | — | ០, ២០ |
| មាតាបិតុឧបដ្ឋានកថា | — | ០, ៣៥ |

១០០ គាថា ........................ ១ សៀវភៅថ្លៃ ០រ. ១០
វិជ្ជាចរណកថា ........................ — ០, ៣០
វុឌ្ឍោទយ ........................ — ០, ២៥
សប្បុរិសធម៌ ........................ — ០, ០៥
សត្តបរិត្តនិងទ្វាទសបរិត្ត ........................ — ០, ៩០
សិមាវិនិច្ឆ័យ ........................ — ០, ១០
សុរិយាត្រឡើងស័ក ........................ — ០, ៣០
សុភាសិតច្បាប់សិន ........................ — ០, ៤០
សេចក្តីផាស់ជឿន ........................ — ០, ០៦
បច្ចគណនាវិធី និងប័ក្ខសម្រេច ........................ — ០, ៣០
សម្ពន្ធមាណ ........................ — ១, ២៥
សីលនិទ្ទេស ........................ — ០, ៧០
សារទេសនា ........................ — ០, ០៨
អក្សរខ្មែរផាប់និងរូបសព្ទ ........................ — ០, ២០
ប្រស្នាវិនយបិដកសង្ខេប ........................ — ១, ០០
រតនប្បភា ........................ — ០, ៤១
វិធីបង្ការរោគ ........................ — ០, ០៣
ទភទជាតិមោក្ខ ........................ — ០, ៨០
គោលសមថកម្មដ្ឋាន ........................ — ០, ១៥
ពុទ្ធមាមកវិធី (បែបធម្មយុត្តិ) ........................ — ០, ៤០
សាមណេរវិន័យ ........................ — ០, ៤០
បញ្ចអភិណ្ហបច្ចវេក្ខណៈ ........................ — ០, ១០
សិង្គាលោវាទសូត្រ ........................ — ០, ៣០
អនុមោទនាវិធី ........................ — ០, ៥០
ព្រះត្រៃលក្ខណ៍និងសង្គហវត្ថុ ........................ — ០, ១៥

| | | | |
|---|---|---|---|
| ពាក្យកាព្យថ្លែងរឿងពុទ្ធប្រវត្តិ . . . . . . . . . . . . . . . | ១ សៀវភៅថ្លៃ | | ០រ.១៥ |
| វសលសូត្រ . . . . . . . . . . . . . . . . . . . . . | | — | ០, ១៨ |
| តាតាជាតក . . . . . . . . . . . . . . . . . . . . . | | — | ០, ៦០ |
| សតិបដ្ឋានសុត្ត . . . . . . . . . . . . . . . . . . . | | — | ០, ៥០ |
| អវសានកិច្ច . . . . . . . . . . . . . . . . . . . . . | | — | ០, ៤៥ |
| វិជ្ជាប្រាំបីប្រការ . . . . . . . . . . . . . . . . . . . | | — | ០, ៦៥ |
| រឿងកាកី . . . . . . . . . . . . . . . . . . . . . | | — | ០, ២៥ |
| ទសបារមីកថា . . . . . . . . . . . . . . . . . . . | | — | ០, ៧៥ |
| ជាតិមោក្ខសង្ខេប . . . . . . . . . . . . . . . . . . | | — | ០, ៤០ |
| សៀវភៅយានជំនិះខ្មែរ . . . . . . . . . . . . . . . . | | — | ០, ៤៥ |
| វេជ្ជសារ . . . . . . . . . . . . . . . . . . . . . | | — | ០, ៦០ |
| ទានកថា . . . . . . . . . . . . . . . . . . . . . | | — | ០, ៦០ |
| វេយ្យាករណ៍សំស្រ្កឹត . . . . . . . . . . . . . . . . | | — | ០, ៦៥ |
| សិលាចារឹកនគរវត្ត . . . . . . . . . . . . . . . . . | | — | ១, ០០ |
| ជយវរ្ម័ន ទី ៧ (អក្សរខ្មែរ) . . . . . . . . . . . . . . | | — | ០, ១០ |
| " " (អក្សរបារាំង) . . . . . . . . . . . . . . . | | — | ០, ៣០ |
| បទានុក្រមភាមកេរ្តិ៍ . . . . . . . . . . . . . . . . . | | — | ០, ០៨ |
| ភាមកេរ្តិ៍ លក់ភាយ . . . . . . . . . . . . . . . . . | | — | ០, ១០ |
| " លក់រូប . . . . . . . . . . . . . . . . . . . . ១៣ | | — | ១, ៥០ |
| ទស្សនាវដ្តី (១ ឆ្នាំ) . . . . . . . . . . . . . . . . ២៤ | | — | ៦, ៥០ |
| សាសនកិច្ចានុក្រម (១ ឆ្នាំ) . . . . . . . . . . . . . ១២ | | — | ១, ៥០ |
| វចនានុក្រមខ្មែរ ក្របរឹង . . . . . . . . . . . . . . . ១ | | — | ៩, ៥០ |
| " ក្របទន់ . . . . . . . . . . . . . . . . . | | — | ៣, ០០ |
| គិហិបដិបត្តិសង្ខេប . . . . . . . . . . . . . . . . . | | — | ០, ១៥ |
| គិហិបដិបត្តិពិស្តារ . . . . . . . . . . . . . . . . . | | — | ០, ៥០ |

| | | | |
|---|---|---|---|
| បព្វជ្ជាខន្ធកសង្ខេប | | ១ សៀវភៅថ្លៃ | ០ រ. ៨៥ |
| សុរាទោសកថា | | — | ០, ១០ |
| មគ្គុទ្ទេសក៍នគរ | ភាគទី ១ | — | ០, ៤៥ |
| " | ភាគទី ២ | — | ១, ២០ |
| ក្រុងសុភមិត្រ | ភាគទី ១ | — | ០, ៧០ |
| " | ភាគទី ២ | — | ០, ០០ |
| " | ភាគទី ៣ | — | ០, ០០ |
| មិលិន្ទបញ្ហា | ភាគទី ១ | — | ០, ៥០ |
| " | ភាគទី ២ | — | ០, ៧០ |
| មង្គលត្ថទីបនី | ភាគទី ១ | — | ២, ០០ |
| " | ភាគទី ២ | — | ២, ៥០ |
| " | ភាគទី ៣ | — | ៣, ០០ |
| " | ភាគទី ៤ | — | ០, ០០ |
| កច្ចាយនូបត្ថម្ភក | ភាគទី ១ | — | ១, ២០ |
| " " | ភាគទី ២ | — | ១, ៤០ |
| ធម្មបទដ្ឋកថា | ភាគទី ១ | — | ០, ៩០ |
| " | តាំងពីភាគទី ២ ដល់ភាគទី ៨ | — | ០, ៦៥ |
| គតិលោក | ភាគទី ១ | — | ០, ៦៥ |
| " | ~~ភាគទី ២-៣~~ | — | ~~០, ១២~~ |
| " | ភាគទី ៤-៥-៦-៧-៨-៩-១០ | — | ០, ២៥ |
| រឿង ១ ពាន់ ១ យប់ | ភាគទី ១ | — | ០, ០២ |
| " | ភាគទី ២-៣-៤-៥-៦-៧-៨-៩ | — | ០, ២៥ |

យើងខ្ញុំជាកូន ខ្ញៅ យុនសំរ៉ង ខ្ញៅ យ៉ាតណៃ ខ្ញៅសុខផល ខ្ញៅ វិសាល ខ្ញៅ រ៉ាមុន
ខ្ញៅ ភារាដា ខ្ញៅ ចំរើន ខ្ញៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook
ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ញៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា** និង **ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **សួស សូរី**

សីហា ឆ្នាំ ២០១៥


បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការប្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។



សូមអរគុណ

ខ្ញៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា


www.elibraryofcambodia.org

**មានលក់ដុំ និង លក់រាយ**

សៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ "**បណ្ណាគារត្រៃរតន៍**"

# 136Eo វិថីខេមរភូមិន្ទ

ទូរស័ព្ទលេខ: 012 706 581

097 905 00 55

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។